# របាយការណ៍

# ស្ដីពី

# សវនកម្មយេនឌ័រសម្រាប់ផែនការអនុវត្តបីឆ្នាំដំបូង(ផអ៣)
# នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
# នៅថ្នាក់ក្រោមជាតិ

លោកស្រី Cherly Urashima
លោក គុង សុប្រាជ្ញ
ក្រុមការងារយេនឌ័រនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី

**លេខាធិការដ្ឋាន គ.ជ.អ.ប**
**ខែមេសា ឆ្នាំ២០១៤**

# មាតិកា


សេចក្តីសង្ខេប.......................................................................................i
១.សេចក្តីផ្តើម.......................................................................................១
១.១. សាវតា និងបរិបទ.......................................................................................១
១.២. សវនកម្មយេនឌ័រជាអ្វី?.......................................................................................៣
១.៣. វិធីសាស្រ្ត និងដំណើរការ.......................................................................................៤
១.៤. ភាពមានកម្រិត និងឧបសគ្គនានា.......................................................................................៥
២. សំណួរគន្លឹះ លទ្ធផលរកឃើញ និងអនុសាសន៍តាមសមាសភាគ.......................................................................................៧
២.១. សមាសភាគទី១៖យេនឌ័រក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ ការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការត្រួតពិនិត្យ ការវាយតម្លៃ និងផលប៉ះពាល់.......................................................................................៧
២.១.១. អនុសមាសភាគ សំណួរគន្លឹះ និងប្រភពព័ត៌មាន.......................................................................................៧
២.១.២. លទ្ធផលរកឃើញសំខាន់ៗ.......................................................................................៨
២.១.៣. អនុសាសន៍.......................................................................................១៣
២.២. សមាសភាគទី២៖ជំនាញបច្ចេកទេសពាក់ព័ន្ធយេនឌ័រ.......................................................................................១៥
២.២.១. អនុសមាសភាគ សំណួរគន្លឹះ និងប្រភពព័ត៌មាន.......................................................................................១៥
២.២.២. លទ្ធផលរកឃើញសំខាន់ៗ.......................................................................................១៦
២.២.៣. អនុសាសន៍.......................................................................................១៧
២.៣. សមាសភាគទី៣៖ស្រ្តីក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំបុគ្គលិក.......................................................................................១៩
២.៣.១. អនុសមាសភាគ សំណួរគន្លឹះ និងប្រភពព័ត៌មាន.......................................................................................១៩
២.៣.២. លទ្ធផលរកឃើញសំខាន់ៗ.......................................................................................២០
២.៣.៣. អនុសាសន៍.......................................................................................២២
២.៤. សមាសភាគទី៤៖វេទយិតយេនឌ័រក្នុងវប្បធម៌ស្ថាប័ន និងទស្សនទានយល់ដឹងអំពីវឌ្ឍនភាពនានាពាក់ព័ន្ធនឹងសមភាពយេនឌ័រ.......................................................................................២៤
២.៤.១. អនុសមាសភាគ សំណួរគន្លឹះ និងប្រភពព័ត៌មាន.......................................................................................២៤
២.៤.២. លទ្ធផលរកឃើញសំខាន់ៗ.......................................................................................២៦
២.៤.៣. អនុសាសន៍.......................................................................................២៧
២.៤. សមាសភាគទី៥៖ការឆ្លើយតបទៅនឹងបញ្ហាយេនឌ័ររបស់អង្គការ/ស្ថាប័នដៃគូ.......................................................................................២៨
២.៤.១. អនុសមាសភាគ សំណួរគន្លឹះ និងប្រភពព័ត៌មាន.......................................................................................២៨
២.៤.២. លទ្ធផលរកឃើញសំខាន់ៗ.......................................................................................២៩
២.៤.៣. អនុសាសន៍.......................................................................................២៩

៣. ការប្រៀបធៀបលទ្ធផលសវនកម្មយេនឌ័រតាមស្ថាប័នដែលបានធ្វើសវនកម្ម ........ ៣០
៣.១. លទ្ធផលជារួមតាមប្រភេទថ្នាក់ស្ថាប័ន ........ ៣០
៣.២.អនុកម្មវិធីនៃផអ៣ ........ ៣២
៣.៣.រដ្ឋបាលថ្នាក់ក្រោមជាតិ ........ ៣៣
៣.៣.១.ថ្នាក់ខេត្ត ........ ៣៣
៣.៣.២.ថ្នាក់ក្រុង ស្រុក ........ ៣៤
៣.៣.១.ភាពខុសគ្នានៃទស្សនទានយល់ដឹងអំពីវឌ្ឍនភាពនៅថ្នាក់ក្រោមជាតិ ........ ៣៥

**ឧបសម្ព័ន្ធនានា ៖**

១. ក្របខ័ណ្ឌការងាររបស់ក្រុមទីប្រឹក្សា
២. បញ្ជីឯកសារដែលបានសិក្សា
៣. ឧបករណ៍ដែលបានប្រើប្រាស់ក្នុងការធ្វើសវនកម្មយេនឌ័រ
៤. ក្រុមសវនកម្មយេនឌ័រ
៥. បញ្ជីឈ្មោះបុគ្គលដែលបានជួបពិភាក្សា
៦. របាយការណ៍ស្តីពីលទ្ធផលនៃកាតដាក់ពិន្ទុសម្រាប់សវនកម្មយេនឌ័រតាមផ្នែកនីមួយៗ
៧. សេចក្តីសង្ខេបពិន្ទុតាមថ្នាក់រដ្ឋបាល
៨. គំរូដ្យាក្រាមបង្ហាញអំពីលទ្ធផលនៃកាតដាក់ពិន្ទុតាមទិន្នន័យមូលដ្ឋានឃុំ សង្កាត់
៩. បករណ៍សវនកម្មយេនឌ័រដែលបានកែលម្អសម្រាប់ការប្រើប្រាស់នាពេលអនាគត។

## អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AWPB | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| BoG | គណៈអភិបាល |
| CCWC | គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ |
| CD | ការអភិវឌ្ឍសមត្ថភាព |
| CDB | ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ |
| CMDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា |
| C/S | ឃុំ សង្កាត់ |
| CSO | អង្គការសង្គមស៊ីវិល |
| DOWA | ការិយាល័យកិច្ចការនារីស្រុក |
| DM | ក្រុង ស្រុក |
| DMK | ក្រុង ស្រុក ខណ្ឌ |
| ERA | សាលាភូមិន្ទរដ្ឋបាល |
| DP | ដៃគូអភិវឌ្ឍន៍ |
| GMAG | ក្រុមការងារបញ្ជ្រាបយេនឌ័រ |
| GMAP | ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ |
| GRB | ការរៀបចំថវិកាដែលមានលក្ខណៈឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ |
| IP3 | ផែនការអនុវត្តរយៈពេលបីឆ្នាំនៃកម្មវិធីជាតិ |
| M&E | តាមដានត្រួតពិនិត្យ និងវាយតម្លៃ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoI | ក្រសួងមហាផ្ទៃ |
| MoP | ក្រសួងផែនការ |
| MoPF | ក្រសួងមុខងារសាធារណៈ |
| MoWA | ក្រសួងកិច្ចការនារី |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCDD-S | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NLC/S | សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ |
| NP | កម្មវិធីជាតិ |
| NP-SNDD | កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

| | |
|---|---|
| OD | ការអភិវឌ្ឍន៍ស្ថាប័ន |
| OL | ច្បាប់រៀបចំអង្គការ |
| PBA | វិធីសាស្ត្រគ្រប់គ្រងតាមកម្មវិធី |
| PDoWA | មន្ទីរកិច្ចការនារីខេត្ត |
| PC | រាជធានី ខេត្ត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| PM&E | ផែនការ តាមដានត្រួតពិនិត្យ និងវាយតម្លៃ |
| Sida | ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែដ |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SNDD | ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| SNIF | ឧបករណ៍ផ្តល់ហិរញ្ញប្បទានវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SSCS | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ |
| TA | ជំនួយបច្ចេកទេស |
| TWG | ក្រុមការងារបច្ចេកទេស |
| WB | ធនាគារពិភពលោក |
| WCCC | គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |

## សវនកម្មយេនឌ័រសម្រាប់ផែនការអនុវត្តបីឆ្នាំដំបូង (ផអ៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD)

# សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈ ក្នុងការជំរុញកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ព្រមទាំងបានបង្កើននូវសមភាពយេនឌ័រ និងភាពអង់អាចក្លាហានរបស់ស្ត្រីនៅក្នុងគោលនយោបាយសំខាន់ៗនានាជាច្រើនដូចជា៖ គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា យុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិជាដើម។

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្តបីឆ្នាំដំបូងនៃកម្មវិធីជាតិ (ផអ៣ ២០១១- ២០១៣) បានកំណត់នូវអាទិភាព និងយុទ្ធសាស្ត្រនានា ដើម្បីធានាថា បញ្ហាយេនឌ័រត្រូវបានផ្តោតការយកចិត្តទុកដាក់នៅក្នុងកិច្ចដំណើរការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃកិច្ចអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។ ក្នុងក្របខ័ណ្ឌនៃផអ៣ ស្ថាប័នអនុវត្តនីមួយៗត្រូវបានប្រគល់នូវការទទួលខុសត្រូវដើម្បីធានាថា ការរៀបចំតាក់តែង និងការអនុវត្តអនុកម្មវិធីនានានៃផអ៣ ត្រូវបានបញ្ជ្រាបនូវការងារយេនឌ័រ។ តួនាទីរបស់ក្រសួងកិច្ចការនារីក៏ត្រូវបានកំណត់ជាស្ថាប័នសម្រាប់ផ្តល់នូវការប្រឹក្សាយោបល់ជាយុទ្ធសាស្ត្រ ការគាំទ្រ និងការធានានូវភាពស៊ីសង្វាក់គ្នានៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់រាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ននេះ។

សវនកម្មយេនឌ័រសម្រាប់ផអ៣ត្រូវបានរៀបចំឡើង ក្នុងន័យឆ្លើយតបទៅនឹងតម្រូវការនៃការពិនិត្យឡើងវិញ ការកែលំអ និងឬការកែសម្រួលនូវយុទ្ធសាស្ត្រយេនឌ័រនៃផអ៣សម្រាប់ការពន្យារពេលផអ៣រយៈពេល១ឆ្នាំក្នុងឆ្នាំ២០១៤ ដែលជាពេលវេលាសម្រាប់ការរៀបចំតាក់តែងផអ៣ដំណាក់កាលបន្ទាប់ផងដែរ។ សវនកម្មយេនឌ័របានធ្វើឡើងចំពោះអនុកម្មវិធីចំនួន៤ក្នុងចំណោមអនុកម្មវិធីទាំង៦នៃផអ៣ ខេត្តចំនួន៤ និងក្រុង ស្រុកពាក់ព័ន្ធចំនួន៤ផងដែរ។

ឧបករណ៍សម្រាប់ការធ្វើសវនកម្មយេឌ័រនៃផអ៣ ត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋាននៃបទពិសោធន៍អនុវត្តល្អជាលក្ខណៈអន្តរជាតិ ដែលសមស្របទៅនឹងបរិបទនៃប្រទេសកម្ពុជា និងក្របខ័ណ្ឌពេលវេលា ព្រមទាំងផ្អែកលើការរំពឹងថា មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី គឺជាអ្នកអនុវត្តនូវសកម្មភាពសវនកម្មយេនឌ័រនេះភាគច្រើនដោយខ្លួនឯង។

សវនកម្មយេនឌ័រនៃផអ៣ បានផ្តោតទៅលើចំណុចសំខាន់ៗចំនួន៥ដូចខាងក្រោម៖

១. យេនឌ័រក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ ការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការត្រួតពិនិត្យ ការវាយតម្លៃ និងផលប៉ះពាល់

២. ជំនាញបច្ចេកទេសក្នុងការគាំទ្រដល់ការរៀបចំតាក់តែង និងអនុវត្តកិច្ចដំណើរការកំណែ

ទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានលក្ខណៈឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ

៣. ស្រ្តីនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងក្នុងការរៀបចំបុគ្គលិក

៤. បញ្ហាយេនឌ័រនៅក្នុងវប្បធម៌ស្ថាប័ន និងទស្សនៈយល់ដឹងអំពីសមិទ្ធផលនានាដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ

៥. ការឆ្លើយតបទៅនឹងបញ្ហាយេនឌ័ររបស់អង្គការ/ស្ថាប័នដៃគូ (ឧទាហរណ៍៖ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា)។

ព័ត៌មាននានាសម្រាប់ការធ្វើសវនកម្មយេនឌ័រនេះ ត្រូវបានប្រមូលតាមរយៈការសិក្សាស្រាវជ្រាវលើឯកសារ ការបំពេញនូវបញ្ជីសំណួរសម្រាប់ការសិក្សាវាយតម្លៃដោយខ្លួនឯងរបស់បុគ្គលម្នាក់ៗ ព្រមទាំងការសម្ភាសន៍ក្នុងលក្ខណៈជាក្រុម និងការសម្ភាសន៍ក្នុងលក្ខណៈជាបុគ្គល។

**ការរកឃើញសំខាន់ៗ និងអនុសាសន៍នានា**

**១. យេនឌ័រនៅក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ ការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការត្រួតពិនិត្យ វាយតម្លៃ និងផលប៉ះពាល់ ៖**

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| **ថ្នាក់ជាតិ** | |
| ជារួម យុទ្ធសាស្រ្តយេនឌ័រសម្រាប់ផអ៣ មានលក្ខណៈទូទៅដោយពុំត្រូវបានរៀបចំជាក់លាក់តាមសមាសភាគនីមួយៗឡើយ។<br><br>ការងារយេនឌ័រពុំទាន់ត្រូវបានបញ្ជ្រាបឲ្យមានលក្ខណៈស្របគ្នានៅក្នុងផែនការ ថវិកា និងក្នុងរបាយការណ៍នានា។ | ១.១.ត្រូវរៀបចំយុទ្ធសាស្រ្តយេនឌ័រសម្រាប់ផអ៣ ដំណាក់កាលបន្ទាប់ទៅតាមរចនាសម្ព័ន្ធ និងសមាភាគនានានៃផអ៣<br>១.២.ត្រូវធានាថាការទទួលខុសត្រូវក្នុងការបញ្ជ្រាបយេនឌ័ររបស់ស្ថាប័នអនុវត្តត្រូវបានដាក់បញ្ចូលនៅក្នុងសេចក្តីសម្រេចរួមស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តនីមួយៗ<br>១.៣.ត្រូវបញ្ជ្រាបយេនឌ័រទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់អនុកម្មវិធីនីមួយៗ និងត្រូវភ្ជាប់ជាមួយនូវឧបសម្ព័ន្ធស្តីពីផែនការសកម្មភាពយេនឌ័រដែលកំណត់អំពីវិធានការណ៍ឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនានាទៅក្នុងផែនការរបស់អនុកម្មវិធីទាំងនោះផងដែរ។ |
| ការវិភាគអំពីតម្រូវការ និងបញ្ហានានារបស់បុរស និងស្រ្តីក្នុងសមាសភាគនានានៃអនុ | ១.៤.នៅមុនពេលចាប់ផ្តើមរៀបចំតាក់តែងផអ៣ ដំណាក់កាលបន្ទាប់ អង្គភាពនីមួយៗនៃលេខាធិ |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
| --- | --- |
| កម្មវិធី ពុំត្រូវបានរៀបចំឡើងក្នុងលក្ខណៈជាប្រព័ន្ធឡើយ | ការដ្ឋាន និងអនុកម្មវិធីនីមួយៗ គួរត្រូវបានទទួលការបណ្ដុះបណ្ដាលស្ដីពីការកំណត់ និងវិភាគបញ្ហាយេនឌ័រនៅក្នុងវិស័យ/កិច្ចការដែលជាការទទួលខុសត្រូវរបស់ខ្លួន ដោយសហការជាមួយក្រសួងកិច្ចការនារី និងទីប្រឹក្សាយេនឌ័រ។<br>១.៥.ត្រូវមានការវិភាគតម្រូវការ និងបញ្ហានានាទាំងរបស់បុរស និងស្ត្រីនៅក្នុងមុខងារនានាដែលនឹងត្រូវផ្ទេរឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>១.៦.ពន្លឿនការរៀបចំបញ្ចប់សេចក្តីណែនាំស្តីពីការកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយធានាថា ការវិភាគយេនឌ័រនៅថ្នាក់ក្រោមជាតិត្រូវបានដាក់បញ្ចូលក្នុងសេចក្តីណែនាំនេះ ហើយទស្សនៈយល់ដឹងអំពីការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនៅក្នុងកិច្ចដំណើរការកសាងផែនការ និងកិច្ចដំណើរការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងកិច្ចដំណើរការកសាងផែនការ និងការរៀបចំថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈប្រទាក់ក្រឡាគ្នាក្នុងការជំរុញគាំទ្រឲ្យមានការកើនឡើងនូវសមភាពយេនឌ័រនៅថ្នាក់ក្រោមជាតិ។ |
| ក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំមានដំណើរការក្នុងការគាំទ្រដល់កិច្ចដំណើរការកសាងផែនការ ការរៀបចំថវិកា និងការអនុវត្តប្រកបដោយការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រឡើយ។ ផ្ទុយមកវិញ ក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួងមុខងារសាធារណៈបានដំណើរការយ៉ាងសកម្មក្នុងក្របខណ្ឌនៃអនុកម្មវិធីទី៣។ ដោយឡែក | ១.៧.លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីត្រូវធ្វើការជាមួយគ្នា ដើម្បីរៀបចំយុទ្ធសាស្ត្រសម្រាប់ជំរុញ និងពង្រឹងកិច្ចដំណើរការនៃក្រុមការងារបញ្ជ្រាបយេនឌ័រ ដែលពាក់ព័ន្ធនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់កិច្ចដំណើរការរៀបចំគោលនយោបាយ និងការកសាងផែនការ។ កិច្ចការនេះ ត្រូវរួមបញ្ចូលទាំងស្ថាប័នអនុវត្តជអ៣ និងក្រសួងស្ថាប័ននានាដែលកំពុងអនុវត្តកិច្ច |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| នៅក្នុងលេខាធិការដ្ឋានពុំបានរៀបចំបង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រឡើយ។ | ដំណើរការផ្ទេរមុខងារឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ |
| ជាទូទៅ ធាតុចូលនានារបស់ក្រសួងកិច្ចការនារីតែងតែត្រូវបានស្នើសុំឲ្យផ្តល់ដោយយឺតយ៉ាវក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ | ១.៨.ក្រសួងកិច្ចការនារី/ទីប្រឹក្សាយេនឌ័រ គួរត្រូវបានស្នើឲ្យចូលរួមផ្តល់ធាតុចូលចាប់តាំងពីដំណាក់កាលដំបូងនៃកិច្ចដំណើរការរៀបចំគោលនយោបាយ និងការកសាងផែនការ។ |
| មូលនិធិមានចំនួនតិចតួចសម្រាប់គាំទ្រដល់សកម្មភាពឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅថ្នាក់ជាតិ។ | ១.៩.បង្កើនមូលនិធិសម្រាប់គាំទ្រសកម្មភាពឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសសកម្មភាពពាក់ព័ន្ធទៅនឹងការពង្រឹងចំណេះដឹងយេនឌ័ររបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត, ការវិភាគ និងការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ និងការបង្កើនប្រសិទ្ធភាពការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ។<br>១.១០.ផ្តល់មូលនិធិសម្រាប់ការធ្វើសវនកម្មយេនឌ័រចំពោះអនុកម្មវិធី និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដទៃទៀត ព្រមទាំងក្រសួង ស្ថាប័នដែលរំពឹងថានឹងមានការផ្ទេរមុខងារទៅឲ្យថ្នាក់ក្រោមជាតិ។ |
| សូចនាករទាក់ទងទៅនឹងយេនឌ័រនៅក្នុងប្រព័ន្ធទិន្នន័យមូលដ្ឋានឃុំ សង្កាត់ នៅមានកម្រិតទាប។ | ១.១១.ត្រូវធានាថា វិធានការនានាត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការឆ្លុះបញ្ចាំងសូចនាករយេនឌ័រទៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា។ |
| **ថ្នាក់ក្រោមជាតិ** | |
| ដំណើរការកសាងផែនការ និងការរៀបចំថវិកាសម្រាប់ថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុកពុំត្រូវបានកំណត់ពេញលេញនៅឡើយចំពោះការបញ្ជ្រាបយេនឌ័រ ។ | សូមអានចំណុច ១.៦ ខាងលើ |
| ការរៀបចំបានតិចតួចសម្រាប់ការវិភាគយេនឌ័រនៅក្នុងដំណាក់កាលត្រៀមរៀបចំ | ១.១២.ត្រូវប្រើប្រាស់ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា និងប័ណ្ណ |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| ផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាហេតុធ្វើឲ្យការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងផែនការខេត្ត/ស្រុកពុំទាន់បានល្អ។ | ដាក់ពិន្ទុតាមវិស័យនៅក្នុងកិច្ចដំណើរការកសាងផែនការនៅថ្នាក់ឃុំ/ស្រុក ដើម្បីកំណត់បញ្ហាអាទិភាព រួមបញ្ចូលទាំងបញ្ហាយេនឌ័រផងដែរ។ ជាមួយគ្នានេះដែរ ក៏ត្រូវរៀបចំកិច្ចដំណើរការដើម្បីធ្វើឲ្យមានសុពលភាពនៃទិន្នន័យមូលដ្ឋានឃុំសង្កាត់ផងដែរ។<br>១.១៣.ត្រូវរៀបចំបង្កើតឧបករណ៍វិភាគយេនឌ័រសម្រាប់ផ្តល់ការណែនាំអំពីការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការមន្ទីរជំនាញនៅថ្នាក់រាជធានី ខេត្ត និងការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុក ខណ្ឌផងដែរ។ |
| សកម្មភាពនានារបស់ក្រសួង និងមន្ទីរកិច្ចការនារីរាជធានី ខេត្ត មានលក្ខណៈជាការផ្តល់ការផ្គត់ផ្គង់ ជាជាងការឆ្លើយតបទៅតាមតម្រូវការរបស់មូលដ្ឋាន | សូមអានចំណុចទី២ខាងក្រោម |
| មូលនិធិមានចំនួនតិចតួចសម្រាប់គាំទ្រដល់សកម្មភាពឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅថ្នាក់ក្រោមជាតិ។ | ១.១៤.បង្កើនមូលនិធិសម្រាប់គាំទ្រការកសាងសមត្ថភាពពាក់ព័ន្ធនឹងយេឌ័រ បណ្តាញយេនឌ័រ និងគាំទ្រដល់ថ្នាក់ក្រោមជាតិ។<br>សូមអានចំណុច ១.៩ និង១.១០ ខាងលើ |
| ការពិបាកក្នុងការដក/ទូទាត់មូលនិធិសម្រាប់គាំទ្រគម្រោងសេវាសង្គមនៅថ្នាក់ឃុំ សង្កាត់ និងសម្រាប់គាំទ្រសកម្មភាពតាមដានត្រួតពិនិត្យរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅថ្នាក់ក្រុង ស្រុក។ ជាទូទៅ ការផ្ទេរថវិកានេះមានការយឺតយ៉ាវ។ | ១.១៥.ត្រូវមានការកែសម្រួលនីតិវិធីសម្រាប់ការទូទាត់ចំណាយចំពោះសកម្មភាពតូចៗនានា (ឧ. ដូចជាសកម្មភាពសេវាសង្គមនិងការតាមដានត្រួតពិនិត្យរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ)។<br>១.១៦.ត្រូវធានាឲ្យបានថា មូលនិធិត្រូវបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិបានទាន់ពេលវេលា។<br>១.១៧.ត្រូវពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារក្នុងការជម្រះបញ្ជីការចំណាយសម្រាប់សកម្មភាពសេវាសង្គម។ |
| ការតាមដានត្រួតពិនិត្យបានផ្តោតតែទៅលើ | ១.១៨.ពង្រឹងការប្រើប្រាស់ព័ត៌មានតាមដានត្រួតពិនិត្យ |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| ទិន្នន័យស្តីពីចំនួននៃអ្នកចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលតាមភេទ (ចំនួនអ្នកចូលរួមជាបុរស និងជាស្ត្រី) | បញ្ហាយេនឌ័រនៅថ្នាក់ក្រោមជាតិ បន្ថែមពីលើការប្រើប្រាស់ព័ត៌មានស្ថិតិស្តីពីភេទផ្សេងៗគ្នានៃចំនួនមន្ត្រី បុគ្គលិក និងអ្នកចូលរួមសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាល។ |
| គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារបាន និងកំពុងដំណើរការតាមតួនាទីភារកិច្ចរបស់ខ្លួន ក៏ប៉ុន្តែត្រូវការកសាងសមត្ថភាព និងការគាំទ្រយ៉ាងច្រើនបន្ថែមទៀតដើម្បីឲ្យកិច្ចដំណើរការនៃគណៈកម្មាធិការនេះកាន់តែមានប្រសិទ្ធភាព។ | ១.១៩.ត្រូវពង្រឹងប្រសិទ្ធភាពការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (សូមអានចំណុច២ខាងក្រោម)។ |
| **យុទ្ធសាស្ត្រសម្រាប់រយៈពេលវែង**<br>១.២០.ក្នុងខណៈដែលកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឈានឆ្ពោះទៅកាន់ការរៀបចំថវិកាតាមកម្មវិធី នោះត្រូវធានាថា បញ្ហាយេនឌ័រនៅថ្នាក់ក្រោមជាតិត្រូវបានឆ្លុះបញ្ចាំងយ៉ាងសមស្របនៅក្នុងផែនការ និងថវិកាកម្មវិធី ព្រមទាំងត្រូវទទួលស្គាល់នូវតម្រូវការផ្សេងៗគ្នា និងការផ្លាស់ប្តូរជាច្រើនដែលនឹងកើតឡើងក្នុងកិច្ចអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។<br>១.២១.ត្រូវបង្កើតយន្តការនានាសម្រាប់ការកំណត់ និងការទទួលស្គាល់នូវគំរូនៃការអនុវត្តល្អ និងការកំណត់នូវសមិទ្ធផលនានាដែលជំរុញ និងគាំទ្រសមភាពយេនឌ័រ ភាពអង់អាចក្លាហានរបស់ស្ត្រីនៅក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនីមួយៗ និងក្នុងលក្ខណៈជាបុគ្គលផងដែរ។ | |

## ២. ជំនាញបច្ចេកទេសពាក់ព័ន្ធនឹងការងារយេនឌ័រ

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| **ថ្នាក់ជាតិ/ថ្នាក់ក្រោមជាតិ** | |
| ការបណ្តុះបណ្តាលស្តីពីយេនឌ័រភាគច្រើនផ្តោតតែទៅលើទ្រឹស្តី។ អ្នកផ្តល់ចម្លើយនានាបានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការបណ្តុះបណ្តាលដែលមានលក្ខណៈជាការអនុវត្តជាក់ស្តែង | ២.១. ត្រូវផ្តល់ការបណ្តុះបណ្តាលបន្ថែមស្តីពីការវិភាគយេនឌ័រ និងការអនុវត្តជាក់ស្តែងដល់មន្ត្រីបច្ចេកទេស (សូមអានចំណុច១.៤ ខាងលើ)<br>២.២.ត្រូវធានាថា អនុកម្មវិធីនានាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបាននូវធាតុចូលដែលមានសារប្រយោជន៍ពីអ្នកជំនាញ/ទីប្រឹក្សាបច្ចេកទេសយេនឌ័រ។ |
| តម្រូវការជាចាំបាច់បន្ថែមទៀតនូវសម្ភារៈ | ២.៣.ត្រូវរៀបចំបង្កើតឯកសារសម្រាប់ការអនុវត្តជាក់ |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| បណ្តុះបណ្តាល និងឯកសារនានាពាក់ព័ន្ធនឹងការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ។ | ស្តែងស្តីពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅក្នុងកិច្ចដំណើរការកសាងផែនការ ការរៀបចំថវិកានិងការតាមដានត្រួតពិនិត្យក្នុងកិច្ចអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។ |
| វគ្គបណ្តុះបណ្តាលស្តីអំពីយេនឌ័របានផ្តោតជាសំខាន់ទៅលើស្ត្រី ។ មន្ត្រីជាន់ខ្ពស់ដែលជាអ្នកធ្វើសម្រេចចិត្តមានចំនួនតិចតួច ប៉ុណ្ណោះដែលបានទទួលការបណ្តុះ បណ្តាលអំពីយេនឌ័រ។ | ២.៤. ដោយសារតែតំណាងស្ត្រីមានចំនួនតិចតួចនៅក្នុង គ.ជ.អ.ប និងអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប  ដូច្នេះការពង្រឹងចំណេះដឹងយេនឌ័រ និងបញ្ហាយេនឌ័ររបស់បុរសនៅក្នុងគណៈកម្មការ និងអនុគណៈកម្មាធិការទាំងនេះត្រូវតែបានផ្តល់អាទិភាពដ៏ចាំបាច់មួយ។<br>២.៥. ត្រូវផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រ ដល់មន្ត្រីជាន់ខ្ពស់ដែលជាអ្នកធ្វើការសម្រេចចិត្តនៅក្នុងស្ថាប័នអនុវត្តផអ៣(បុរសស្ទើរតែទាំងអស់) ដោយត្រូវផ្តោតទៅលើការបញ្ជ្រាបយេនឌ័រទៅតាមសមាសភាគនានានៃអនុកម្មវិធីរបស់ខ្លួន។<br>២.៦. ត្រូវផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រដល់សមាជិកក្រុមប្រឹក្សា គណៈអភិបាលទាំងអស់និងប្រធាន មន្ទីរ អង្គភាព ការិយាល័យជំនាញនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (រួមទាំងសមាជិកនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ) និងមន្ត្រីជាន់ខ្ពស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| មន្ត្រីអភិវឌ្ឍន៍សមត្ថភាព និងមន្ត្រីសម្របសម្រួលក្រុមប្រឹក្សាភាគច្រើនគឺជាបុរស។ | ២.៧.ត្រូវធានាថា មន្ត្រីអភិវឌ្ឍន៍សមត្ថភាព និងមន្ត្រីសម្របសម្រួលក្រុមប្រឹក្សាមានការយល់ដឹងអំពីបញ្ហាគន្លឹះយេនឌ័រនៅថ្នាក់ក្រោមជាតិ។ |
| សមត្ថភាពរបស់ក្រសួងកិច្ចការនារី/មន្ទីរកិច្ចការនារីរាជធានី ខេត្ត/ការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌនៅមានកម្រិតទាបសម្រាប់ការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សមត្ថភាព។ | ២.៨.ពង្រឹងសមត្ថភាពមន្ត្រីក្រសួងកិច្ចការនារីក្នុងការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សមត្ថភាព និងផ្តល់ការគាំទ្រដល់តំណាងក្រសួងកិច្ចការនារីនៅ គ.ជ.អ.ប និងអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប។ |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| | ២.៩.ពង្រឹងសមត្ថភាពមន្ត្រីមន្ទីរកិច្ចការនារីរាជធានី ខេត្ត/ការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ ក្នុងការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សមត្ថភាព។ |
| **យុទ្ធសាស្ត្រសម្រាប់រយៈពេលវែង**<br>២.១០.ត្រូវធានាថា អ្នកជំនាញ/ទីប្រឹក្សាបច្ចេកទេស យេនឌ័រត្រូវបានបន្តផ្តល់ការគាំទ្រដល់ស្ថាប័នអនុវត្តអនុកម្មវិធី និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ឧ. ត្រូវពង្រឹងសមត្ថភាពក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការគាំទ្រដល់អនុកម្មវិធីនានា(រួមបញ្ចូលទាំងអ្នកជំនាញយេនឌ័រនៅក្នុងក្រុមទីប្រឹក្សាសម្រាប់កិច្ចការជាក់លាក់នានា)<br>២.១១.ត្រូវបញ្ជ្រាបការងារយេនឌ័រទៅក្នុងកម្មវិធីសិក្សានៃសាលាភូមិន្ទរដ្ឋបាល<br>២.១២.ត្រូវធានាថា សមាជិកក្រុមប្រឹក្សា និងមន្ត្រីដែលត្រូវបានជាប់ឆ្នោត ឬត្រូវបានតែងតាំងថ្មីនឹងត្រូវបានទទួលការបណ្តុះបណ្តាលយ៉ាងសមស្របអំពីការងារយេនឌ័រ។ | |

## ៣. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងក្នុងការរៀបចំបុគ្គលិក

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| **ថ្នាក់ជាតិ** | |
| តំណាងស្ត្រីមានចំនួនតិចតួចបំផុតនៅក្នុង គ.ជ.អ.ប និងអនុគណៈកម្មាធិការនៃ គ.ជ.អ.ប។<br><br>តំណាងស្ត្រីមានចំនួនតិចតួចបំផុតនៅក្នុងជួរមន្ត្រីជាន់ខ្ពស់ថ្នាក់ធ្វើសេចក្តីសម្រេចចិត្តនៃស្ថាប័នអនុវត្តអនុកម្មវិធីនានា | ៣.១.ត្រូវបង្កើតជម្រើសនានាសម្រាប់ធ្វើឲ្យប្រសើរឡើងនូវជំនាញ និងជំនឿចិត្តរបស់មន្ត្រីជាស្ត្រី ដើម្បីឲ្យពួកគេអាចមានលក្ខណសម្បត្តិសម្រាប់ការតែងតាំងក្នុងមុខតំណែងជាន់ខ្ពស់នៅក្នុងស្ថាប័នអនុវត្តអនុកម្មវិធីនានា (ឧ. ការបណ្តុះបណ្តាលអំពីស្ត្រីក្នុងការដឹកនាំដល់មន្ត្រីជាស្ត្រីនៃស្ថាប័នអនុវត្ត និងការបញ្ជូនមន្ត្រីជាស្ត្រីឲ្យទៅសិក្សានៅសាលាភូមិន្ទរដ្ឋាល ឬផ្តល់អាទិភាពដល់មន្ត្រីជាស្ត្រី ក្នុងការកសាងសមត្ថភាពនៅក្នុងប្រទេស និងនៅក្រៅប្រទេសសម្រាប់រយៈពេលវែង)។ |
| ស្ត្រីចង់ឲ្យខ្លួនត្រូវបានជ្រើសរើសតែងតាំងក្នុងមុខតំណែងដែលមានលក្ខណៈជាប្រពៃណីការងាររបស់ស្ត្រី។ ស្ត្រីមានចំនួនតិចតួចបានដាក់ពាក្យសម្រាប់មុខតំណែងបច្ចេកទេសនានា។ ការខិតខំប្រឹងប្រែងក្នុង | ៣.២.កំណត់ជម្រើសនានាដែលមានលក្ខណៈត្រៀមជាមុន ក្នុងការទាក់ទាញ និងជ្រើសរើសបុគ្គលិកជាស្ត្រីបន្ថែមទៀតសម្រាប់មុខតំណែងនានានៅក្នុងស្ថាប័នអនុវត្ត រួមមាន៖ មុខតំណែងដែលមិនមែនជាលក្ខណៈប្រពៃណីការងាររបស់ស្ត្រី។ ឧ. |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| ការជ្រើសរើស និងបង្កើនចំនួនស្ត្រីបន្ថែមទៀតហាក់ដូចជាពុំទាន់មានលក្ខណៈសកម្មក្នុងការត្រៀមរៀបចំមុនឡើយ។ | ទាហរណ៍៖ ជំរុញអនុវត្តតាមកូតា(២០ទៅ៥០% ជាស្ត្រី) ក្នុងការជ្រើសរើសបុគ្គលិកថ្មី, ការពិនិត្យឡើងវិញនូវលក្ខណៈសម្បត្តិដើម្បីអនុញ្ញាតឲ្យមានការជំនួសនូវលក្ខណៈសម្បត្តិនៃបទពិសោធន៍ការងារចំពោះលក្ខណៈសម្បត្តិពាក់ព័ន្ធនឹងកម្រិតអប់រំ, ការប្រើប្រាស់មធ្យោបាយបន្ថែមផ្សេងទៀតក្នុងការប្រកាសជ្រើសរើសបុគ្គលិកក្រៅពីប្រកាសតាមសារព័ត៌មាន និងគេហទំព័រ (ដូចជាការប្រកាសជ្រើសរើសនៅតាមសាកលវិទ្យាល័យ ឬការកំណត់ជ្រើសរើសយកបុគ្គលិកស្ត្រីណាម្នាក់ដោយផ្ទាល់តែម្តង)។ |
| អាទិភាពនានាពាក់ព័ន្ធនឹងយេនឌ័រ ពុំត្រូវបានបញ្ជ្រាបឲ្យមានក្ខណៈស៊ីសង្វាក់ទៅនឹងលក្ខខ័ណ្ឌការងាររបស់បុគ្គលិក និងទីប្រឹក្សា | ៣.៣.ត្រូវធានាថា តម្រូវការយេនឌ័រ ត្រូវបានដាក់បញ្ចូលយ៉ាងស៊ីសង្វាក់គ្នាទៅក្នុងលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសបុគ្គលិក និងលក្ខខ័ណ្ឌការងាររបស់បុគ្គលិក(ដូចជាលក្ខខ័ណ្ឌការងាររបស់បុគ្គលិក ឬទីប្រឹក្សានានាជាដើម) ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសបុគ្គលិកគួរដាក់បញ្ចូលទាំងចំណេះដឹង និងបញ្ហាយេនឌ័រផងដែរ។ លក្ខខ័ណ្ឌការងាររបស់បុគ្គលិកគួរតែដាក់បញ្ចូលផងដែរនូវវិធានការនានាដើម្បីធានាថា តម្រូវការបុរស និងស្ត្រីត្រូវបានផ្តោតនៅក្នុងការទទួលខុសត្រូវអនុវត្តការងារ ។ ត្រូវធានាថា មានតំណាងស្ត្រីនៅក្នុងសមាសភាពគណៈកម្មការជ្រើសរើសបុគ្គលិក។ |
| **ថ្នាក់ក្រោមជាតិ** | |
| ស្ត្រីមានចំនួនតិចតួចនៅក្នុងសមាសភាពក្រុមប្រឹក្សា | ៣.៤. ជំរុញលើកទឹកចិត្តដល់គ្រប់គណបក្សនយោបាយទាំងអស់ ដើម្បីដាក់បញ្ចូលចំនួនស្ត្រីបន្ថែម នៅតាមលេខរៀងផ្នែកខាងលើនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើស |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| | រើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលនឹងត្រូវធ្វើឡើងក្នុងពេលឆាប់ៗខាងមុខនេះ ឬក៏ត្រូវមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលមានឈ្មោះបេក្ខជនជាស្ត្រី និងបេក្ខជនបុរសឆ្លាស់គ្នា។<br>៣.៥.គួរមានការសិក្សាអំពីទំនាក់ទំនងរវាងជាភាគរយនៃតំណាងស្ត្រីនៅក្នុងក្រុមប្រឹក្សាឃុំទៅនឹងសូចនាករលទ្ធផលនៃកិច្ចអភិវឌ្ឍ ជាពិសេសទំនាក់ទំនងដែលពាក់ព័ន្ធទៅនឹងស្ត្រី និងកុមារ។<br>៣.៦.ត្រូវដាក់បញ្ចូលនូវការពង្រឹង និងការគាំទ្រសមាជិកក្រុមប្រឹក្សាជាស្ត្រីនៅថ្នាក់ក្រោមជាតិទៅក្នុងការរៀបចំកាត់តែង និងការអភិវឌ្ឍន៍សមត្ថភាពនៃសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំសង្កាត់ (អនុកម្មវិធីទី៦)។ គួរពិគ្រោះយោបល់ជាមួយនឹងវិទ្យាស្ថានសភាកម្ពុជាអំពីទស្សនៈរបស់ពួកគេ ចំពោះការពង្រីកចំណេះដឹង និងការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅក្នុងព្រឹទ្ធសភា និងសភាជាតិ |
| ស្ត្រីមានចំនួនតិចតួចនៅក្នុងមុខតំណែងធ្វើសេចក្ដីសម្រេចចិត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ | ៣.៧.ត្រូវស្វែងរកជម្រើសសម្រាប់កែលំអនូវជំនាញនានា និងបង្កើននូវភាពជឿជាក់របស់មន្ត្រីជាស្ត្រី ដើម្បីឲ្យមន្ត្រីជាស្ត្រីទាំងនោះអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការតែងតាំងសម្រាប់មុខតំណែងជាន់ខ្ពស់នានា (ឧទាហរណ៍៖ ការបណ្ដុះបណ្ដាលអំពីភាពជាអ្នកដឹកនាំរបស់ស្ត្រីដល់មន្ត្រី បុគ្គលិកជាស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, ការបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបុគ្គលិកជាស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរៀននៅសាលាភូមិន្ទរដ្ឋបាល, ផ្ដល់អាទិភាពដល់មន្ត្រី បុគ្គលិកជាស្ត្រីសម្រាប់ឱកាសអភិវឌ្ឍន៍សមត្ថភាពនៅក្នុងស្រុក និងទទួលអាហារូបករណ៍ទៅសិក្សានៅបរទេស)។ |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| បេក្ខជនជាស្ត្រីមានចំនួនតិចតួច ដែលបានដាក់ពាក្យចូលធ្វើការតាមមុខតំណែងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ | ៣.៨.ត្រូវកំណត់រកជម្រើសដែលមានលក្ខណៈត្រៀមជាមុនដើម្បីកំណត់ និងទាក់ទាញស្ត្រីឲ្យដាក់ពាក្យសម្រាប់តំណែងនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងមុខតំណែងដែលមិនមែនជាប្រពៃណីការងាររបស់ស្ត្រី។ (សូមអានចំណុច ៣.២ ខាងលើ) |
| ការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនអាចបង្កើតនូវភាពលំអៀងក្នុងការធ្វើសេចក្តីសម្រេចចិត្តតែងតាំងដំឡើងមុខតំណែងស្ត្រី ប្រសិនបើមុខតំណែងនោះតម្រូវឲ្យចុះអនុវត្តការងារនៅតាមមូលដ្ឋាននានា។ | ៣.៩.បេក្ខជនជាស្ត្រីដែលត្រូវតែងតែងដំឡើងមុខតំណែង គួរតែអាចធ្វើការសិក្សាវាយតម្លៃដោយខ្លួនឯងថា តើសុវត្ថិភាពការងារអាចជាបញ្ហានៅក្នុងមុខតំណែងខ្ពស់នោះដែរ ឬទេ។ ការគាំទ្រគួរតែត្រូវបានផ្តល់ដើម្បីកាត់បន្ថយនូវការព្រួយបារម្ភអំពីសុវត្ថិភាពការងារទាំងនោះ។ |
| **យុទ្ធសាស្ត្រសម្រាប់រយៈពេលវែង៖**<br>៣.១០.ការបង្កើនចំនួនស្ត្រីឲ្យមានលក្ខណៈសម្បត្តិសមស្របសម្រាប់មុខតំណែងធ្វើការសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ តម្រូវឲ្យមានឆន្ទៈផ្នែកនយោបាយ និងត្រូវការបង្កើននូវកម្រិតអប់រំរបស់ស្ត្រីនៅក្នុងការអនុវត្តការងារ។ កិច្ចការនេះ តម្រូវឲ្យមានវិធានការត្រៀមទុកជាមុនក្នុងការជ្រើសរើស ការតែងតាំង និងការគាំទ្រស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត ព្រមទាំងជំរុញ និងរក្សាកុមារីឲ្យនៅរៀននៅតាមសាលា ដើម្បីធ្វើឲ្យពួកគេអាចបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា ឬថ្នាក់ខ្ពស់ៗបន្ថែមទៀត។ | |

**៤. បញ្ហាយេនឌ័រនៅក្នុងវប្បធម៌ស្ថាប័ន និងទស្សនៈយល់ដឹងអំពីសមិទ្ធផលនានាដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ ៖**

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| **ថ្នាក់ជាតិ** | |
| យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ មានលក្ខណៈច្របូកច្របល់ | ៤.១.ត្រូវធានាថា ផអ៣ជំហានត្រូវ៖<br>១)មានការបញ្ជ្រាបយេនឌ័រ (សូមអានចំណុច ១.៣ និង១.៤ ខាងលើ)<br>២)មានភ្ជាប់ជាមួយនូវឧបសម្ព័ន្ធដែលរៀបរាប់សង្ខេបអំពីអាទិភាពនានានៃឆ្លើយតបទៅនឹងបញ្ហាយេនឌ័រសម្រាប់អនុកម្មវិធីននីមួយៗ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និង |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| | ៣) បានផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ |
| ការលើកកម្ពស់សមភាពយេនឌ័រ នៅកន្លែងធ្វើការ ត្រូវបានរាយការណ៍ថាមានលក្ខណៈល្អ នៅក្នុងអនុកម្មវិធីទី១ ទី២ និងទី៣ ក៏ប៉ុន្តែនៅពុំទាន់បានល្អក្នុងអនុកម្មវិធីទី៤។ | ៤.២.ត្រូវមានខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីកាត់បន្ថយនូវទស្សនៈដែលពុំលើកទឹកចិត្តចំពោះសមភាពយេនឌ័រ នៅក្នុងកន្លែងធ្វើការ (ដូចជា៖ ផ្ទាំងរូបភាព ការផ្ដល់មតិយោបល់ និងនិយាយរឿងកំប្លែងផ្ដេសផ្ដាសដែលមិនគោរពតម្លៃស្ត្រី។ |
| ទទួលស្គាល់នូវសារៈសំខាន់នៃការបង្កើនសមភាពយេនឌ័រថាជាអាទិភាពមួយ ក៏ប៉ុន្តែទស្សនទានយល់ឃើញអំពីវឌ្ឍភាពនៅមានកម្រិតទាប។ | ៤.៣.គួរមានការសិក្សាអង្កេត និងការចងក្រងជាឯកសារបន្ថែមទៀតអំពីកត្តាដែលបានចូលរួមចំណែកធ្វើឲ្យពិន្ទុសវនកម្មយេនឌ័រមានកម្រិតខ្ពស់នៅក្នុងអនុកម្មវិធីទី៣។ |
| **ថ្នាក់ក្រោមជាតិ** | |
| យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ មានលក្ខណៈច្របូកច្របល់ | សូមអាចចំណុច៤.១ខាងលើ |
| ស្ត្រីជាអ្នកទទួលខុសត្រូវចំពោះបញ្ហាស្ត្រី (និងកុមារ) | ៤.៤.ត្រូវមានការខិតខំដើម្បីជំនះឲ្យបាននូវទស្សនដែលយល់ឃើញថា យេនឌ័រគឺជារឿងរបស់ស្ត្រី ហើយស្ត្រីគឺអ្នកទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហារបស់ស្ត្រីដោយខ្លួនឯង។<br>៤.៥.ត្រូវមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងបន្ថែមទៀតដើម្បីកាត់បន្ថយនូវទស្សនដែលមិនលើកទឹកចិត្តចំពោះសមភាពយេនឌ័រនៅក្នុងកន្លែងធ្វើការ (ដូចជា៖ ផ្ទាំងរូបភាព ការផ្ដល់មតិយោបល់ និងនិយាយកំប្លែងផ្ដេសផ្ដាសដែលដែលមិនគោរពតម្លៃស្ត្រី។ល។ |
| ទស្សនយល់ឃើញអំពីវឌ្ឍនភាពក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ នៅថ្នាក់ក្រោមជាតិមានលក្ខណៈផ្សេងៗគ្នាយ៉ាងខ្លាំង | ៤.៦.គួរមានការសិក្សាអង្កេត និងការចងក្រងជាឯកសារបន្ថែមទៀតអំពីកត្តាដែលបានចូលរួមចំណែកធ្វើឲ្យពិន្ទុសវនកម្មយេនឌ័រមានកម្រិតខ្ពស់នៅក្នុងខេត្តស្វាយរៀង។ |
| **យុទ្ធសាស្ត្រសម្រាប់រយៈពេលវែង៖**<br>៤.៧.ការខិតខំជំនះនូវអាកប្បកិរិយា និងឥរិយាបថបែបប្រពៃណីពាក់ព័ន្ធនឹងយេនឌ័រ គឺជាដំណើរការរយៈពេលវែងដែលតម្រូវឲ្យមានការគាំទ្រយ៉ាងទូលាយ ដើម្បីលើកស្ទួយ និងគាំទ្រគោលការណ៍ | |

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| និងការអនុវត្តសមភាពយេនឌ័រ ដែលក្នុងនោះរួមមានដូចជា៖<br>- ការចូលរួមចំណែករបស់ស្ត្រីធ្វើការងារនៅផ្ទះ នៅក្នុងសហគមន៍ នៅកន្លែងធ្វើការ និងកន្លែងដែលអាចរកប្រាក់ចំណូលបាន គឺត្រូវបានឲ្យតម្លៃទាប សូម្បីតែស្ត្រីគ្នាឯងក៏ដោយ។<br>- អាកប្បកិរិយា និងឥរិយាបថរបស់បុរសឆ្លុះបញ្ចាំងទៅលើបុព្វសិទ្ធិយេនឌ័រ (ឧទាហរណ៍៖ បុរសអាចធ្វើអ្វី ដែលពួកគេចង់ធ្វើ ហើយប្រពន្ធរបស់ពួកគេអាចមានយោបល់តិចតួចប៉ុណ្ណោះ)<br>- ស្ត្រីខ្វះខាតភាពជឿជាក់ជាពិសេសចំពោះមុខតំណែង ឬតួនាទីដែលមិនមែនជាប្រពៃណីការងាររបស់ស្ត្រី។<br>៤.៨.បន្តផ្តល់វគ្គបណ្តុះបណ្តាលស្តីអំពីយេនឌ័រដល់បុរស ដែលស្ថិតនៅក្នុងមុខតំណែង/តួនាទីធ្វើសេចក្តីសម្រេចចិត្ត និងជំរុញឲ្យបុរសមានការចូលរួមពាក់ព័ន្ធនឹងការលើកកម្ពស់ និងការគាំទ្រសកម្មភាពនានាដែលឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅថ្នាក់ក្រោមជាតិ។ | |

**៥. ការឆ្លើយតបទៅនឹងបញ្ហាយេនឌ័ររបស់អង្គការ/ស្ថាប័នដៃគូ**

| ការរកឃើញសំខាន់ៗ | អនុសាសន៍នានា |
|---|---|
| **ថ្នាក់ជាតិ** | |
| ត្រូវមានការគាំទ្របន្ថែមទៀតពីដៃគូអភិវឌ្ឍន៍នានាក្នុងការពង្រឹងសមត្ថភាពក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរាជការ ដើម្បីលើកកម្ពស់ និងគាំទ្រឲ្យមានការកើនឡើងនូវសមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រី។ | ៥.១.គួរកៀរគរការគាំទ្រពីដៃគូរអភិវឌ្ឍន៍នានាដើម្បីពង្រឹងសមត្ថភាពក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរាជការបន្ថែមទៀតក្រៅពីការផ្តោតតែទៅលើបញ្ហាស្ត្រីក្នុងការសម្រេចចិត្ត។ |
| ត្រូវការធ្វើឲ្យមានសុខដមនីយកម្មចំពោះសកម្មភាពឆ្លើយតបទៅនឹងយេនឌ័ររបស់គម្រោងដោយឡែកៗនីមួយៗ (stand-alone projects) ជាមួយនឹងក្របខ័ណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NP-SNDD) រយៈពេល១០ឆ្នាំ និងផអ៣។ | ៥.២.ត្រូវពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រយេនឌ័ររបស់គម្រោងដោយឡែកៗនីមួយៗ ដើម្បីកំណត់ឲ្យបាននូវគំរូនៃការអនុវត្តល្អ ដើម្បីដាក់បញ្ចូលទៅក្នុងសកម្មភាពអភិវឌ្ឍន៍សមត្ថភាព។<br>៥.៣.ស្វែងរកនូវអ្វីដែលអាចរៀនសូត្របានពីគម្រោងដោយឡែកៗនីមួយៗ អំពីការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ។<br>៥.៤.ធ្វើឲ្យមានសុខដមនីយកម្មនូវសកម្មភាពឆ្លើយតបទៅនឹងបញ្ហាយេនឌ័ររបស់អង្គការ/ស្ថាប័នដៃគូរនៅថ្នាក់ក្រោមជាតិ។ |
| ទំនាក់ទំនងការងារជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលនានាមានតិចតួច។ | ៥.៥.ត្រូវជំរុញឲ្យមានចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការកិច្ចដំណើរការរៀបចំតាក់តែង |

<table>
<tr><th>ការរកឃើញសំខាន់ៗ</th><th>អនុសាសន៍នានា</th></tr>
<tr><td></td><td>ផអ៣ដំណាក់កាលបន្ទាប់។<br>៥.៦.គួរបញ្ចូលតំណាងអង្គការក្រៅរដ្ឋាភិបាលទៅក្នុងសមាសភាពនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ<br>៥.៧.គួរពិនិត្យ និងរៀនសូត្រអំពីសកម្មភាពនានារបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅថ្នាក់ឃុំ។</td></tr>
<tr><td colspan="2">យុទ្ធសាស្ត្រសម្រាប់រយៈពេលវែង<br>៥.៨.រាជរដ្ឋាភិបាលត្រូវតែឈានមុខក្នុងការធានាថា គម្រោងនានារបស់ដៃគូរអភិវឌ្ឍន៍ត្រូវមានការឆ្លើយតបទៅនឹងយេនឌ័រក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិ និងដោយមិនត្រូវមានការឆ្លើយតបតែទៅនឹងអាទិភាពរបស់ដៃគូរអភិវឌ្ឍន៍ខ្លួនឯងឡើយ។<br>៥.៩.អង្គការមិនមែនរដ្ឋាភិបាលនានាមានបទពិសោធន៍យ៉ាងច្រើនក្នុងការលើកកម្ពស់ និងគាំទ្រនានាដល់ការបង្កើនសមភាពយេនឌ័រ និងភាពអង់អាចរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិ។ បទពិសោធន៍ទាំងនេះគួរតែត្រូវបានប្រមូល បញ្ជ្រាប និងគាំទ្រផអ៣នាពេលខាងមុខ។</td></tr>
</table>

# សវនកម្មយេនឌ័រសម្រាប់ផែនការអនុវត្តបីឆ្នាំដំបូង នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## របាយការណ៍

## ១. សេចក្តីផ្តើម

### ១.១. សាវតា និងបរិបទ[1]

រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈ ក្នុងការជម្រុញកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ស្របតាមច្បាប់រៀបចំអង្គការឆ្នាំ២០០៨(ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ ដើម្បីអនុវត្តគោលនយោបាយ នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរបស់រាជរដ្ឋាភិបាល គ.ជ.អ.ប បានរៀបចំកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) និងផែនការអនុវត្តបីឆ្នាំដំបូង(ផអ៣ ២០១១-២០១៣)។ ផអ៣ មានអនុកម្មវិធីចំនួន៦ និងស្ថាប័នអនុវត្តចំនួន៧[2]។ ការពន្យារពេលមួយឆ្នាំនៃផអ៣សម្រាប់ឆ្នាំ២០១៤ ត្រូវបានរៀបចំ និងឯកភាពដោយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធសំខាន់ៗនៃផអ៣ នៅឆ្នាំ២០១៣។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានប្តេជ្ញាចិត្តផងដែរក្នុងការបង្កើនសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រីនៅក្នុងគោលនយោបាយនានាជាច្រើន ដូចជាគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ កម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផអ៣ សុទ្ធតែមានភ្ជាប់នូវឯកសារឧបសម្ព័ន្ធស្តីពីយុទ្ធសាស្ត្រយេនឌ័រ[3] ដែលគូសបញ្ជាក់អំពីរបៀបដាក់បញ្ចូលទស្សនយេនឌ័រទៅក្នុងការអនុវត្តជាក់ស្តែង។ ការទទួលខុសត្រូវចម្បងៗ សម្រាប់ការ

---

[1] បានមកពីល័ក្ខខ័ណ្ឌការងាររបស់ទីប្រឹក្សារយៈពេលខ្លី (ឧបសម្ព័ន្ធទី១)

[2] អនុកម្មវិធីនានានៃផអ៣ ៖

- អនុកម្មវិធីទី១ ៖ ការរៀបចំគោនយោបាយនិងការសម្របសម្រួលកម្មវិធី ព្រមទាំងការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សាក្នុងការប្រឹក្សាយោបល់ និងការរៀបចំគោនយោបាយ (លេខាធិការដ្ឋាន គ.ជ.អ.ប)
- អនុកម្មវិធីទី២ ៖ ការរៀបចំ និងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រសួងមហាផ្ទៃ)
- អនុកម្មវិធីទី៣ ៖ ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រសួងមុខងារសាធារណៈ)
- អនុកម្មវិធីទី៤ ៖ ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)
- អនុកម្មវិធីទី៥ ៖ ប្រព័ន្ធកសាងផែនការ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រសួងផែនការ)
- អនុកម្មវិធីទី៦ ៖ ការអភិវឌ្ឍសមត្ថភាពសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់)
- ស្ថាប័នអនុវត្តទី៧ គឺក្រសួងកិច្ចការនារី គាំទ្រដល់សមភាពយេនឌ័រ ដែលជាបញ្ហាអន្តរវិស័យ។

[3] ឧបសម្ព័ន្ធទី១នៃកម្មវិធីជាតិ និងឧបសម្ព័ន្ធទី៣នៃផអ៣។

រៀបចំតាក់តែង និងការអនុវត្តការងារយេនឌ័រដែលត្រូវបញ្ជ្រាបនៅតាមអនុកម្មវិធីនានា គឺជាការទទួលខុសត្រូវរបស់អនុកម្មវិធីនីមួយៗ។ ចំណែកឯក្រសួងកិច្ចការនារីមានតួនាទីផ្តល់យោបល់ជាយុទ្ធសាស្ត្រ គាំទ្រ និងពិនិត្យបន្ថែម និងធានានូវភាពស៊ីសង្វាក់គ្នានៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់រាជរដ្ឋាភិបាលនាពេលបច្ចុប្បន្ននេះ។

តម្រូវការក្នុងការពិនិត្យ ការកែលម្អ និងឬការកែសម្រួលឡើងវិញនូវយុទ្ធសាស្ត្រយេនឌ័រ និងការអនុវត្តយុទ្ធសាស្ត្រនេះ ត្រូវបានកំណត់ក្នុងរយៈពេលកន្លងមក ជាពិសេសនៅក្នុងពេលការពន្យារពេលមួយឆ្នាំនៃផអ៣។ នៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៣ ចំណុចដៅមួយក្នុងចំណោមចំណុចដៅទាំង១៩ គឺការធ្វើសវនកម្មយេនឌ័រ ដើម្បីវាយតម្លៃអំពីកម្រិតប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ល័ក្ខខ័ណ្ឌការងារទីប្រឹក្សាសវនកម្មយេនឌ័រ ក៏ត្រូវបានពង្រីកវិសាលភាពដោយរួមបញ្ចូលនូវការធ្វើសវនកម្មយេនឌ័រអនុកម្មវិធីនានានៅថ្នាក់ជាតិផងដែរ។

ដូចបានកំណត់នៅក្នុងល័ក្ខខ័ណ្ឌការងាររបស់ទីប្រឹក្សាសវនកម្មយេនឌ័រ គោលបំណងនៃសវនកម្មយេនឌ័រសម្រាប់ផអ៣ គឺដើម្បី ៖

១. វាយតម្លៃអំពីកម្រិតប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រ និងអំពីរបៀបពង្រឹងភាពអង់អាចរបស់ស្ត្រីនៅក្នុងស្ថាប័នអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (សំណាក)
២. វាយតម្លៃ ដកស្រង់បទពិសោធន៍ និងផ្តល់អនុសាសន៍នានាសម្រាប់ការកែលំអការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ និងយន្តការបញ្ជ្រាបយេនឌ័រនានាដែលមានបច្ចុប្បន្ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងរយៈពេលនៃការពន្យារពេលផអ៣ (ឆ្នាំ២០១៤)
៣. កំណត់យុទ្ធសាស្ត្រសម្រាប់ពេលអនាគត កំណត់វិស័យការងារ ការសម្រេចចិត្តខាងគោលនយោបាយ ព្រមទាំងវិធានការនានាដែលត្រូវដាក់បញ្ចូលទៅក្នុងផែនការអនុវត្តជំហានបន្ទាប់នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
៤. រៀបចំវិធីសាស្ត្រសវនកម្មយេនឌ័រនានា ដែលអាចដាក់បញ្ចូលទៅក្នុងដំណើរការអនុវត្តនៃការអភិវឌ្ឍស្ថាប័ននាពេលអនាគត។

យោងតាមល័ក្ខខ័ណ្ឌការងាររបស់ទីប្រឹក្សាសវនកម្មយេនឌ័រ សវនកម្មយេនឌ័រនេះត្រូវអនុវត្តទៅលើអនុកម្មវិធីចំនួន៤ក្នុងចំណោមអនុកម្មវិធីទាំង៦នៃផអ៣ (អនុកម្មវិធីទី១ ទី២ ទី៣ និងទី៤) ទៅលើខេត្តចំនួន៤ក្នុងចំណោមរាជធានី ខេត្តទាំង២៤ និងទៅលើក្រុង ស្រុកដែលពាក់ព័ន្ធចំនួន៤។ ខេត្តចំនួន៤ និងក្រុង ស្រុកដែលពាក់ព័ន្ធទាំងនោះត្រូវបានជ្រើសរើសតាមវិធីសាស្ត្រជ្រើសរើសដោយចៃដន្យផ្អែកតាមភូមិសាស្ត្រនីមួយៗនៃតំបន់ភូមិសាស្ត្រទាំង៤នៃប្រទេសកម្ពុជា។ ខេត្ត និងក្រុង ស្រុកដែលបានជ្រើសរើសទាំងនោះ រួមមានដូចខាងក្រោម ៖

| តំបន់ | ខេត្ត | ក្រុង ស្រុក |
|---|---|---|
| - ទន្លេសាប | បាត់ដំបង | ស្រុករតនមណ្ឌល |
| - ឆ្នេរសមុទ្រ | កោះកុង | ក្រុងខេមរភូមិន្ទ |
| - ខ្ពង់រាប | ក្រចេះ | ស្រុកសំបូរ |

- ទំនាប ស្វាយរៀង ស្រុកស្វាយទាប

សវនកម្មយេនឌ័រនៃផអ៣ ត្រូវបានអនុវត្តចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤។ ទីប្រឹក្សាជាតិ និងអន្តរជាតិសម្រាប់សវនកម្មយេនឌ័រ ត្រូវបានចុះកិច្ចសន្យាបំពេញការងាររយៈពេល៦ និង៧សប្តាហ៍។ ផ្អែកតាមលក្ខខ័ណ្ឌការងារ និងក្របខ័ណ្ឌពេលវេលានៃកិច្ចសន្យារំពឹងថា ទីប្រឹក្សានឹងផ្តល់ការកសាងសមត្ថភាពដល់បុគ្គលិកលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី ដើម្បីឱ្យមានលទ្ធភាពអនុវត្តសវនកម្មយេនឌ័រដោយខ្លួនឯង និងរៀបចំនូវវិធីសាស្ត្រនានាដែលអាចយកទៅប្រើប្រាស់សម្រាប់ការធ្វើសវនកម្មយេនឌ័រនាពេលអនាគត ដែលជាផ្នែកមួយនៃដំណើរការអភិវឌ្ឍន៍ស្ថាប័ន។ ផ្អែកតាមក្របខ័ណ្ឌពេលវេលាសម្រាប់ការផ្តល់សេវារបស់ទីប្រឹក្សា និងការរំពឹងទុកថា ការរៀបចំបាននូវវិធីសាស្ត្រនានាដែលអាចជួយដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប ឬក្រសួងកិច្ចការនារីអនុវត្តសវនកម្មយេនឌ័រដោយខ្លួនឯង ព្រមទាំងត្រូវបានប្រើប្រាស់នាពេលអនាគត គឺជាការផ្តោតការយកចិត្តក្នុងការរៀបចំឧបករណ៍ និងវិធីសាស្ត្រសម្រាប់ការធ្វើសវនកម្មយេនឌ័រនេះ។

## ១.២. តើសវនកម្មយេនឌ័រ គឺជាអ្វី?

ដូចបានកំណត់នៅក្នុងលក្ខខ័ណ្ឌការងាររបស់ទីប្រឹក្សាសវនកម្មយេនឌ័រនៃផអ៣"សវនកម្មយេនឌ័រ គឺជាការវាយតម្លៃអំពីកម្រិតនៃប្រសិទ្ធភាពដែលស្ថាប័នអនុវត្តផអ៣ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានបញ្ជ្រាបយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រី"។ របកគំហើញនៃសវនកម្មយេនឌ័រគឺមានបំណងធ្វើជា" ទិន្នន័យដើមគ្រាសម្រាប់ប្រើប្រាស់ជាប្រព័ន្ធនៃការវាស់វែងនូវការសម្រេចបាននានានៃសកម្មភាពបញ្ជ្រាបយេនឌ័រ និងការព្រងឹងភាពអង់អាចដល់ស្ត្រី"។

ដូចមានបង្ហាញតាមដ្យាក្រាមខាងក្រោម ការបញ្ជ្រាបយេនឌ័រមានយុទ្ធសាស្ត្រសំខាន់ចំនួន២ ៖

១. ការដាក់បញ្ចូលនូវផលប្រយោជន៍របស់ស្ត្រី និងបុរស (ឧទាហរណ៍ តម្រូវការ និងការព្រួយបារម្ភ) នៅក្នុងគ្រប់គោលនយោបាយ កម្មវិធី និងសកម្មភាពទាំងអស់

២. សកម្មភាពជាក់លាក់នានាដែលមានគោលបំណងក្នុងការពង្រឹងភាពអង់អាចរបស់ស្ត្រី។

**រូបភាពទី១ ៖ មធ្យោបាយសំខាន់ៗចំនួន២ក្នុងការបញ្ជ្រាបយេនឌ័រ**



ធាតុទាំងពីរនៃយុទ្ធសាស្ត្រនេះ ត្រូវបានវាយតម្លៃជាផ្នែកមួយនៃសវនកម្មយេនឌ័រ។ ដោយសារតែការបញ្ជ្រាបយេនឌ័រប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យមានការខិតខំប្រឹងប្រែងទាំងបុគ្គលម្នាក់ៗ និងទាំងបរិយាកាសគាំទ្រផ្នែកស្ថាប័ន ដូចនេះសវនកម្មយេនឌ័របានពិនិត្យមើលទាំងកត្តាបុគ្គលម្នាក់ៗ និងកត្តាស្ថាប័នផងដែរ ដែលក្នុងនោះ ៖

១. **ការពិនិត្យមើលលើកត្តាបុគ្គលម្នាក់ៗ** ៖ ការយល់ដឹង អាកប្បកិរិយា ទស្សនៈ និងសមត្ថភាព

២. **ការពិនិត្យមើលលើកត្តាស្ថាប័ន** ៖ ភស្តុតាងនៃការបញ្ជ្រាបយេនឌ័រ ដែលបានឆ្លុះបញ្ចាំងនៅក្នុងឯកសារពាក់ព័ន្ធនានា និងសម្ភារៈផ្សេងៗទៀត[4]។

សវនកម្មយេនឌ័រនៃផអ៣ បានពិនិត្យទៅលើវិស័យឬសមាសភាគសំខាន់ៗចំនួន៥ ៖

១. យេនឌ័រនៅក្នុងការរៀបចំតាក់តែងគោលនយោបាយសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការតាមដាននិងវាយតម្លៃ និងផលប៉ះពាល់

២. ជំនាញបច្ចេកទេសគាំទ្រដល់ការរៀបចំ និងការអនុវត្តនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលឆ្លើយតបទៅនឹងយេនឌ័រ

៣. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំបុគ្គលិក

៤. បញ្ហាយេនឌ័រនៅក្នុងវប្បធម៌ និងទស្សនៈរបស់ស្ថាប័នទាក់ទងនឹងសមភាពយេនឌ័រ

៥. ការឆ្លើយតបយេនឌ័រនៃអង្គការ/ស្ថាប័នដៃគូនានា (ឧទាហរណ៍ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា)

## ១.៣. វិធីសាស្ត្រ និងដំណើរការ

នៅក្នុងការរៀបចំវិធីសាស្ត្រ និងឧបករណ៍នានាសម្រាប់សវនកម្មយេនឌ័រនៃផអ៣ ជាដំបូងទីប្រឹក្សាបានពិនិត្យវិធីសាស្ត្រ និងឧបករណ៍សវនកម្មយេនឌ័រនានា ដែលឆ្លុះបញ្ចាំងនៅក្នុងបទពិសោធន៍អន្តរជាតិល្អៗ និងនៅក្នុងឯកសារជាច្រើនដែលទាក់ទងនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផអ៣ រួមទាំងផែនការសកម្មភាពនិងថវិកា និងរបាយការណ៍ប្រចាំឆ្នាំនានា ដើម្បីស្វែងយល់ឱ្យបានច្បាស់លាស់ និងកំណត់ប្រភពព័ត៌មានដែលមានសក្តានុពលសម្រាប់ការធ្វើសវនកម្ម។ បញ្ជីឈ្មោះឯកសារដែលបានពិនិត្យមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២។

ព័ត៌មានសម្រាប់សវនកម្មយេនឌ័រត្រូវបានប្រមូលតាមរយៈការពិនិត្យឯកសារនានា បញ្ជីសំណួរសម្រាប់ការបំពេញដោយបុគ្គលម្នាក់ដោយខ្លួនឯង ការសម្ភាសន៍បុគ្គលម្នាក់ៗ និងការសម្ភាសន៍ដែលមានលក្ខណៈជាក្រុម។ ឧបករណ៍នានាសម្រាប់ដំណើរការប្រមូលព័ត៌មាននីមួយៗ ត្រូវបានរៀបចំ (ឧទាហរណ៍ បញ្ជីកិច្ចការសម្រាប់ពិនិត្យឯកសារ បញ្ជីសំណួរសម្រាប់ការបំពេញដោយខ្លួនឯង កម្មវិធីកុំ

[4] ឯកសារទាំងនោះរួមមាន កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ផអ៣ ឯកសារគោលនយោបាយនានា ផែនការសកម្មភាពនិងថវិកា របាយការណ៍ស្តីពីការអនុវត្តផអ៣ របាយការណ៍តាមដាននិងវាយតម្លៃ សៀវភៅណែនាំ សេចក្តីណែនាំបច្ចេកទេស សម្ភារៈប្រាស្រ័យទាក់ទងនានា។ល។

ព្យូទ័រសម្រាប់បញ្ចូល និងវិភាគទិន្នន័យ សំណួរនាំមុខសម្រាប់សម្ភាសន៍) ព្រមទាំងឧបករណ៍សម្រាប់បូកសរុប និងសង្ខេបព័ត៌មានពីប្រភពផ្សេងៗ ទៅក្នុងរបាយការណ៍សវនកម្មយេនឌ័រតាមសមាសភាគនីមួយៗ (ឧទាហរណ៍ បញ្ជីកិច្ចការសម្រាប់ដាក់ពិន្ទុ របាយការណ៍កាតពិន្ទុ)។ សមាសភាគសវនកម្មយេនឌ័រនីមួយៗ មានសូចនាករនានា ដែលត្រូវដាក់ពិន្ទុក្នុងចន្លោះពី ០ ទៅ៣។ ប្រភពព័ត៌មាននានាសម្រាប់សូចនាករនីមួយៗ និងការណែនាំសម្រាប់ការដាក់ពិន្ទុ ត្រូវបានកំណត់នៅក្នុងបញ្ជីកិច្ចការសម្រាប់ដាក់ពិន្ទុ។ ឧបករណ៍នានាដែលបានប្រើប្រាស់សម្រាប់សវនកម្មយេនឌ័រមានភ្ជាប់ជាឧបសម្ព័ន្ធទី៣។

បញ្ជីសំណួរសម្រាប់ការបំពេញដោយបុគ្គលម្នាក់ៗ ដោយខ្លួនឯងត្រូវបានឲ្យបំពេញតាមប្រព័ន្ធគេហទំព័រ (on-line) នៅថ្នាក់ជាតិ និងតាមឯកសារថតចម្លងនៅថ្នាក់ក្រោមជាតិ។ អ្នកផ្តល់ព័ត៌មានសរុបចំនួន២៣៣នាក់បានបំពេញបញ្ជីសំណួរ (ថ្នាក់ជាតិចំនួន៣៩នាក់[5] ថ្នាក់ខេត្តចំនួន១១៩នាក់ និងថ្នាក់ស្រុកចំនួន៧៥នាក់)។

ក្រុមការងារមួយដែលមានសមាជិក១២ មកពីលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី ត្រូវបានបង្កើតឡើង ដើម្បីធ្វើការជាមួយទីប្រឹក្សា និងទទួលខុសត្រូវទាំងស្រុងក្នុងការធ្វើសវនកម្មយេនឌ័រនៅអនុកម្មវិធីមួយ (អនុកម្មវិធីទី៤) និងនៅខេត្ត និងក្រុង ស្រុកចំនួន៦ ក្នុងចំណោមខេត្ត និងក្រុង ស្រុកចំនួន៨ ដែលបានជ្រើសរើស។ ទីប្រឹក្សាបានផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសរយៈកន្លះថ្ងៃ ដូចបានកំណត់នៅក្នុងលក្ខខ័ណ្ឌការងារ និងផ្តល់ការអនុវត្តផ្ទាល់ដល់ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី។ សមាជិកក្រុមការងារបានចូលរួមសម្ភាសន៍អនុកម្មវិធីទី១ ទី២ និងទី៣ និងការសម្ភាសន៍នៅថ្នាក់ខេត្ត ឬស្រុកដំបូងនៅថ្នាក់ក្រោមជាតិ ដែលបានធ្វើនៅខេត្តក្រចេះ។ ដោយសារតែការសម្ភាសន៍នៅខេត្តក្រចេះមានវឌ្ឍនភាពល្អ សមាជិកក្រុមការងារបានចាប់ផ្តើមសួរសំណួរ និងផ្តល់យោបល់នានាដោយខ្លួនឯងផ្ទាល់។ បញ្ជីឈ្មោះសមាជិកក្រុមការងារសវនកម្មយេនឌ័រមាននៅក្នុងសម្ព័ន្ធទី៤។ អ្នកដែលបានជួប និងប្រឹក្សាយោបល់មាននៅក្នុងឧបសម្ព័ន្ធទី៥។

ក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីបានទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ និងការធ្វើបទបង្ហាញអំពីការរកឃើញ និងអនុសាសន៍នានាសម្រាប់ការធ្វើសវនកម្មរបស់ខ្លួន។ ការផ្តល់យោបល់ត្រឡប់ត្រូវបានផ្តល់ដល់អ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ អំពីការរកឃើញ និងអនុសាសន៍នានាដែលទទួលបានពីការធ្វើសវនកម្មយេនឌ័រនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ។ ការផ្តល់យោបល់ត្រឡប់នានាចំពោះការរកឃើញត្រូវបានទទួលយក ដោយសារការរកឃើញទាំងនោះភាគច្រើនពាក់ព័ន្ធនឹងការព្រួយបារម្ភណ៍នានាដែលអាចកើតឡើងជាមួយនឹងអនុសាសន៍ ហើយដែលបញ្ហាទាំងនោះភាគច្រើនត្រូវបានលើកឡើងដោយអ្នកពាក់ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិខ្លួនឯង។ ក្រុមការងារសវនកម្មយេនឌ័របានពន្យល់ថា ការរកឃើញ និងអនុសាសន៍នានានឹងត្រូវបានបូកសរុប និងរាយការណ៍ជូន គ.ជ.អ.ប។

[5] ដោយសារតែមានការលំបាកផ្នែកបច្ចេកទេស ទិន្នន័យមួយចំនួននៅថ្នាក់ជាតិមិនបានរក្សាទុកបានត្រឹមត្រូវ និងមិនអាចប្រើប្រាស់បាន។ ទោះបីយ៉ាងណាក៏ដោយ ការរកឃើញតាមរយៈបញ្ជីសំណួរ មានលក្ខណៈស៊ីគ្នាជាមួយការរកឃើញតាមរយៈការសំភាសន៍ និងការពិនិត្យឯកសារនានា។

បន្ទាប់ពីបញ្ចប់សវនកម្មយេនឌ័រនៃផអ៣ ឧបករណ៍នានាត្រូវបានពិនិត្យ និងកែសម្រួលឡើងវិញសម្រាប់ធ្វើជាឯកសារយោង និងការប្រើប្រាស់នាពេលអនាគត (ឧបសម្ព័ន្ធទី៩)។

## ១.៤. ភាពមានកម្រិត និងឧបសគ្គនានា

**ក្របខ័ណ្ឌពេលវេលា**

ដោយសារតែកិច្ចការនេះត្រូវបានអនុវត្តនៅចុងឆ្នាំ មានកត្តាផ្សេងៗជាច្រើនដែលជាឧបសគ្គដល់កិច្ចដំណើរការធ្វើសវនកម្មយេនឌ័រសម្រាប់ផអ៣។ នៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៣ បានកំណត់ត្រឹមតែធ្វើសវនកម្មយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិប៉ុណ្ណោះ ប៉ុន្តែនៅពេលជ្រើសរើសទីប្រឹក្សាបាន ការធ្វើសវនកម្មយេនឌ័រនេះ ត្រូវបានពង្រីកវិសាលភាពដោយរួមបញ្ចូលនូវការធ្វើសវនកម្មយេនឌ័រតាមអនុកម្មវិធីនានានៅថ្នាក់ជាតិ ដែលបណ្តាលឱ្យពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការបញ្ចប់ការងារទាំងអស់នៅមុនពេលដំណាច់ឆ្នាំ។ ទោះបីជាការធ្វើសវនកម្មនៅតាមអនុកម្មវិធីនានាត្រូវបានបញ្ចប់នៅដំណាច់ឆ្នាំក៏ដោយ ក៏ការធ្វើសវនកម្មយេនឌ័រនៅថ្នាក់ក្រោមជាតិមិនអាចអនុវត្តបានចប់សព្វគ្រប់ឡើយ គឺត្រូវពន្យារពេលរហូតដល់ខែមករា ឆ្នាំ២០១៤។

**ការបកប្រែភាសា**

ការបកប្រែភាសា គឺជាឧបសគ្គមួយដែលបានធ្វើឲ្យមានការប្រើប្រាស់រយៈពេលយូរ ដោយសារតែឧបករណ៍សវនកម្មយេនឌ័រនានាត្រូវបានចាប់ផ្តើមរៀបចំដោយទីប្រឹក្សាអន្តរជាតិ និងតម្រូវឱ្យមានការបកប្រែពីភាសាអង់គ្លេសទៅភាសាខ្មែរ។ ការសម្ភាសន៍បុគ្គលម្នាក់ៗ និងការសម្ភាសន៍លក្ខណៈជាក្រុមសម្រាប់ការធ្វើសវនកម្មអនុកម្មវិធីទី១ និងនៅខេត្តក្រចេះត្រូវបានដឹកនាំដោយទីប្រឹក្សាអន្តរជាតិ ដូច្នេះការបកប្រែភាសា គឺជាតម្រូវការចាំបាច់ អាស្រ័យហេតុនេះវាបានធ្វើឲ្យពុំមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាឲ្យបានច្រើនជាមួយបុគ្គលម្នាក់ៗ ឬជាមួយការសម្ភាសន៍ជាក្រុមឡើយ។ ការបកប្រែឯកសារពីភាសាអង់គ្លេសទៅភាសាខ្មែរនៃការរកឃើញ និងអនុសាសន៍នានាដែលទទួលបានពីការធ្វើសវនកម្មយេនឌ័រនៅខេត្តក្រចេះ ដើម្បីផ្តល់យោបល់ត្រឡប់ទៅឱ្យអ្នកពាក់ព័ន្ធនានានៅខេត្ត និងស្រុកវិញ មិនអាចធ្វើបាននៅមុនពេលកិច្ចប្រជុំផ្តល់យោបល់ត្រឡប់ឡើយ។ ក្នុងន័យនេះ គឺត្រូវការប្រើប្រាស់ពេលវេលាបន្ថែមសម្រាប់ការបកប្រែភាសាក្នុងអំឡុងពេលកិច្ចប្រជុំផ្តល់យោបល់ត្រឡប់ និងពេលវេលាសម្រាប់បកប្រែរបាយការណ៍ និងយោបល់ត្រឡប់នានាដែលទទួលបានពីអ្នកពាក់ព័ន្ធនានាទាំងនោះ បន្ទាប់ពីកិច្ចប្រជុំ។

ទោះបីជាពុំមាននៅក្នុងលក្ខខ័ណ្ឌការងាររបស់ទីប្រឹក្សាជាតិក៏ដោយ ក៏ការងារបកប្រែផ្ទាល់មាត់ និងការបកប្រែឯកសារភាគច្រើន បានធ្លាក់ទៅលើទីប្រឹក្សាជាតិនេះ។ សមាជិកក្រុមការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប បានជួយបកប្រែភាសានៅក្នុងអំឡុងពេលសម្ភាសន៍ និងបានព្រមព្រៀងផ្តល់របាយការណ៍ជាភាសាអង់គ្លេស ចំពោះសវនកម្មយេនឌ័រដែលពួកគេបានធ្វើ។

**អនុកម្មវិធីទី៤**

ព័ត៌មានដែលមានក្នុងការធ្វើសវនកម្មអនុកម្មវិធីទី៤ គឺហាក់មានឧបសគ្គបន្តិចបន្តួច ដោយសារតែមានតែ២នាក់ប៉ុណ្ណោះ ក្នុងចំណោម៤នាក់ដែលបានកំណត់សម្រាប់ការសម្ភាសន៍ បានជួបសម្ភាសន៍។ ការសម្ភាសន៍ជាមួយអ្នកទាំងពីរនេះ ត្រូវបានធ្វើឡើងក្នុងលក្ខណៈជាក្រុមពិភាក្សា។ មានតែម្នាក់គត់នៃអនុកម្មវិធីទី៤ ដែលបានបំពេញបញ្ជីសំណួរ (ទីប្រឹក្សា)។ ទោះបីយ៉ាងណាក៏ដោយ ការពិនិត្យឯកសារ និងការសម្ភាសន៍ទទួលបាននូវព័ត៌មាន ដែលមានតម្លៃសម្រាប់ការវាយតម្លៃស្ថានភាពបច្ចុប្បន្ននៃការបញ្ជ្រាបយេនឌ័រនៅក្នុងអនុកម្មវិធីទី៤ ដែលមានភាពស៊ីគ្នាជាមួយនឹងការរកឃើញនៅក្នុងអនុកម្មវិធីផ្សេងៗទៀតផងដែរ។

**ការប្រឹក្សាយោបល់ជាមួយដៃគូ**

ការប្រឹក្សាយោបល់ជាមួយអង្គការដៃគូនានា (ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា) អាចមានសារៈសំខាន់ច្រើន ប៉ុន្តែកិច្ចការនេះពុំបានបញ្ចូលនៅក្នុងល័ក្ខខ័ណ្ឌការងាររបស់ទីប្រឹក្សាឡើយ ឬដោយសារពុំមានពេលវេលាគ្រប់គ្រាន់។

## ២. សំណួរគន្លឹះ លទ្ធផលរកឃើញ និងអនុសាសន៍ តាមសមាសភាគសវនកម្មយេនឌ័រ

ជំពូកនេះរៀបរាប់អំពីសមាសភាគរង សំណួរគន្លឹះ និងប្រភពសំខាន់ៗនៃព័ត៌មានសម្រាប់សមាសភាគនីមួយៗ ក្នុងចំណោមសមាសភាគទាំង៥នៃការធ្វើសវនកម្មយេនឌ័រ ព្រមទាំងធ្វើការសង្ខេបនូវលទ្ធផលរកឃើញ និងអនុសាសន៍សំខាន់ៗសម្រាប់សមាសភាគនីមួយៗដោយផ្អែកលើរបាយការណ៍ស្តីពីការធ្វើសវនកម្មយេនឌ័រទាំង១២ស្ថាប័ន។ លទ្ធផលរកឃើញ និងអនុសាសន៍នានាសម្រាប់អនុកម្មវិធី និងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ មាននៅក្នុងរបាយការណ៍ដាក់ពិន្ទុសវនកម្មយេនឌ័រនៅក្នុងឧបសម្ព័ន្ធទី៦។

### ២.១. សមាសភាគទី១ ÷ យេនឌ័រនៅក្នុងការរៀបចំគោលនយោបាយការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការត្រួតពិនិត្យ និងការវាយតម្លៃកម្មវិធី

#### ២.១.១. អនុសមាសភាគ សំណួរគន្លឹះ និងប្រភពព័ត៌មាន

សមាសភាគទី១នៃសវនកម្មយេនឌ័រនៅក្នុងវិស័យទាំង៦៖

| អនុសមាសភាគ | សំណួរគន្លឹះ | ប្រភពព័ត៌មាន |
|---|---|---|
| ១.១. ការយល់ដឹងពីយេនឌ័រក្នុងការរៀបចំគោលនយោបាយ(នៅថ្នាក់ជាតិ) | តើយេនឌ័រត្រូវបានពិចារណាក្នុងដំណើរការរៀបចំតាក់តែងគោលនយោបាយ និងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយដែរឬទេ? | – ការពិនិត្យមើលរបាយការណ៍ឆ្លើយតបរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិចំពោះអនុសាសន៍នៃការវាយតម្លៃយេនឌ័រក្នុងប្រទេសកម្ពុជា |

| អនុសមាសភាគ | សំណួរគន្លឹះ | ប្រភពព័ត៌មាន |
|---|---|---|
| | | – ពិនិត្យមើលលិខិតបទដ្ឋានគតិយុត្តនានា<br>– ការសម្ភាសន៍នានា |
| ១.២.ការវិភាគយេនឌ័រក្នុងដំណើរការកសាងផែនការ | តើយេនឌ័រត្រូវបានពិចារណាក្នុងដំណើរការកសាងផែនការ និងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការដែរឬទេ? | – ការពិនិត្យមើលលើការបញ្ចូលនូវសមាសធាតុសំខាន់ៗនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងយុទ្ធសាស្ត្រយេនឌ័រនៃគម្រោងផអ៣ទៅក្នុងផែនការ<br>– ពិនិត្យមើល ផ.ស.ថ ប្រចាំឆ្នាំ<br>– ការសម្ភាសន៍នានា<br>– បញ្ជីសំណួរៈប្រព័ន្ធរៀបចំកម្មវិធីឡើងវិញ |
| ១.៣. ការរៀបចំថវិកាឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ | តើមានថវិកាគ្រប់គ្រាន់ដើម្បីដោះស្រាយ ការព្រួយបារម្ភពាក់ព័ន្ធយេនឌ័រ មានបង្ហាញក្នុងផែនការដែរឬទេ? | – ការពិនិត្យមើល ផ.ស.ថ ប្រចាំឆ្នាំ |
| ១.៤. ការអនុវត្តនូវការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ | តើវិធានការឆ្លើយតបយេនឌ័រដែលត្រូវបានបញ្ចូលក្នុងផែនការ និងថវិកាត្រូវបានអនុវត្តដែរឬទេ? | – ការពិនិត្យមើលរបាយការណ៍អនុវត្ត |
| ១.៥. ការត្រួតពិនិត្យការឆ្លើយតបចំពោះបញ្ហាយេនឌ័រ | តើសូចនាករឆ្លើយតបយេនឌ័រ និងទិន្នន័យអំពីភេទត្រូវបានបញ្ចូលក្នុងក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃដែរឬទេ? | – ការពិនិត្យមើលក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃ |
| ១.៦.ផលប៉ះពាល់នៃការឆ្លើយតបបញ្ហាយេនឌ័រ (អនុកម្មវិធីទី១ និងរដ្ឋបាលថ្នាក់ក្រោមជាតិ) | តើមានផលប៉ះពាល់អ្វីខ្លះលើស្ថាបន និងការអភិវឌ្ឍចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់សមភាពយេនឌ័រ? | – ការពិនិត្យមើលទិន្នន័យឃុំសង្កាត់ គោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា និងរបាយការណ៍ដាក់ពិន្ទុតាមវិស័យ<br>– ការពិនិត្យមើលរបាយការណ៍អង្កេត |

| អនុសមាសភាគ | សំណួរគន្លឹះ | ប្រភពព័ត៌មាន |
|---|---|---|
| | | អភិបាលកិច្ច<br>- ការពិនិត្យមើលការវាយតម្លៃសមត្ថភាព ក្រុង ស្រុក ខណ្ឌ (ប្រសិទ្ធភាពរបស់ គ.ក.ស.ក<br>- ការសម្ភាសន៍នានា |

### ២.១.២. លទ្ធផលរកឃើញសំខាន់ៗ

**នៅថ្នាក់ជាតិ**

**យុទ្ធសាស្ត្រយេនឌ័រនៃផអ៣ ភាគច្រើនមានលក្ខណៈទូទៅពេក ពុំបានកំណត់ឲ្យបានជាក់លាក់នូវយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមសមាសភាគនានានៃអនុកម្មវិធីនីមួយៗ**

ឧបសម្ព័ន្ធនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិស្តីពីការបញ្ជ្រាបយេនឌ័រសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំស្របតាមសមាសធាតុកម្មវិធីសំខាន់ៗទាំង៥នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ហើយសកម្មភាពអាទិភាពត្រូវបានឆ្លុះបញ្ចាំងបានត្រឹមត្រូវក្នុងឯកសារគោលទាំងនេះ។ ទោះបីយ៉ាងណាក៏ដោយ មានការទទួលស្គាល់ថា ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានការខ្វះចន្លោះដោយសារតែក្នុងសេចក្តីព្រាងដំបូងពុំបានបញ្ចូលបញ្ហាយេនឌ័រឡើយ ដោយហេតុថា នៅក្នុងលក្ខខណ្ឌការងាររបស់ក្រុមទីប្រឹក្សារៀបចំតាក់តែងកម្មវិធីជាតិនេះពុំបានកំណត់ឲ្យផ្តោតការយកចិត្តទុកដាក់អំពីអាទិភាពនៃបញ្ហាយេនឌ័រឡើយ។ លើសពីនេះទៀត នៅពេលរៀបចំតាក់តែងពីសមាសធាតុកម្មវិធីនៃកម្មវិធីជាតិទៅជាអនុកម្មវិធីនានានៃផអ៣ ទំនាក់ទំនងរវាងវិធានការនានានៃការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃយុទ្ធសាស្ត្រការបញ្ជ្រាបយេនឌ័ររបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣មានភាពខ្វះចន្លោះ។

យុទ្ធសាស្ត្រយេនឌ័រនៃផអ៣ បានកំណត់នូវអាទិភាពគោលនយោបាយចំនួន៤ ដែលប្រហាក់ប្រហែលនឹងសមាសភាគនានានៃសវនកម្មយេនឌ័រ ដូចជា ការបញ្ជ្រាបយេនឌ័រ ការអភិវឌ្ឍសមត្ថភាពសម្រាប់ការបញ្ជ្រាបយេនឌ័រ ការពង្រឹងភាពអង់អាចរបស់ស្ត្រី និងយុទ្ធសាស្ត្រទំនាក់ទំនងយេនឌ័រ។ សកម្មភាពសំខាន់ៗដែលកំណត់ក្នុងយុទ្ធសាស្ត្រយេនឌ័រនៃផអ៣មានលក្ខណៈទូទៅពេក ដោយពុំបានកំណត់ច្បាស់លាស់ថាតើអនុកម្មវិធីនានាត្រូវទទួលខុសត្រូវដូចម្តេចក្នុងសកម្មភាពនីមួយៗ។ ឯកសារឧបសម្ព័ន្ធយុទ្ធសាស្ត្រយេនឌ័រត្រូវបានរៀបចំ ក្រោយពេលរៀបចំឯកសារគោលរួចរាល់ និងសកម្មភាពឆ្លើយតបយេនឌ័រត្រូវបានបញ្ចូលទៅក្នុងផអ៣តាមក្រោយផងដែរ។ សកម្មភាពសំខាន់ៗជាច្រើនពុំបានឆ្លុះបញ្ចាំងបានឲ្យត្រឹមត្រូវនៅក្នុងទស្សនៈបញ្ជ្រាបយេនឌ័រនៃផអ៣ឡើយ ជាពិសេស សកម្មភាពពាក់ព័ន្ធនឹងអាទិភាពគោលនយោបាយទី៤ (គឺយុទ្ធសាស្ត្រទំនាក់ទំនងយេនឌ័រ)។

**ការវិភាគតម្រូវការ និងការព្រួយបារម្ភរបស់បុរស និងស្ត្រីនៅក្នុងអនុកម្មវិធីនីមួយៗពុំត្រូវបានអនុវត្ត**

ជំហានដំបូងក្នុងការបញ្ជ្រាបយេនឌ័រ គឺការវិភាគយេនឌ័រ (ដូចជា ការវិភាគតម្រូវការ និងការព្រួយបារម្ភរបស់បុរស ស្ត្រីនៅក្នុងបរិបទនៃគោលនយោបាយ ផែនការ កម្មវិធី គម្រោង កម្មវិធីបណ្តុះបណ្តាល និងសកម្មភាពផ្សេងៗ)។ រីឯបុគ្គលិកនៃស្ថាប័នអនុវត្តអនុកម្មវិធីនៅថ្នាក់ជាតិ ទទួលស្គាល់ថាពួកគេទទួលខុសត្រូវសម្រាប់ការបញ្ជ្រាបយេនឌ័រ ក៏ប៉ុន្តែពួកគេពុំទាន់ដឹងច្បាស់ថាតើត្រូវធ្វើដូចម្តេចក្នុងន័យបច្ចេកទេស (ដូចជា តើត្រូវធ្វើការវិភាគយេនឌ័រដូចម្តេច តើលទ្ធផលរកឃើញត្រូវបញ្ចូលក្នុងគោលនយោបាយ និងក្នុងផែនការដូចម្តេច? លើសពីនេះ បុគ្គលិកនៃស្ថាប័នអនុវត្តអនុកម្មវិធីតែងតែរៀបចំសេចក្តីព្រាងឯកសារមុនពេលធ្វើការពិគ្រោះយោបល់ ស្វែងរកធាតុចូលនានាពីអ្នកជំនាញយេនឌ័រ ដែលធ្វើឲ្យការបញ្ជ្រាបបញ្ហាយេនឌ័រគ្រាន់តែជាផ្នែកបន្ថែម ជាជាងការវិភាគនូវតម្រូវយេនឌ័រដែលចាំបាច់ត្រូវបញ្ចូលក្នុងឯកសារនានាទាំងនោះ ដូចជានៅពេលរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ហើយនៅពេលថ្មីៗនេះ គឺការរៀបចំឯកសារពន្យារពេលផអ៣សម្រាប់ឆ្នាំ២០១៤ជាដើម។

**ការបញ្ជ្រាបយេនឌ័រ នៅពុំទាន់មានសង្គតិភាពនៅក្នុងផែនការ ថវិកា និងរបាយការណ៍ផអ៣**

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ផអ៣(ឆ្នាំ២០១១) ពុំបានបញ្ជ្រាបយេនឌ័រ (ដោយសារឯកសារផអ៣ក៏ពុំបានបញ្ជ្រាបយេនឌ័រនៅពេលរៀបចំតាក់តែងដំបូង)។ ចំពោះផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១២ យេនឌ័រត្រូវបានបញ្ជ្រាបយ៉ាងទូលំទូលាយ ក៏ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏សកម្មភាពជាច្រើនដែលមានការបញ្ជ្រាបយេនឌ័រពុំត្រូវបានអនុវត្តឡើយ។ ក្រៅពីនេះរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១២ បានរាយការណ៍អំពីលទ្ធផលនៃការអនុវត្តធៀបនឹងលទ្ធផលរំពឹងនៃផអ៣ ហើយក៏ពុំបានធ្វើការប្រៀបធៀបទៅនឹងលទ្ធផលសកម្មភាពនៃការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ។

ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំឆ្នាំ២០១៣ អាទិភាពឆ្លើយតបទៅនឹងបញ្ហាយេនឌ័រត្រូវបានកំណត់នៅក្នុងអនុកម្មវិធីមួយចំនួន។ ក្នុងឆ្នាំ២០១៣ ការធ្វើសវនកម្មយេនឌ័រត្រូវបានកំណត់អាទិភាពមួយក្នុងចំណោមអាទិភាពទាំង១៩របស់កម្មវិធី (ចំណុចដៅ)។ ថវិកាសម្រាប់សវនកម្មយេនឌ័រជាលទ្ធផលមួយក្នុងការអនុវត្តយុទ្ធសាស្ត្រត្រួតពិនិត្យតាមដាន និងវាយតម្លៃ (រួមជាមួយការអង្កេតកិច្ចការអភិបាលកិច្ច ការវាយតម្លៃសមត្ថភាព និងការងារផ្សេងៗទៀត)។ ការរៀបចំតាក់តែងគោលនយោបាយថវិកាឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ នៅក្រោមក្របខ័ណ្ឌនៃអនុកម្មវិធីទី៤ ត្រូវបានរាយការណ៍ថា មានធនធានមិនគ្រប់គ្រាន់ និងធ្វើឲ្យមានការពន្យារពេលក្នុងការជ្រើសរើសទីប្រឹក្សា [6]។

[6] ក្នុងករណីពុំទាន់បានធ្វើបច្ចុប្បន្នភាពដំណើរការកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវពិចារណាតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលបានបង្កើតនាពេលថ្មីៗ និងការវិភាគនូវការព្រួយបារម្ភលើយេនឌ័រ ការរៀបចំតាក់តែងគោលនយោបាយថវិកាឆ្លើយតបយេនឌ័រ ហាក់ដូចជានៅពុំទាន់បានរៀបចំនៅឡើយ។ តើរៀបចំ ថវិកាដូចម្តេចបើពុំទាន់មានផែនការនៅឡើយ? ក្នុងបរិបទនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុទូលំទូលាយ ការផ្លាស់ ប្តូរទៅរកអភិក្រមផ្អែកលើកម្មវិធីគួរសម្របសម្រួលលើការគិតគូបញ្ហាយេនឌ័រឲ្យកាន់តែមានលក្ខណៈជាប្រព័ន្ធនៅក្នុងផែនការនិងថវិការបស់កម្មវិធី។ ទោះ

**ក្រុមការងារអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំមានដំណើរការពេញលេញដើម្បីគាំទ្រដល់ការកសាងផែនការ ថវិកា និងការអនុវត្តឆ្លើយតបយេនឌ័រ**

ជាគោលការណ៍ ក្រុមការងារអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រត្រូវជំរុញ និងគាំទ្រការបញ្ជ្រាបយេនឌ័រទៅក្នុងការតាក់តែងគោលនយោបាយ ការកសាងផែនការ ការវិភាជន៍ថវិកា ការអនុវត្ត និងការត្រួតពិនិត្យតាមដាន។ ចំពោះការអនុវត្តជាក់ស្តែង ក្រុមការងារអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រជាច្រើនមានសមត្ថភាពតិចតួចក្នុងការអនុវត្តតួនាទីរបស់ខ្លួន។ ករណីនេះត្រូវបានរកឃើញពិតប្រាកដនៅពេលធ្វើសវនកម្មអនុកម្មវិធីចំនួន២ គឺក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លើកលែងអនុកម្មវិធីទី៣ដែលក្រុមការងារអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ក្រសួងមុខងារសាធារណៈមានដំណើរការ និងមានទំនាក់ទំនងល្អជាមួយក្រុមការងារផអ៣។ ចំពោះលេខាធិកាដ្ឋាន គ.ជ.អ.ប ពុំបានរៀបចំបង្កើតក្រុមការងារអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រឡើយ។

**ការស្នើសុំធាតុចូលពីក្រសួងកិច្ចការនារីជាទូទៅធ្វើឡើងយឺតពេលក្នុងដំណើរការកសាងផែនការ និងការរៀបចំគោលនយោបាយ**

អនុកម្មវិធីនីមួយៗទទួលខុសត្រូវក្នុងការធានាថា យេនឌ័រត្រូវបានបញ្ជ្រាបទៅក្នុងអនុកម្មវិធីរបស់ខ្លួន។ ក្រសួងកិច្ចការនារីជាស្ថាប័នអនុវត្តទី៧នៃផអ៣ ទទួលខុសត្រូវក្នុងការផ្តល់ធាតុចូលលើការបញ្ជ្រាបបញ្ហាយេនឌ័រនៅក្នុងការតាក់តែងគោលនយោបាយ និងផែនការ ព្រមទាំងផ្តល់ការគាំទ្រការអភិវឌ្ឍសមត្ថភាព។ សេចក្តីព្រាងឯកសារគោលនយោបាយ និងឯកសាពាក់ព័ន្ធនានាដែលត្រូវបានរៀបចំដោយអនុកម្មវិធីនានាតែងតែមានការយឺតយ៉ាវក្នុងផ្ញើរមកក្រសួងកិច្ចការនារីដើម្បីផ្តល់យោបល់។ ឧទាហរណ៍ សេចក្តីព្រាងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤ ក្រសួងកិច្ចការនារីបានទទួលនៅថ្ងៃធ្វើសិក្ខាសាលាពិគ្រោះយោបល់តែម្តង។ ខ្លឹមសារពាក់ព័ន្ធយេនឌ័រជាទូទៅគ្រាន់តែជាផ្នែកបន្ថែមដោយមិនមែនជាការបញ្ជ្រាបស្របតាមការវិភាគយេនឌ័រនៅដំណាក់កាលដំបូងនៃកិច្ចដំណើរការរៀបចំតាក់តែងគោលនយោបាយ ឬដំណើរការកសាងផែនការ។

**ការផ្តល់ថវិកាតិចតួចសម្រាប់សកម្មភាពឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

ទោះបីក្រសួងកិច្ចការនារីត្រូវបានកំណត់ថាជាស្ថាប័នអនុវត្តផអ៣ក៏ដោយ ក៏ក្រសួងនេះទទួលថវិកាតិចតួចសម្រាប់គាំទ្រដល់សកម្មភាពពិគ្រោះយោបល់ និងប្រតិបត្តិការនានា បើប្រៀបធៀបជាមួយអនុកម្មវិធីផ្សេងៗទៀត។ នៅក្នុងលេខាធិការដ្ឋាន គ.ជ.អ.ប តំណែងទីប្រឹក្សាយេនឌ័រអន្តរជាតិត្រូវបានកាត់បន្ថយនៅក្នុងឆ្នាំ២០១៤ហើយទីប្រឹក្សាជាតិតែម្នាក់នឹងត្រូវផ្តល់ការគាំទ្រដល់អនុកម្មវិធីទាំង៦ រួមជាមួយនឹងមន្ត្រីរដ្ឋាភិបាល២នាក់នៃការិយាល័យអន្តរវិស័យ និងសហប្រតិបត្តិការនៃអង្គភាពវិភាគ និង

បីអនុកម្មវិធីទី៥(ប្រព័ន្ធកសាងកម្មវិធីវិនិយោគ និងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ) ដែលអនុវត្តដោយក្រសួងផែនការ ពុំបានបញ្ចូលនូវសវនកម្មយេនឌ័រ សមាហរណកម្មដំណើរការកសាងផែនការ និងថវិកា រួមមានទាំងការវិភាគយេនឌ័រ និងភាពជាតំណាងរបស់ស្ត្រីក្នុងដំណើរការផែនការ និងថវិកាគឺមានភាពចាំបាច់។

អភិវឌ្ឍន៍គោលនយោបាយ។ បុគ្គលិកទាំងនេះក៏ទទួលខុសត្រូវក្នុងការគាំទ្រដល់កិច្ចការរដ្ឋបាលជាច្រើនផ្សេងទៀតរបស់អង្គភាពផងដែរ។ ការផ្តល់ថវិកាភាគច្រើនសម្រាប់សកម្មភាពឆ្លើយតបទៅនឹងបញ្ហាយេនឌ័រទទួលបានពីគម្រោងដាច់ដោយឡែកៗដែលមិនមែនជាចំណែកពីកញ្ចប់ថវិការួមឡើយ។ ទោះបីជាមានការវិភាជន៍ថវិកាទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់រាជធានី ខេត្តដើម្បីគាំទ្រសកម្មភាពការបង្កើតបណ្តាញ និងការអភិវឌ្ឍសមត្ថភាព ក៏ដូចជាការគាំទ្រសេវាសង្គមក៏ដោយ ក៏អ្នកផ្តល់ព័ត៌មាននៅថ្នាក់ក្រោមជាតិបានផ្តល់ព័ត៌មានថា ថវិកានេះមានតិចតួច មិនគ្រប់គ្រាន់សម្រាប់ការគាំទ្រ និងលើសពីនេះទៀតការផ្ទេរថវិកាទាំងនេះមករដ្ឋបាលថ្នាក់ក្រោមជាតិតែងតែមានការយឺតយ៉ាវ។

**សូចនាករពាក់ព័ន្ធយេនឌ័រដែលមានក្នុងទិន្នន័យមូលដ្ឋានឃុំ សង្កាត់នៅមានកម្រិត**

សូចនាករនៃផលប៉ះពាល់ផ្នែកអភិវឌ្ឍដែលបានពិនិត្យមើល គឺរួមមាន៖ ពិន្ទុសម្រាប់គោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជាទី៣ និងទី៥ នៅក្នុងបណ្ណដាក់ពិន្ទុគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជានៃទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងពិន្ទុសម្រាប់ផ្នែកយេនឌ័រនៃបណ្ណដាក់ពិន្ទុតាមវិស័យ។ ជាមួយគ្នានេះដែរ សូចនាករនៃផលប៉ះពាល់លើកម្រិតស្ថាប័នការដែលបានពិនិត្យមើល គឺសមធម៌យេនឌ័រក្នុងសូចនាករអភិបាលកិច្ច និងប្រសិទ្ធភាពរបស់គ.ក.ស.ក។ ដោយលើកលែងសមធម៌យេនឌ័រក្នុងសូចនាករអភិបាលកិច្ច ពិន្ទុទាំងអស់ដែលបានរកឃើញគឺមានកម្រិតទាប។

## នៅថ្នាក់ក្រោមជាតិ

**ដំណើរការរៀបចំថវិកា និងការកសាងផែនការ មិនបានកំណត់បានពេញលេញនៅថ្នាក់ក្រុង ស្រុក ឬថ្នាក់ខេត្ត**

ដោយសារការកែសម្រួលដំណើរការកសាងផែនការ និងថវិកាមិនទាន់បានបញ្ចប់ ហេតុនេះនៃការបញ្ចូលទស្សនទានយេនឌ័រទៅក្នុងឯកសារនេះមិនទាន់មាននៅឡើយ។ ក្នុងការសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធបានបង្ហាញពីការព្រួយបារម្ភអំពីថា តើដំណើរការកសាងផែនការ (ដឹកនាំដោយអនុកម្មវិធីទី៥) និងដំណើរការរៀបចំថវិកា(ដឹកនាំដោយអនុកម្មវិធី៤)ដែលកំពុងត្រូវបានកែសម្រួលនឹងគាំទ្រដល់ការបញ្ចូលនូវបញ្ហាយេនឌ័រក៏ដូចជាពិចារណាលើតំណាងស្ត្រីនៅក្នុងដំណើរការកសាងផែនការ និងថវិកានៅថ្នាក់ក្រោមជាតិ ដែរឬទេ?។

**ការវិភាគយេនឌ័រធ្វើបានតិចតួចក្នុងការរៀបចំផែនការថ្នាក់ក្រោមជាតិ ហើយបញ្ហាយេនឌ័រ មិនត្រូវបានបញ្ជ្រាបឲ្យបានត្រឹមត្រូវក្នុងផែនការថ្នាក់ខេត្ត និងស្រុក**

ដូចដែលបានរកឃើញនៅថ្នាក់ជាតិដែរ ការវិភាគយេនឌ័របានធ្វើឡើងតិចតួចក្នុងការរៀបចំផែនការ។ ការពិនិត្យមើលឡើងវិញលើវិធានការនានាក្នុងការឆ្លើយតបទៅនឹងយេនឌ័រនៅក្នុងផែនការរាជធានីខេត្តត្រូវបានធ្វើឡើងតិចតួចតាមរយៈសកម្មភាពរបស់ក្រសួងកិច្ចការនារី ឬមន្ទីរកិច្ចការនារីរាជធានីខេត្ត។ អ្នកផ្តល់ព័ត៌មានបានលើកឡើងនូវការព្រួយបារម្ភអំពីការយល់ដឹងពីយេនឌ័រ និងការតាំងចិត្តរបស់តំណាងគ.ក.ស.ក ពីមន្ទីរ ឬការិយាល័យកិច្ចការនារីស្រុក ព្រមទាំងការបារម្ភអំពីសមត្ថភាពក្នុងការវិភាគយេនឌ័រ និងការគាំទ្រលើការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការថ្នាក់ក្រោមជាតិ។

**សកម្មភាពក្រសួងកិច្ចការនារី ឬមន្ទីរកិច្ចការនារី ដើរតួជាអ្នកផ្គត់ផ្គង់ជាជាងអ្នកឆ្លើយតបទៅនឹងតម្រូវការ**

សកម្មភាពក្រសួងកិច្ចការនារី ឬមន្ទីរកិច្ចការនារី ផ្តោតលើការពង្រឹងសមត្ថភាព និងការគាំទ្របណ្តាញក្រុមប្រឹក្សាជាស្ត្រី អភិបាលរងជាស្ត្រី និង គ.ក.ស.ក ក្នុងការកែប្រែឥរិយាបថដែលថាស្ត្រីគឺទទួលខុសត្រូវដោះស្រាយតែលើបញ្ហារបស់ស្ត្រី (រួមទាំងកុមារ)។ ក្នុងអំឡុងការបន្តគាំទ្រដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅតែត្រូវការ អ្នកផ្តល់ព័ត៌មាននៅថ្នាក់ក្រោមជាតិបានផ្តល់ព័ត៌មានអំពីតម្រូវការនៃការយល់ដឹងអំពីយេនឌ័រ និងការគាំទ្ររបស់ថ្នាក់ដឹកនាំនៅក្នុងរដ្ឋបាលរបស់ខ្លួន (សំដៅលើបុរស)។

**ការលំបាកក្នុងការទូទាត់ថវិកាសម្រាប់គម្រោងសេវាសង្គមនៅថ្នាក់ឃុំ សង្កាត់ និងសម្រាប់ការត្រួតពិនិត្យការងាររបស់គ.ក.ន.ក ដោយថ្នាក់ស្រុក ហើយការផ្ទេរថវិកាមានការយឺតយ៉ាវ**

នីតិវិធីទូទាត់ថវិកានៅថ្នាក់ឃុំ ពឹងផ្អែកលើការសហការពីស្មៀនឃុំ ហើយការទូទាត់ថវិកាសម្រាប់សកម្មភាពតូចៗមានការលំបាក។ តាមការរាយការណ៍ បញ្ហានេះបានកើតឡើងចាប់តាំងពីថវិកាឃុំសង្កាត់សម្រាប់សេវកម្មសង្គមដែលផ្តល់ថវិកាដោយអង្គការត្រូវផ្ទេរតាមរយៈរតនាគារជាតិ។ ការលំបាកទាំងនេះ ក៏ដោយសារសមត្ថភាពមានកម្រិតរបស់គ.ក.ន.ក និងជនបង្គោលយេនឌ័រក្នុងការរៀបចំឯកសារគាំទ្រដើម្បីជម្រះបញ្ជីចំណាយ ក៏ដូចជាការពុំសូវបានផ្តល់អាទិភាពលើការងារសេវាកម្មសង្គមរបស់ស្មៀនឃុំ។ម្យ៉ាងទៀតក៏មានការរាយការណ៍ពីការបង្វែរមូលនិធិឃុំ សង្កាត់សម្រាប់សេវាកម្មសង្គមទៅប្រើប្រាស់សម្រាប់គោលបំណងផ្សេង (ដូចជាធុងទឹក សម្រាប់ស្នាក់ការឃុំ ជាជាងសម្រាប់សហគមន៍)។ ថវិកាសម្រាប់ការត្រួតពិនិត្យតាមដានគ.ក.ន.ក របស់បុគ្គលិកស្រុកបានជួបប្រទះបញ្ហាដូចគ្នានៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួន។ ជាងនេះទៅទៀត ការផ្ទេរថវិកាមានការយឺតយ៉ាវ ដែលធ្វើឲ្យពេលវេលាសម្រាប់អនុវត្តសកម្មភាពមានរយៈពេលខ្លី។

**ការត្រួតពិនិត្យតាមដានផ្តោតលើទិន្នន័យនានាបង្ហាញពីភេទសម្រាប់អ្នកចូលរួមសិក្ខាសាលាឬការបណ្តុះបណ្តាលផ្សេងៗ**

ជាទូទៅ មានការយកចិត្តទុកដាក់តិចតួចលើការផ្លាស់ប្តូរការយល់ដឹង អត្តចរិក ឥរិយាបថ ជាពិសេសក្នុងចំណោមអ្នកធ្វើសេចក្តីសម្រេចជាបុរស។ ការត្រួតពិនិត្យតាមដានធ្វើសម្រាប់តែគោលបំណងធ្វើរបាយការណ៍ មិនបានប្រើប្រាស់សម្រាប់ណែនាំតម្រង់ទិស និងពង្រឹងការរៀបចំ និងអនុវត្តសកម្មភាពឡើយ។

**ដំណើរការរបស់គ.ក.ស.ក ត្រូវការពង្រឹងសមត្ថភាពបន្ថែមទៀត និងត្រូវការការគាំទ្ររបស់ថ្នាក់ដឹកនាំប្រកបដោយប្រសិទ្ធភាព**

គ.ក.ស.ក កំពុងមានដំណើរការ (ដូចជាកិច្ចប្រជុំបានទៀងទាត់) ក៏ប៉ុន្តែនៅពុំទាន់មានប្រសិទ្ធភាពល្អនៅឡើយ។ កិច្ចប្រជុំភាគច្រើនបង្ហាញតែពីរបាយការណ៍ និងការរីកចម្រើននានាពីសមាជិក គ.ក.ស.ក។

របាយការណ៍ក៏ពុំបានឆ្លុះបញ្ចាំងនូវការវិភាគច្បាស់លាស់អំពីការព្រួយបារម្ភចំពោះការងារយេនឌ័រក្នុងវិស័យនីមួយៗដែលរាយការណ៍ដោយសមាជិក គ.ក.ស.ក ឡើយ។ លើសពីនេះ ការចូលរួមរបស់មន្ទីរ និងការិយាល័យជំនាញនៅខ្សោយនៅឡើយ។

## ២.១.៣. អនុសាសន៍

**នៅថ្នាក់ជាតិ**

១.១. យុទ្ធសាស្ត្រយេនឌ័រសម្រាប់ផអ៣ដំណាក់កាលបន្ទាប់ គួររៀបចំ និងអនុវត្តតាមរចនាសម្ព័ន្ធ និងសមាសភាគនៃផអ៣

១.២. ធានាថាការទទួលខុសត្រូវរបស់ស្ថាប័នអនុវត្តសម្រាប់ការបញ្ជ្រាបយេនឌ័រ ត្រូវបានបញ្ចូលក្នុងការកិច្ចព្រមព្រៀងជាមួយស្ថាប័នអនុវត្ត

១.៣. ត្រូវបញ្ជ្រាបយេនឌ័រទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់អនុកម្មវិធីនីមួយៗ ដោយភ្ជាប់ជាមួយនូវឧបសម្ព័ន្ធនៃផែនការសកម្មភាពយេនឌ័រ ដែលកំណត់អំពីសកម្មភាពឆ្លើយតបទៅនឹងបញ្ហាយេនឌ័រក្នុងផែនការ (រៀបចំដោយអនុកម្មវិធី)

១.៤. មុនពេលរៀបចំតាក់តែងផអ៣ដំណាក់កាលបន្ទាប់ អង្គភាពនីមួយៗរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងអនុកម្មវិធីនានាគួរទទួលបានការបណ្តុះបណ្តាលអំពីការកំណត់ និងការវិភាគបញ្ហាយេនឌ័រក្នុងវិស័យរបស់ខ្លួនក៏ដូចជានៅក្នុងការតាក់តែងគោលនយោបាយផងដែរ

១.៥. ត្រូវមានការវិភាគសេចក្តីត្រូវការ និងការព្រួយបារម្ភរបស់ស្ត្រី និងបុរសចំពោះមុខងារដែលត្រូវផ្ទេរទៅថ្នាក់ក្រោមជាតិ

១.៦. ត្រូវពន្លឿនការបញ្ចប់សេចក្តីណែនាំស្តីពីការរៀបចំថវិកា និងការកសាងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធានាថាការវិភាគយេនឌ័រនៅថ្នាក់ក្រោមជាតិ ត្រូវបានបញ្ចូលក្នុងសេចក្តីណែនាំ ទស្សនទាននៃការឆ្លើយតបយេនឌ័រក៏ត្រូវបានបញ្ចូលក្នុងដំណើរការរៀបចំថវិកា និងការកសាងផែនការ ហើយដំណើរការនេះត្រូវបន្សុីគ្នាដើម្បីគាំទ្រដល់ការធ្វើឲ្យមានសមភាពយេនឌ័រនៅថ្នាក់ក្រោមជាតិ

១.៧. លេខាធិការដ្ឋានគ.ជ.អ.ប និងក្រសួងកិច្ចការនារីត្រូវធ្វើការរួមគ្នាដើម្បីរៀបចំតាក់តែង យុទ្ធសាស្ត្រពង្រឹងតួនាទីរបស់ក្រុមការងារបញ្ជ្រាបយេនឌ័រ ពាក់ព័ន្ធនឹងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់ដំណើរការកសាងផែនការ និងការរៀបចំតាក់តែងគោលនយោបាយ។ កិច្ចការនេះ រួមបញ្ចូលនូវស្ថាប័នអនុវត្តផអ៣នាបច្ចុប្បន្ន ក៏ដូចជាក្រសួងអាទិភាពមួយចំនួនដែលត្រូវធ្វើការផ្ទេរមុខងារទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ លេខាធិការដ្ឋានគ.ជ.អ.ប គួរពង្រឹងបន្ថែមលើបទពិសោធន៍របស់ក្រុមសវនកម្មយេនឌ័រ និងអនុសាសន៍នានារបស់សវនកម្មយេនឌ័រដើម្បីពង្រីកបន្ថែមនូវការយល់ដឹង និងការតាំងចិត្តចំពោះសមភាពយេនឌ័រតាមរយៈការអនុវត្តនូវអនុសាសន៍ដែលពាក់ព័ន្ធនានា

១.៨. ត្រូវស្វះស្វែងប្រមូលមតិយោបល់ពីក្រសួងកិច្ចការនារី អ្នកជំនាញយេនឌ័រនៅក្នុងដំណាក់កាលចាប់ផ្តើមដំបូងនៃដំណើរការកសាងផែនការ និងការរៀបចំតាក់តែងគោលនយោបាយនានា

១.៩. បង្កើនថវិកាសម្រាប់សកម្មភាពឆ្លើយតបទៅបនឹងបញ្ហាយេនឌ័រ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសសម្រាប់ពង្រឹងសមត្ថភាពដោយផ្តោតការយកចិត្តទុកដាក់ទៅលើៈ១).ការយល់ដឹងពីបញ្ហាយេនឌ័រសម្រាប់អ្នកធ្វើសេចក្តីសម្រេចទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិខេត្ត (ពិសេសបុរស) ២).ការពង្រឹងសមត្ថភាពដល់មន្ត្រីរាជការជាស្ត្រី ក្នុងនោះផ្តោតលើស្ត្រីដែលមានតំណែងក្នុងការធ្វើសេចក្តីសម្រេច ៣). ការពង្រឹងសមត្ថភាពក្រសួងកិច្ចការនារី លេខាធិការដ្ឋាន គ.ជ.អ.ប និងស្ថាប័នអនុវត្តដ៏ទៃទៀតក្នុងការវិភាគ និងការឆ្លើយតបចំពោះបញ្ហាយេនឌ័រ និង៤). ធានាឲ្យមានធនធានគ្រប់គ្រាន់នៅថ្នាក់មូលដ្ឋាន និងផ្ទេរធនធានថវិកាទាំងនោះឲ្យបានទាន់ពេលវេលាសម្រាប់ការអនុវត្តសកម្មភាពយេនឌ័រ

១.១០. ផ្តល់ថវិកាសម្រាប់ធ្វើសវនកម្មយេនឌ័រដល់អនុកម្មវិធីនានា និងរាជធានី ខេត្ត ក្រុង ស្រុក ក៏ដូចជាក្រសួងនានាដែលនឹងត្រូវផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិ ព្រមទាំងត្រូវមានឧបករណ៍សមស្របសម្រាប់ត្រួតពិនិត្យតាមដាន ដើម្បីធានាថា ការធ្វើសវនកម្មយេនឌ័រជួយលើកកម្ពស់ការយល់ដឹងអំពីបញ្ហានានាពាក់ព័ន្ធសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី ទាំងនៅតាមស្ថាប័ន និងជាលក្ខណៈបុគ្គល ព្រមទាំងជួយកំណត់នូវបទពិសោធន៍អនុវត្តល្អៗ។

១.១១. ធានាថាវិធានការនានាត្រូវបានប្រកាន់យកដើម្បីដោះស្រាយការព្រួយបារម្ភ ដែលបានបង្ហាញនៅក្នុងសូចនាករពាក់ព័ន្ធយេនឌ័រក្នុងគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា។

**នៅថ្នាក់ក្រោមជាតិ**

១.១២.ត្រូវប្រើប្រាស់គោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា នៅក្នុងទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និង ប័ណ្ណដាក់ពិន្ទុដើម្បីកំណត់អាទិភាពនៃបញ្ហានៅថ្នាក់ឃុំ ថ្នាក់ស្រុក ក្នុងដំណើរការកសាងផែនការ រួមទាំងបញ្ហាពាក់ព័ន្ធនឹងយេនឌ័រ។ បង្កើតដំណើរការសម្រាប់ធ្វើសុពលភាពទិន្នន័យមូលដ្ឋានឃុំ សង្កាត់។ សំណាកប័ណ្ណដាក់ពិន្ទុរបស់ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ មាននៅក្នុងឧបសម្ព័ន្ធទី៨

១.១៣.ត្រូវបង្កើតឧបករណ៍វិភាគយេនឌ័រ ដើម្បីណែនាំអំពីការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការរបស់មន្ទីរ ជំនាញ និងការិយាល័យស្រុក

១.១៤.ត្រូវបង្កើនការផ្តល់ថវិកាសម្រាប់ពង្រឹងសមត្ថភាពពាក់ព័ន្ធយេនឌ័រ ការបង្កើតបណ្តាញ និងការគាំទ្រនៅថ្នាក់ក្រោមជាតិ

១.១៥.ត្រូវបញ្ចូលនូវនីតិវិធីសម្រាប់ទូទាត់ថវិកាសម្រាប់សកម្មភាពតូចៗ (ដូចជាសេវាសង្គម សកម្មភាពត្រួតពិនិត្យតាមដានរបស់សមាជិកគ.ក.ន.ក)

១.១៦.ត្រូវធានានូវការផ្ទេរថវិកាទៅថ្នាក់ក្រោមជាតិបានទាន់ពេលវេលា

១.១៧.ត្រូវពង្រឹងសមត្ថភាពសមាជិក គ.ក.ន.ក ក្នុងការជម្រុះបញ្ជីទូទាត់ចំណាយសម្រាប់សេវាសង្គម ដោយសហការជាមួយស្មៀនឃុំ

១.១៨.ត្រូវពង្រឹងការប្រើប្រាស់ព័ត៌មានត្រួតពិនិត្យតាមដានពាក់ព័ន្ធយេនឌ័រនៅថ្នាក់ក្រោមជាតិបន្ថែម ក្រៅពីព័ត៌មានផ្ដោតលើចំនួនអ្នកចូលរួម មន្ត្រីរាជការតាមភេទ (ដូចជាការធ្វើតេស្តសាកល្បងមុន និងក្រោយវគ្គបណ្ដុះបណ្ដាល ការត្រួតពិនិត្យតាមដាន និងការវិភាគពីសូចនាករអភិវឌ្ឍសំខាន់ៗដែលពាក់ព័ន្ធបញ្ហាយេនឌ័រ)

១.១៩.ត្រូវពង្រឹងប្រសិទ្ធភាពរបស់គ.ក.ស.ក (សូមមើលអនុសាសន៍ក្នុងចំណុច២.២ ខាងក្រោម)

**យុទ្ធសាស្ត្ររយៈពេលវែង**

១.២០.នៅពេលដែលកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណើរការទៅមុខឆ្ពោះទៅរកការរៀបចំថវិកាកម្មវិធី ត្រូវមានការធានាថា បញ្ហាយេនឌ័រនៅថ្នាក់ក្រោមជាតិត្រូវបានបង្ហាញឲ្យបានសមស្របនៅក្នុងផែនការ និងថវិការបស់កម្មវិធី ដោយទទួលស្គាល់នូវភាពផ្សេងៗគ្នានៃស្ថានភាពអភិវឌ្ឍន៍ដែលអាចកើតឡើងនៅថ្នាក់ក្រោមជាតិ

១.២១.ត្រូវរៀបចំបង្កើតយន្តការសម្រាប់កំណត់ ទទួលស្គាល់ និងលើកទឹកចិត្តនូវបទពិសោធន៍នៃការអនុវត្តល្អ និងសមិទ្ធផលក្នុងការលើកកម្ពស់ និងការគាំទ្រសមភាពយេនឌ័រ និងការបង្កើតភាពអង់អាចរបស់ស្ត្រី ក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅគ្រប់កម្រិត (ឧទា. អនុកម្មវិធីនានា ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់) ក៏ដូចជាដល់បុគ្គលផងដែរ។

## ២.២. សមាសភាគទី២ ៖ ជំនាញបច្ចេកទេសពាក់ព័ន្ធយេនឌ័រ

### ២.២.១. អនុសមាសភាគ សំណួរគន្លឹះ និងប្រភពព័ត៌មាន

**សមាសភាគ២នៃសវនកម្មយេនឌ័រក្នុងអាទិភាព៥៖**

| អនុសមាសភាគ | សំណួរគន្លឹះ | ប្រភពព័ត៌មាន |
|---|---|---|
| ២.១.សមត្ថភាពបញ្ជ្រាបយេនឌ័រ(ទាំងបុគ្គល និងស្ថាប័ន) | – តើលោក លោកស្រីមានសមត្ថភាពកម្រិតណាដើម្បីបញ្ជ្រាបបញ្ហាយេនឌ័រនៅក្នុងការងាររបស់ខ្លួន?<br>– តើលោក លោកស្រីពិចារណាបញ្ហាយេនឌ័រទៅក្នុងការងារខ្លួនញឹកញាប់ប៉ុណ្ណា?<br>– តើអង្គភាពរបស់លោក លោកស្រីមានសមត្ថភាពកម្រិតណាក្នុងការវិភាគយេនឌ័រ និងបញ្ចូលទៅដំណើរការកសាងផែនការ? | – បញ្ជីសំណួរ<br>– កិច្ចសម្ភាសន៍ |
| ២.២.ការពង្រឹងសមត្ថភាព | – តើលោក លោកស្រីមានឱកាសក្នុងការ | – បញ្ជីសំណួរ |

| | | |
|---|---|---|
| វិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រទៅក្នុងការងារត្រួតពិនិត្យតាមដានកម្មវិធី | ពង្រឹងចំណេះដឹងអំពីបញ្ហាយេនឌ័រនៅក្នុងការជំនាញ និងបច្ចេកទេសរបស់ខ្លួនឬទេ?<br>– តើវគ្គបណ្តុះបណ្តាលមានប្រយោជន៍កម្រិត? | – កិច្ចសម្ភាសន៍ |
| ២.៣.ចំនួនវគ្គបណ្តុះបណ្តាល និងសម្ភារៈពាក់ព័ន្ធបញ្ហាយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ | – តើមានឧបករណ៍ និងបច្ចេកទេសគ្រប់គ្រាន់សម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងការងាររបស់លោក លោកស្រីដែរឬទេ?<br>– តើលោក លោកស្រីមានឧបករណ៍សម្រាប់វិភាគយេនឌ័រ និងបញ្ចូលការសន្និដ្ឋានទៅក្នុងការតាក់តែងកម្មវិធី និងសកម្មភាពដែរឬទេ? | – បញ្ជីសំណួរ<br>– កិច្ចសម្ភាសន៍ |
| ២.៤.ជំនាញសមត្ថភាពដើម្បីគាំទ្រការបញ្ជ្រាបសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី | – តើលោក លោកស្រីពិគ្រោះយោបល់ប៉ុន្មានដងជាមួយអ្នកជំនាញយេនឌ័រកាលពីឆ្នាំមុខ? តើលោក លោកស្រីពេញចិត្តកម្រិតណាពីការគាំទ្រទាំងនេះ(ដូចជាក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារី ការិយាល័យកិច្ចការនារី និងពីទីប្រឹក្សាយេនឌ័ររបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រុមការងារបញ្ជ្រាបយេនឌ័? | – បញ្ជីសំណួរ៖ ពាក់ព័ន្ធការប្រើប្រាស់ជំនាញយេនឌ័រ និងការពេញចិត្តជាមួយការគាំទ្រដែលទទួលបាន<br>– កិច្ចសម្ភាសន៍ |
| ២.៥.ការបញ្ជ្រាបសមភាពយេនឌ័រទៅក្នុងការអភិវឌ្ឍសមត្ថភាព | តើបញ្ហាពាក់ព័ន្ធយេនឌ័របានឆ្លុះបញ្ចាំងក្នុងការអភិវឌ្ឍសមត្ថភាពដែរឬទេ? | – ការពិនិត្យមើលឡើងវិញសៀវភៅ និងសេចក្តីណែនាំការអភិវឌ្ឍសមត្ថភាព |

### ២.២.២. លទ្ធផលរកឃើញសំខាន់ៗ

បញ្ហាមួយចំនួនពាក់ព័ន្ធសបច្ចេកទេសពាក់ព័ន្ធនឹងការងារយេនឌ័រ គឺមានប្រហាក់ប្រហែលគ្នាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖

**ការបណ្តុះបណ្តាលស្តីពីយេនឌ័រភាគច្រើនជាទ្រឹស្តី ប៉ុន្តែមានតម្រូវការឲ្យវគ្គបណ្តុះបណ្តាលផ្តោតលើការអនុវត្តជាក់ស្តែង**

អ្នកឆ្លើយសំណួរភាគច្រើនយល់ថា ពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបញ្ជ្រាបយេនឌ័រ ហើយស្វះស្វែងរកការគាំទ្រពីអ្នកជំនាញយេនឌ័ររបស់ក្រសួងកិច្ចការនារី លេខាធិការដ្ឋានគ.ជ.អ.ប

ប៉ុន្តែទោះយ៉ាងណាក៏ដោយពួកគេត្រូវការការណែនាំបន្ថែមទៀត និងត្រូវការការគាំទ្រដល់ការអនុវត្តតាមទ្រឹស្តី ក្នុងការទទួលខុសត្រូវជាក់លាក់របស់ពួកគេ។

**មានតម្រូវការបន្ថែមទៀតនូវការបណ្តុះបណ្តាល និងឯកសារពាក់ព័ន្ធសម្រាប់ការវិភាគ និងការបញ្ជ្រាបយេនឌ័រ**

ជារួម មានតម្រូវបន្ថែមទៀតនូវឧបករណ៍នានា (ដូចជា សេចក្តីណែនាំ សៀវភៅណែនាំ បញ្ជីផ្ទៀងផ្ទាត់) ដើម្បីគាំទ្រដល់ការបញ្ជ្រាបយេនឌ័រ នៅក្នុងកិច្ចការទទួលខុសត្រូវជាក់លាក់របស់ពួកគេ។

**ការបណ្តុះបណ្តាលស្តីពីយេនឌ័របានផ្តោតលើស្ត្រី ប៉ុន្តែបានផ្តោតតិចតួចសម្រាប់មន្ត្រីជាន់ខ្ពស់ក្នុងថ្នាក់ធ្វើសេចក្តីសម្រេច**

ការបណ្តុះបណ្តាលស្តីពីយេនឌ័របានផ្តោតលើមន្ត្រីជាស្ត្រី។ តាមរបាយការណ៍បានបង្ហាញថា មានតម្រូវការឲ្យមានការយល់ដឹងអំពីយេនឌ័រ និងការគាំទ្រពីមន្ត្រីជាន់ខ្ពស់ដែលជាអ្នកធ្វើសេចក្តីសម្រេច ដើម្បីលើកកម្ពស់ និងគាំទ្រដល់ការបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងផែនការ និងគោលនយោបាយនានា។

**គ្រូបង្គោលបណ្តុះបណ្តាល និងបុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាភាគច្រើនជាបុរស**

គ្រូបង្គោលបណ្តុះបណ្តាល និងបុគ្គលិកសម្របសម្រួលក្រុមប្រឹក្សាដែលភាគច្រើនជាបុរស បានលើកឡើងថា ពួកគេពុំបានយល់ពីច្បាស់លាស់អំពីបញ្ហាយេនឌ័រនៅក្នុងកិច្ចការរបស់ពួកគេឡើយ។ បញ្ហានេះ ដោយសារសមត្ថភាពវិភាគយេនឌ័ររបស់បុគ្គលិកបច្ចេកទេសនៅមានកម្រិតទាប។

**សមត្ថភាពរបស់ក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីស្រុក នៅមានកម្រិតដើម្បីឆ្លើយតបចំពោះលើការអភិវឌ្ឍសមត្ថភាព**

ក្រសួងកិច្ចការនារី មានបុគ្គលិកតិចតួចដែលមានបទពិសោធន៍ និងជំនាញក្នុងការបណ្តុះបណ្តាល និងគាំទ្រដល់មន្ត្រីជាន់ខ្ពស់ជាអ្នកធ្វើសេចក្តីសម្រេច ឬមន្ត្រីបច្ចេកទេសនៅថ្នាក់ជាតិ។ មន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីស្រុក ជួបប្រទះបញ្ហាទាំងនេះដូចនៅថ្នាក់ក្រសួងដែរ។ ជំនាញក្នុងការណែនាំលើកការវិភាគយេនឌ័រនៅទន់ខ្សោយ។

### ២.២.៣. អនុសាសន៍

**ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

២.១. ត្រូវផ្តល់វគ្គបណ្តុះបណ្តាលស្តីពី ការវិភាគយេនឌ័រដែលមានលក្ខណៈអនុវត្តជាក់ស្តែងដល់បុគ្គលិកបច្ចេកទេស

២.២. ត្រូវធានាថា អនុកម្មវិធីនានាមានលទ្ធភាពក្នុងការរៀនសូត្រពីអ្នកជំនាញបច្ចេកទេសយេនឌ័រ

២.៣. ត្រូវរៀបចំចងក្រងនូវវិធីសាស្រ្តសម្រាប់អនុវត្តជាក់ស្តែងស្តីពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅក្នុងការកសាងផែនការ ការរៀបចំថវិកា និងត្រួតពិនិត្យតាមដានក្នុងការអភិវឌ្ឍថ្នាក់ក្រោមជាតិ

២.៤. ដោយស្ត្រីមានចំនួនតិចតួចនៅក្នុង គ.ជ.អ.ប និងអនុគណៈកម្មការនានា ការពង្រឹងការយល់ដឹងអំពីយេនឌ័រ និងវេទយិតយេនឌ័ររបស់បុរសនៅក្នុងគណៈកម្មការទាំងនោះត្រូវចាត់ទុកជាអាទិភាពខ្ពស់

២.៥. ត្រូវផ្តល់វគ្គបណ្តុះបណ្តាលការយល់ដឹងពីយេនឌ័រ ដល់មន្ត្រីជាន់ខ្ពស់ដែលជាអ្នកធ្វើសេចក្តីសម្រេច នៅក្នុងស្ថាប័នអនុវត្ត (ស្ទើរទាំងអស់ជាបុរស) ផ្តោតលើសមាសភាគនានារបស់អនុកម្មវិធីនីមួយៗ

២.៦. ត្រូវផ្តល់វគ្គបណ្តុះបណ្តាល និងផ្តល់ការយល់ដឹងអំពីយេនឌ័រដល់ក្រុមប្រឹក្សាជាបុរស គណៈអភិបាល ប្រធានមន្ទីរជំនាញថ្នាក់ខេត្ត ការិយាល័យថ្នាក់ស្រុក (រួមទាំងសមាជិក គ.ក.ស.ក) និងមន្ត្រីជាន់ខ្ពស់នៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ

២.៧. ត្រូវធានាថាគ្រូបង្គោលអភិវឌ្ឍសមត្ថភាព និងបុគ្គលិកសម្របសម្រួលក្រុមប្រឹក្សា យល់ដឹងពីបញ្ហាយេនឌ័រលើបញ្ហាសំខាន់ៗនៅថ្នាក់ក្រោមជាតិ

២.៨. ត្រូវពង្រឹងសមត្ថភាពក្រសួងកិច្ចការនារីដើម្បីឆ្លើយតបចំពោះតម្រូវការអភិវឌ្ឍសមត្ថភាព និងផ្តល់ការគាំទ្រដល់តំណាងក្រសួងកិច្ចការនៅគ.ជ.អ.ប និងអនុគណៈកម្មការនានារបស់ខ្លួន

២.៩. ពង្រឹងសមត្ថភាពមន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីស្រុកដើម្បីឆ្លើយតបចំពោះ តម្រូវការអភិវឌ្ឍសមត្ថភាព

**យុទ្ធសាស្ត្ររយៈពេលវែង**

២.១០.ត្រូវធានាថា អ្នកជំនាញបច្ចេកទេសយេនឌ័រដែលមានលក្ខណសម្បត្តិសមស្របត្រូវបានផ្តល់ដល់ស្ថាប័នអនុវត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ (ដូចជា ពង្រឹងសមត្ថភាពក្រុមការងារបញ្ជ្រាបយេនឌ័រ ក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីគាំទ្រដល់អនុកម្មវិធីនានា ព្រមទាំងបញ្ចូលនូវជំនាញយេនឌ័រក្នុងក្រុមទីប្រឹក្សាសម្រាប់ការងារជាក់លាក់ណាមួយ)

២.១១.ត្រូវបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីសិក្សារបស់សាលាភូមិន្ទរដ្ឋបាល

២.១២.នៅពេលដែលមានបុគ្គលិកត្រូវបានតែងតាំង ឬជាប់ឆ្នោត ត្រូវធានាថាបុគ្គលិកទាំងនោះទទួលបាននូវវគ្គបណ្តុះបណ្តាលពាក់ព័ន្ធយេនឌ័រ។

**កំណត់សម្គាល់ ÷**

វគ្គបណ្តុះបណ្តាលស្តីពីយេនឌ័រ ត្រូវផ្តល់ទាំងសមាសភាគទី២នៃសវនកម្មយេនឌ័រ (ដូចជាសមត្ថភាពបច្ចេកទេសពាក់ព័ន្ធយេនឌ័រ) និងសមាសភាគទី៣(ដូចជាស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនិងការចាត់ចែងបុគ្គលិក)។ វគ្គបណ្តុះបណ្តាលស្តីពីយេនឌ័រក្នុងសមាសភាគទី២ដែលចង់ឲ្យធ្វើ គឺផ្តោតលើការពង្រឹងសមត្ថភាពបុគ្គលិកម្នាក់ៗ និងស្ថាប័នដើម្បីបញ្ចូលនូវផលប្រយោជន៍របស់ស្ត្រី និងបុរស (ដូចជាតម្រូវការផ្សេងៗនិងការព្រួយបារម្ភនានា) ទៅក្នុងគោលនយោបាយ កម្មវិធី និងសកម្មភាពនានា ដែលជាអាទិភាពដំបូងនៃអាទិភាពទាំងពីរនៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ។ ការងារនេះ រួមបញ្ចូលវគ្គបណ្តុះបណ្តាលការយល់ដឹងពីយេនឌ័រសម្រាប់ (ភាគច្រើនជាបុរស) អ្នកធ្វើសេចក្តីសម្រេច ការវិភាគ និងការ

បញ្ជ្រាបយេនឌ័រ នៅក្នុងវគ្គបណ្តុះបណ្តាលពីការកសាងផែនការ ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃដល់មន្ត្រីបច្ចេកទេស។ អនុសាសន៍លើការអភិវឌ្ឍសមត្ថភាពនៅក្នុងសមាសភាគទី៣ (ដូចបង្ហាញខាងក្រោម) ផ្តោតលើការពង្រឹងសមត្ថភាព និងការពង្រឹងភាពអង់អាចរបស់ស្ត្រីនៅក្នុងក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលរបស់ខ្លួនដែលជាអាទិភាពទី២នៃអាទិភាពទាំងពីរនៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ។

## ២.៣. សមាសភាគទី៣ ៖ ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំបុគ្គលិក

### ២.៣.១. អនុសមាសភាគ សំណួរគន្លឹះ និងប្រភពព័ត៌មាន

សមាសភាគទី៣នៃសវនកម្មយេនឌ័រផ្តោតលើបួនផ្នែកដូចខាងក្រោម ៖

| អនុសមាសភាគ | សំណួរគន្លឹះ | ប្រភពព័ត៌មាន |
|---|---|---|
| ៣.១.ភាគរយស្ត្រីនៅក្នុងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (និងនៅក្នុងអនុកម្មវិធីទី១) | - តើសមាជិកក្រុមប្រឹក្សាជាស្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនប៉ុន្មាននាក់?<br>- តើសមាជិកក្រុមប្រឹក្សាសរុបមានចំនួនប៉ុន្មាននាក់? | - សម្ភាសន៍ |
| ៣.២.ភាគរយស្ត្រីនៅក្នុងកម្រិតអ្នកធ្វើសេចក្តីសម្រេចចិត្តជាន់ខ្ពស់ | - តើមានស្ត្រីនៅក្នុងក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្តជាន់ខ្ពស់ចំនួនប៉ុន្មាននាក់?<br>- តើចំនួនមន្ត្រីដែលស្ថិតនៅក្នុងមុចតំណែងនេះសរុបចំនួនប៉ុន្មាន?<br>**កំណត់សម្គាល់ ៖**<br>- អនុកម្មវិធី ៖ មុខតំណែងប្រធាននាយកដ្ឋាន/អង្គភាព<br>- រដ្ឋបាលរាជធានី ខេត្ត ៖ មុខតំណែងនាយកទីចាត់ការ<br>- រដ្ឋបាលក្រុងស្រុកខណ្ឌ ៖ មុខតំណែងប្រធានការិយាល័យ | - ទិន្នន័យរបស់រដ្ឋបាល<br>- សម្ភាសន៍ |
| ៣.៣.ភាគរយស្ត្រីនៅក្នុងមុខតំណែងគ្រប់គ្រងថ្នាក់មធ្យម និងមុខតំណែងមន្ត្រីជំនាញ | - តើមានស្ត្រីប៉ុន្មាននាក់ស្ថិតនៅក្នុងមុខតំណែងគ្រប់គ្រងថ្នាក់មធ្យម និងមុខតំណែងមន្ត្រីជំនាញ?<br>- តើមានមន្ត្រីសរុបទាំងអស់ចំនួនប៉ុន្មាននាក់?<br>**កំណត់សម្គាល់ ៖**<br>- អនុកម្មវិធី ៖ មុខតំណែងអនុប្រធាននាយកដ្ឋាន | - ទិន្នន័យរបស់រដ្ឋបាល<br>- សម្ភាសន៍ |

| អនុសមាសភាគ | សំណួរគន្លឹះ | ប្រភពព័ត៌មាន |
|---|---|---|
| | ឬអង្គភាព និងមន្ត្រី<br>- រដ្ឋបាលរាជធានី ខេត្ត ៖ មុខតំណែងនាយករង ទីចាត់ការ និងមន្ត្រី<br>- រដ្ឋបាលក្រុងស្រុកខណ្ឌ ៖ មុខតំណែងអនុប្រធានការិយាល័យ និងមន្ត្រី | |
| ៣.៤.ការយល់ដឹងអំពីយេនឌ័រ និងបញ្ហាយេនឌ័រក្នុងការគ្រប់គ្រងធនធានមនុស្សជាក់ស្តែង | - តើអ្នកយល់ថា ការលើកកម្ពស់សមភាពយេនឌ័រ គឺជាចំណុចសំខាន់ក្នុងដំណើរការតែងតាំង ឬ តម្លើងថ្នាក់ដល់មន្ត្រីដែរឬទេ?<br>- តើការយល់ដឹងអំពីយេនឌ័រ និងការកំណត់អំពីការយកចិត្តទុកដាក់ផ្នែកយេនឌ័រ គឺជាអាទិភាពដែលត្រូវកំណត់ក្នុងល័ក្ខខ័ណ្ឌការងារលម្អិតរបស់មន្ត្រីដែរឬទេ?<br>- តើមានបុរេសកម្មភាពអ្វីខ្លះ ដែលត្រូវអនុវត្តក្នុងការជ្រើសរើសមន្ត្រីជាស្ត្រី?<br>- តើមានការអនុវត្តស្មើភាពគ្នារវាងបុរស និងស្ត្រីដែរឬទេ (ពាក់ព័ន្ធនឹងការតម្លើងថានៈ)? | - បញ្ជីសំណួរ<br>- ពិនិត្យឯកសារ<br>- សម្ភាសន៍ |

**២.៣.២. របកគំហើញចម្បងៗ**

ទោះបីជា ជាទូទៅការអនុវត្តការគ្រប់គ្រងធនធានមនុស្សបានបង្ហាញឲ្យឃើញថា មានការយល់ដឹង និងយកចិត្តទុកដាក់ខ្លាំងអំពីបញ្ហាយេនឌ័រក៏ដោយ ក៏នៅមានបញ្ហាមួយចំនួន ដែលនាំឲ្យសមាសភាគនេះទទួលបានពិន្ទុទាបក្នុងការធ្វើសវនកម្មយេនឌ័រ។ តាមរយៈការស្រាវជ្រាវនេះបានបង្ហាញឲ្យឃើញថា ស្ត្រីទទួលបានការអប់រំតិចតួចទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត ក្រៅពីឧបសគ្គផ្នែកអប់រំ ភាពលម្អៀងផ្នែកវប្បធម៌បាននាំឲ្យទាំងបុគ្គល និងស្ថាប័នមានការយល់ឃើញថា កិច្ចការជាបឋមដែលសមស្របសម្រាប់ស្ត្រី គឺមុខដំណែងក្នុងការងាររដ្ឋបាល និងហិរញ្ញវត្ថុ ហើយកម្រឃើញមានមន្ត្រីជាំស្ត្រីក្នុងមុខតំណែងជាអ្នកធ្វើសេចក្តីសម្រេចជាន់ខ្ពស់ណាស់។

**ថ្នាក់ជាតិ**

**ស្ត្រីមានចំនួនតិចតួចបំផុតនៅក្នុង គ.ជ.អ.ប និងអនុគណៈកម្មាធិការនានា**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) និងអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប មានសមាជិកជាស្ត្រីតែមួយរូបៗប៉ុណ្ណោះ (ស្ត្រីមួយរូបៗនោះ គឺជាតំណាងមកពីក្រសួងកិច្ចការនារី)។

**ស្ត្រីមានចំនួនតិចតួចណាស់នៅក្នុងថមុខតំណែងធ្វើសេចក្តីសម្រេចចិត្តរបស់ស្ថាប័នអនុវត្តអនុកម្មវិធីនីមួយៗ**

នៅតាមអនុកម្មវិធីនីមួយៗ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន ឬប្រធានអង្គភាពឡើងទៅមានចំនួនស្ត្រីតិចតួចបំផុត។ ប៉ុន្តែភាគរយស្ត្រីនៅមុខតំណែងគ្រប់គ្រងថ្នាក់មធ្យម និងមន្ត្រីជំនាញមានចំនួនច្រើនជាង។ ផ្អែកតាមការសម្ភាសន៍ សមត្ថភាព និងទំនុកចិត្តរបស់ស្ត្រីកាន់មុខតំណែងជាន់ខ្ពស់ក៏មានលក្ខណៈសមស្របតាមស្ថានភាពខាងលើផងដែរ។

**ស្ត្រីហាក់ដូចជាត្រូវបានជ្រើសរើស និងតម្លើងមុខតំណែងតាមតួនាទីដែលជាប្រពៃណីការងាររបស់ស្ត្រី និងមានចំនួនស្ត្រីតិចតួចណាស់បានស្នើសុំបំពេញការងារផ្នែកបច្ចេកទេស**

បុគ្គលិកជាស្ត្រីនៃស្ថាប័នអនុវត្តអនុកម្មវិធីនីមួយៗត្រូវបានជ្រើសរើស និងតម្លើងមុខតំណែងនៅក្នុងការងាររដ្ឋបាល និងហិរញ្ញវត្ថុ និងមុខតំណែងនានាដែលពាក់ព័ន្ធនឹងការងារយេនឌ័រ។ ពាក់ព័ន្ធនឹងសំណួរដែលសួរថា ហេតុអ្វីបានជាមានស្ត្រីតិចតួចបម្រើការងារក្នុងផ្នែកបច្ចេកទេស ជាទូទៅចម្លើយគឺដោយសារតែមានចំនួនស្ត្រីតិចតួចប៉ុណ្ណោះបានដាក់ពាក្យស្នើសុំបំពេញការងារបច្ចេកទេសនេះ។ ភាពខុសគ្នាផ្នែកយេនឌ័រនៅក្នុងការអប់រំកម្រិតខ្ពស់ ព្រមទាំងភាពខុសគ្នានៅកន្លែងការងារ ការប្រកួតប្រជែងរវាងស្ថានប័ន ឬអង្គភាពផ្សេងៗក្នុងការជ្រើសរើសស្ត្រីដែលមានសមត្ថភាព ព្រមទាំងការជ្រើសរើសមុខវិជ្ជាដែលត្រូវសិក្សា និងប្រភេទការងារដែលធ្វើដោយផ្អែកតាមផ្នត់គំនិតយេនឌ័រ គឺតែងតែឆ្លុះបញ្ចាំងទៅនឹងភាពលម្អៀងខាងវប្បធម៌ជាមូលដ្ឋាន ដែលចាំបាច់ត្រូវតែមានដំណោះស្រាយសមស្របដើម្បីឲ្យមានសមភាពក្នុងការរៀបចំមន្ត្រី បុគ្គលិក។

**ពុំមានសកម្មភាពត្រៀមសម្រាប់ការជ្រើសរើស និងការតម្លើងមុខតំណែងដល់ស្ត្រី**

ទោះបីជាមានការទទួលស្គាល់ថា ចាំបាច់ត្រូវបង្កើនចំនួនស្ត្រីឲ្យមានសមភាពយេនឌ័រនៅកន្លែងធ្វើការក៏ដោយ ក៏អនុកម្មវិធីនីមួយៗ ពិសេសអនុកម្មវិធីទី២ និងទី៤ យល់ឃើញថា មានការត្រៀមទុកជាមុនបានតិចតួចប៉ុណ្ណោះ ក្នុងការជ្រើសរើស និងតម្លើងមុខតំណែងដល់ស្ត្រីឲ្យបានច្រើននៅក្នុងអនុកម្មវិធីរបស់ខ្លួន។

**អាទិភាពផ្នែកយេនឌ័រពុំត្រូវបានដាក់បញ្ចូលឲ្យបានសមស្របនៅក្នុងល័ក្ខខ័ណ្ឌការងារលម្អិតរបស់មន្ត្រី និងទីប្រឹក្សា**

ទោះបីជាមានការទទួលស្គាល់ជាទូទៅថា ការយល់ដឹងអំពីយេនឌ័រ គឺជាបញ្ហាអាទិភាពនៅក្នុងអាណត្តិនៃផអពក៏ដោយ ក៏ការដាក់បញ្ចូលយេនឌ័រទៅក្នុងល័ក្ខខ័ណ្ឌការងារលម្អិតរបស់មន្ត្រី និងទីប្រឹក្សាមិនទាន់បានសមស្របនៅឡើយទេ។ ជាមួយគ្នានេះ គណៈកម្មការជ្រើសរើសបុគ្គលិកក៏ត្រូវបានចាត់ចែងដោយបុរសផងដែរ។

**នៅថ្នាក់ក្រោមជាតិ**

**សមាជិកក្រុមប្រឹក្សាជាស្ត្រីមានចំនួនតិចតួច**

ជាមធ្យម សមាជិកក្រុមប្រឹក្សាជាស្ត្រីនៅខេត្តចំនួន០៤ និងស្រុកចំនួន០៤ ដែលបានធ្វើសវនកម្ម

យេនឌ័រមានចំនួនតិចជាង២០%។ ប្រធានក្រុមប្រឹក្សាទាំងអស់ គឺជាបុរស។ លើសពីនេះ មានតែសមាជិកក្រុមប្រឹក្សាជាស្ត្រីមួយរូបប៉ុណ្ណោះ បានបំពេញតួនាទីជាប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារដែលគណៈកម្មាធិការនេះគឺជាតំណាងឲ្យស្ត្រី និងកុមារនៅក្នុងគ្រប់ទិដ្ឋភាពនានាពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រនៅក្នុងគណៈកម្មាធិការផ្សេងៗ ព្រមទាំងការគាំទ្រ និងការត្រួតពិនិត្យ គ.ក.ស.ក និងឬ គ.ក.ន.ក។ ហេតុនេះ គ.ក.ស.ក នៅសល់ពេលវេលាតិចតួចប៉ុណ្ណោះសម្រាប់ជួយក្រុមប្រឹក្សាក្នុងកិច្ចការផ្សេងទៀត។

**រដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនស្ត្រីតិចតួចក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្ត**

ជាមធ្យម ចំនួនស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្តជាន់ខ្ពស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនតិចជាង២០%។ មន្ត្រីរាជការជាស្ត្រីបានបំពេញតួនាទីជាបឋមក្នុងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ។

**រដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនស្ត្រីតិចតួចបានដាក់ពាក្យស្នើសុំបំពេញការងារ**

នៅរដ្ឋបាលថ្នាក់ក្រោមជាតិមានចំនួនស្ត្រីតិចតួចបានដាក់ពាក្យស្នើសុំបំពេញការងារ។ បេក្ខនារីទាំងនោះមានសមត្ថភាពសម្រាប់តែមុខតំណែងទាបៗប៉ុណ្ណោះ។ លើសពីនេះទៀត រដ្ឋបាលខេត្ត និងក្រុង ស្រុក មានភាពទន់ខ្សោយក្នុងការត្រៀមជ្រើសរើសស្ត្រីឲ្យបានចូលបម្រើការងារនៅក្នុងរដ្ឋបាលរបស់ខ្លួន។

**ការព្រួយបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួនអាចបង្កើតនូវភាពលំអៀងក្នុងការធ្វើសេចក្តីសម្រេចចិត្តតែងតាំងដំឡើងមុខតំណែងស្ត្រី ប្រសិនបើមុខតំណែងនោះតម្រូវឲ្យចុះអនុវត្តការងារនៅតាមមូលដ្ឋាន**

ដោយសារការបារម្ភអំពីសុវត្ថិភាព ប្រធានដែលជាបុរសតែងតែមើលរំលងបេក្ខនារីសម្រាប់ការតម្លើងមុខតំណែង ប្រសិនបើមុខតំណែងនោះត្រូវចុះបំពេញការងារនៅតាមមូលដ្ឋាន ដោយមិនបានពិគ្រោះពិភាក្សាជាមួយសាមីខ្លួនម្នាក់ៗឡើយ។

### ២.៣.៣. អនុសាសន៍

**សម្រាប់ថ្នាក់ជាតិ**

**នៅថ្នាក់ជាតិ៖**

៣.១. ត្រូវបង្កើតជម្រើសនានាសម្រាប់លើកកម្ពស់សមត្ថភាពជំនាញ និងទំនុកចិត្តរបស់បុគ្គលិកជាស្ត្រី ដើម្បីឲ្យបុគ្គលិកជាស្ត្រីមានសមត្ថភាពក្នុងការទទួលបាននូវការតម្លើងមុខដំណែង និងតួនាទីនៅតាមអនុកម្មវិធីនីមួយៗ (ដូចជាវគ្គបណ្តុះបណ្តាលស្តីពីស្ត្រីក្នុងភាពជាអ្នកដឹកនាំសម្រាប់សិក្ខាកាមជាស្ត្រីមកពីអនុកម្មវិធីនានា ការចុះឈ្មោះចូលរៀននៅសាលាភូមិន្ទរដ្ឋបាល ការផ្តល់អាទិភាពឲ្យស្ត្រីបានទទួលអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាលរយៈពេលវែងទាំងក្នុង និងក្រៅប្រទេសជាដើម)

៣.២. ត្រូវបង្កើតជម្រើសនានាសម្រាប់ការត្រៀមសកម្មភាពក្នុងការទាក់ទាញ និងជ្រើសរើសឲ្យបានស្ត្រីកាន់តែច្រើននៅតាមអនុកម្មវិធីនីមួយៗ ដោយរួមបញ្ចូលទាំងមុខតំណែងដែលមិនមែនជា

មុខតំណែងប្រពៃណីការងាររបស់ស្ត្រី (ដូចជា ការកំណត់ចំនួនកូតាបុគ្គលិកស្ត្រីចន្លោះ២០%-៥០% ពិនិត្យលើតម្រូវការសមត្ថភាពសម្រាប់មុខតំណែងនីមួយៗ ដើម្បីឲ្យសមត្ថភាពរបស់ស្ត្រីដែលមានលក្ខណៈសមស្របអាចមកជំនួសតម្រូវការសមត្ថភាពជាក់លាក់ដែលបានកំណត់ ប្រើប្រាស់យន្តការនានាសម្រាប់ការផ្សព្វផ្សាយជ្រើសរើសបុគ្គលិក បន្ថែមលើសពីការផ្សព្វផ្សាយតាមកាសែត និងគេហទំព័រ ដូចជា តាមរយៈសាកលវិទ្យាល័យ ឬការជ្រើសរើសដោយកំណត់យកស្ត្រីណាម្នាក់ដោយផ្ទាល់តែម្តង)។

៣.៣. ត្រូវធានាថា តម្រូវការយេនឌ័រ ត្រូវបានដាក់បញ្ចូលយ៉ាងស៊ីសង្វាក់គ្នាទៅក្នុងលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក ឬទីប្រឹក្សានានា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសបុគ្គលិក គួរដាក់បញ្ចូលទាំងចំណេះដឹង និងវេទយិតយេនឌ័រផងដែរ។ ល័ក្ខខ័ណ្ឌការងាររបស់មន្ត្រី និងទីប្រឹក្សាគួរតែដាក់បញ្ចូលផងដែរនូវវិធានការនានាដើម្បីធានាថា តម្រូវការបុរស និងស្ត្រីត្រូវបានផ្តោតនៅក្នុងការទទួលខុសត្រូវលើការអនុវត្តការងារ ។ ត្រូវធានាថា មានតំណាងស្ត្រីនៅក្នុងគណៈកម្មការជ្រើសរើសបុគ្គលិក។

**សម្រាប់ថ្នាក់ក្រោមជាតិ**

៣.៤. ត្រូវជំរុញលើកទឹកចិត្តដល់គ្រប់គណបក្សនយោបាយទាំងអស់ ដើម្បីដាក់បញ្ចូលចំនួនស្ត្រីបន្ថែម នៅតាមលេខរៀងផ្នែកខាងលើៗនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលនឹងត្រូវធ្វើឡើងក្នុងពេលឆាប់ៗខាងមុខនេះ ឬក៏ត្រូវមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលមានឈ្មោះបេក្ខជនជាស្ត្រី និងបេក្ខជនបុរសឆ្លាស់គ្នា។

៣.៥. ត្រូវសិក្សាអំពីទំនាក់ទំនងរវាងអត្រានៃភាពជាតំណាងរបស់ស្ត្រី នៅក្នុងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយនឹងសូចនាករនៃលទ្ធផលនៃការអភិវឌ្ឍឃុំ សង្កាត់ពិសេសលទ្ធផលនៃការអភិវឌ្ឍដែលឆ្លើយតបទៅនឹងបញ្ហា តម្រូវការរបស់ស្ត្រី និងកុមារ។

៣.៦. ត្រូវបញ្ចូលការពង្រឹង និងការគាំទ្រដល់ក្រុមប្រឹក្សាជាស្ត្រីនៅថ្នាក់ក្រោមជាតិទៅក្នុងក្នុងការរៀបចំ និងការអនុវត្តការអភិវឌ្ឍសមត្ថភាពរបស់សម្ព័ន្ធភាពសមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (អនុកម្មវិធីទី៦)។ ពិគ្រោះ ពិភាក្សាជាមួយវិទ្យាស្ថានសភានៃកម្ពុជា (PIC) អំពីទស្សនៈ និងការយល់ឃើញអំពីការបង្កើនការយល់ដឹងផ្នែកយេនឌ័រ និងការទទួលខុសត្រូវរបស់រដ្ឋសភាជាតិ និងព្រឹទ្ធសភា។

៣.៧. ត្រូវស្វែងរកជម្រើសសម្រាប់កែលំអនូវជំនាញនានា និងបង្កើននូវភាពជឿជាក់របស់មន្ត្រីជាស្ត្រី ដើម្បីឲ្យមន្ត្រីជាស្ត្រីទាំងនោះអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការតែងតាំងសម្រាប់មុខតំណែងជាន់ខ្ពស់នានា (ឧទាហរណ៍៖ ការបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំរបស់ស្ត្រីដល់មន្ត្រី បុគ្គលិកជាស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, ការបង្កលក្ខណៈងាយស្រួលសដល់មន្ត្រី បុគ្គលិក

ជាស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរៀននៅសាលាភូមិន្ទរដ្ឋបាល, ផ្តល់អាទិភាពដល់មន្ត្រី បុគ្គលិកជាស្ត្រីសម្រាប់ឱកាសការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងស្រុក និងអាហារូបករណ៍ទៅសិក្សានៅបរទេស)។

៣.៨. ត្រូវបង្កើតជម្រើសនានាសម្រាប់សកម្មភាពត្រៀមទុកជាមុនក្នុងការទាក់ទាញ និងជ្រើសរើសឲ្យបានស្ត្រីកាន់តែច្រើននៅតាមអនុកម្មវិធីនីមួយៗ ដោយរួមបញ្ចូលទាំងមុខតំណែងដែលមិនមែន ជាមុខតំណែងប្រពៃណីការងាររបស់ស្ត្រី (មើលចំណុច ៣.២.ខាងលើ)

៣.៩. បេក្ខជនជាស្ត្រីគួរមានឱកាសក្នុងការពិភាក្សាដោយផ្ទាល់អំពីការតម្លើងតួនាទីរបស់ខ្លួន ក្នុងករណីដែលតួនាទីថ្មីនោះមានបញ្ហាផ្នែកសុវត្ថិភាព។

**យុទ្ធសាស្ត្ររយៈពេលវែង**

៣.១០. សម្រាប់រយៈពេលវែង ដើម្បីបង្កើនចំនួនស្ត្រីដែលមានសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ គឺត្រូវបង្កើនកម្រិតនៃការអប់រំដល់ស្ត្រីនៅក្នុងការអនុវត្តការងារ។ កិច្ចការនេះ តម្រូវឲ្យមានវិធានការត្រៀមទុកជាមុនសម្រាប់ការជ្រើសរើស ការតម្លើងតួនាទី និងការគាំទ្រដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ លើសពីនេះទៀត ត្រូវធ្វើយ៉ាងណាឲ្យកុមារីបន្តការសិក្សាឲ្យបានខ្ពស់។

## ២.៤. សមាសភាពទី៤ ÷ បញ្ហាយេនឌ័រនៅក្នុងស្ថាប័ននិងឧស្សាហៈយល់ដឹងលើសមិទ្ធិផលសម្រេចបានទាក់ទងនឹងសមភាពយេនឌ័រ

### ២.៤.១. អនុសមាសភាគ សំណួរគន្លឹះ និងប្រភពព័ត៌មាន

ក្នុងសមាសភាពទី៤នេះ សវនកម្មយេនឌ័រផ្តោតលើ :

| អនុសមាសភាគ | សំណួរគន្លឹះ | ប្រភពព័ត៌មាន |
|---|---|---|
| ៤.១.ការយល់ឃើញអំពីភាពចាំបាច់នៃសមភាព យេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី | - តើអ្នកគិតថា វាមានភាពចាំបាច់យ៉ាងដូចម្តេច ដែលរាជរដ្ឋាភិបាលកម្ពុជា គ.ជ.អ.ប បានយកចិត្តទុកដាក់ក្នុងការសម្រេចឲ្យបាននូវគោលបំណងរួមនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ?<br>- តើយុទ្ធសាស្ត្រយេនឌ័រនៅក្នុងផអ៣ មានសារសំខាន់យ៉ាងដូចម្តេចដល់ស្ថាប័នរបស់អ្នកក្នុងការសម្រេចឲ្យ បានគោលបំណងរួមរបស់ខ្លួន? | - បញ្ជីសំណួរ |
| ៤.២. ភាពដូចគ្នានៅក្នុងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិ | - តើអ្នកបានអានឧបសម្ព័ន្ធនៃឯកសារកម្មវិធីជាតិស្តីពីការបញ្ជ្រាបយេនឌ័រ ឬយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុង ផអ៣ ដែរឬទេ? | - បញ្ជីសំណួរ |

| អនុសមាសភាគ | សំណួរគន្លឹះ | ប្រភពព័ត៌មាន |
|---|---|---|
| បតេយ្យនៅថ្នាក់ក្រោមជាតិ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុង ផអ៣ | - តើយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុង ផអ៣ បានផ្តល់ការណែនាំច្បាស់អំពីរបៀបបញ្ចូលសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីនៅក្នុងការងាររបស់អ្នកដែរឬទេ?<br>- តើអនុសាសន៍ណាខ្លះ ដែលបានបញ្ចូលក្នុងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ ផអ៣? (ជម្រើសចំនួន៤/៣ ត្រឹមត្រូវ) | |
| ៤.៣.ការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងកន្លែងធ្វើការងារ | - តើអ្នកអាចផ្តល់ពិន្ទុលើវិធីសាស្ត្រដែលស្ថាប័នរបស់អ្នកបានអនុវត្តដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងការធ្វើឲ្យមានជម្រើសផ្សេងៗគ្នា ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ព្រមទាំងការគោរពលើឥរិយាបថ ក្រមសីលធម៌ការងារ និងការចែករំលែកព័ត៌មាននានាយ៉ាងដូចម្តេច?<br>- តើស្ថាប័នរបស់អ្នកបានអនុវត្តគ្រប់គ្រាន់ក្នុងការពុំលើកទឹកចិត្តឲ្យមានការនិយាយអំពីវិសមភាពយេនឌ័រ (ដូចជា ផ្ទាំងរូបភាព ការផ្តល់យោបល់ការនិយាយកំប្លែងផ្តេសផ្តាស និងតាមរយៈគេហទំព័រជាដើមដែលបង្ហាញពីការមិនគោរពដល់ស្ត្រី<br>- តើអ្នកបានយកចិត្តទុកដាក់កម្រិតណាក្នុងការធានាឲ្យមានការគោរពរវាងស្ត្រី និងបុរសក្នុងកន្លែងធ្វើការងារ?<br>- តើអ្នកឯកភាព ឬមិនឯកភាពអំពីទស្សនដែលយល់ថា កិច្ចប្រជុំក្នុងស្ថាប័នរបស់អ្នក គឺទំនងជាត្រូវបានគ្រប់គ្រង និងចាត់ចែងដោយបុរស?<br>- តើអ្នកឯកភាព ឬមិនឯកភាពអំពីទស្សនដែលយល់ថា ការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងផអ៣ គឺជាការទទួលខុសត្រូវរបស់ទីប្រឹក្សាយេនឌ័រ និងក្រសួង កិច្ចការនារី (រួមទាំង គ.ក.ស.ក គ.ក.ន.ក មន្ទីរកិច្ចការនារី ការិយាល័យកិច្ចការនារីនៅរដ្ឋបាលថ្នាក់ក្រោម | - បញ្ជីសំណួរ |

| អនុសមាសភាគ | សំណួរគន្លឹះ | ប្រភពព័ត៌មាន |
|---|---|---|
| | ជាតិ)<br>- តើអ្នកបានចាត់វិធានការអ្វីខ្លះ ដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងការរៀបចំ និងអនុវត្ត ផអ៣ និងឬឆ្លើយតបបញ្ហាពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងស្ថាប័នរបស់អ្នក? | |
| ៤.៤.ឆ្លុះបញ្ចាំងអំពីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីក្នុងឯកសារផ្សព្វផ្សាយជាសាធារណៈរបស់ស្ថាប័ន(ដូចជា សន្លឹកព័ត៌មាន របាយការណ៍ គេហទំព័រ ក្តារព័ត៌មាន។ល។) | - តើសម្ភារសម្រាប់ផ្សព្វផ្សាយ និងទំនាក់ទំនងត្រូវបានរៀបចំ និងបានឆ្លុះបញ្ចាំងទៅនឹងសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីបានល្អកម្រិតណា? | - ពិនិត្យឯកសារ<br>- ការអង្កេត |
| ៤.៥ ការយល់ឃើញអំពីវឌ្ឍនភាពនៃសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី | - តើអ្នកយល់ថា ការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ផអ៣ បានសម្រេចលទ្ធផលកម្រិតណា? | - បញ្ជីសំណួរ |

### ២.៤.២. របកគំហើញចម្បងៗ

#### សម្រាប់ថ្នាក់ជាតិ

**ការយល់ដឹងអំពយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ ផអ៣ មានភាពច្របូកច្របល់**

អ្នកផ្តល់ព័ត៌មានភាគច្រើន បានអានឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឬយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ ឬបានអានឯកសារទាំងពីរ ព្រមទាំងបានបង្ហាញថា ឯកសារយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងផអ៣បានផ្តល់ការណែនាំច្បាស់លាស់។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកផ្តល់ព័ត៌មានទាំងនោះមានការយល់ដឹងអំពីខ្លឹមសារជាក់លាក់នៃឯកសារយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតិចតួចប៉ុណ្ណោះ។ លើសពីនេះ ឯកសារផអ៣ដែលបានបញ្ជ្រាបយេនឌ័រមិនត្រូវបានបោះពុម្ព និងផ្សព្វផ្សាយជាផ្លូវការ ព្រមទាំងអ្នកផ្តល់ព័ត៌មានភាគច្រើនបានប្រើប្រាស់ឯកសារ ផអ៣ ដែលមិនទាន់បានបញ្ជ្រាបយេនឌ័រសម្រាប់ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំ

ឆ្នាំ[7]។

**អនុកម្មវិធីទី១ ដល់ទី៣ បានអនុវត្តការលើកកម្ពស់សមភាពយេនឌ័រនៅកន្លែងធ្វើការងារបានល្អ ប៉ុន្តែការអនុវត្តរបស់អនុកម្មវិធីទី៤នៅមានកម្រិតទាបនៅឡើយ**

ផ្នែកមួយដែលត្រូវយកចិត្តទុកដាក់នៅក្នុងអនុកម្មវិធីទី១ និងទី២ គឺការមិនលើកទឹកចិត្តឲ្យបង្ហាញនូវវិសមភាពយេនឌ័រ (ដូចជា ផ្ទាំងរូបភាព ការផ្តល់យោបល់ ការនិយាយកំប្លែងដែលមិនគោរពតម្លៃរបស់ស្ត្រី ។ល។)

***ទទួលស្គាល់យ៉ាងខ្លាំងអំពីសារសំខាន់នៃការលើកកម្ពស់សមភាពយេនឌ័រ និងចាត់ទុកជាអាទិភាព ប៉ុន្តែមានវឌ្ឍនភាពតិចតួចក្នុងការអនុវត្ត***

ខណៈពេលដែលអ្នកផ្តល់ព័ត៌មានទាំងអស់យល់ឃើញថា ការបង្កើនសមភាពយេនឌ័រ គឺជាការងារអាទិភាពក៏ដោយ ក៏សវនកម្មយេនឌ័របានរកឃើញថា ក្នុងចំណោមអ្នកផ្តល់ព័ត៌មានទាំងអស់នោះ មានប្រមាណមួយភាគបី (១/៣) យល់ឃើញថា ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រសម្រេចបានលទ្ធផលតិចតួចណាស់។ តាមរយៈការដាក់ពិន្ទុ លទ្ធផលអនុកម្មវិធីទី៣ទទួលបានពិន្ទុខ្ពស់បំផុត ហើយអនុកម្មវិធីទី៤ទទួលបានពិន្ទុទាបបំផុត។

### សម្រាប់ថ្នាក់ក្រោមជាតិ

**ការយល់ដឹងអំពយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ ផអ៣ មានភាពច្របូកច្របល់**

ទោះបីជាអ្នកផ្តល់ព័ត៌មានភាគច្រើនបំផុតបានអានឯកសារកម្មវិធីជាតិ ឬយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ផអ៣ ឬបានអានឯកសារទាំងពីរក៏ដោយ ក៏កម្រិតយល់ដឹងលម្អិតរបស់ពួកគេលើខ្លឹមសារយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ផអ៣នៅមានកម្រិតនៅឡើយ[8]។

**ស្ត្រីទទួលបន្ទុកក្នុងការដោះស្រាយបញ្ហាស្ត្រី និងកុមារ**

អ្នកផ្តល់ព័ត៌មាននៅថ្នាក់ក្រោមជាតិច្រើនជាងពាក់កណ្តាលយល់ឃើញថា គ.ក.ស.ក គ.ក.ន.ក មន្ទីរកិច្ចការនារី ការិយាល័យកិច្ចការនារី គឺជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ផអ៣។

**ការយល់ឃើញអំពីវឌ្ឍនភាពក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រមានភាពខុសគ្នាយ៉ាងខ្លាំងនៅថ្នាក់ក្រោមជាតិ**

ខ្លឹមសារលម្អិតមានបង្ហាញនៅក្នុងចំណុច ៣.៣.៣។

### ២.៤.៣. អនុសាសន៍

---

[7] សៀវភៅ ផអ៣ ដែលរៀបចំសម្រាប់ក្រុមទីប្រឹក្សា មិនមែនជាឯកសារ ផអ៣ ដែលបានបញ្ជ្រាបយេនឌ័រចុងក្រោយ។ ឯកសារដែលមិនមែនជាឯកសារចុងក្រោយនេះ ក៏បានបង្ហោះក្នុងគេហទំព័រ គ.ជ.អ.ប ផងដែរ។

[8] អ្នកផ្តល់ព័ត៌មានមួយចំនួនបង្ហាញថា ពួកគេទើបនឹងបានអានឯកសារយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ នៅពេល ស្នើឲ្យបំពេញបញ្ជីសំណួរស្វ័យវាយតម្លៃប៉ុណ្ណោះ។

**សម្រាប់ថ្នាក់ជាតិ**

៤.១. គួរធានាថា ឯកសារផអ៣ ដំណាក់កាលទី២ គឺ ១).បានបញ្ជ្រាបយេនឌ័រ (មើលចំណុច ៣.១.១ ខាងលើ) ២).បញ្ចូលជាឧបសម្ព័ន្ធ ដោយសង្ខេបអំពីអាទិភាពនានាសម្រាប់ឆ្លើយតបនឹងយេនឌ័រ សម្រាប់អនុកម្មវិធីនីមួយៗ និង ៣).ឯកសារផអ៣ត្រូវបានផ្សព្វផ្សាយ ហើយអ្នកពាក់ព័ន្ធនានាអាចទទួលបាន។

៤.២. តម្រូវឲ្យមានខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីកាត់បន្ថយនូវទស្សនៈដែលលើកទឹកចិត្តចំពោះវិសមភាពយេនឌ័រនៅក្នុងកន្លែងធ្វើការ (ដូចជា៖ ផ្ទាំងរូបភាព ការផ្តល់មតិយោបល់ និងនិយាយរឿងកំប្លែងផ្តេសផ្តាសដែលមិនគោរពតម្លៃរបស់ស្ត្រី)។

៤.៣. ត្រូវបន្តតាមដាន និងចងក្រងឯកសារនានាពាក់ព័ន្ធនឹងកត្តាដែលនាំឲ្យអនុកម្មវិធីទី៣ទទួលបានពិន្ទុសវនកម្មយេនឌ័រខ្ពស់។

**សម្រាប់ថ្នាក់ក្រោមជាតិ**

៤.៤. ត្រូវដោះស្រាយនូវទស្សនយល់ឃើញជារួមរបស់ថ្នាក់ក្រោមជាតិដែលថា យេនឌ័រ គឺស្ត្រី និងទស្សនៈដែលយល់ឃើញថា ស្ត្រីគឺជាអ្នកទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហាស្ត្រី។

៤.៥. ត្រូវបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីកាត់បន្ថយនូវទស្សនៈដែលនាំឲ្យមានវិសមភាពយេនឌ័រនៅក្នុងកន្លែងធ្វើការងារ (ដូចជា ផ្ទាំងរូបភាព ការផ្តល់យោបល់ ការនិយាយកំប្លែងផ្តេសផ្តាសដែលមិនគោរពតម្លៃរបស់ស្ត្រី។ល។)

៤.៦. បន្តតាមដាន និងចងក្រងឯកសារនានាពាក់ព័ន្ធនឹងកត្តាដែលនាំឲ្យខេត្តស្វាយរៀងទទួលបានពិន្ទុសវនកម្មយេនឌ័រខ្ពស់។

**យុទ្ធសាស្ត្ររយៈពេលវែង**

៤.៧. ការដោះស្រាយបញ្ហាឥរិយាបថ និងអត្តចរិតជាប្រពៃណីអំពីទំនាក់ទំនងយេនឌ័រ គឺជាដំណើរការរយៈពេលវែង ដោយតម្រូវឲ្យមានការគាំទ្រយ៉ាងទូលំទូលាយ ដើម្បីលើកកម្ពស់ និងគាំទ្រការអនុវត្តគោលការណ៍នៃការលើកកម្ពស់សមភាពយេនឌ័រ :

- ការចូលរួមចំណែករបស់ស្ត្រីនៅក្នុងគេហស្ថាន សហគមន៍ នៅកន្លែងធ្វើការងារ និងនៅក្នុងសកម្មភាពសេដ្ឋកិច្ចនានា មិនត្រូវបានផ្តល់តម្លៃគ្រប់គ្រាន់ រួមទាំងអ្នកផ្តល់តម្លៃនោះជាស្ត្រីខ្លួនឯងក៏ដោយ។
- ឥរិយាបថ និងអត្តចរិតរបស់បុរស ឆ្លុះបញ្ចាំងអំពីឯកសិទ្ធិរបស់ខ្លួន (ដូចជា បុរសអាចធ្វើអ្វីៗ ដែលខ្លួនចង់ធ្វើ ហើយស្ត្រីជាភរិយាអាចនិយាយបានតិចតួចប៉ុណ្ណោះ)
- ស្ត្រីមិនមានទំនុកចិត្ត ពិសេសពាក់ព័ន្ធនឹងការអនុវត្តតួនាទី ដែលមិនមែនជាតួនាទីជាប្រពៃណីរបស់ស្ត្រី

៤.៨. ត្រូវបន្តផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រដល់បុរស ក្នុងការធ្វើសេចក្តីសម្រេច ព្រមទាំងបញ្ចូលបុរសនៅក្នុងការគាំទ្រ និងលើកកម្ពស់សកម្មភាពឆ្លើយតបនឹងយេនឌ័រនៅថ្នាក់ក្រោម

ជាតិ

## ២.៥. សមាសភាពទី៥ ៖ ការឆ្លើយតបយេនឌ័ររបស់អង្គការ/ស្ថាប័នដៃគូ

### ២.៥.១. អនុសមាសភាព សំណួរគន្លឹះ និងប្រភពព័ត៌មាន

ក្នុងសមាសភាពទី៥នេះ សវនកម្មយេនឌ័រផ្តោតលើវិស័យចំនួនពីរ គឺ ៖

| អនុសមាសភាគ | សំណួរគន្លឹះ | ប្រភពព័ត៌មាន |
|---|---|---|
| ៥.១.តួនាទីរបស់អង្គការ/ប័នដៃគូក្នុងការគាំទ្រ និងលើកកម្ពស់សមភាព យេនឌ័រ | - តើការលើកកម្ពស់សមភាពយេនឌ័ររបស់អង្គការ/ស្ថាប័នដៃគូអភិវឌ្ឍន៍មានសារសំខាន់យ៉ាងដូចម្តេចខ្លះ? | - បញ្ជីសំណួរ<br>- សម្ភាសន៍ |
| ៥.២.តួនាទីរបស់អង្គការសង្គមស៊ីវិលជាដៃគូក្នុងការគាំទ្រ និងលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការចូលរួមបង្កើតកម្មវិធីគោលនយោបាយ ការអនុវត្ត និងការតាមដាន | - តើការចូលរួមរបស់អង្គការសង្គមស៊ីវិលជាដៃគូក្នុងការរៀបចំ និងអនុវត្តកិច្ចការ ដើម្បីបង្កើនសមភាពយេនឌ័រ និងការបង្កើនភាពជាតំណាងរបស់ស្ត្រី មានសារសំខាន់យ៉ាងដូចម្តេចខ្លះ? | - បញ្ជីសំណួរ<br>- សម្ភាសន៍ |

៥.២.២. របកគំហើញចម្បងៗ

ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានាបានទទួលស្គាល់យ៉ាងច្បាស់លាស់អំពីភាពចាំបាច់នៃការគាំទ្រ និងលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។

**ត្រូវការការគាំទ្រពីដៃគូបន្ថែមទៀតក្នុងការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា គណៈអភិបាល មន្ត្រីរាជការស៊ីវិលដើម្បីគាំទ្រ និងលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី**

បន្ថែមលើកិច្ចខិតខំប្រឹងប្រែងគាំទ្រដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច ការបន្តអភិវឌ្ឍសមត្ថភាពពាក់ព័ន្ធនឹងយេនឌ័រដល់បុរសនៅតែជាតម្រូវការចាំបាច់ ដោយរួមបញ្ចូលទាំងការអភិវឌ្ឍសមត្ថភាពដល់អ្នកធ្វើសេចក្តីសម្រេចចិត្តនៅក្នុងលេខាធិការដ្ឋាន គ.ជ.អ.ប និងនៅតាមអនុកម្មវិធីនានា សមាជិកក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិជាបុរស អភិបាល អភិបាលរង អ្នកធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ សមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ជាបុរស ស្មៀនឃុំសង្កាត់ ទីប្រឹក្សា និងមន្ត្រីបច្ចេកទេស។ល។ លើសពីនេះទៀត ក៏ចាំបាច់ត្រូវមានការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការជាស្ត្រី ដើម្បីឲ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់សម្រាប់មុខតំណែងខ្ពស់ៗ ទាំងនៅថ្នាកក់ជាតិ និងថ្នាក់ក្រោមជាតិ។

**ត្រូវធ្វើឲ្យមានសុខុដុមនីយកម្មនូវរាល់សកម្មភាពឆ្លើយតបនឹងបញ្ហាយេនឌ័ររបស់គម្រោងដោយ**

**ឡៃកៗនានាដែលស្ថិតនៅក្នុងក្របខណ្ឌនៃកម្មវិធីជាតិ និងផអ៣**

សកម្មភាពឆ្លើយតបនឹងយេនឌ័ររបស់គម្រោងដោយឡែកៗនានាមិនទាន់បានឆ្លុះបញ្ចាំងទៅនឹងផែនការសកម្មភាព និងថវិការបស់ខ្លួនបានពេញលេញនៅឡើយ។ គម្រោងដោយឡែកនីមួយៗ គឺជាប្រភពព័ត៌មានអំពីយុទ្ធសាស្ត្រ ដែលមានសក្តានុពលសម្រាប់ឆ្លើយតបទៅនឹងការព្រួយបារម្ភផ្នែកយេនឌ័រនៅក្នុងកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**ការចូលរួមពីអង្គការសង្គមស៊ីវិលមានតិចតួច**

ការចូលរួមពីអង្គការសង្គមស៊ីវិលមានតិចតួចនៅថ្នាក់ជាតិ លើកលែងតែការងារពាក់ព័ន្ធនឹងក្របខណ្ឌគណនេយ្យភាពសង្គមប៉ុណ្ណោះ។ អង្គការសង្គមស៊ីវិលដែលធ្វើការនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានបទពិសោធន៍យ៉ាងច្រើន និងច្បាស់លាស់ពាក់ព័ន្ធនឹងការគាំទ្រ និងការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីនៅថ្នាក់ឃុំ សង្កាត់ ហើយអង្គការសង្គមស៊ីវិលទាំងនោះមិនមានតំណាងរបស់ខ្លួននៅក្នុង គ.ក.ន.ក ឡើយ។

**២.៥.៣. អនុសាសន៍**

**សម្រាប់ថ្នាក់ជាតិ**

៥.១. ត្រូវកៀរគរការគាំទ្រពីដៃគូអភិវឌ្ឍន៍សម្រាប់ការពង្រឹងសមត្ថភាពក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរាជការឲ្យបានច្រើនបន្ថែមទៀត ក្រៅពីការការគាំទ្រតែលើការជំរុញតួនាទីរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត

៥.២. ត្រូវពិនិត្យឡើងវិញនូវយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុងគម្រោងដោយឡែកៗនីមួយៗ ដើម្បីកំណត់បាននូវបទពិសោធន៍ល្អៗ ដោយរួមទាំងសកម្មភាពអភិវឌ្ឍសមត្ថភាពផងដែរ

៥.៣. ត្រូវបញ្ចូលអង្គការសង្គមស៊ីវិលនៅក្នុងដំណើរការរៀបចំផអ៣ ដំណាក់កាលទី២។

**សម្រាប់ថ្នាក់ក្រោមជាតិ**

៥.៤. ត្រូវកំណត់មេរៀនបទពិសោធន៍ដែលទទួលបានពីគម្រោងដោយឡែកៗអំពីការបញ្ជ្រាបយេនឌ័រ នៅថ្នាក់ក្រោមជាតិ

៥.៥. ត្រូវពិនិត្យ និងរៀនសូត្រនូវសកម្មភាពឆ្លើយតបយេនឌ័ររបស់អង្គការសង្គមស៊ីវិលនៅថ្នាក់ឃុំ សង្កាត់

៥.៦. ត្រូវបញ្ចូលតំណាងអង្គការសង្គមស៊ីវិលនៅក្នុង គ.ក.ន.ក

៥.៧. ត្រូវធ្វើសុខុដុមនីយកម្មនូវរាល់សកម្មភាពឆ្លើយតបយេនឌ័ររបស់អង្គការដៃគូនៅថ្នាក់ក្រោមជាតិ។

**យុទ្ធសាស្ត្ររយៈពេលវែង**

៥.៨. រាជរដ្ឋាភិបាលគួរតែនាំមុខក្នុងការធានាថា គម្រោងរបស់ដៃគូអភិវឌ្ឍន៍នានាមានការឆ្លើយតបយេនឌ័រក្នុងក្របខណ្ឌកម្មវិធីជាតិ និងផអ៣ និងដោយមិនគ្រាន់តែឆ្លើយតបតាមអាទិភាពរបស់

ដៃគូនីមួយៗឡើយ

៥.៩. អង្គការសង្គមស៊ីវិលមានបទពិសោធន៍ច្បាស់លាស់អំពីការគាំទ្រ និងលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីនៅថ្នាក់ក្រោមជាតិ។ មេរៀន និងបទពិសោធន៍ទាំងនេះគួរត្រូវបានរៀបចំ និងចងក្រង ដើម្បីដាក់បញ្ចូល និងគាំទ្រដល់ការរៀបចំផអ៣នាពេលខាងមុខ។

## ៣. ការប្រៀបធៀបនូវលទ្ធផលសវនកម្មយេនឌ័រតាមស្ថាប័នដែលបានធ្វើសវនកម្ម

### ៣.១. លទ្ធផលជារួមតាមស្ថាប័នអនុវត្តនានា

ស្ថាប័នទាំងបីថ្នាក់ (ថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក) ដែលបានធ្វើសវនកម្ម មានពិន្ទុប្រហាក់ប្រហែលគ្នា[9] តាមសមាសភាគនីមួយៗនៃសវនកម្មយេនឌ័រដូចដែលឃើញមាននៅក្នុងរូបភាពទី២ខាងក្រោមនេះ។ ប័ណ្ណដាក់ពិន្ទុលម្អិតសម្រាប់ស្ថាប័ននីមួយៗបានបង្ហាញលម្អិតនៅក្នុងឧបសម្ព័ន្ធទី៦។ ការសង្ខេបពិន្ទុតាមអនុសមាសភាគនីមួយៗសម្រាប់ស្ថាប័នទាំង៣ថ្នាក់ ដែលបានធ្វើសវនកម្មមាននៅក្នុងឧបសម្ព័ន្ធទី៧។

**រូបភាពទី២ ៖ ពិន្ទុសវនកម្មយេនឌ័រនៃស្ថាប័នអនុវត្តអនុកម្មវិធី និងរដ្ឋបាលថ្នាក់ក្រោមជាតិ**




[9] **កំណត់ចំណាំអំពីការដាក់ពិន្ទុ៖** មានគម្លាតខុសគ្នាខ្លាំងរវាងចំនួនអ្នកឆ្លើយសំណួរនៅក្នុងស្ថាប័នដែលបានធ្វើសវនកម្ម យេនឌ័រនីមួយៗ (ឧទាហរណ៍ៈ អនុកម្មវិធី ខេត្ត និងស្រុក) ដូច្នេះភាពខុសគ្នារវាងអនុកម្មវិធី និងអនុកម្មវិធី និងរវាងអនុកម្មវិធី និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងពីរថ្នាក់សម្រាប់សមាសភាគនីមួយៗ ដែលមិនមានកម្រិតជឿជាក់តាមបែបស្ថិតិឡើយតែទោះជាយ៉ាងណាក៏ដោយវាក៏បង្ហាញនូវទស្សនៈជារួមដែរ។

ការឆ្លើយតបទៅនឹងបញ្ហាយេនឌ័ររបស់អង្គការ/ស្ថាប័នដៃគូអភិវឌ្ឍន៍ទទួលបានពិន្ទុខ្ពស់ជាងគេ។ អ្នកឆ្លើយសំណួរទទួលស្គាល់ថា ការលើកកម្ពស់សមភាពយេនឌ័រ គឺពិតជាមានសារៈសំខាន់ចំពោះដៃគូអភិវឌ្ឍន៍ ហើយអង្គការមិនមែនរដ្ឋាភិបាលត្រូវបានទទួលស្គាល់ថា គួរមានតួនាទីក្នុងចូលរួមរៀនចំតាក់តែង និងការអនុវត្តនៃយុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣។ យេនឌ័រនៅក្នុងវប្បធម៌ស្ថាប័នត្រូវបានឲ្យពិន្ទុលំដាប់ទី២ ហើយ អ្នកឆ្លើយសំណួរដឹងយ៉ាងច្បាស់ថា ការបញ្ជ្រាបយេនឌ័រ និងការបង្កើតភាពអង់អាចរបស់ស្ត្រីពិតជាមានសារៈសំខាន់ក្នុងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាគច្រើនបានដឹងច្បាស់អំពីយុទ្ធសាស្ត្ររបស់ផអ៣។ អ្នកឆ្លើយសំណួរភាគច្រើនមានអារម្មណ៍ថា សមភាពយេនឌ័រត្រូវបានលើកកម្ពស់នៅក្នុងកន្លែងធ្វើការងារផងដែរ។

ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងការរៀបចំបុគ្គលិកត្រូវបានឲ្យពិន្ទុទាបបំផុត។ ស្ត្រីជាតំណាងនៅក្នុងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិមានចំនួនតិច រួមទាំងនៅក្នុង គ.ជ.អ.ប ។ ស្ត្រីនៅក្នុងមុខតំណែងធ្វើក្ដីសម្រេចចិត្តនៅតាមអនុកម្មវិធី និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានធ្វើសវនកម្មក៏មានចំនួនតិចតួចដែរ។ ជាទូទៅហាក់មានទំនោរក្នុងការជ្រើសរើសបុគ្គលិកជាស្ត្រីឲ្យធ្វើការនៅក្នុងមុខតំណែងធ្វើសម្រេចចិត្តថ្នាក់មធ្យម និងមុខតំណែងជំនាញដែលមានលក្ខណៈជាប្រពៃណីការងាររបស់ស្ត្រី ដូចជាមុខតំណែងសម្រាប់ការងារគណនេយ្យ ការងារលទ្ធកម្ម ការងារគ្រប់គ្រងធនធានមនុស្ស និងជាពិសេសមុខតំណែងទទួលខុសត្រូវក្នុងការលើកកម្ពស់ និងគាំទ្រការបញ្ជ្រាបយេនឌ័រ (ឧទហរណ៍ ៖ ការិយាល័យអន្តរវិស័យ និងសហប្រតិបត្តិការនៃលេខាធិការដ្ឋាន គ.ជ.អ.ប)។

ពិន្ទុយេនឌ័ររបស់ក្រុង ស្រុកខ្ពស់ជាងពិន្ទុយេនឌ័ររបស់ខេត្ត ឬអនុកម្មវិធីបន្ថិចចំពោះសមាសភាគភាគច្រើន ដែលនេះបានបង្ហាញឲ្យឃើញថា ការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅថ្នាក់មូលដ្ឋានមានកម្រិតខ្ពស់ជាង។

### ៣.២. អនុកម្មវិធី នៃ ផអ៣

នៅតាមស្ថានប័នអនុវត្តអនុកម្មវិធី មានភាពខុសៗគ្នាក្នុងការផ្ដល់ពិន្ទុចំពោះអនុកម្មវិធីទាំង៤ ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី៣ខាងក្រោម ៖

**រូបភាពទី៣ ៖ ពិន្ទុសង្ខេបនៃសវនកម្មយេនឌ័រសម្រាប់អនុកម្មវិធី នៃផអ៣**




អនុកម្មវិធីទី៤ ត្រូវបានរកឃើញថានៅមានភាពទន់ខ្សោយក្នុងសមាសភាគចំនួន៤ ក្នុងចំណោមសមាសភាគទាំង៥ ( ខ្សោយទាំងអស់ លើកលែងតែសមាសភាគការឆ្លើយតបយេនឌ័រពីអង្គការដៃគូ)។

អនុកម្មវិធីទី៣ ត្រូវបានវាយតម្លៃថាមានភាពខ្លាំងក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការបង្កើតគោលនយោបាយ និងធ្វើផែនការ ការត្រួតពិនិត្យ និងការវាយតម្លៃ ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងចាត់ចែងបុគ្គលិក តែទោះជាយ៉ាងណាក៏ដោយហាក់ដូចជាមានពិន្ទុទាបចំពោះសមាសភាគនៃការឆ្លើយតបយេនឌ័ររបស់អង្គការ/ស្ថាប័នដៃគូអភិវឌ្ឍន៍។

អនុកម្មវិធីនេះគឺជាអនុកម្មវិធីតែមួយគត់ដែលក្រុមការងារបញ្ជ្រាបយេនឌ័រ(GMAG)មានដំណើរការល្អដោយបានសហការងារយ៉ាងល្អជាមួយក្រុមការងារអនុកម្មវិធីនៃផអ៣។ ភាពខ្លាំងរបស់ក្រុមការងារអញ្ជ្រាបយេនឌ័រនេះអាចមកពីហេតុផលការគាំទ្រតាំងពីដំបូងរបស់ដៃគូអភិវឌ្ឍន៍ រួមទាំងការទំនាក់ទំនងការងារដ៏ល្អជាមួយក្រសួងកិច្ចការនារី។

ជារួមអនុកម្មវិធីទី២ ត្រូវបានដាក់ពិន្ទុមធ្យម ប៉ុន្តែពិន្ទុទាបនៅឡើយក្នុងសមាសភាគស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំបុគ្គលិក។

ជារួមអនុកម្មវិធីទី១ត្រូវបានដាក់ពិន្ទុមធ្យម។ ពិន្ទុហាក់ទាបសម្រាប់ការធ្វើផែនការ ការត្រួតពិនិត្យ និងវាយតម្លៃដែលឆ្លុះបញ្ចាំងឲ្យឃើញនូវភាពមិនស៊ីសង្វាក់គ្នាក្នុងការបញ្ជ្រាបយេនឌ័រ ទៅក្នុងផែនការ សកម្មភាព ថវិកា និងការអនុវត្តនូវវិធានការឆ្លើយតបនឹងយេនឌ័រ។ ជាមួយគ្នានេះដែរ ពិន្ទុលើសូចនាករនៃផលប៉ះពាល់ដែលពាក់ព័ន្ធទៅនឹងបញ្ហាយេនឌ័រក៏ទាបដែរ។ សូចនាករនៃផលប៉ះពាល់ត្រូវបានវាយតម្លៃតែចំពោះអនុកម្មវិធីទី១ គឺលេខាធិការដ្ឋានគ.ជ.អ.ប ដែលទទួលខុសត្រូវលើការអភិវឌ្ឍគោលន

យោបាយ និងសម្របសម្រួលកម្មវិធីជារួម។ កិច្ចប្រឹងប្រែងដ៏ល្អត្រូវបានធ្វើឡើងដើម្បីបញ្ជ្រាបសូចនាករយេនឌ័រទៅក្នុងក្របខ័ណ្ឌការងារត្រួតពិនិត្យ វាយតម្លៃជារួមសម្រាប់ផអ៣។ ពាក់ព័ន្ធទៅនឹងស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំបុគ្គលិក ត្រូវបានកត់សម្គាល់ឃើញថា អនុកម្មវិធីទី១មានសមាមាត្រចំនួនស្ត្រីខ្ពស់នៅក្នុងអង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ។ ប្រសិនបើអង្គភាពនីមួយៗរបស់លេខាធិការដ្ឋានគ.ជ.អ.ប ត្រូវបានធ្វើសវនកម្មយេនឌ័រដាច់ដោយឡែកពីគ្នា អង្គភាព ០៣ ផ្សេងទៀតនឹងមានពិន្ទុទាប(ចំនួនស្ត្រីតិច)។

## ៣.៣. អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ

### ៣.១.១. ថ្នាក់ខេត្ត

នៅថ្នាក់ខេត្ត ពិន្ទុក៏មានភាពខុសៗគ្នានៅតាមខេត្តដែលបានធ្វើសវនកម្ម ដូចដែលបានឃើញក្នុងរូបភាពទី៤ខាងក្រោម ៖

**រូបភាពទី៤ ៖ ពិន្ទុសង្ខេបនៃសវនកម្មយេនឌ័រសម្រាប់ខេត្តទាំង០៤**




ខេត្តស្វាយរៀងមានពិន្ទុខ្ពស់លើផ្នែកយេនឌ័រក្នុងការធ្វើផែនការ ការត្រួតពិនិត្យនិងវាយតម្លៃ និងជំនាញបច្ចេកទេសយេនឌ័រ។ ការបានពិន្ទុខ្ពស់គឺដោយសារការគាំទ្រពី គ.ក.ន.ក រដ្ឋបាលខេត្ត និងស្ត្រីដែលមានភាពសកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំបុគ្គលិក។

រីឯខេត្តក្រចេះ និងខេត្តកោះកុង សូចនាករភាគច្រើនបង្ហាញថាមានលទ្ធផលមធ្យម។

សម្រាប់ខេត្តបាត់ដំបងមានពិន្ទុល្អលើយេនឌ័រក្នុងការធ្វើផែនការ ការត្រួតពិនត្យនិងវាយតតម្លៃ និងជំនាញបច្ចេកទេសយេនឌ័រ ក៏ប៉ុន្តែមានពិន្ទុទាបចំពោះសមាសភាគស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត

និងការរៀបចំបុគ្គលិក ដែលនេះគឺជាការដែលគួរឲ្យភ្ញាក់ផ្អើលមួយផងដែរ ព្រោះខេត្តបាត់ដំបងជាខេត្តដ៏ធំមួយនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានរំពឹងថានឹងមានបញ្ហាតិចជាងខេត្តដ៏ទៃទៀតក្នុងការជ្រើសរើសបុគ្គលិកជាស្ត្រីដែលមានសមត្ថភាពគ្រប់គ្រាន់។

### ៣.៣.២. ថ្នាក់ក្រុង ស្រុក

នៅថ្នាក់ក្រុង ស្រុក ពិន្ទុក៏មានភាពខុសៗគ្នានៅក្នុងចំណោមស្រុក ក្រុងទាំង៤ ដែលបានធ្វើសវនកម្ម ដូចមានបង្ហាញក្នុងរូបភាពទី៥។

**រូបភាពទី៥ ៖ ពិន្ទុសង្ខេបនៃសវនកម្មយេនឌ័រសម្រាប់ខេត្តក្រុង ស្រុកទាំង០៤**




នៅថ្នាក់ស្រុក ស្រុកស្វាយទាបក្នុងខេត្តស្វាយរៀងក៏បានពិន្ទុខ្ពស់ចំពោះសមាសភាគពាក់ព័ន្ធនឹងការកសាងផែនការ ការត្រួតពិនិត្យ និងវាយតម្លៃ និងជំនាញបច្ចេកទេសយេនឌ័រ ក៏ប៉ុន្តែមានពិន្ទុទាបចំពោះសមាសភាគនៃស្ត្រីក្នុងការធ្វើសម្រេចចិត្ត និងការរៀបចំបុគ្គលិក។

ផ្ទុយទៅវិញ ក្រុងខេមរៈភូមិន្ទនៅក្នុងខេត្តកោះកុងបានពិន្ទុខ្ពស់លើសមាសភាគស្ត្រីក្នុងការធ្វើសម្រេចចិត្ត និងការរៀបចំបុគ្គលិកដោយសារភាគរយស្ត្រីនៅក្នុងសមាជិកក្រុមប្រឹក្សាក្រុងមានចំនួនច្រើន (មាន៤ក្នុងចំណោម១១នាក់) ប៉ុន្តែមានពិន្ទុទាបទៅលើសមាសភាគយេនឌ័រក្នុងវប្បធម៌ស្ថាប័ន។ ល្បែងស៊ីសងត្រូវបានកំណត់ជាបញ្ហាដ៏សំខាន់មួយនៅក្នុងក្រុងនេះ រួមទាំងជាបញ្ហាក្នុងចំណោមមន្ត្រីផងដែរ។ ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលក៏ត្រូវបានមើលឃើញជាបញ្ហាកង្វល់ផងដែរ។

ស្រុកសម្បូរ នៅក្នុងខេត្តក្រចេះមានពិន្ទុទាបក្រោមមធ្យមបន្តិច លើសមាសភាគការការបញ្ជ្រាបយេបឌ័រក្នុងការកសាងផែនការ ការត្រួតពិនត្យ និងវាយតតម្លៃ។ បញ្ហាទាំងនេះ ក៏មានពាក់ព័ន្ធទៅនឹងទី

តាំងភូមិសាស្ត្រផងដែរ។ បញ្ហាវប្បធម៌ និងភាសានៃជនជាតិភាគតិចនៅក្នុងស្រុកនេះត្រូវបានមើលឃើញជាបញ្ហាប្រឈមដ៏សំខាន់។

ស្រុករតនៈមណ្ឌលនៅក្នុងខេត្តបាត់ដំបងបានពិន្ទុប្រសើរជាងរដ្ឋបាលខេត្តរបស់ខ្លួន។

### ៣.៣.៣. ភាពផ្សេងៗគ្នានូវទស្សនៈយល់ឃើញអំពីវឌ្ឍនភាពនៅថ្នាក់ក្រោមជាតិ

ដូចដែលបានឃើញនៅក្នុងរូបភាពទី៦ ជាទូទៅសង្កេតឃើញថា វឌ្ឍនភាពក្នុងការអនុវត្តយុទ្ធសាស្ត្រផអ៣ បានល្អប្រសើរនៅថ្នាក់ស្រុកជាងនៅថ្នាក់ខេត្ត លើកលែងតែខេត្តក្រចេះ។ នៅថ្នាក់ខេត្តអ្នកឆ្លើយសំណួរភាគច្រើននៅក្នុងខេត្តបាត់ដំបង និងខេត្តកោះកុងគិតថា មានវឌ្ឍនភាពតិចតួចក្នុងការអនុវត្តយុទ្ធសាស្ត្រយេនឌ័រនៃផអ៣ ក៏ប៉ុន្តែអ្នកឆ្លើយសំណួរនៅក្នុងខេត្តក្រចេះ និងខេត្តស្វាយរៀងគិតថាមានលក្ខណៈល្អប្រសើរ និងមានវឌ្ឍនភាព។

នៅថ្នាក់ស្រុក អ្នកឆ្លើយសំណួរទាំងអស់នៅក្នុងស្រុកស្វាយទាបនៃខេត្តស្វាយរៀងយល់ឃើញថាមានលក្ខណៈល្អប្រសើរ និងមានវឌ្ឍនភាព។ ទាំងនៅក្នុងខេត្តបាត់ដំបង និងខេត្តកោះកុង ថ្នាក់ស្រុកមានវឌ្ឍនភាពល្អជាងថ្នាក់ខេត្តរបស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកឆ្លើយសំណួរចំនួន២៩%នៅក្នុងក្រុងខេមរភូមិន្ទនៃខេត្តកោះកុងបានយល់ឃើញថាពួកគេមិនដឹងថាទទួលបានលទ្ធផលអ្វីខ្លះទេ។

**រូបភាពទី៥ ៖ ទស្សនៈទានអំពីការរីកចម្រើនលើផ្នែកយេនឌ័រនៅថ្នាក់ក្រោមជាតិ**




ថ្នាក់ខេត្ត ថ្នាក់ស្រុក

# ឧបសម្ព័ន្ធទី ១
# លក្ខខណ្ឌការងារ
# សវនកម្មយេនឌ័រសម្រាប់ផអ៣

**កម្មវិធី** ÷ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ-ផែនការអនុវត្ត៣ឆ្នាំដំបូង (ផអ៣/២០១១ដល់ ២០១៣)

**កិច្ចការ** ÷ សវនកម្មយេនឌ័រសម្រាប់ផអ៣

**ទីកន្លែង** ÷ រាជធានីភ្នំពេញ និងនៅតាមខេត្តមួយចំនួន

**រយៈពេល** ÷ ៦សប្តាហ៍

## ១. ប្រវត្តិ

រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈ ក្នុងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោម ជាតិ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក៏ត្រូវបានរៀបចំបង្កើតឡើងដោយព្រះរាជក្រឹត្យ ក្រោមក្របខណ្ឌនៃច្បាប់រៀបចំអង្គការដែលបានដាក់អនុម័ត និងដាក់ឲ្យប្រើប្រាស់នៅឆ្នាំ២០០៨។ ដើម្បីអនុវត្តគោលនយោបាយកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប បានរៀបចំតាក់តែងកម្មវិធីជាតិមួយ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ (២០១០-២០១៩) ព្រមទាំងផែនការអនុវត្ត៣ឆ្នាំដំបូងនៃកម្មវិធីជាតិនេះ។ ក្រៅពីនេះ ការពន្យារពេលផអ៣សម្រាប់រយៈពេល១ឆ្នាំបន្ថែមទៀតក៏ត្រូវបានរៀបចំតាក់តែងផងដែរ។

គ.ជ.អ.ប ត្រូវបានផ្តល់អាណត្តិជាអាជ្ញាធរគ្រប់គ្រងកម្មវិធីរួមមួយ ហើយតាមរយៈលេខាធិការដ្ឋានរបស់ខ្លួនត្រូវមានតួនាទី និងការទទួលខុសត្រូវក្នុងការរៀបចំតាក់តែងគោលនយោបាយ និងការសម្របសម្រួលការកម្មវិធី។ ការទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធីត្រូវបានផ្តល់ឲ្យទៅស្ថាប័នជាតិចំនួន ៧ ដែលក្នុងនោះមានស្ថាប័នអនុវត្តចំនួន៦ ជាស្ថាប័នដែលត្រូវអនុវត្តអនុកម្មវិធីរបស់ខ្លួននីមួយៗ ដែលក្នុងនោះរួមមាន៖ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងមុខងារសាធារណៈ និងសម្ព័ន្ធភាពជាតិនៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នអនុវត្តចំនួន១ផ្សេងទៀត គឺជាស្ថាប័នដែលមានតួនាទី និងការទទួលខុសត្រូវលើការងារអន្តរវិស័យ (ក្រសួងកិច្ចការនារី)។

ក្នុងឯកសារកម្មវិធីជាតិរយៈពេល១០ និងផអ៣ ត្រូវបានភ្ជាប់ជាមួយនូវឯកសារឧបសម្ព័ន្ធស្តីពីយុទ្ធសាស្ត្រនឌ័រ ដែលកំណត់អំពីវិធីសាស្ត្រសម្រាប់ការបញ្ជ្រាបទស្សនទានយេនឌ័រទៅក្នុងការអនុវត្តជាក់ស្តែង។ គោលដៅនៃឯកសារយុទ្ធសាស្ត្រយេនឌ័រនៃផអ៣ គឺ៖

"ជំរុញឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិបានលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅគ្រប់ដំណាក់កាល

ដោយរួមទាំងការចូលរួម និងទទួលបានដោយស្មើភាពរបស់ស្ត្រី និងបុរសនូវធនធាន សេវាកម្ម ព្រមទាំងតួនាទីជាអ្នកដឹកនាំ និងក្នុងថ្នាក់ធ្វើសេចក្តីសម្រេចចិត្ត”។

នៅពាក់កណ្តាលឆ្នាំ២០១១ សមាសធាតុ គោលបំណង និងសនិទានកម្មនានា ព្រមទាំងលទ្ធផលរំពឹងទុកទាំងឡាយរបស់អនុកម្មវិធីនីមួយៗនៃផអ៣ត្រូវបានបញ្ជ្រាបនូវកិច្ចការយេនឌ័រ។ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ផអ៣ក៏ត្រូវបានរៀបចំដោយផ្អែកលើអនុកម្មវិធីទាំង៦។ ជាមួយគ្នានេះដែរ ក៏មានការឯកភាពគ្នាថា ការអនុវត្តអនុកម្មវិធីប្រកបដោយការបញ្ជ្រាបយេនឌ័រ គឺជាការទទួលខុសត្រូវដ៏សំខាន់របស់ស្ថាប័នអនុវត្តនីមួយៗ។ ដោយឡែក ក្រសួងកិច្ចការនារីត្រូវទទួលខុសត្រូវក្នុងការផ្តល់ប្រឹក្សាយោបល់ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ផ្តល់ការគាំទ្រ និងការត្រួតពិនិត្យនានា ដែលតួនាទីទាំងនេះមានលក្ខណៈស្របទៅនឹងស្ថានភាពនៃការបញ្ជ្រាបយេនឌ័រនៅក្នុងប្រទេសកម្ពុជា។

ការតាមដានត្រួតពិនិត្យ និងការសិក្សាវាយតម្លៃមួយចំនួនរួមបញ្ចូលទាំងការងារយេនឌ័រផងដែរ ក៏ត្រូវបានអនុវត្តក្នុងរយៈពេលកន្លងមក។ របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃសមត្ថភាព ក្រុង ស្រុក ខណ្ឌ (ទិន្នន័យមូលដ្ឋាន ឆ្នាំ២០១១) ក៏ត្រូវបានរៀបចំបញ្ចប់នៅក្នុងខែកញ្ញា ឆ្នាំ២០១១។ របាយការណ៍ស្តីពីការអង្កេតអភិបាលកិច្ចក៏ត្រូវបានរៀបចំបញ្ចប់នៅក្នុងខែឧសភា ឆ្នាំ២០១២ និងការកែសម្រួលរបាយការណ៍ស្តីពីផលប៉ះពាល់របស់មូលនិធិឃុំ សង្កាត់ទៅលើភាពក្រីក្រ និងសុខមាលភាព ក៨បានរៀបចំបញ្ចប់នៅក្នុងឆ្នាំ១០១៣។ សូចនាករនៃការអនុវត្តជាច្រើន (ការបណ្តុះបណ្តាល ការរៀបចំបុគ្គលិក ការចូលរួមកិច្ចប្រជុំ និងកិច្ចដំណើរការកសាងផែនការ...) ត្រូវបានកត់ត្រាដោយបែងចែកតាមភេទនានា។ ទោះបី មានព័ត៌មានជាច្រើនដែលត្រូវបានរក្សាទុកនៅតាមកន្លែងជាច្រើនផ្សេងៗគ្នាក៏ដោយ ក៏ការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីពុំទាន់ត្រូវបានវាយតម្លៃឲ្យបានទូលំទូលាយឡើយ។

តម្រូវការក្នុងការពិនិត្យឡើងវិញ ការកែលំអ ឬការកែសម្រួលយុទ្ធសាស្ត្រយេនឌ័រ និងការអនុវត្តយុទ្ធសស្ត្រនេះត្រូវបានទទួលស្គាល់ក្នុងពេលកន្លងមក ជាពិសេសក្នុងពេលវេលាដែលសមស្របសម្រាប់ការកែលំអការអនុវត្តយុទ្ធសាស្ត្រនេះក្នុងការពន្យារពេលផអ៣។ ក្នុងឆ្នាំ២០១៣ ចំណុចដៅ១ក្នុងចំណោមចំណុចដៅទាំង១៩ (សកម្មភាពអាទិភាពនានាដែលត្រូវអនុវត្តបញ្ចប់) នៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៣ គឺការបញ្ចប់នូវសវនកម្មយេនឌ័រ ដើម្បីសិក្សាវាយតម្លៃវាស់វែងកម្រិតប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការធ្វើសវនកម្មយេនឌ័រនឹងត្រូវអនុវត្តរួមគ្នាដោយក្រុមការងារមួយដែលមានការគាំទ្រពីទីប្រឹក្សារយៈពេលខ្លីចំនួន២រូប (០១រូបជាទីប្រឹក្សាអន្តរជាតិ និង ០១ជាទីប្រឹក្សាជាតិ) លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី។

## ២. គោលបំណង

គោលបំណងក្នុងការធ្វើសវកម្មយេនឌ័រនេះក្នុងឆ្នាំ២០១៣ គឺដើម្បី ៖

- សិក្សាវាយតម្លៃនូវកម្រិតប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រ និងរបៀបនៃការបង្កើនភាពអង់អាចរបស់ស្ត្រី និងក្នុងស្ថាប័នអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- សិក្សាវាយតម្លៃ និងចងក្រងមេរៀនបទពិសោធន៍ និងផ្តល់អនុសាសន៍សម្រាប់ការពន្យារពេលផអ៣ (ឆ្នាំ១០១៤) ដើម្បីធ្វើឲ្យប្រសើរឡើងនូវការអនុវត្តយុទ្ធសាស្ត្រ និងយន្តការបញ្ជ្រាបយេនឌ័រដែលមាននាពេលបច្ចុប្បន្ននេះទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- កំណត់យុទ្ធសាស្ត្រសម្រាប់ពេលអនាគត ការងារតាមវិស័យ ការសម្រេចចិត្តផ្នែកគោលនយោបាយ និងវិធានការនានាដែលអាចត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអនុវត្ត៣ឆ្នាំដំណាក់កាលបន្ទាប់នសកម្មវិធីជាតិ (ឧទាហរណ៍ ដើម្បីធ្វើឲ្យមានលក្ខណៈសមស្របទៅនឹងការរៀបចំកម្មវិធីគាំទ្រដំណាក់កាលបន្ទាប់)
- រៀបចំបង្កើតវិធីសាស្ត្រនានាសម្រាប់ការធ្វើសវនកម្មយេនឌ័រ ដែលអាចដាក់បញ្ចូលទៅក្នុងកិច្ចដំណើរការអនុវត្តក្របខ័ណ្ឌអភិវឌ្ឍស្ថាប័នសម្រាប់ការប្រើប្រាស់នាពេលអនាគត។

## ៣. ការរំពឹងទុកនៃការធ្វើសវនកម្មយេនឌ័រ

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ការធ្វើសវកម្មយេនឌ័រនឹងត្រូវបានរំពឹងថា ៖

- សិក្សាវាយតម្លៃកម្រិតដែលស្ថាប័នអនុវត្តសំខាន់ៗនៃផអ៣ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិបានបញ្ជ្រាបយេនឌ័រ និងបង្កើនភាពអង់អាចរបស់ស្ត្រី ដោយប្រើប្រាស់វិធីសាស្ត្រ ឬប្រភេទនៃព័ត៌មានចំនួន៣៖
  - ✓ ទិន្នន័យរដ្ឋបាល
  - ✓ ការសិក្សាវាយតម្លៃដែលមានលក្ខណៈឯករាជ្យដោយទីប្រឹក្សា
  - ✓ ការសិក្សាវាយតម្លៃអំពីទស្សនយល់ដឹងរបស់មន្ត្រី បុគ្គលិកនៃស្ថាប័នអនុវត្តផអ៣ដោយខ្លួនឯង។
- ការធ្វើឲ្យមានតុល្យភាពនៃវិធីសាស្ត្រ ឬប្រភេទនៃព័ត៌មានទាំង៣ខាងលើដើម្បីធានាដល់ការចូលរួម និងភាពជាម្ចាស់ព្រមទាំងគុណភាព និងភាពត្រឹមត្រូវ។ ពាក្យ "សវនកម្ម" ត្រូវបានប្រើប្រាស់ពីព្រោះការសិក្សាវាយតម្លៃនេះត្រូវបានរំពឹងថាផ្អែកលើភស្តុតាងភាគច្រើន
- ការធ្វើសវនកម្មស្ថាប័នអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដោយហេតុថា គោលនយោបាយនានារបស់រាជរដ្ឋាភិបាល មានបំណងធ្វើឲ្យមានផលប៉ះពាល់យ៉ាងទូលំទូលាយពីរបៀបនៃការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សវនកម្មនឹងផ្តោតជាសំខាន់បរិយាកាសផ្នែកស្ថាប័នដែលបានរៀបចំបង្កើតឡើងដោយរាជរដ្ឋាភិបាល។
- ធ្វើសវនកម្មទាំងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់រាជធានី ខេត្ត
- ការអនុវត្តសវនកម្មយេនឌ័ររួមគ្នាជាមួយមន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី តាមវិធីសាស្ត្រអភិវឌ្ឍន៍សមត្ថភាពរៀនបណ្តើរអនុវត្តបណ្តើរ។
- បង្កើតបានលទ្ធផលក្នុងទិន្នន័យមូលដ្ឋានមួយដែលអាចធ្វើការវាស់វែងដោយស្វ័យប្រវត្តិនូវសមិទ្ធផលនានាពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីក្នុង

រយៈពេលនៃការអនុវត្ត។ ឧបករណ៍ដែលបានរៀបចំបង្កើតឡើង នឹងរំពឹងថាអាចប្រើប្រាស់សម្រាប់វិស័យមួយចំនួន និងដើម្បីបង្កើតលក្ខណៈវិនិច្ឆ័យ/បញ្ជីត្រួតពិនិត្យ/បញ្ជីត្រួតពិនិត្យ/ការដាក់ពិន្ទុ/ឧបករណ៍ផ្សេងៗទៀតសម្រាប់វិស័យនីមួយៗទាំងនោះ

- អាចអនុវត្តបន្តបាន។បន្ទាប់ពីមានការកែសម្រួលឲ្យខ្លី និងមានលក្ខណៈងាយស្រួល ដែលអាចអនុវត្តបន្តបានដោយមន្ត្រីរាជរដ្ឋាភិបាល ឬទីប្រឹក្សាបំពេញការងារឲ្យរាជរដ្ឋាភិបាល
- ត្រូវផ្អែកលើស្តង់ដារ បទពិសោធន៍ ឧបករណ៍ និងវិធីសាស្ត្រសម្រាប់ធ្វើសវនកម្មយេនឌ័រ ដែលមានលក្ខណៈអន្តរជាតិ។ ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើបទពិសោធន៍ មេរៀន និងគំរូនៃការអនុវត្តល្អលក្ខណៈអន្តរជាតិ។ សៀវភៅណែនាំ និងកិច្ចដំណើរការសវនកម្មយេនឌ័ររបស់អង្គការ ILO នឹងរំពឹងថាត្រូវបានយកមកសិក្សាសម្រាប់ការចាប់ផ្តើមអនុវត្តការងារនេះ
- នាំឲ្យមានអនុសាសន៍ច្បាស់លាស់នានារួមបញ្ចូលទាំងអនុសាសន៍សម្រាប់ការអនុវត្តជាក់ស្តែងផងដែរ
- ត្រូវរៀបចំឲ្យបានចប់ រួមបញ្ចូលទាំងការរៀបចំរបាយការណ៍ កិច្ចការត្រៀមរៀបចំនានា ដែលត្រូវធ្វើក្នុង១សប្តាហ៍សម្រាប់ការធ្វើសវនកម្មស្ថាប័នអនុវត្តនីមួយៗនៅថ្នាក់ជាតិ និងសម្រាប់២រាជធានី ខេត្ត/ក្រុង ស្រុក
- ផ្អែកលើការធ្វើសវនកម្មស្ថាប័នអនុវត្តផ្សេងៗគ្នា ត្រូវបង្កលទ្ធភាពក្នុងការចងក្រងបាននូវមេរៀនកម្រិតជាតិក្នុងការសិក្សាវាយតម្លៃយុទ្ធសាស្ត្រយេនឌ័រ និងផែនទីបង្ហាញផ្លូវដើម្បីកែលំអ ឬជំនួសយុទ្ធសាស្ត្រទាំងនោះដោយជម្រើសសមស្របណាមួយ។

## ៤. វិធីសាស្ត្រ/សកម្មភាពដែលត្រូវអនុវត្ត

ទីប្រឹក្សានឹងត្រូវអនុវត្តសកម្មភាពនានាដូចខាងក្រោម ៖

- សិក្សាលើឯកសារដែលមានស្រាបនានា ដើម្បីឲ្យធ្វើមានការយល់ដឹងច្បាស់អំពីផអ៣ យុទ្ធសាស្ត្រយេនឌ័រនៃផអ៣ និងស្ថានភាពបច្ចុប្បន្នរបស់ស្ត្រី និងបុរសនៅក្នុងប្រទេសកម្ពុជា ដើម្បីទទួលបាននូវការយល់ដឹងអំពីបរិបទនៃប្រទេសកម្ពុជា។ បញ្ជីឯកសារសម្រាប់ការសិក្សានឹងត្រូវបាន កំណត់នៅខាងក្រោម
- សិក្សាលើបទពិសោធន៍ ឬគំរូនៃការអនុវត្តល្អលក្ខណៈអន្តរជាតិ ឧទាហរណ៍នានានៃសវនកម្មយេនឌ័រ កិច្ចដំណើរការ និងឧបការណ៍នានាសម្រាប់សវនកម្មយេនឌ័រ
- រៀបចំធ្វើបទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដើម្បីវាស់ស្ទង់ការរំពឹងទុករបស់ពួកគេ
- រៀបចំបង្កើតវិធីសាស្ត្រ/ឧបករណ៍សវនកម្មយេនឌ័រមួយសម្រាប់ស្ថាប័នអនុវត្តនៅថ្នាក់ជាតិ និង ស្ថាប័នអនុវត្តនៅថ្នាក់ក្រោមជាតិ
- ផ្តល់ការបណ្តុះបណ្តាលដើម្បីណែនាំតម្រង់ទិសដល់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីដែលត្រូវសហការជាមួយទីប្រឹក្សា និងចូលរួមក្នុងកិច្ចដំណើរការសវនកម្ម

- ធ្វើសវនកម្ម និងរៀបចំរបាយការណ៍សវនកម្មចំពោះស្ថាប័នអនុវត្តដូចមានរៀបរាប់នៅខាងក្រោម
- រៀបចំរបាយការណ៍រួមមួយស្តីពីលទ្ធផលនៃការពិនិត្យឡើងវិញ ការសិក្សាវាយតម្លៃ និងការលើកអនុសាសន៍នានា ដើម្បីកែលំអនូវការអនុវត្តយុទ្ធសាស្ត្រយេនឌ័រនៃផអ៣ក្នុងពេលបន្ទាន់ចំពោះមុខ និងការកំណត់នូវយុទ្ធសាស្ត្រនានាសម្រាប់ពេលអនាគត ការងារតាមវិស័យនានា ការសម្រេចចិត្តផ្នែកគោលនយោបាយ និងវិធានការនានាដែលអាចដាក់បញ្ចូលទៅក្នុងកម្មវិធីអនុវត្តសម្រាប់ជំហានបន្ទាប់

ក្នុងការអនុវត្តសកម្មភាពភាពទាំងនេះ ទីប្រឹក្សានឹងត្រូវជួបប្រជុំប្រចាំសប្តាហ៍ជាមួយក្រុមការងារមួយដែលសមាសភាពជាមន្ត្រីសេលខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី។ ក្នុងកិច្ចប្រជុំប្រចាំសប្តាហ៍នេះ ទីប្រឹក្សាត្រូវ៖

- ចែករំលែកព័ត៌មានអំពីកិច្ចការនានាដែលបានអនុវត្ត
- វាយការណ៍អំពីវឌ្ឍនភាពការងារ
- ដោះស្រាយបញ្ហានានាដែលអាចលើកឡើងដោយមន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប ឬមន្ត្រីនៃក្រសួងកិច្ចការនារី
- កំណត់បញ្ហាគន្លឹះនានា និងពិភាក្សាលើសេចក្តីសម្រេចចិត្តជាយុទ្ធសាស្ត្រនានា

## ៥. ភារកិច្ច និងការទទួលខុសត្រូវរបស់ទីប្រឹក្សាអន្តរជាតិ (ប្រធានក្រុម)

ប្រធានក្រុម គឺជាអ្នកគ្រប់គ្រងទូទៅលើក្រុមការងារសវនកម្ម (សមាសភាពនៃក្រុមការងាររួមមាន៖ ទីប្រឹក្សាអន្តរជាតិ០១រូប ទីប្រឹក្សាជាតិ០១រូប មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប និងមន្ត្រីនៃក្រសួងកិច្ចការនារី)។ ប្រធានក្រុមត្រូវមានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម ៖

- គ្រប់គ្រងក្រុមការងារ រួមទាំងការបែងចែកការងារ ការរៀបចំរបាយការណ៍ ការធ្វើបទបង្ហាញ និងការទំនាក់ទំនងជាមួយថ្នាក់គ្រប់គ្រងលេខាធិការដ្ឋាន គ.ជ.អ.ប
- ធានាគុណភាពការងារសមាជិកក្រុមការងារ និងផ្តល់ការគាំទ្រដល់សមាជិកក្រុមការងារក្នុងការបំពេញកិច្ចការរបស់ខ្លួន
- ផ្តល់យោបល់លើបញ្ហាបច្ចេកទេសនានាដែលពាក់ព័ន្ធនឹងជំនាញ និងបទពិសោធន៍របស់សមាជិកនានានៃក្រុមការងារ

## ៦. លទ្ធផលរំពឹងទុក

ការធ្វើសវនកម្មយេនឌ័រនេះរំពឹងថា កំណត់បាននូវរបកគំហើញនានា អនុសាសន៍ ប្រមូលចងក្រងបាននូវមេរៀនបទពិសោធន៍ និងការសិក្សាវាយតម្លៃលើការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី។ សវនកម្មយេនឌ័រនេះ ក៏ត្រូវបានរំពឹងថានឹងផ្តល់នូវអនុសាសន៍សម្រាប់ការរៀបចំតាក់តែងផែនការអនុវត្តដំណាក់កាលបន្ទាប់នៃកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

លទ្ធផលរំពឹងទុករួមមាន៖

- របាយការណ៍ខ្លីមួយសម្រាប់ដំណាក់កាលចាប់ផ្តើមដំបូងដែលកំណត់អំពីបញ្ហាសំខាន់ៗ និងផែនការការងារ
- កិច្ចប្រជុំប្រចាំសប្តាហ៍ជាមួយក្រុមការងារលេខាធិការដ្ឋាន និងក្រសួងកិច្ចការនារីព ដើម្បីផ្តល់ការគាំទ្រលើការអនុវត្តការងារ និងការចុះធ្វើសវនកម្មនៅតាមមូលដ្ឋាន (ដូចបានកំណត់នៅក្នុងតារាងខាងក្រោម)
- ការតម្រង់ទិស កិច្ចដំណើរការ និងឧបករណ៍សម្រាប់ធ្វើសវនកម្មនៅតាមស្ថាប័នអនុវត្តផអ៣នៅថ្នាក់ជាតិ។ ឧបករណ៍សម្រាប់ធ្វើសវនកម្មនៅថ្នាក់ជាតិនឹងមានលក្ខណៈលម្អិតជាងឧបករណ៍សម្រាប់ធ្វើសវនកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយហេតុថានៅស្ថាប័នអនុវត្តនៅថ្នាក់ជាតិមានតួនាទីក្នុងការធ្វើគោលនយោបាយ។ សេចក្តីព្រាងឧបករណ៍នានានឹងត្រូវបានរៀបចំរួចរាល់នៅក្នុងសប្តាហ៍ទី១។ ការពិនិត្យសម្រេច និងការកែសម្រួលបញ្ចប់ឧបករណ៍ទាំងនេះនឹងត្រូវអនុវត្តនៅក្នុងសប្តាហ៍ទី២។
- ការតម្រង់ទិស កិច្ចដំណើរការ និងឧបករណ៍នានាសម្រាប់ធ្វើសវនកម្មនៅតាមខេត្ត ក្រុងស្រុកគោលដៅ។ សេចក្តីព្រាងឧបករណ៍នានានឹងត្រូវបានរៀបចំរួចរាល់នៅក្នុង២សប្តាហ៍ និងការពិនិត្យសម្រេច និងការកែសម្រួលបញ្ចប់ឧបករណ៍ទាំងនេះនឹងត្រូវធ្វើឡើងនៅក្នុងសប្តាហ៍ទី២។
- វគ្គបណ្តុះបណ្តាលតម្រង់ទិសរយៈពេលកន្លះថ្ងៃសម្រាប់មន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីអំពីកិច្ចដំណើរការសវនកម្ម
- ធ្វើបទបង្ហាញអំពីលទ្ធផលនៃការធ្វើសវនកម្មជូនស្ថាប័នអនុវត្តនីមួយៗទាំង១១ស្ថាប័ន (ក្រុមការងារដែលចុះធ្វើសវនកម្មលើស្ថាប័នអនុវត្តនឹងត្រូវធ្វើបទបង្ហាញជូនស្ថាប័ននោះ)
- របាយការណ៍សង្ខេប (មិនលើសពី៥ទំព័រ) ស្តីពីលទ្ធផលនៃសវនកម្មលើស្ថាប័នអនុវត្តនីមួយៗ ទាំង១១ស្ថាប័ន (ក្រុមការងារដែលចុះធ្វើសវនកម្មលើស្ថាប័នអនុវត្តនឹងត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការធ្វើសវនកម្មលើស្ថាប័ននោះ)
- រៀបចំសិក្ខាសាលាមួយនៅលេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានការចូលរួមពីអ្នកពាក់ព័ន្ធដើម្បីពិភាក្សាលើលទ្ធផលបឋមនៃសវនកម្ម
- រៀបចំរៀបាយការណ៍បញ្ចប់ដែលសង្ខេបអំពីលទ្ធផលនៃសវនកម្ម ដែលបានសិក្សាវាយតម្លៃលើយុទ្ធសាស្ត្រយេនឌ័រនៃផអ៣ និងលើកអនុសាសន៍នានា ដើម្បីកែលំអនូវការអនុវត្តយុទ្ធសាស្ត្រយេនឌ័រនៃផអ៣ក្នុងពេលបន្ទាន់ចំពោះមុខ និងការកំណត់នូវយុទ្ធសាស្ត្រនានាសម្រាប់ពេលអនាគត ការងារតាមវិស័យនានា ការសម្រេចចិត្តផ្នែកគោលនយោបាយ និងវិធានការនានាដែលអាចដាក់បញ្ចូលទៅក្នុងកម្មវិធីអនុវត្តសម្រាប់ជំហានបន្ទាប់

## ៧. ទំហំការងារ និងសកម្មភាពនានា

លើកលែងតែអនុកម្មវិធីទី១ សវនកម្មយេនឌ័រនៅថ្នាក់ក្រោមជាតិនៃមួយនឹងអាចត្រូវបានរៀបចំបញ្ចប់នៅក្នុងសប្តាហ៍ទី១។ កិច្ចការទាំងនោះរួមមាន៖ ការងារសិក្សាឯកសារ ការប្រមូលទិន្នន័យពាក់ព័ន្ធ ការរៀបចំធ្វើបទសម្ភាសន៍ និងសិក្ខាសាលា ការកំណត់លក្ខណៈវិនិច្ឆ័យ ឬការដាក់ពិន្ទុ ការរៀបចំសេចក្តីព្រាងរបាយការណ៍ និងការធ្វើបទបង្ហាញសេចក្តីព្រាងរបាយការណ៍ជូនថ្នាក់ដឹកនាំស្ថាប័នអនុវត្តដែលបានធ្វើសវនកម្ម។ ដូចបានកំណត់ខាងលើ របាយការណ៍ទាំងនេះគឺជារបាយការណ៍សង្ខេបខ្លីមិនលើសពី៥ទំព័រ។

ការធ្វើសវនកម្មនៅថ្នាក់ជាតិនឹងត្រូវអនុវត្តលើអនុកម្មវិធីទី១ ទី២ ទី៤ និងទី៣ ដោយរួមបញ្ចូលទាំងបញ្ហានានាពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅថ្នាក់ក្រោមជាតិផងដែរ។ នៅថ្នាក់ក្រោមជាតិ ខេត្តចំនួន៤ និងក្រុង ស្រុកចំនួន៤ នឹងត្រូវជ្រើសរើសតាមលក្ខណៈចៃដន្យសម្រាប់ការធ្វើសវនកម្ម។ ការធ្វើសវនកម្មលើខេត្ត និងស្រុកក្នុងខេត្តនីមួយៗនឹងត្រូវធ្វើក្នុងរយៈពេល១សប្តាហ៍។

សវនកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការប្រព្រឹត្តទៅរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និងតួនាទីសមាជិកក្រុមប្រឹក្សា (ទាំងបុរស និងស្ត្រី) ក្នុងការធ្វើជាអ្នកតំណាងឲ្យផលប្រយោជន៍របស់ស្ត្រី និងកុមារ។ សេចក្តីព្រាងកាលវិភាគការងារមានកំណត់ក្នុងតារាងខាងក្រោម ៖

**តារាងទី១ ៖ កាលវិភាគការងារ**

| សកម្មភាព | ថិរវេលា |
|---|---|
| 1. ដំណាក់ការចាប់ផ្តើម/ការរៀបចំឧបករណ៍ | ២សប្តាហ៍ |
| 1.1. របាយការណ៍សម្រាប់ដំណាក់កាលចាប់ផ្តើម | |
| 1.2. រៀបចំបង្កើតឧបករណ៍សម្រាប់សវនកម្មតាមអនុកម្មវិធី | |
| 1.3. រៀបចំបង្កើតឧបករណ៍សម្រាប់សវនកម្មនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ | |
| 1.4. ការបណ្តុះបណ្តាលតម្រង់ទិសដល់ក្រុមការងារ | |
| 2. ការធ្វើសវនកម្ម | |
| 2.1. អនុកម្មវិធីទី១ | ២សប្តាហ៍ |
| 2.2. អនុកម្មវិធីទី២ | |
| 2.3. អនុកម្មវិធីទី៤ | |
| 2.4. ខេត្តទី១ និងស្រុកទី១ | ១សប្តាហ៍ |
| 2.5. ខេត្តទី២ និងស្រុកទី២ | |
| 2.6. ខេត្តទី៣ និងស្រុកទី៣ | |
| 2.7. ខេត្តទី១ និងស្រុកទី១ | |
| 3. ការរៀបចំរបាយការណ៍បញ្ចប់ និងការសិក្សាវាយតម្លៃលើយុទ្ធសាស្ត្រយេនឌ័រនៃផអ៣ | ១សប្តាហ៍ |

ទីប្រឹក្សាអន្តរជាតិនឹងមានរយៈពេល៦សប្តាហ៍សម្រាប់កិច្ចការនេះ។ ដូចបានកំណត់ខាងលើ កិច្ចនេះនឹងត្រូវអនុវត្តរួមគ្នាជាមួយក្រុមការងារមួយដែលមានទីប្រឹក្សាអន្តរជាតិ១រូប(ប្រធានក្រុម) ទីប្រឹក្សាជាតិ១រូប មន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប និងមន្ត្រីក្រសួងកិច្ចការនារី។ ទីប្រឹក្សាអន្តរជាតិមានកាតព្វកិច្ចសហការជាមួយក្រុមការងារ។ ផ្អែកតាមសកម្មភាព និងពេលវេលាដែលបានកំណត់ក្នុងតារាងខាងលើ ទីប្រឹក្សាអន្តរជាតិនឹងត្រូវ ៖

- ធ្វើការសហការជាមួយទីប្រឹក្សាជាតិក្នុងការរៀបចំបង្កើតឧបករណ៍សម្រាប់ធ្វើសវនកម្ម (២សប្តាហ៍)
- ធ្វើការសហការជាមួយទីប្រឹក្សាជាតិក្នុងការធ្វើសវនកម្មអនុកម្មវិធីទី១ (២សប្តាហ៍)
- ធ្វើការសហការជាមួយទីប្រឹក្សាជាតិ និងមន្ត្រីលេខាធិការដ្ឋាន និងក្រសួងកិច្ចការនារីក្នុងការធ្វើសវនកម្មខេត្តចំនួន១ និងស្រុកចំនួន១ (១សប្តាហ៍)
- ធ្វើការសហការជាមួយទីប្រឹក្សាជាតិក្នុងការរៀបចំរបាយការណ៍សវនកម្ម (១សប្តាហ៍)

ការធ្វើសវនកម្មជាបន្តបន្ទាប់លើអនុកម្មវិធីទី១ ទី៤ និងខេត្ត ក្រុង ស្រុកដែលបានកំណត់ដទៃទៀតនឹងត្រូវអនុវត្តដោយមន្ត្រីលេខាធិការដ្ឋាន គ.ជ.អ.ប និងមន្ត្រីក្រសួងកិច្ចការនារី ដោយមានការគាំទ្របច្ចេកទេសពីទីប្រឹក្សា។ ការទទួលខុសត្រូវការងារផ្សេងទៀតរបស់ទីប្រឹក្សាអន្តរជាតិមានកំណត់នៅក្នុងចំណុច៥ខាងលើ។

## ៨. ការរៀបចំនានា និងឯកសារសម្រាប់ការសិក្សា

លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីនឹងរៀបចំបង្កើតក្រុមការងារ១ដើម្បីគ្រប់គ្រងកិច្ចការងារនេះ និងអនុវត្តសវនកម្មមួយចំនួន។ លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីនឹងត្រូវ ៖

- ធានាដល់ការផ្តល់នូវទិន្នន័យ និងឯកសារពាក់ព័ន្ធនានា
- ឆ្លើយបតទៅនឹងសំណួរនានា
- ចាត់តាំងមន្ត្រីឲ្យចូលរួមការងារជាមួយទីប្រឹក្សា និងអនុវត្តនូវសវនកម្មមួយចំនួន
- រៀបចំគាំទ្រភស្តុភា កិច្ចប្រជុំ និងលិខិតរដ្ឋបាលនានា
- រៀបចំមធ្យោបាយធ្វើដំណើរសម្រាប់ទៅធ្វើសវនកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំសិក្ខាសាលា

ឯកសារដែលត្រូវផ្តល់ជូនរួមមាន ៖

- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ផអ៣ ២០១១-២០១៣
- ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំទាំងអស់ (២០១១-២០១៣)
- របាយការណ៍វឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ
- ទិន្នន័យមូលដ្ឋានស្តីពីការសិក្សាវាយតម្លៃសមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ទិន្នន័យមូលដ្ឋានស្តីពីការអង្កេតអភិបាលកិច្ច

- របាយការណ៍សិក្សាវាយតម្លៃអំពីផលប៉ះពាល់នៃមូលនិធិឃុំ សង្កាត់លើភាពក្រីក្រ និងសុខមាលភាព
- របាយការណ៍ស្ដីពីការវិភាគយេនឌ័រនៃកំណែទម្រង់វិមជ្ឈការនៅកម្ពុជា រៀបចំដោយវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០១២
- ផ្ដល់លទ្ធភាពក្នុងការទទួល សិក្សាលើទិន្នន័យនានា បណ្ណាល័យនៃឯកសាច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

## ៩. ជំនាញ និងលក្ខណៈសម្បត្តិនៃទីប្រឹក្សា

ក្រុមការងារមួយដែលមានទីប្រឹក្សាអន្តរជាតិ១រូប និងទីប្រឹក្សាជាតិ១រូប។ ទីប្រឹក្សាអន្តរជាតិដែលនឹងត្រូវជ្រើសរើសសម្រាប់កិច្ចការសវនកម្មយេនឌ័រនៃនឹងត្រូវបំពេញការងារក្នុងរយៈពេល៦សប្ដាហ៍ និងត្រូវមានជំនាញ និងលក្ខណសម្បត្តិដូចខាងក្រោម៖

| ប្រវត្តិ/បទពិសោធន៍ការងារ | ជំនាញ |
|---|---|
| **តម្រូវការ៖**<br>- មានបទពិសោធន៍ក្នុងការរៀបចំបង្កើតឧបករណ៍សម្រាប់ធ្វើសវនកម្មយេនឌ័រក្នុងរយៈពេលកន្លងមក<br>- មានបទពិសោធន៍ក្នុងការរៀបចំធ្វើសវនកម្មយេនឌ័រក្នុងរយៈពេលកន្លងមក<br>- យ៉ាងតិចមានសញ្ញាប័ត្រកម្រិតបរិញ្ញាទៅផ្នែកយេនឌ័ររដ្ឋបាលសាធារណៈ គោលនយោបាយសាធារណៈ វិទ្យាសាស្ត្រសង្គម និងការសិក្សាពាក់ព័ន្ធផ្សេងទៀត<br>**តម្រូវការដែលចង់បានបំផុត៖**<br>- មានបទពិសោធន៍យ៉ាងតិច៥ឆ្នាំលើការងារបញ្ជ្រាបយេនឌ័រក្នុងកម្មវិធី និងគម្រោងនានា<br>- មានបទពិសោធន៍យ៉ាងតិច៣ឆ្នាំលើការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃ ឬសវនកម្មលើការបំពេញការងារ<br>- មានបទពិសោធន៍ក្នុងការបំពេញការងារជាប្រធានក្រុម<br>- មានបទពិសោធន៍ក្នុងការធ្វើសវនកម្មផ្នែកស្ថាប័ន/សង្គមដែលផ្អែកលើភស្តុតាង | - ការបញ្ជ្រាបយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី<br>- កំណែទម្រង់រដ្ឋបាលមូលដ្ឋាន/វិមជ្ឈការ និងវិសហមជ្ឈការ |

# ឧបសម្ព័ន្ធទី ២
## បញ្ជីឯកសារដែលបានធ្វើការសិក្សា

- សេចក្តីព្រាងឯកសារស្តីពីយេនឌ័រក្នុងក្របខ័ណ្ឌការងារគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត ៖ សេចក្តីសង្ខេបរៀបចំដោយលោកស្រី Andersen Henny ក្នុងឆ្នាំ២០១៣
- ការសិក្សាវាយតម្លៃអំពីជម្រើសសម្រាប់ការរៀបចំបង្កើតឧបករណ៍ផ្តល់ហិរញ្ញប្បទានវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ(SNIF)នៅកម្ពុជា ដោយលោក Ayandele, Olajumoke; Nary Ung and Tschabold, Matthew ខែឧសភា ឆ្នាំ២០១៣
- របាយការណ៍ស្តីពីការបញ្ជ្រាបយេនឌ័រ និងវិមជ្ឈការ ៖ ការសិក្សាវាយតម្លៃនៃកិច្ចដំណើរការជាមួយនឹងអនុសាសន៍នានារបស់ UNDP/SEILA/UNFPA/UNICEF/WB/MoWA រៀបចំដោយ Brereton Helen ឆ្នាំ២០០៦
- សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលសវនកម្មយេនឌ័រ ៖ វិធីសាស្ត្រសវនកម្មយេនឌ័រដោយមានការចូលរួម រៀបចំដោយអង្គការ ILO ឆ្នាំ២០១២ នៅទីក្រុង Geneva
- សៀវភៅណែនាំសង្ខេបស្តីពីសវនកម្មយេនឌ័រ ៖ ឧបករណ៍សម្រាប់ការវាយតម្លៃផ្នែកស្ថាប័នដោយខ្លួនឯង និងការផ្លាស់ប្តូរ រៀបចំដោយ Inter-Action នៅទីក្រុង Washington DC ឆ្នាំ ២០១០
- របាយការណ៍ស្តីពីការវិភាគយេនឌ័រនៃកំណែទម្រង់វិមជ្ឈការនៅកម្ពុជា រៀបចំដោយលោក គីម សេដ្ឋារ៉ា និងលោក Öjendal, Joakim នៃវិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ខែធ្នូ ឆ្នាំ២០១២
- របាយការណ៍ស្តីពីការកៀរគរប្រភពចំណូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយ Martinez -Vazquez, Jorge នៃសកលវិទ្យាល័យ Andrew Young School of Policy Studies Georgia State ឆ្នាំ២០១២
- ផែនការសកម្មភាពបញ្ជ្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០០៨ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហការជាមួយក្រសួងកិច្ចការនារី ឆ្នាំ២០០៨
- ប្រកាសលេខ ៤២៧៥ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំបង្កើត និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- របាយការណ៍ស្តីពីលទ្ធផលនៃកាតដាក់ពិន្ទុលើការអនុវត្តគោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជានៅថ្នាក់ក្រោមជាតិ តាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗនៅឆ្នាំ២០១២, រៀបចំដោយក្រសួងផែនការ រាជធានីភ្នំពេញ ខែកក្កដា ឆ្នាំ២០១២។
- ស្ថានភាពនៃកាតដាក់ពិន្ទុតាមវិស័យនានានៅតាមរាជធានី ខេត្ត រៀបចំដោយក្រសួងផែនការ រាជធានីភ្នំពេញ ខែកក្កដា ឆ្នាំ២០១៣

- ស្ថានភាពនៃកាតដាក់ពិន្ទុតាមវិស័យនានានៅតាមស្រុកនីមួយៗនៃខេត្តស្វាយរៀង រៀបចំដោយក្រសួងផែនការ នៅរាជធានីភ្នំពេញ ខែកក្កដា ឆ្នាំ២០១៣
- ស្ថានភាពនៃកាតដាក់ពិន្ទុតាមវិស័យនានានៅតាមឃុំនីមួយៗនៃស្រុកសំបូរ រៀបចំដោយក្រសួងផែនការ នៅរាជធានីភ្នំពេញ ខែឧសភា ឆ្នាំ២០១៣
- ស្ថានភាពនៃកាតដាក់ពិន្ទុតាមវិស័យនានានៅតាមស្រុកនីមួយៗនៃខេត្តក្រចេះ រៀបចំដោយក្រសួងផែនការ នៅរាជធានីភ្នំពេញ ខែកក្កដា ឆ្នាំ២០១៣
- ស្ថានភាពនៃកាតដាក់ពិន្ទុតាមវិស័យនានានៅតាមស្រុកនីមួយៗនៃខេត្តបាត់ដំបង រៀបចំដោយក្រសួងផែនការ នៅរាជធានីភ្នំពេញ ខែកក្កដា ឆ្នាំ២០១៣
- របាយការណ៍នៃការសិក្សាវាយតម្លៃយេនឌ័រនៅកម្ពុជា ស្តីពីការចែករំលែកដោយយុត្តិធម៌សម្រាប់ស្ត្រី រៀបចំដោយក្រសួងកិច្ចការនារី នៅរាជធានីភ្នំពេញ ខែមេសា ឆ្នាំ២០០៨
- ព្រឹត្តិបត្រព័ត៌មាននារីរតនៈ លេខ០៧ ចុះខែមីនា ឆ្នាំ២០១៣ របស់ក្រសួងកិច្ចការនារី
- ឯកសារសវនកម្មយេនឌ័រ រៀបចំដោយ Moser, Caroline; M'Chaju-Liwewe, Olivia; Moser, Annalise and Ngwira, Naomi នៃ DFIDនៅប្រទេស Malawi, ខែតុលា ឆ្នាំ២០០៤
- ឯកសារណែនាំអំពីវិធីសាស្ត្រម្រាប់ការធ្វើសវនកម្មយេនឌ័រ ដែលតាក់តែង និងអនុវត្តនៅក្នុង DFID នៅប្រទេស Malawi រៀបចំដោយ Moser, Caroline នៅទីក្រុងឡុង ខែឧសភា ឆ្នាំ ២០០៥
- សេចក្តីណែនាំស្តីពីតួនាទី និងរបៀបរបបការងារនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៃក្រុមប្រឹក្សារាជធានី ខេត្ត រៀបចំដោយ គ.ជ.អ.ប ខែកញ្ញា ឆ្នាំ២០១១
- ផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប ឆ្នាំ២០១១ រៀបចំដោយ គ.ជ.អ.ប ឆ្នាំ២០១០
- របាយការណ៍ស្តីពីលទ្ធផលនៃការអង្កេតអភិបាលកិច្ច រៀបចំដោយ គ.ជ.អ.ប រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២
- ទិន្នន័យមូលដ្ឋានស្តីពីលទ្ធផលនៃការសិក្សាវាយតម្លៃសមត្ថភាពក្រុង ស្រុក ខណ្ឌ រៀបចំដោយ គ.ជ.អ.ប រាជធានីភ្នំពេញ ខែកញ្ញា ឆ្នាំ២០១២
- ឯកសារបច្ចេកទេសបច្ចេកទេសស្តីពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សម្រាប់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដោយ គ.ជ.អ.ប ខែតុលា ឆ្នាំ២០១២
- របាយការណ៍ស្តីពីលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផអ៣ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយ គ.ជ.អ.ប រាជធានីភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០១២
- ឯកសារបច្ចេកទេសបច្ចេកទេសស្តីពីកិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដោយ គ.ជ.អ.ប រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ ២០១២

- របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីការអនុវត្តផអ៣ ដោយ គ.ជ.អ.ប រាជធានីភ្នំពេញ ខែមករា ឆ្នាំ២០១៣
- ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៣របស់ គ.ជ.អ.ប រាជធានីភ្នំពេញ ខែមករា ឆ្នាំ ២០១៣
- ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយ គ.ជ.អ.ប រាជធានីភ្នំពេញ ខែកក្កដា ឆ្នាំ២០១៣
- របាយការណ៍វឌ្ឍនភាពប្រចាំឆមាសទី១ស្តីពីការអនុវត្តផអ៣ ដោយ គ.ជ.អ.ប រាជធានីភ្នំពេញ ខែមករា ឆ្នាំ២០១៣
- ក្របខ័ណ្ឌការងារអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយ គ.ជ.អ.ប ខែមករា ឆ្នាំ២០១៣
- ឯកសារពន្យារពេលផអ៣នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយ គ.ជ.អ.ប រាជធានីភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០១៣
- ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៤របស់ គ.ជ.អ.ប រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០១៣
- សេចក្តីព្រាងវិធានផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក ដោយលេខាធិការដ្ឋាន គ.ជ.អ.ប ខែមីនា ឆ្នាំ២០១២
- សេចក្តីព្រាងរបាយការណ៍ស្តីពីការវិភាពផលប៉ះពាល់នៃយន្តការផ្ទេរមូលនិធិឃុំ សង្កាត់ក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដោយលោក នី បូរ៉េត នៃលេខាធិការដ្ឋាន គ.ជ.អ.ប រាជធានីភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១៣
- ឯកសារកម្មវិធិជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១០-២០១៩) ដោយរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០
- ឯកសារផែនការអនុវត្តបីឆ្នាំដំបូងនៃកម្មវិធិជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២០១១-២០១៣) ដោយរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០១១
- អនុក្រឹត្យលេខ ៣៦ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំបង្កើត និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- អនុក្រឹត្យលេខ ១៧២ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក

# ឧបសម្ព័ន្ធទី ៣.១ “ក”

## សវនកម្មយេនឌ័រសម្រាប់ផអ៣៖ អនុកម្មវិធី

## ការបញ្ជ្រាបយេនឌ័រក្នុងផអ៣

| | កូឡោនទី១ | កូឡោនទី២ | កូឡោនទី៣ |
|---|---|---|---|
| ល.រ | វិធានការពាក់ព័ន្ធនានាពីយុទ្ធសាស្ត្រយេនឌ័រនៃផអ៣ | ភស្តុតាងដែលការឆ្លុះបញ្ចាំងក្នុងការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ ក្នុងផអ៣ និងអនុកម្មវិធី | កម្រិតនៃការដាក់បញ្ចូល |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

**ពិន្ទុទូទៅ**

**ដូចពិន្ទុទូទៅដែរ**

៣ = បានបញ្ចូលយ៉ាងពេញលេញ

២ = បានបញ្ចូលស្ទើរពេញលេញ

១ = បានបញ្ចូលខ្លះៗ

0 = ពុំបានដាក់បញ្ចូល

**ឧបសម្ព័ន្ធទី ៣.១ "ខ"**

## សវនកម្មយេនឌ័រសម្រាប់ផអ៣៖ អនុកម្មវិធី
## ការបញ្ជ្រាបយេនឌ័រក្នុងផែនការសកម្មភាព និងថវិកា

| ល.រ<br>(កូឡោនទី១) | វិធានការនានាពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ នៅក្នុងអនុកម្មវិធីនានានៃផអ៣<br>(កូឡោនទី១) | ភស្តុតាងដែលឆ្លុះបញ្ចាំងក្នុងការឆ្លើយតបបញ្ហាយេនឌ័រក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (កូឡោនទី២) | | | កម្រិតនៃការដាក់បញ្ចូល<br>(កូឡោនទី៣) |
|---|---|---|---|---|---|
| | | ឆ្នាំ២០១១ | ឆ្នាំ២០១២ | ឆ្នាំ២០១៣ | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

**ពិន្ទុទូទៅ** **ដូចពិន្ទុទូទៅដែរ**

៣ = បានបញ្ចូលយ៉ាងពេញលេញ

២ = បានបញ្ចូលស្ទើរពេញលេញ

១ = បានបញ្ចូលខ្លះៗ

0 = ពុំបានដាក់បញ្ចូល

## ឧបសម្ព័ន្ធទី ៣.១ "គ"

**សវនកម្មយេនឌ័រសម្រាប់ផអ៣៖ អនុកម្មវិធី**

**ថវិកា និងការអនុវត្តវិធានការនានាក្នុងការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ**

| | កូឡោនទី១ | កូឡោនទី២ | កូឡោនទី៣ | កូឡោនទី៤ |
|---|---|---|---|---|
| ល.រ | វិធានការនានាពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រនៅក្នុង ផ.ស.ថ របស់អនុកម្មវិធីនានានៃផអ៣ | ថវិកាវិភាជន៍ | ស្ថានភាពនៃការអនុវត្ត | ថវិកាចំណាយ |
| | ២០១១ | | | |
| | | | | |
| | | | | |
| | ២០១២ | | | |
| | | | | |
| | | | | |
| | ២០១៣ | | | |
| | | | | |
| | | | | |

**ពិន្ទុទូទៅក្នុងការអនុវត្តវិធានការឆ្លើយតបទៅនឹងបញ្ហាយេនឌ័រដែលបានដាក់បញ្ចូលក្នុង ផ.ស.ថ**

៣ = បានអនុវត្តយ៉ាងពេញលេញ

២ = បានអនុវត្តស្ទើរពេញលេញ

១ = បានអនុវត្តខ្លះៗ

0 = ពុំបានអនុវត្ត

## ឧបសម្ព័ន្ធទី ៣.២
## បញ្ជីសំណួរវាយតម្លៃដោយខ្លួនឯងរបស់បុគ្គលពាក់ព័ន្ធម្នាក់ៗ
## សម្រាប់ការធ្វើសវនកម្មយេនឌ័រនៃផអ៣នៅតាមអនុកម្មវិធីនីមួយៗ

សវនកម្មយេនឌ័រសម្រាប់ផអ៣ ត្រូវបានកំណត់ជាសកម្មភាពអាទិភាពនៅក្នុងផែនការការងារ និងថវិកាប្រចាំឆ្នាំ២០១៣នៃផអ៣។ ជាផ្នែកមួយនៃការធ្វើសវនកម្មយេនឌ័រនេះ យើងនឹងពិគ្រោះពិភាក្សាយោបល់ជាមួយមន្ត្រី និងបុគ្គលិកពាក់ព័ន្ធនានា តាមរយៈបញ្ជីសំណួរនេះ ដើម្បីស្វែងយល់ឲ្យបានកាន់តែច្បាស់អំពីទស្សទាន និងការអនុវត្តនានាសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការផ្តល់អំណាចឲ្យស្ត្រីក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ក្នុងការបំពេញបញ្ជីសំណួរនេះលោក លោកស្រីប្រហែលជាត្រូវចំណាយពេលវេលាមិនលើសពី១៥នាទីឡើយ។ ចំពោះសំណួរនីមួយៗខាងក្រោម សូមជ្រើសរើសយកចម្លើយតែមួយដែលលោក លោកស្រី យល់ឃើញថាសមស្របបំផុតក្នុងចំណោមចម្លើយទាំងឡាយ។ **លើកលែងតែសំណួរទី៤ លោក លោកស្រីអាចគូសចម្លើយលើសពី១។**

យើងសូមស្វាគមន៍ និងអរគុណចំពោះការចូលរួមរបស់លោក លោកស្រីក្នុងការធ្វើសវនកម្មយេនឌ័រក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ចូរជ្រើសរើសយកចម្លើយមួយក្នុងចំណោមចម្លើយទាំងឡាយខាងក្រោម ៖

**អនុកម្មវិធីដែលលោក លោកស្រីទទួលខុសត្រូវក្នុងការអនុវត្ត ៖**

☐ អនុកម្មវិធីទី១

☐ អនុកម្មវិធីទី២

☐ អនុកម្មវិធីទី៣

☐ អនុកម្មវិធីទី៤

១. តើលោក លោកស្រីគិតថា រាជរដ្ឋាភិបាលកម្ពុជា និងគ.ជ.អ.ប ចាត់ទុកបញ្ហាយេនឌ័រសំខាន់កម្រិតណាក្នុងការធ្វើឲ្យសម្រេចបាននូវគោលដៅរួមរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ?

☐ សំខាន់ខ្លាំង

☐ សំខាន់

☐ មិនសូវសំខាន់

☐ មិនសំខាន់អ្វីទាំងអស់

២. តើលោក លោកស្រី បានអានឧបសម្ព័ន្ធកម្មវិធីជាតិ គ.ជ.អ.ប ស្តីអំពីការបញ្ជ្រាបយេនឌ័រក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ផអ៣ ដែរឬទេ?

☐ បានអានទាំងពីរ

☐ បានអានមួយក្នុងចំណោមពីរ

☐ មិនបានអានទាំងពីរ

៣. តើយុទ្ធសាស្ត្រយេនឌ័រនៃផអ៣ ផ្តល់គោលការណ៍ណែនាំច្បាស់លាស់ដែរឬទេ ចំពោះការដាក់បញ្ចូលសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីទៅក្នុងការអនុកម្មវិធីដែលលោក លោកស្រីទទួលខុសត្រូវក្នុងការអនុវត្ត?

☐ ច្បាស់លាស់ល្អណាស់

☐ ច្បាស់លាស់ខ្លះៗ

☐ មិន ច្បាស់លាស់អ្វីទាំងអស់

☐ មិនដឹងទេ ព្រោះមិនដែលបានអានផង

៤. តើអនុសាសន៍ណាមួយក្នុងចំណោមអនុសាសន៍ខាងក្រោមនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រយេនឌ័រផអ៣៖ *(សំណួរទី៤នេះ លោក-លោកស្រី ជ្រើសចម្លើយអាចលើសពីមួយ)*

ក. ការធ្វើសមាហរណកម្មទស្សនៈយេនឌ័រទៅក្នុងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត កម្មវិធីនិងគម្រោងនានាដែលពាក់ព័ន្ធការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ខ. រៀបចំតាក់តែងគោលនយោបាយ ដើម្បីធ្វើឲ្យប្រសើរឡើងនូវតុល្យភាពយេនឌ័រ នៅក្នុងកម្មវិធីនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

គ. ការដាក់បញ្ចូលនូវបទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធមានដូចជា បទបញ្ញត្តិដែលមានលក្ខណៈជាអន្តរជាតិ (ឧ. សន្ធិសញ្ញាCEDAW) ច្បាប់នៅក្នុងប្រទេសកម្ពុជា យុទ្ធសាស្ត្រថ្នាក់ជាតិ (ឧ. នារីរតនៈ ទី២) និងផែនការតាមវិស័យនានា (ឧ. ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ ) ទៅក្នុងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ។

ឃ. ដាក់បញ្ចូលសូចនាករដែលពាក់ពាន្ធ័ទៅនឹងយេនឌ័រទាំងគុណភាព និងទាំងបរិមាណ ក្នុងការវាយតម្លៃការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ង. មិនដឹង។

៥. តើស្ថាប័នអនុវត្តអនុកម្មវិធីរបស់លោក លោកស្រី ចាត់ទុកយុទ្ធសាស្ត្រយេនឌ័រក្នុង ផអ៣ សំខាន់កម្រិតណាក្នុងការសម្រេចគោលដៅរួម?

☐ សំខាន់ខ្លាំង

☐ សំខាន់

☐ មិនសូវសំខាន់

☐ មិនសូវសំខាន់អ្វីទាំងអស់

៦. តើលោក លោកស្រីមានដឹងទេថា ការលើកកម្ពស់សមភាពយេនឌ័រមានសារៈសំខាន់កម្រិតណានៅក្នុងដំណើការជ្រើសរើសបុគ្គលិក? (ពោលគឺ៖ ការជ្រើសរើស ការសម្ភាសន៍ ការតែងតាំងបុគ្គលិក។ល។)

☐ ដឹងច្បាស់

☐ ដឹងគ្រប់គ្រាន់

☐ ដឹងមិនគ្រប់គ្រាន់

☐ មិនដឹងគ្រប់គ្រាន់អ្វីទាំងអស់

៧. តើលោក លោកស្រី គិតអំពីបញ្ហាយេនឌ័រនៅក្នុងការអនុវត្តការងារផ្ទាល់ខ្លួនក្នុងកម្រិតណា?

☐ ជានិច្ចកាល

☐ ជារឿយៗ

☐ យូរៗម្តង

☐ មិនដែល

៨. តើប្រព័ន្ធនៃការរៀបចំ និងអនុវត្តកម្មវិធីក្នុងស្ថាប័នរបស់លោក លោកស្រី ធានាដល់គុណភាពនៃការអនុវត្តយុទ្ធសាស្ត្រយេនឌ័រផអ៣បានល្អកម្រិតណា?

☐ ល្អណាស់

☐ គ្រប់គ្រាន់

☐ មិនគ្រប់គ្រាន់

☐ មិនគ្រប់គ្រាន់អ្វីទាំងអស់

៩. កាលពីឆ្នាំកន្លងទៅ តើលោក លោកស្រីបានពិគ្រោះយោបល់ដោយផ្ទាល់ជាមួយនឹងមន្ត្រីក្រសួងកិច្ចការនារី ទីប្រឹក្សាយេនឌ័រ ឬក៏អ្នកជំនាញផ្នែកយេនឌ័រផ្សេងទៀតក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការងាររបស់លោក លោកស្រី ប៉ុន្មានដងដែរ?

☐ ច្រើនជាង៣ដង

☐ ២ដង

☐ ម្តង

☐ មិនដែលសោះ

☐ គ្មានសារៈសំខាន់សម្រាប់ខ្ញុំទេចំពោះការងារនេះ

១០. តើលោក លោកស្រីគិតថាស្ថាប័នដែលកំពុងអនុវត្តអនុកម្មវិធីរបស់លោក លោកស្រី បានរៀបចំទុកជាមុនគ្រប់គ្រាន់សម្រាប់ដំណាក់កាលមួយទៅមួយក្នុងការជ្រើសរើសមន្ត្រីជាស្ត្រី?

☐ បានល្អណាស់

☐ បានល្អ

☐ បានតិចតួចណាស់

☐ មិនបានរៀបចំអ្វីទាំងអស់

១១. តើស្ត្រីត្រូវបានមើលឃើញ និងយកចិត្តទុកដាក់ដូចបុរសដែរឬទេ នៅក្នុងស្ថាប័នដែលកំពុងតែអនុវត្តអនុកម្មវិធីរបស់លោក លោកស្រី? កម្រិតណា?

☐ ស្ត្រីត្រូវបានលើកកម្ពស់យ៉ាងសកម្ម និងការលើកកម្ពស់នេះសមរម្យរួចហើយ

☐ បុរសនិងស្ត្រី ត្រូវគេយកចិត្តទុកដាក់ និងផ្តល់ឱកាសដូចគ្នា

☐ មានករណីករណីខ្លះដែលរើសអើងចំពោះស្ត្រីពាក់ព័ន្ធនឹងការចំណាយ ឬប្រយោជន៍ ដោយសារស្ត្រីមានការទទួលខុសត្រូវតិចជាង

☐ ស្ត្រីត្រូវបានគេមិនយកទុកដាក់ដូចបុរសទេ

១២. តើលោក លោកស្រីវាយតម្លៃកម្រិតណា ចំពោះការចូលរួមយ៉ាងសកម្ម នៃស្ថាប័នអនុកម្មវិធីរបស់លោក លោកស្រី កំពុងអនុវត្តទាក់ទងនឹងការលើស្ទួយសមភាពយេនឌ័រដូចជាការធ្វើសេចក្តីសម្រេចចិត្ត អាកប្បកិរិយា ឥរិយាបទ ក្រមសីលធម៌នៃការងារ និងព័ត៌មាន?

☐ ល្អប្រសើរ

☐ គ្រប់គ្រាន់

☐ មិនគ្រប់គ្រាន់

☐ មិនមែនគោលនយោបាយបែបនេះទេ

១៣. តើអង្គភាពរបស់លោក លោកស្រី បានចាត់វិធានការទប់ស្កាត់នឹងសកម្មភាពដែលមិនលើកកម្ពស់សមភាពយេនឌ័រគ្រប់គ្រាន់កម្រិតណា ដូចជាការចាត់វិធានការទប់ស្កាត់ការតាំងផ្ទាំងរូបភាពធំ ការសម្តែងមតិយោបល់ និងការនិយាយរឿងកំប្លែងដែលមិនគោរពតម្លៃរបស់ស្ត្រី។ល។?

☐ លើសពីគ្រប់គ្រាន់

☐ គ្រប់គ្រាន់

☐ មិនគ្រប់គ្រាន់

☐ គ្មានទាល់តែសោះ

១៤. តើលោក លោកស្រីយកចិត្តទុកដាក់កម្រិតណាក្នុងការធានាទំនាក់ទំនងដោយការគោរពរវាងបុរស និងស្ត្រីក្នុងកន្លែងធ្វើការរបស់លោក លោកស្រី?

☐ ខ្លាំងណាស់

☐ ខ្លះៗ

☐ មិនគ្រប់គ្រាន់

☐ គ្មានទាល់តែសោះ

១៥. កិច្ចប្រជុំទាំងឡាយនៅក្នុងអង្គភាពរបស់លោក លោកស្រីមានការបញ្ចេញមតិគ្របដណ្តប់លើសលប់ដោយបុរស។

☐ មិនយល់ស្របខ្លាំង

☐ មិនយល់ស្រប

☐ យល់ស្រប

☐ យល់ស្របខ្លាំង

១៦. ការអនុវត្តយុទ្ធសាស្ត្រយេនឌ័រ ផអ៣ គឺជាការទទួលខុសត្រូវរបស់ទីប្រឹក្សាយេនឌ័រ និងក្រសួងកិច្ចការនារី។

☐ មិនយល់ស្របខ្លាំង

☐ មិនយល់ស្រប

☐ យល់ស្រប

☐ យល់ស្របខ្លាំង

១៧. តើលោក លោកស្រីធ្លាប់បានចាត់វិធានការណាមួយក្នុងការលើកស្ទួយសមភាពយេនឌ័រ ក្នុងការតាក់តែង និងអនុវត្ត ផអ៣ ឬឆ្លើយតបនឹងបញ្ហាទាក់ទងនឹងយេនឌ័រ ក្នុងអង្គភាពការងាររបស់លោក លោកស្រី?

☐ ច្រើន

☐ ខ្លះៗ

☐ តិចតួច

☐ គ្មានទាល់តែសោះ

១៨. តើមានសារៈសំខាន់កម្រិតណាក្នុងការលើកស្ទួយសមភាពយេនឌ័រចំពោះដៃគូរអភិវឌ្ឍន៍?

☐ សំខាន់ណាស់ចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់

☐ សំខាន់ចំពោះដៃគូអភិវឌ្ឍន៍មួយចំនួន

☐ សំខាន់តិចតួចចំពោះដៃគូអភិវឌ្ឍន៍

☐ មិនសំខាន់ចំពោះដៃគូអភិវឌ្ឍន៍អ្វីទាំងអស់

១៩. តើមានសារៈសំខាន់កម្រិតណាចំពោះការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល ក្នុងការតាក់តែង និងការអនុវត្តយុទ្ធសាស្ត្រយេនឌ័រនៅក្នុងផអ៣?

☐ សំខាន់ខ្លាំងណាស់

☐ សំខាន់

☐ មិនសូវសំខាន់

☐ មិនសំខាន់អ្វីទាំងអស់

២០. តើលោក លោកស្រីមានការរំពឹងថានឹងបញ្ជ្រាបបញ្ហាយេនឌ័រទៅក្នុងដំណាក់កាលនានានៃការរៀបចំ ឬតាក់តែងកម្មវិធី ឬសកម្មភាពដែរឬទេ? តើលោក លោកស្រីគិតថាក្តីរំពឹងនេះនឹងបានល្អកម្រិតណា?

☐ អាចរំពឹងច្រើន

☐ អាចរំពឹងគ្រប់គ្រាន់

☐ មិនអាចរំពឹងគ្រប់គ្រាន់ទេ

☐ មិនមានរំពឹងអ្វីទាំងអស់

☐ មិនត្រូវបានរំពឹង

២១. តើអង្គភាពរបស់លោក លោកស្រីផ្តល់ឱកាស ដើម្បីពង្រឹងចំណេះដឹងទាក់ទងនឹងបញ្ហាយេនឌ័រក្នុងវិជ្ជាជីវៈ ឬជំនាញបច្ចេកទេសការងាររបស់លោក លោកស្រីដែរឬទេ? ក្នុងកម្រិតណា? (ឧទា. ការកសាងសមត្ថភាព ការបណ្តុះបណ្តាល ការគាំទ្របច្ចេកទេស ការចងក្រងឯកសារ)

☐ លើសពីគ្រប់គ្រាន់

☐ គ្រប់គ្រាន់

☐ មិនគ្រប់គ្រាន់

☐ មិនគ្រប់គ្រាន់អ្វីទាំងអស់

២២. តើលោក លោកស្រីគិតថា មានឧបករណ៍សម្រាប់ (ឧទាហរណ៍៖ គោលការណ៍ណែនាំ ក្បួនខ្នាត បញ្ជីចុះត្រួតពិនិត្យ... ។ល។) និងបច្ចេកទេសគ្រប់គ្រាន់សម្រាប់លោក លោកស្រី ប្រើប្រាស់ក្នុងការបញ្ជ្រាបយេនឌ័រក្នុងការងាររបស់លោក លោកស្រី? ហើយក្នុងកម្រិតណា?

☐ លើសពីគ្រប់គ្រាន់

☐ គ្រប់គ្រាន់

☐ មិនគ្រប់គ្រាន់

☐ គ្មានអ្វីទាំងអស់

២៣. តើលោក លោកស្រីមានលទ្ធភាពទទួលព័ត៌មាន បទពិសោធន៍អនុវត្តការងារ និងការប្រើប្រាស់ឧបករណ៍នានា សម្រាប់ធ្វើការវិភាគយេនឌ័រ និងបញ្ចូលលទ្ធផលនៃការវិភាគទាំងនេះទៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការតាក់តែងកម្មវិធី និងសកម្មភាពដែរឬទេ? ក្នុងកម្រិតណា?

☐ ពេញលេញ

☐ គ្រប់គ្រាន់

☐ មិនគ្រប់គ្រាន់

☐ គ្មានអ្វីទាំងអស់

២៤. តើលោក លោកស្រីអាចនិយាយបានទេថា សមត្ថភាពរបស់ស្ថាប័នរបស់លោក លោកស្រីក្នុងការវិភាគយេនឌ័រ និងបញ្ចូលលទ្ធផលការវិភាគទាំងនេះទៅក្នុងដំណើរការកសាងផែនការបានកម្រិតណា?

☐ មានសមត្ថភាពខ្លាំង

☐ មានសមត្ថភាពគ្រប់គ្រាន់

☐ មិនមានសមត្ថភាពគ្រប់គ្រាន់

☐ មិនមានសមត្ថភាពទាល់តែសោះ

២៥. តើលោក លោកស្រីពេញចិត្តកម្រិតណា ចំពោះការរួមចំណែកគាំទ្ររបស់ទីប្រឹក្សាយេនឌ័រនៃលេខាធិការដ្ឋាន គ.ជ.អ.ប លើការបញ្ជ្រាបយេនឌ័រក្នុងកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ?

☐ ពេញចិត្តខ្លាំងណាស់

☐ ពេញចិត្ត

☐ មិនពេញចិត្ត

☐ គ្មានបានទទួលការគាំទ្រទេ នៅពេលស្នើសុំ

☐ ពុំបានស្នើសុំជំនួយ

២៦. តើលោក លោកស្រីវាយតម្លៃកម្រិតណា ចំពោះការរួមចំណែកគាំទ្ររបស់ក្រសួងកិច្ចការនារីលើការបញ្ជ្រាបយេនឌ័រក្នុងកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ?
□ ល្អប្រសើរ
□ គ្រប់គ្រាន់
□ មិនគ្រប់គ្រាន់
□ គ្មានបានជួយ
□ មិនដឹង

២៧. តើលោក លោកស្រីវាយតម្លៃកម្រិតណា ចំពោះការរួមចំណែករបស់ក្រុមការងារការបញ្ជ្រាបយេនឌ័រ ក្នុងកិច្ចដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ?
□ ល្អប្រសើរ
□ គ្រប់គ្រាន់
□ មិនគ្រប់គ្រាន់
□ គ្មានបានជួយ
□ មិនដឹង

២៨. តើលោក លោកស្រីគិតថា លទ្ធផលសម្រេចបានកម្រិតណា នៅក្នុងការអនុវត្តយុទ្ធសាស្ត្រយេនឌ័រនៃផអ៣?
□ សម្រេចបានធំធេង
□ សម្រេចបានល្អ
□ សម្រេចបានខ្លះ ប៉ុន្តែមិនតិចតួចណាស់
□ ពុំសម្រេចបានអ្វីទាំងអស់
□ មិនដឹង

២៩ **ចំណាំ៖** សំណួរនេះ សម្រាប់សួរតែអនុកម្មវិធីទី១ នៃលេខាធិការដ្ឋាន គ.ជ.អ.ប
តើលោក លោកស្រីគិតថាមានប្រយោជន៍ដែរឬទេ ក្នុងការបង្កើតក្រុមការងារមួយធ្វើការទៅលើបញ្ហាយេនឌ័រនៅកន្លែងធ្វើការក្នុងលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីស្រាវជ្រាវបន្ថែមលើបញ្ហាយេនឌ័រនេះ?
□ មានប្រយោជន៍ខ្លាំងណាស់
□ មានប្រយោជន៍ល្មម
□ មិនសូវមានប្រយោជន៍
□ គ្មានប្រយោជន៍អ្វីទាំងអស់

៣០. **ចំណាំ៖** សំណួរនេះ សម្រាប់សួរតែអនុកម្មវិធីទី១ នៃលេខាធិការដ្ឋាន គ.ជ.អ.ប
មូលហេតុអ្វីបានជាលោក លោកស្រីជ្រើសរើសយកចម្លើយណាមួយខាងលើនេះ?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

៣១. តើលោក លោកស្រីមានយោបល់អ្វីខ្លះ ដើម្បីពង្រឹងការអនុវត្តយុទ្ធសាស្ត្រយេនឌ័រផអ៣?

..........................................................................................................................

..........................................................................................................................

..........................................................................................................................

នេះជាការស្ទង់មតិដោយសម្ងាត់ ក៏ប៉ុន្តែជាវាមានសារៈប្រយោជន៍ខ្លាំងណាស់ ប្រសិនបើលោក លោកស្រីអាចផ្តល់ព័ត៌មានខាងក្រោមនេះបាន?

**ភេទ ៖** ☐ ប្រុស
☐ ស្រី

**អាយុ ៖** ........................................

**សញ្ជាតិ ៖** ☐ ខ្មែរ
☐ ផ្សេងៗ ...........................

**តួនាទី ៖** ..........................................

**ឋានៈ ៖** ☐ មន្ត្រីរាជការ
☐ បុគ្គលិកជាប់កិច្ចសន្យា

# ឧបសម្ព័ន្ធទី ៣.៣
## សំណួរនាំមុខសម្រាប់ការសម្ភាសន៍នៃការធ្វើសវនកម្មយេនឌ័រ

សំណួរនាំមុខត្រូវបានរៀបចំឡើងសម្រាប់ការសម្ភាសន៍លក្ខណៈបុគ្គល និងលក្ខណៈជាក្រុមគោលដៅនីមួយៗ។ សំណួរទាំងនេះត្រូវបានរៀបចំដោយមានលក្ខណៈសមស្របចំពោះបុគ្គល និងក្រុមគោលដៅនីមួយៗដែលត្រូវជួបសម្ភាសន៍។ ទោះជាយ៉ាងនេះក្ដី ក៏បញ្ហាស្រដៀងគ្នានានាត្រូវបានសាកសួរ និងពិភាក្សានៅក្នុងកិច្ចសម្ភាសន៍លក្ខណៈបុគ្គល និងលក្ខណៈក្រុមគោលដៅនីមួយៗ។ ខាងក្រោមនេះ គឺជាគំរូនៃសំណួរនាំមុខសម្រាប់ការសម្ភាសន៍ជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប (អនុកម្មវិធីទី១) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អនុកម្មវិធីទី៤) និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ការសម្ភាសន៍ជាមួយប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ

## សេចក្ដីផ្ដើម

ចំណុចសំខាន់ៗចំនួន៥នឹងត្រូវធ្វើសវនកម្ម៖

១. យេនឌ័រក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ ការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការត្រួតពិនិត្យ ការវាយតម្លៃ និងផលប៉ះពាល់។

២. ជំនាញបច្ចេកទេសក្នុងការគាំទ្រដល់ការរៀបចំតាក់តែង និងអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានលក្ខណៈឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ។

៣. ស្ត្រីនៅក្នុងកិច្ចដំណើរការធ្វើសេចក្ដីសម្រេចចិត្ត និងក្នុងការរៀបចំបុគ្គលិក។

៤. វេទយិតភាពយេនឌ័រនៅក្នុងវប្បធម៌ស្ថាប័ន និងទស្សនៈយល់ដឹងនៃសមិទ្ធផលនានាដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ។

៥. ការឆ្លើយតបទៅនឹងបញ្ហាយេនឌ័ររបស់ស្ថាប័នដៃគូ ឧទាហរណ៍ដូចជា ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា។

**ទិដ្ឋភាពទូទៅនៃកិច្ចដំណើរការធ្វើសវនកម្មយេឌ័រ** (ឧទាហរណ៍ ការសិក្សាលើឯកសារ ការប្រើប្រាស់សំណួរសម្រាប់ការវាយតម្លៃដោយខ្លួនឯង ការសម្ភាសន៍ជាលក្ខណៈបុគ្គល និងលក្ខណៈជាក្រុមជាដើម)។

**វិសាលភាព ៖** អនុកម្មវិធីទី១ ទី២ ទី៣ ទី៤ ខេត្តចំនួន៤ ស្រុកចំនួន៣ និងក្រុងចំនួន១ (ខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តស្វាយរៀង និងខេត្តកោះកុង)។ ក្រុមការងារលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារី នឹងទទួលខុសត្រូវក្នុងការធ្វើសវនកម្មយេនឌ័រដោយខ្លួនឯងចំពោះអនុកម្មវិធីទី៤ និងខេត្តចំនួន៣ និងក្រុង ស្រុកគោលដៅនៅខេត្តទាំងនោះ។

អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយត្រូវដើតួយ៉ាងសំខាន់ក្នុងការផ្តល់ការណែនាំ និងគាំទ្រដល់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផអ៣ រួមទាំងការធានាថា សមភាពតយេនឌ័រ និងការលើកកម្ពស់ភាពអង់អាចក្លាហានរបស់ស្ត្រី ត្រូវបានដាក់បញ្ចូលទៅក្នុងការងាររបស់លេខាធិការដ្ឋាន និងស្ថាប័នអនុវត្តនានា។

តើលោកសង្ឃឹមថានឹងបានរៀនសូត្រអ្វីខ្លះពីការរៀបចំធ្វើសវនកម្មយេនឌ័រនេះ?

តើមានបញ្ហាប្រឈមអ្វីខ្លះ ដែលលោកបានជួបប្រទះក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការងារ របស់លេខាធិការដ្ឋាន គ.ជ.អ.ប និងការលើកកម្ពស់ភាពអង់អាចក្លាហានរបស់ស្ត្រីនៅក្នុងលេខាធិការដ្ឋាន ព្រមទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ?

យើងដឹងថា ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីជាតិ និងផអ៣មានលក្ខណៈពិបាកយល់។ ចំពោះឯកសារផអ៣ សមាសភាគយេនឌ័រត្រូវបានដាក់បន្ថែមបន្ទាប់ពីផែនការនៃអនុកម្មវិធីនានាត្រូវបានរៀបចំ។ ចំពោះឯកសារការពន្យារពេលផអ៣ ការងារយេនឌ័រត្រូវបានពិភាក្សាក្នុងជំពូកមួយដោយឡែក និងពុំបាននឆ្លុះបញ្ចាំងនៅក្នុងជំពូកនៃអនុកម្មវិធីនីមួយៗឡើយ។ តើលោកគិតថា មានមូលហេតុអ្វីខ្លះដែលធ្វើឲ្យមានការលំបាកសម្រាប់មន្ត្រី បុគ្គលិក និងស្ថាប័នក្នុងការបញ្ជ្រាបយេនឌ័រ?

តើលោកគិតថា យុទ្ធសាស្ត្រយេនឌ័រសម្រាប់ផអ៣មានសារៈសំខាន់យ៉ាងដូចម្តេច?

តើលោកឃើញភាពជោគជ័យជាងគេអ្វីខ្លះ នៃការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពនានានៃផអ៣ និងការលើកកម្ពស់ភាពអង់អាចក្លាហានរបស់ស្ត្រី?

តើមានតំណាងស្ត្រីល្អដែរ ឬទេនៅក្នុងអង្គភាពរបស់លោក?

តើអង្គភាពរបស់លោកបានព្យាយាមយ៉ាងសកម្មដើម្បីសម្រេចឲ្យបានតុល្យភាពយេនឌ័រក្នុងការរៀបចំបុគ្គលិក? តើបានព្យាយាមយ៉ាងដូចម្តេច? តើមានបញ្ហាប្រឈមអ្វីខ្លះ?

តើមានប្រសិទ្ធភាពយ៉ាងដូចម្តេចក្នុងការសហការជាមួយក្រសួងកិច្ចការនារី ដើម្បីបញ្ជ្រាបយេនឌ័រក្នុងផអ៣?

តើមានការផ្តោតការយកចិត្តទុកដាក់យ៉ាងដូចម្តេចរបស់ដៃគូអភិវឌ្ឍន៍ និងស្ថាប័នអនុវត្តនានា រួមទាំងលេខាធិការដ្ឋាន គ.ជ.អ.ប ផងដែរ លើបញ្ហាយេនឌ័រក្នុងកម្មវិធីជាតិ និងផអ៣?

អង្គការមិនមែនរដ្ឋាភិបាលមានប្រវត្តិក្នុងការពង្រឹងក្រុមប្រឹក្សាឃុំ សង្កាត់។ តើអង្គការមិនមែនរដ្ឋបាលភិបាលមានការចូលរួមយ៉ាងដូចម្តេចក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ? តើពួកគេមានការពាក់ព័ន្ធយ៉ាងដូចម្តេច?

មានការផ្តល់យោបល់ថា គួរមានការរៀបចំបង្កើតក្រុមការងារយេនឌ័រនៅក្នុងលេខាធិការដ្ឋាន គ.ជ.អ.ប។ លោកយល់យ៉ាងដូចម្តេចចំពោះគំនិតនេះ? តើអ្នកណាខ្លះគួរធ្វើការសមាជិកភាពនៃក្រុមការងារនេះ?

## បទសម្ភាសន៍ស្តីពីសវនកម្មយេនឌ័រសម្រាប់អនុកម្មវិធីទី៤ (SP4)

ឯកឧត្តម លោកជំទាវ លោក លោកស្រីជ្រាបស្រាប់ហើយថា ការធ្វើសវនកម្មយេនឌ័រ ត្រូវបានកំណត់ជាចំណុចដៅមួយក្នុងចំណោមចំណុចដៅសំខាន់ៗទាំង១៩ នៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៣ សម្រាប់ផអ៣។ សវនកម្មយេនឌ័រផ្តល់នូវយន្តការមួយសម្រាប់វាយតម្លៃកម្រិតប្រសិទ្ធភាពនៃការបញ្ជ្រាបយេនឌ័រ។

ចំណុចសំខាន់ៗចំនួន៥នឹងត្រូវធ្វើសវនកម្មយេនឌ័រ ដែលក្នុងនោះរួមមាន ៖

១. យេនឌ័រក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ ការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការត្រួតពិនិត្យ ការវាយតម្លៃ និងផលប៉ះពាល់។

២. ជំនាញបច្ចេកទេសក្នុងការគាំទ្រដល់ការរៀបចំតាក់តែង និងអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលមានលក្ខណៈឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ។

៣. ស្ត្រីនៅក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងក្នុងការរៀបចំបុគ្គលិក។

៤. វេទយិតភាពយេនឌ័រនៅក្នុងវប្បធម៌ស្ថាប័ន និងទស្សនៈយល់ដឹងនៃសមិទ្ធផលនានាដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ។

៥. ការឆ្លើយតបទៅនឹងបញ្ហាយេនឌ័ររបស់ស្ថាប័នដៃគូ ឧទាហរណ៍ដូចជា ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា។

**វិធីសាស្ត្រនៃការធ្វើសវនកម្មយេនឌ័រ ៖** រួមមានការពិនិត្យឡើងវិញនូវឯកសារពាក់ព័ន្ធ ការប្រើប្រាស់បញ្ជីកម្រងសំណួរ បទសម្ភាសន៍ជាលក្ខណៈបុគ្គល និងជាលក្ខណៈក្រុមពិភាក្សា។

**វិសាលភាព៖** សវនកម្មនឹធ្វើចំពោះអនុកម្មវិធីទី១ ទី២ ទី៣ និងទី៤ ព្រមទាំង៤ខេត្ត ៣ស្រុក និងក្រុងចំនួន១ (ខេត្តក្រចេះ ខេត្តបាត់ដំបង ខេត្តស្វាយរៀង និងខេត្តកោះកុង)។

**សំណួរ**

យើងដឹងថា ការបញ្ជ្រាបយេនឌ័រទាំងនៅក្នុងកម្មវិធីជាតិ និងផអ៣មានភាពពិបាកបន្តិច។ ចំពោះផអ៣ សមាសធាតុបញ្ជ្រាបយេនឌ័រ ត្រូវបានបន្ថែមក្រោយពេលផែនការរបស់អនុកម្មវិធីនីមួយៗ ត្រូវបានរៀបចំតាក់តែងឡើងរួចហើយ។ ក្រៅពីនេះ ចំពោះការពន្យារផអ៣រយៈពេល១ឆ្នាំ ការបញ្ជ្រាបយេនឌ័រក៏ត្រូវបានពិភាក្សានៅក្នុងជំពូកដោយឡែកមួយ ពុំបានឆ្លុះបញ្ចាំងនៅក្នុងជំពូកនៃអនុកម្មវិធីនីមួយៗឡើយ។ ក្នុងន័យនេះ ហេតុអ្វីបានជាលោក លោកស្រីគិតថាមានការលំបាកខ្លាំង ក្នុងការបញ្ជ្រាបយេនឌ័រឲ្យស៊ីសង្វាក់នឹងគ្នានឹងការធ្វើផែនការ?

តើលោក លោកស្រីយល់ឃើញថា យុទ្ធសាស្ត្រយេនឌ័រនៅក្នុងផអ៣នេះ មានសារៈប្រយោជន៍ប៉ុណ្ណា?

តើមានការជួបប្រទះបញ្ហាអ្វីខ្លះ ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងការងារអនុកម្មវិធីទី៤ និងការបង្កើនតំណាងស្ត្រីក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/អនុកម្មវិធី៤ រួមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ?

| **៣. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការ រៀបចំបុគ្គលិក** | **២,០** | | |
| ៣.១. ភាគរយស្ត្រីនៅក្នុង គ.ជ.អ.ប(អនុកម្មវិធីទី១) | ១,០ | • ក្នុងចំណោមសមាជិក គ.ជ.អ.ប ១៦រូប មានស្ត្រី១រូប (៦,៣%) | • |
| ៣.២. ភាគរយស្ត្រីនៅកម្រិតធ្វើសេចក្តីសម្រេចចិត្ត ជាន់ខ្ពស់នៅក្នុងអនុកម្មវិធី | ០,០ | • ពុំមានស្ត្រីនៅថ្នាក់ធ្វើសេចក្តីសម្រេចចិត្តជាន់ខ្ពស់នៅ ក្នុងលេខាធិការដ្ឋាន គ.ជ.អ.ប (ចាប់ពីថ្នាក់ប្រធានអង្គ ភាពឡើង) | • |
| ៣.៣. ភាគរយស្ត្រីនៅកម្រិតបុគ្គលិករដ្ឋបាលជីវៈនៅ ក្នុងអនុកម្មវិធី | ៣,០ | • ទោះបីជាមានស្ត្រី៣៦% នៅក្នុងមុខតំណែងគ្រប់គ្រង ថ្នាក់កណ្តាល និងរដ្ឋបាលជីវៈ តែភាគច្រើននៅអង្គភាពរដ្ឋ បាល និងហិរញ្ញវត្ថុ | • បង្កើនតុល្យភាពយេនឌ័រនីគ្រប់អង្គភាពទាំង អស់ (ឧទា. បង្កើនចំនួនបុរសនៅក្នុងអង្គភាព រដ្ឋបាល និងហិរញ្ញវត្ថុ និងបង្កើនចំនួនស្ត្រីនៅ |

| សូចនាករ | ពិន្ទុ | យោបល់នានា | អនុសាសន៍បឋម |
|---|---|---|---|
| | | | ក្នុងអង្គភាពផ្សេងៗទៀត) |
| ៣.៤. ការយល់ដឹង និងវេទយិតភាពយេនឌ័រនៅក្នុងការគ្រប់គ្រងធនធានមនុស្ស | ២,០ | • បុគ្គលិកទាំងអស់បានរាយការណ៍ថា ពួកគេត្រូវបានធ្វើឱ្យមានយល់ដឹងអំពីសារសំខាន់នៃការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងដំណើរការជ្រើសរើសបុគ្គលិក<br>• ទោះបីជាការយល់ដឹង និងវេទយិតភាពយេនឌ័រពុំបានដាក់បញ្ចូលយ៉ាងរលូននៅក្នុងសេចក្ដីបរិយាយការងារ និងល័ក្ខខ័ណ្ឌការងារក៏ដោយ ក៏ជាទូទៅមានការទទួលស្គាល់ថា វាជាអាទិភាពមួយ ទាក់ទងនឹងអាណត្តិទូទៅរបស់ផអ៣<br>• ៣២%យល់ឃើញថា មានតិចតួច ឬពុំមានការគ្រោងទុកជាមុននូវការជ្រើសរើសនិយោជិតជាស្ត្រី(ការប្រកាសផ្សព្វផ្សាយមុខតំណែងតាមរយៈគេហទំព័រ និងសារព័ត៌មាននានា)<br>• ២១%យល់ឃើញថា ស្ត្រីត្រូវបានដំឡើងឋានៈ ហើយការដំឡើងនេះមានភាពសមរម្យ។ ៦៧%យល់ឃើញថា បុរស និងស្ត្រីត្រូវបានយកចិត្តទុកដាក់ដូចគ្នា។ | • ធានាថា ទិដ្ឋភាពយេនឌ័រនានាត្រូវបានដាក់បញ្ចូលយ៉ាងរលូននៅក្នុងសេចក្ដីបរិយាយការងារ និងល័ក្ខខ័ណ្ឌការងារ<br>• ណែនាំតម្រង់ទិសបន្ថែមអំពីវិធីសាស្ត្រនានាក្នុងការគ្រោងទុកជាមុននូវការជ្រើសរើសបុគ្គលិកជាស្ត្រីដែលមានគុណវុឌ្ឍិ។ |
| **៤. វេទយិតភាពយេនឌ័រនៅក្នុងវប្បធម៌ និងទស្សនៈស្ថាប័ន ទាក់ទងនឹងសមភាពយេនឌ័រ** | **២,១** | | |
| ៤.១. ទស្សនៈអំពីសារសំខាន់នៃសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រីនៅក្នុង | ២,៥ | • មានការយល់ដឹងកម្រិតខ្ពស់អំពីសារសំខាន់នៃសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រីនៅក្នុង | |

| សូចនាករ | ពិន្ទុ | យោបល់នានា | អនុសាសន៍បឋម |
|---|---|---|---|
| អនុកម្មវិធី | | គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា<br>• មានទស្សនៈទាបបន្តិចអំពីសារសំខាន់នៃគោលនយោបាយយេនឌ័ររបស់ផអ៣ ចំពោះលេខាធិការដ្ឋាន គ.ជ.អ.ប | |
| ៤.២. ភាពស្គាល់ច្បាស់នូវឧបសម្ព័ន្ធស្តីពីការបញ្ជ្រាបយេនឌ័រនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងឧបសម្ព័ន្ធស្តីពីយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ | ២,៤ | • ៥០% បានរាយការណ៍ថា បានអានទាំងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងទាំងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣។ ៣៧% បានរាយការណ៍ថា បានអានមួយក្នុងចំណោមឯកសារទាំង២<br>• ៥០%បានយល់ឃើញថា យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ មានលក្ខណៈច្បាស់លាស់ណាស់ ៣៨% យល់ឃើញថា ច្បាស់លាស់ខ្លះៗ និង១២% យល់ឃើញថា មិនច្បាស់លាស់សោះ<br>• ស្ទើរតែទាំងអស់(៩២%)បានកំណត់ថា ការដាក់បញ្ចូលទស្សនៈយេនឌ័រនៅក្នុងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត កម្មវិធី និងគម្រោងនានា ពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ទៅតាមអនុសាសន៍មួយនៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ផអ៣។ មានតែ៤៦%ប៉ុណ្ណោះបានកំណត់ថា ការរៀបចំតាក់តែងគោលនយោបាយនានាដើម្បីលើកកម្ពស់ | |

| សូចនាករ | ពិន្ទុ | យោបល់នានា | អនុសាសន៍បឋម |
|---|---|---|---|
| | | តុល្យភាពយេនឌ័រការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ ទៅតាមអនុសាសន៍មួយនៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់ផអ៣។ | |
| ៤.៣. ការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងទីកន្លែងធ្វើការងារ | ២,២ | • មួយភាគបីនៃអ្នកផ្តល់ព័ត៌មានបានយល់ឃើញថា វិធីសាស្ត្រយ៉ាងសកម្មរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការគោរពចំពោះភាពចម្រុះនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត អាកប្បកិរិយា ក្រមសីលធម៌ការងារ និងព័ត៌មាន គឺមិនគ្រប់គ្រាន់<br>• ៧៥%បានរាយការណ៍ថា ពួកគេបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការធានាឱ្យមានទំនាក់ទំនងប្រកបដោយការគោរពរវាងបុរស និងស្ត្រីនៅក្នុងទីកន្លែងធ្វើការងារ។ ២១%បានរាយការណ៍ថា បានយកចិត្តទុកដាក់ខ្លះៗ។<br>• ៧៥%បានយល់ព្រម ឬយល់ព្រមយ៉ាងខ្លាំថា កិច្ចប្រជុំនានាមានទំនោរទៅរកភាពលុបដោយបុរស។<br>• ទាំងអស់ទទួលស្គាល់ថា ការអនុវត្តយុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣ ពុំមែនជាការទទួលខុសត្រូវរបស់ទីប្រឹក្សាយេនឌ័រ និងក្រសួងកិច្ចការនារីទេ។<br>• ៥៨%បានរាយការណ៍ថា បានចាត់វិធានការជាច្រើនដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងឬឆ្លើយតបចំពោះបញ្ហាពាក់ព័ន្ធយេនឌ័រ។ ២៩%ផ្សេងទៀត បាន | |

| សូចនាករ | ពិន្ទុ | យោបល់នានា | អនុសាសន៍បឋម |
|---|---|---|---|
| | | រាយការណ៍ថា បានចាត់វិធានការមួយចំនួន។ | |
| ៤.៤. ការឆ្លុះបញ្ចាំងនៃសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រីនៅក្នុងមុខមាត់ជាសាធារណៈរបស់ស្ថាប័ន | ២,០ | • សាច់រឿងជាច្រើនអំពីស្ត្រីជាអ្នកដឹកនាំ និងជាភ្នាក់ងារផ្លាស់ប្តូរ បានបង្ហោះនៅលើគេហទំព័រ គ.ជ.អ.ប<br>• ទោះបីជាស្ត្រីត្រូវបានបង្ហាញនៅក្នុងប្រតិទិនដាក់លើតុរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ក៏ដោយ ក៏រូបថតទាំងនេះភាគច្រើនក្នុងតួនាទីអកម្ម (កំណត់សម្គាល់ ៖ភាគច្រើននៃរូបថត គឺផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត) | |
| ៤.៥. ទស្សនៈអំពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣ | ១,៦ | • ៥៨%បានយល់ឃើញថា ការអនុវត្តយុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣ មានវឌ្ឍនភាពល្អ, ៤២%បានយល់ឃើញថា មានវឌ្ឍនភាពខ្លះៗ ប៉ុន្តែបន្តិចបន្តួច។ | |
| **៥. ការឆ្លើយតបយេនឌ័ររបស់ស្ថាប័នដៃគូនានា** | **២,៨** | | |
| ៥.១. តួនាទីរបស់ដៃគូអភិវឌ្ឍន៍នានាក្នុងការលើកកម្ពស់ និងការគាំទ្រដល់បង្កើនសមភាពយេនឌ័រ | ២,៩ | • ស្ទើរតែទាំងអស់(៨៨%)បានយល់ឃើញថា ការលើកកម្ពស់សមភាពយេនឌ័រ គឺសំខាន់ចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់<br>• ១២%បានយល់ឃើញថា សំខាន់ចំពោះដៃគូអភិវឌ្ឍន៍មួយចំនួន | • អាចមានមេរៀនបទពិសោធន៍នានា ដែលអាចដកស្រង់ពីយុទ្ធសាស្ត្រយេនឌ័ររបស់គម្រោងដាច់ដោយឡែកនានា |
| ៥.២. តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាលដៃគូរនៅក្នុងការលើកកម្ពស់ និងការគាំទ្រការបង្កើនសមភាពយេនឌ័រ តាមរយៈការចូលរួមនៅក្នុងការតាក់តែង ការអនុវត្ត និងការ | ២,៧ | • ៧១%បានយល់ឃើញថា អង្គការមិនមែនរដ្ឋាភិបាលគឺសំខាន់ណាស់នៅក្នុងការរៀបចំតាក់តែង និងការអនុវត្តយុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣។ ២៩% បានយល់ឃើញថាសំខាន់ | • ប្រឹក្សាយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការរៀបចំផអ៣ទី២ |

| សូចនាករ | ពិន្ទុ | យោបល់នានា | អនុសាសន៍បឋម |
|---|---|---|---|
| តាមដានគោលនយោបាយឬកម្មវិធីនានា | | • ជាដំបូង ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងគម្រោងជាច់ដោយឡែកនានា និងនៅក្នុងការរៀបចំក្របខ័ណ្ឌការងារគណនេយ្យភាពសង្គម។ | |
| **ពិន្ទុសរុប** | ១,៩ | | |

# ឧបសម្ព័ន្ធទី ៦.២ ÷ ប័ណ្ណដាក់ពិន្ទុ

អនុកម្មវិធីទី២៖ ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងស្ថាប័នសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រសួងមហាផ្ទៃ)

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| **១. យេនឌ័រនៅក្នុងការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការត្រួតពិនិត្យ វាយតម្លៃ និងឥទ្ធិពល ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** | ១.៨ | | |
| ១.១. ការរៀបចំតាក់តែងគោលនយោបាយ | ២.០ | • កម្មវិធីជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្លើយតបភាគច្រើនចំពោះអនុសាសន៍របស់សវនកម្ម យេនឌ័រ<br>• ឆ្លើយតបដោយប្រសិទ្ធភាពចំពោះបញ្ហាយេនឌ័រតាមរយៈលិខិតបទដ្ឋានគតិយុត្តនានា | • ពាក់ព័ន្ធគោលនយោបាយស្តីពីកូតាយេនឌ័រ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវគិតអំពីគុណភាពផងដែរ។ |
| ១.២. ការកសាងផែនការ | ១.៧ | • ៥៥.៥% នៃអ្នកដែលបានឆ្លើយសំណួរគិតថាប្រព័ន្ធនៃការរៀបចំកម្មវិធីក្នុងស្ថាប័នអនុវត្តអនុកម្មវិធីនៅមានការខ្វះខាតដើម្បីធានានូវគុណភាពនៃការអនុវត្តយុទ្ធសាស្ត្រយេនឌ័រផអ៣។<br>• អ្នកដែលបានឆ្លើយសំណួរស្ទើរទាំងអស់ឯកភាពថាមានការលំបាកក្នុងការបញ្ជ្រាបយេនឌ័រក្នុងយុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣ពីព្រោះជាការលំបាកសម្រាប់អនុកម្មវិធីទាំងអស់ដើម្បី កំណត់ការទទួលខុសត្រូវ និងសកម្មភាពនានា។ | • យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រត្រូវកំណត់សកម្មភាពឲ្យបានច្បាស់លាស់នូវការទទួលខុសត្រូវរបស់អនុកម្មវិធីនីមួយៗ (រួមទាំងអនុកម្មវិធីទី២)<br>• លេខាធិការដ្ឋានគ.ជ.អ.ប ត្រូវបង្កើតអង្គភាពមួយដែលទទួលខុសត្រូវការងារយេនឌ័រ។ ប្រសិនបើអនុកម្មវិធីណាមួយត្រូវការ ស្នើសុំយោបល់ស្តីពីការបញ្ជ្រាបយេនឌ័រគឺអង្គភាពយេនឌ័រ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | | អាច គាំទ្រដល់អនុកម្មវិធីទាំងនោះ។ |
| ១.៣. ការរៀបចំថវិកា | ១.៦ | • ពុំមានការប្រែប្រួលនៅក្នុងថវិកាផអ៣សម្រាប់សកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅថ្នាក់ជាតិរវាងឆ្នាំ២០១២ និង២០១៣ សម្រាប់បណ្តុះបណ្តាល ការពង្រឹងបណ្តា និងការគាំទ្រផ្សេងៗ។ ឧទាហរណ៍ៈកិច្ចប្រជុំរៀបចំផែនការថវិកាមានការយឺតយ៉ាវ ដែលមិនបានរៀបចំសម្រាប់ការបញ្ជ្រាបយេនឌ័រ ហើយនាំឲ្យមានផលប៉ះពាល់លើការបញ្ជ្រាបយេនឌ័រ។<br>• នៅពេលគម្រោងមួយទទួលថវិកាពីដៃគូ គឺមានការគិតគូពី យេនឌ័រនៅក្នុងផែនការ និងថវិកា ដូច្នេះហេតុអ្វីបានជាពួកគេមិនគិតអំពីយេនឌ័រសម្រាប់ថវិការបស់រដ្ឋាភិបាល?<br>• ផែនការថវិកាប្រចាំឆ្នាំ២០១៤ ការបញ្ជ្រាបយេនឌ័រមិនបានឆ្លុះបញ្ចាំងនៅក្នុងដំណើរការរៀបចំទេលើកលែងអនុកម្មវិធីទី២ ដែលបានគិតគូរបញ្ហាយេនឌ័រ។<br>• ការវិភាជថវិកាទៅឲ្យឃុំ សង្កាត់សម្រាប់សេវាសង្គមបានថយចុះ (ពី៩៦%ក្នុងឆ្នាំ២០០៩ មកប្រហែល៣៦%ក្នុងឆ្នាំ២០១២)។ | • គួរបង្កើនថវិកាដល់ខេត្តដើម្បីប្រើប្រាស់ពង្រឹងសមត្ថភាពសម្រាប់ដល់បុគ្គលិកជាស្ត្រីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការបណ្តុះបណ្តាលយេនឌ័រ ពិសេសស្ត្រីនៅថ្នាក់ស្រុកនៅក្នុងអាណត្តថ្មី។<br>• ថវិការបស់រដ្ឋាភិបាលគួរផ្តោតលើការបញ្ជ្រាបយេនឌ័រផងដែរ។ |
| ១.៤. ការអនុវត្ត | ២.០ | • ផ.ស.ថរបស់ផអ៣ឆ្នាំ២០១៣ៈភាគច្រើនបានអនុវត្តការអភិវឌ្ឍសមត្ថភាពដល់គ្រូបង្គោលនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត។ មានគ្រូបង្គោល២៦នាក់នៅនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន។<br>• ក្រុមអភិវឌ្ឍសមត្ថភាពនៅតែប្រើប្រាស់សៀវភៅណែនាំអភិវឌ្ឍន៍ស្ថាប័នដែលដាក់ឲ្យប្រើប្រាស់នៅឆ្នាំ២០១២ ដែលមិនបានផ្តោត | • បង្កើនគ្រូបង្គោលជាស្ត្រីនៅក្នុងក្រុមអភិវឌ្ឍន៍សមត្ថភាព<br>• ត្រូវបញ្ចូលសៀវភៅណែនាំអភិវឌ្ឍន៍ស្ថាប័នរួមទាំងការបញ្ជ្រាប យេនឌ័រក្នុងស្ថាប័ន |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | លើបញ្ហាយេនឌ័រ។ ក្រុមអភិវឌ្ឍន៍សមត្ថភាពបានបញ្ចូលការយល់ដឹងពីយេនឌ័រដោយប្រើប្រាស់សៀវភៅណែនាំពង្រឹង ការយល់ដឹងពីយេនឌ័រដើម្បីគាំទ្រ។<br>• ក្រុមអភិវឌ្ឍន៍សមត្ថភាពពិនិត្យមើលសៀវភៅណែនាំការអភិវឌ្ឍន៍ស្ថាប័ន (ជាង៤០០ទំព័រ) ដើម្បីបញ្ជ្រាបយេនឌ័រ<br>• ប៉ុន្តែមន្ត្រីរៀបចំសៀវភៅណែនាំការអភិវឌ្ឍន៍ស្ថាប័ន ភាគច្រើនជាបុរស (ប្រុស៥នាក់ ស្ត្រី១នាក់) ហើយពួកគេមិនបានដឹងច្បាស់អំពីតម្រូវការ និងបញ្ហារបស់ស្ត្រីមានអ្វីខ្លះ។<br>• អនុកម្មវិធីទី២ យល់ដឹងនៅមានកម្រិតពីការបញ្ជ្រាបយេនឌ័រ នៅក្នុងការរៀបចំគោលនយោបាយនៅថ្នាក់ជាតិ។ ឧទាហរណ៍ការអនុវត្តគោលនយោបាយជាតិនៅពុំទាន់បានឆ្លើយតប ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្នាក់ខេត្ត និងថ្នាក់ស្រុក)។ | • សៀវភៅណែនាំអភិវឌ្ឍន៍ស្ថាប័នដែលមានការបញ្ជ្រាបយេនឌ័រគួរបញ្ចូលពីរបៀបបញ្ជ្រាបយេនឌ័រក្នុងការអនុវត្តជាក់ស្តែង ដូចជាការកសាងផែនការការរៀបចំថវិកា ដំណើរការលទ្ធកម្ម ជាដើម ក្រៅពីការលើកឡើងតែទ្រឹស្តី។ |
| ១.៥. ការត្រួតពិនិត្យ | ១.៨ | • ក្រសួងមហាផ្ទៃពិនិត្យឃើញមានការលំបាកក្នុងការឆ្លុះបញ្ចាំងការបញ្ជ្រាបយេនឌ័រនៅក្នុងសមាសភាគអនុកម្មវិធីៈការចាត់ចែងបុគ្គលិក ការអភិវឌ្ឍស្ថាប័ន ការងារស្ថាប័ននិងការចាត់ចែងហេដ្ឋារចនាសម្ព័ន្ធ ការលំបាកក្នុងការកំណត់នូវវិធានជាក់លាក់ណាមួយ<br>• ក្រសួងមហាផ្ទៃបានអនុវត្តការបញ្ជ្រាបយេនឌ័រ ប៉ុន្តែជាការលំបាកក្នុងមើលឃើញក្នុងសកម្មភាពនានា។ ឧទាហរណ៍ៈ ការ ចុះបញ្ជីទូទៅនៅថ្នាក់ឃុំ។ | |
| យោបល់ផ្សេងៗទៀត | | • ក្រសួងមហាផ្ទៃខិតខំប្រឹងប្រែងលើកកម្ពស់ស្ត្រីនៅថ្នាក់ជាតិ និង | • ការពង្រឹងសមត្ថភាពស្ត្រី ផ្នែក |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | ថ្នាក់ក្រោមជាតិ យ៉ាងហោចណាស់ស្ត្រី១រូបមានតំណែងជាអនុប្រធាន។ នៅរដ្ឋបាលថ្នាក់ក្រោមជាតិមានសមាជិកក្រុមប្រឹក្សាខេត្ត/រាជធានីៈមានស្ត្រី៤១រូបក្នុងចំណោមសមាជិកសរុបៈ៣៧៤រូប សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌមានស្ត្រី៣៧៦រូបក្នុងចំណោមសមាជិកសរុប២៨៨០រូប។<br>• ក្រសួងមហាផ្ទៃរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់រៀបចំផែនការ វិនិយោគលើបញ្ហាយេនឌ័រ ពិសេស ការធ្វើលទ្ធកម្មត្រូវឆ្លើយតបចំពោះក្របខ័ណ្ឌអនុកម្មវិធីទី២<br>• ទោះបីយ៉ាងណាក៏ដោយ អនុកម្មវិធីទី២នៅប្រឈមបញ្ហាផ្នែកសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេស សមត្ថភាពថ្នាក់ក្រុង ស្រុក ខណ្ឌក្នុងការបញ្ជ្រាបយេនឌ័រ។ | គ្រប់គ្រង និងភាពជាអ្នកដឹកនាំ ទាំងអ្នកជាប់ឆ្នោត និងអ្នកត្រូវបានតែងតាំង។ |
| **២. ជំនាញបច្ចេកទេសដើម្បីគាំទ្រការតាក់តែង និងការអនុវត្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលមានលក្ខណៈឆ្លើយតបយេនឌ័រ** | ១.៧ | | |
| ២.១. សមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ | ២.១ | • អ្នកពាក់ព័ន្ធភាគច្រើនយល់ថាពួកគាត់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបញ្ជ្រាបយេនឌ័រ សៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នកំពុងធ្វើការកែសម្រួលឡើងវិញដើម្បីបញ្ចូលបញ្ហាយេនឌ័រ។<br>• ប៉ុន្តែគ្រូបង្គោលសំខាន់ៗនៅថ្នាក់ជាតិស្ទើរទាំងអស់ជាបុរស។<br>• ៥៦%យល់ថាពួកគាត់មានសមត្ថភាពក្នុងបង្ហាញពីបញ្ហាយេនឌ័រ | សូមពិនិត្យមើលចំណុច ១.២.ខាងលើ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | ក្នុងដំណាក់កាលខុសៗគ្នា<br>• ៦៧%បានគិតគូពីការព្រួយបារម្ភបញ្ហាយេនឌ័រក្នុងការងាររបស់ពួកគាត់។<br>• ៥៦%នៃអ្នកដែលបានឆ្លើយសំណួរគិតថាស្ថាប័នអនុវត្តអនុកម្មវិធីមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការវិភាគយេនឌ័រនិងបញ្ចូលនូវការសន្និដ្ឋានបានពីការវិភាគទៅក្នុងដំណើរការកសាងផែនការ។ | |
| ២.២. ការពង្រឹងសមត្ថភាពផ្ទៃក្នុងស្តីពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រទៅក្នុងការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី | ១.៨ | • ភាគច្រើនយល់ថាពួកគាត់ទទួលបានការពង្រឹងសមត្ថភាពគ្រប់គ្រាន់ស្តីពីយេនឌ័រ ក្រុមអភិវឌ្ឍន៍សមត្ថភាពអនុកម្មវិធីទី២ យល់ថាពួកគេត្រូវការគាំទ្របន្ថែមទៀតពីអ្នកជំនាញយេនឌ័រ របស់ក្រសួងកិច្ចការនារី និងលេខាធិការដ្ឋានគ.ជ.អ.ប ដើម្បី កែសម្រួលសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័ន និងប្រព័ន្ធ ត្រួតពិនិត្យតាមដានពីព្រោះក្រុមអភិវឌ្ឍន៍សមត្ថភាពភាគច្រើន ជាបុរសដែលមិនបានយល់ដឹងស៊ីជម្រៅតើអ្វីជាតម្រូវការរបស់ ស្ត្រី។<br>• ការបណ្តុះបណ្តាលស្តីពីយេនឌ័រភាគច្រើនតាមត្រឹមតែទ្រឹស្តី និងការយល់ដឹងផ្សេងៗ ប៉ុន្តែមានការសំណូមពរឲ្យការបណ្តុះបណ្តាលពីភាពជាក់ស្តែង<br>• ការបណ្តុះបណ្តាលសំដៅតែលើស្ត្រី<br>• ៥៥,៦%គិតថាអង្គភាពពួកគាត់បានផ្តល់ឱកាសគ្រប់គ្រាន់ដើម្បីពង្រឹងចំណេះដឹងស្តីពីបញ្ហាយេនឌ័រ។ | • ពង្រឹងការយល់ដឹងស្តីពីយេនឌ័រ ជំនាញវិភាគ និងបញ្ជ្រាបយេន ឌ័រ សម្រាប់គ្រូបង្គោល និងបុគ្គលិកដើម្បីអនុវត្តតួនាទី និងភារកិច្ចក្នុងការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>• បណ្តុះបណ្តាលស្តីពីយេនឌ័រដល់បុរសឲ្យបានច្រើនដើម្បីយល់ ដឹងពីយេនឌ័រ និងពង្រឹងការគាំទ្រដល់ការបញ្ជ្រាបយេនឌ័រ និងបង្កើនតំណាងសម្លេងស្ត្រីនៅក្នុងរដ្ឋបាលមូលដ្ឋាន។ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| ២.៣. ការបណ្តុះបណ្តាលគ្រប់គ្រាន់ និងឯកសារយោងផ្សេងៗស្តីពីបញ្ហាយេនឌ័រ និងការបញ្រ្ជាបយេនឌ័រ។ | ១.៣ | • ភាគច្រើនយល់ថាពួកគេត្រូវការពិគ្រោះយោបល់ពីការងារអភិវឌ្ឍ និងបញ្ហាយេនឌ័របន្ថែមទៀតដើម្បីយល់ដឹងកាន់តែច្បាស់ពី របៀបអនុវត្តនូវទស្សនទានយេនឌ័រក្នុងការងាររដ្ឋបាលមូលដ្ឋានដើម្បីគាំទ្រគ្រួបង្គោលនៅថ្នាក់ជាតិ ព្រមទាំងយល់ពីសេចក្តីណែនាំ និងឧបករណ៍អនុវត្តលើការបញ្រ្ជាបយេនឌ័រ និងការវិភាគ យេនឌ័រដល់រដ្ឋបាលមូលដ្ឋាន។<br>• ១០០%គិតថានៅពុំទាន់មានឧបករណ៍គ្រប់គ្រាន់ក្នុងការបញ្រ្ជាប (ឧ.សេចក្តីណែនាំ សៀវភៅណែនាំ បញ្ជីផ្ទៀងផ្ទាត់ជាដើម) ព្រមទាំងខ្វះបច្ចេកទេសបញ្រ្ជាបយេនឌ័រនៅក្នុងការងារ។<br>• ៦៧%គិតថាពួកគាត់មិនមានព័ត៌មាន និងអនុវត្តមិនគ្រប់គ្រាន់លើការប្រើប្រាស់ឧបករណ៍វិភាគយេនឌ័រ និងបញ្ចូលការសន្និដ្ឋានពីការវិភាគទៅក្នុងគ្រប់ដំណាក់កាលនៃដំណើរការរៀបចំកម្មវិធី និងសកម្មភាពផ្សេងៗ។ | • ចងក្រងឧបករណ៍សមស្របដែលពាក់ព័ន្ធចំនុច២.២ខាងលើ<br>• ត្រូវមានក្រុមហ៊ុនពិគ្រោះយោបល់ពីការបញ្រ្ជាបយេនឌ័រ ដើម្បី យល់ឲ្យពីការងាររដ្ឋបាលមូលដ្ឋានបានច្បាស់លាស់។ |
| ២.៤. មានជំនាញដើម្បីគាំទ្រដល់ការបញ្រ្ជាបអំពីគុណភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | ១.៨ | • ភាគច្រើនបានប្រើប្រាស់ចំណេះដឹង និងពេញចិត្តចំពោះការ គាំទ្រពីអ្នកជំនាញយេនឌ័ររបស់លេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងកិច្ចការនារី និងក្រុមការងារបញ្រ្ជាបយេនឌ័រ។<br>• ៥៦%បានពិគ្រោះយោបល់ផ្ទាល់ជាមួយក្រសួងកិច្ចការនារី ទីប្រឹក្សា ឬអ្នកជំនាញយេនឌ័រផ្សេងទៀតពីការបញ្រ្ជាបយេនឌ័រនៅក្នុងការងារដែលបានធ្វើយ៉ាងតិចម្តងកាលពីឆ្នាំមុន។<br>• ៧៨%ពេញចិត្តចំពោះការគាំទ្រពីទីប្រឹក្សាយេនឌ័ររបស់លេខាធិ | • អនុកម្មវិធីទី២ត្រូវការអ្នកជំនាញយេនឌ័រជាតិនៅលេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានសញ្ញាប័ត្រយេនឌ័រ និងការអភិវឌ្ឍ ហើយមានបទពិសោធន៍ច្រើនឆ្នាំក្នុងការបញ្រ្ជាបយេនឌ័រ។ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | ការដ្ឋានគ.ជ.អ.បស្តីពីការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។<br>• ៥៦%គិតថាការរួមចំណែករបស់ក្រសួងកិច្ចការនារីក្នុងការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅពុំទាន់បានគ្រប់គ្រាន់នៅឡើយ។<br>• ៧៨%គិតថាការរួមចំណែករបស់ក្រុមការងារបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅពុំទាន់បានគ្រប់គ្រាន់នៅឡើយ។ | |
| ២.៥. បញ្ចូលគុណភាពយេនឌ័រទៅក្នុងការអភិវឌ្ឍសមត្ថភាពនៃកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ១.៥ | • មានការប្រឹងប្រែងបញ្ចូលយេនឌ័រទៅក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។<br>• សៀវភៅណែនាំស្តីពីការអភិវឌ្ឍសមត្ថភាពដែលបានផ្សព្វផ្សាយនៅឆ្នាំ២០១២មិនបានបញ្ចូលបញ្ហាយេនប៉ុន្តែក្រុមអភិវឌ្ឍសមត្ថភាពបានប្រើប្រាស់សៀវភៅណែនាំស្តីពីការយល់ដឹងយេនឌ័រ សម្រាប់រៀបចំសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័ន | • ត្រូវបញ្ចប់ការកែសម្រួលសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័ន ដោយមានបញ្ចូលការបញ្ជ្រាបយេនឌ័រ។ |
| **៣. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងការចាត់ចែងបុគ្គលិក** | ១.៣ | | |
| **សម្គាល់ ៖** | | • ១១% នៃសមាជិកក្រុមប្រឹក្សាខេត្តគឺជាស្ត្រី(៤១នាក់/៣៧៤នាក់) ផ្អែកតាមក្រសួងមហាផ្ទៃឆ្នាំ២០១៣<br>• ១៣% នៃសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌគឺជាស្ត្រី(៤១នាក់/៣៧៤នាក់) ផ្អែកតាមក្រសួងមហាផ្ទៃឆ្នាំ២០១៣។ | • ជំរុញលើកទឹកចិត្តគណបក្សនយោបាយក្នុងការបញ្ចូលបេក្ខភាពជាស្ត្រីកាន់តែច្រើននៅលើគេនៃបញ្ជីឈ្មោះគណបក្ស |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| ៣.២. សមាមាត្រស្ត្រីនៅតំណែងធ្វើសេចក្តីសម្រេច ក្នុងអនុកម្មវិធីនានា | ១.០ | • ១១%នៃតំណែងធ្វើសេចក្តីសម្រេចថ្នាក់ខ្ពស់នៅក្រសួងមហាផ្ទៃនៅថ្នាក់ជាតិ មានស្ត្រី ៨នាក់/៧១នាក់ ដែលមានឋានៈចាប់ពីលំដាប់អគ្គនាយកដល់លំដាប់នាយកដ្ឋាន និងអង្គភាព នានា (ព្រឹត្តប័ត្រនារីរតនៈផ្សាយលេខ៧ខែមិនាឆ្នាំ២០១៣)<br>• ៩% នៃតំណែងធ្វើសេចក្តីសម្រេចថ្នាក់ខ្ពស់នៅថ្នាក់ខេត្តមានស្ត្រី ៣១នាក់/៣៥៤នាក់ដែលមានឋានៈចាប់ពីលំដាប់គណៈអភិបាលដល់លំដាប់នាយកអង្គភាពនានាផ្អែកតាមក្រសួងមហាផ្ទៃឆ្នាំ ២០១៣<br>• ១០%នៃតំណែងធ្វើសេចក្តីសម្រេចថ្នាក់ខ្ពស់នៅថ្នាក់ស្រុកមានស្ត្រី ១១៩នាក់/១១៤៨នាក់ដែលមានឋានៈចាប់ពីលំដាប់គណៈអភិបាលស្រុកដល់លំដាប់ការិយាល័យនានាផ្អែកតាមក្រសួងមហាផ្ទៃឆ្នាំ២០១៣។ | • ខិតខំស្វែងរកជម្រើសនានាសម្រាប់ពង្រឹងជំនាញ និងទំនុកចិត្ត ដល់បុគ្គលិកជាស្ត្រីដើម្បីពួកគាត់មានគុណសម្បត្តិទទួលបាន តំណែងខ្ពស់ៗ |
| ៣.៣. សមាមាត្រស្ត្រី ក្នុងតំណែងគ្រប់គ្រងថ្នាក់កណ្តាល និងបុគ្គលិកជំនាញនៅតាមអនុកម្មវិធីនានា | ១.០ | • ១៦%នៃតំណែងគ្រប់គ្រងថ្នាក់កណ្តាលនៅថ្នាក់ជាតិមានស្ត្រី ២០០នាក់/១២៨៦នាក់ដែលមានឋានៈចាប់ពីអនុប្រធាននាយកដ្ឋានដល់មន្ត្រីជំនាញផ្អែកតាមក្រសួងមហាផ្ទៃឆ្នាំ២០១៣<br>• ២៥%នៃតំណែងគ្រប់គ្រងថ្នាក់កណ្តាល និងបុគ្គលិកជំនាញនៅថ្នាក់ខេត្តមានស្ត្រី៩៧៩នាក់/៣៨៧៧នាក់ដែលមានឋានៈចាប់ពីអនុប្រធានអង្គភាពដល់មន្ត្រីផ្អែកតាមក្រសួងមហាផ្ទៃឆ្នាំ២០១៣<br>• ២៣%នៃតំណែងគ្រប់គ្រងថ្នាក់កណ្តាល និងបុគ្គលិកជំនាញនៅថ្នាក់ស្រុកមានស្ត្រី១១៣៩នាក់/៤៩០២នាក់ដែលមានឋានៈចាប់ | ដូចចំនុចខាងលើ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | ពីអនុប្រធានការិយាល័យដល់មន្ត្រីផ្នែកតាមក្រសួងមហាផ្ទៃឆ្នាំ ២០១៣។ | |
| ៣.៤. ការយល់ដឹងស្តីពីយេនឌ័រ និង បញ្ហារសើបផ្នែកយេនឌ័រនៅក្នុងការគ្រប់គ្រងធនធានមនុស្ស | ១.៩ | • កម្រិតយល់ដឹងពីយេនឌ័រ និងការលើកកម្ពស់សមភាពយេនឌ័រ ត្រូវបានបញ្ចូលក្នុងលក្ខខ័ណ្ឌការងារ ដែលផ្តល់អាទិភាពពេលជ្រើសរើសតាមរយៈការផ្តល់ពិន្ទុ ការសម្ភាសន៍ និងការសម្រេចចុងក្រោយ<br>• មានការប្រឹងប្រែងក្នុងការជ្រើសរើស និងលើកកម្ពស់ស្ត្រី ប៉ុន្តែ នៅពុំទាន់បានផ្តួចផ្តើមជាមុនឲ្យបានសកម្មខ្លាំងខ្លានៅឡើយ<br>• ស្ត្រីច្រើនត្រូវជ្រើសរើស និងតែងតាំងក្នុងតួនាទីជាប្រពៃណីរបស់ស្ត្រី (ដូចជាៈផ្នែកហិរញ្ញវត្ថុ ធនធានមនុស្ស និងលទ្ធកម្មជាដើម)<br>• សម្រាប់ព្រឹត្តិការណ៍នានាពាក់ព័ន្ធយេនឌ័រ អ្នកធ្វើសេចក្តីសម្រេចជាបុរសតែងជ្រើសរើសស្ត្រីឲ្យចូលរួមកិច្ចប្រជុំឬសិក្ខាសាលា<br>• ៥៦%គិតថាពួកគាត់បានយល់ដឹងដែលថាការលើកកម្ពស់សមភាពយេនឌ័រមានសារសំខាន់នៅក្នុងកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅក្នុងដំណើរការជ្រើសរើស (ដូចជា ការតែងតាំង ការជ្រើសរើស និងការសម្ភាសន៍ជាដើម)<br>• ៦៧%យល់ថាទាំងបុរស និងស្ត្រីត្រូវបានអនុវត្តដូចគ្នាក្នុងការសម្រេចលើការតែងតាំងផ្សេងៗ។ | • ខិតខំរិះរកជម្រើសរើសលើការផ្តួចផ្តើមជាមុនឲ្យបានច្រើន ក្នុងការកំណត់ និងទាក់ទាញស្ត្រីបន្ថែមទៀត ដើម្បីប្រកួតប្រជែង តំណែងក្នុងក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំង តួនាទីមិនមែនជាប្រពៃណីរបស់ស្ត្រី។<br>• បុរសដែលធ្វើសេចក្តីសម្រេច ត្រូវចូលរួមក្នុងបញ្ហាពាក់ព័ន្ធ យេនឌ័រនៅរាល់កិច្ចប្រជុំដើម្បីបានយល់ដឹងពីបញ្ហារបស់បុរស និងស្ត្រីកាន់ប្រសើរ។ |
| ៣.៥. យេនឌ័រនៅក្នុងប្រព័ន្ធគ្រប់គ្រងលើការបំពេញ ការងារ | -- | • ប្រព័ន្ធកូតាៈ ជាការគិតខុសប្រសិនយើងមិនអនុញ្ញាតឲ្យស្ត្រី ពាក់ព័ន្ធក្នុងការងារអភិវឌ្ឍន៍។ យើងអាចចាប់ផ្តើមពី០ទៅ១ ហើយពី១ | |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | ទៅ២។ យើងតែងលើកទឹកចិត្តស្ត្រី ជាឧទាហរណ៍ នៅមូលដ្ឋានស្ត្រីមានឱកាសក្នុងការក្លាយជាសមាជិកក្រុមប្រឹក្សា ឃុំ ប៉ុន្តែស្នើសុំលាឈប់ដោយសារគាត់គិតថាតួនាទីនេះបាន បន្ថែមការងារច្រើនដល់គាត់។ យើងព្យាយាមផ្តល់អំណាចឲ្យ ស្ត្រីទទួលខុសត្រូវកាន់តែច្រើន ព្រមទាំងផ្តល់ការណែនាំពីរបៀប ចាត់ចែងដោយខ្លួនឯង។ បច្ចុប្បន្នពួកគាត់បានល្អប្រសើរ ហើយ ស្ត្រីខ្លះបានបំពេញការងារតាំងពីអាណត្តទី១ ទី២ និងទី៣។ រីឯ ថ្នាក់ខេត្ត និងស្រុកស្ត្រីមានបទពិសោធន៍ និងសមត្ថភាពច្រើនជាង។ | |
| ៣.៦. ការបណ្តុះបណ្តាលពីភាពជាអ្នកដឹកនាំដល់ស្ត្រី | -- | • ផ្នែកទី៣នៃសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នៈ ការដឹកនាំ និងការគ្រប់គ្រង<br>• ក្រុមអភិវឌ្ឍន៍សមត្ថភាពបានបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ក្រោមជាតិស្តីពីភាពជាអ្នកដឹកនាំ និងការយល់ដឹងពីយេនឌ័រ។ ១៨%នៃអ្នកចូលរួមជាស្ត្រី ដែលជាភាគរយទាបដោយសារចំនួនស្ត្រីនៅថ្នាក់ក្រោមជាតិមានចំនួនតិច(របាយការណ៍បណ្តុះបណ្តាលរបស់អនុកម្មវិធីទី២ឆ្នាំ២០១៣)។ | • បញ្ចប់ការកែសម្រួលសៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័ន ដោយបញ្ចូលនូវការបញ្ជ្រាបយេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ ស្ត្រី។ |
| **៤. ចំនុចរសើបផ្នែកយេនឌ័រ នៅក្នុងការអនុវត្តរបស់ស្ថាប័ន និងការយល់ដឹងពីលទ្ធផលនានាពាក់ព័ន្ធសមភាពយេនឌ័រ** | ២.២ | | |
| ៤.១. ការយល់ដឹងពីសារសំខាន់នៃសមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | ២.៤ | • មានការយល់ដឹងច្រើនពីសារសំខាន់នៃសមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅក្នុងគោលនយោបាយរបស់ រាជរដ្ឋា | -- |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | ភិបាលកម្ពុជា<br>• ការយល់ដឹងពីសារសំខាន់នៃគោលនយោបាយយេនឌ័រក្នុងផអ៣ នៅមានកម្រិតទាបជាង លើការបញ្ជ្រាបយេនឌ័រទៅក្នុង ផែនការ និងសកម្មភាពនៅថ្នាក់ជាតិ<br>• ៥៦%នៃមន្ត្រីរដ្ឋាភិបាលនិងនៅលេខាធិការដ្ឋានគ.ជ.អ.ប គិតគូពីយេនឌ័រនៅក្នុងគោលបំណងរួមនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>• ៦៧%នៃអ្នកចូលរួមមកពីស្ថាប័នអនុវត្តអនុកម្មវិធីបានគិតគូ យុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣ ដើម្បីសម្រេចបាននូវគោលបំណងរួមរបស់គម្រោង។ | |
| ៤.២. ការយល់ដឹងពីយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់កម្មវិធីជាតិ និងគម្រោងផអ៣ | ២.៣ | • ភាគច្រើនបានយល់ដឹងពីយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់កម្មវិធីជាតិ និងគម្រោងផអ៣ និងយល់ថាយុទ្ធសាស្ត្រផអ៣ មានភាពច្បាស់លាស់គ្រប់គ្រាន់។<br>• ៨៩%បានរាយការណ៍ថាបានអាននូវឧបសម្ព័ន្ធស្តីពីការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិនៃឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិងយុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣<br>• ៦៧%គិតថាយុទ្ធសាស្ត្រយេនឌ័រនៃផអ៣បានផ្តល់នូវការណែនាំបានច្បាស់លាស់ពីរបៀបបញ្ចូលសមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅក្នុងអនុកម្មវិធីរបស់ខ្លួន | -- |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | • ៥៦%បានផ្តល់ពិន្ទុលើស២ក្នុងពិន្ទុសរុប៣ ក្នុងការកំណត់នូវ អនុសាសន៍ដែលបានបញ្ចូលក្នុងយុទ្ធសាស្រ្តយេនឌ័ររបស់ផអ៣ | |
| ៤.៣. លើកកម្ពស់សមភាពយេនឌ័រនៅកន្លែងធ្វើ | ២.២ | • បុគ្គលិកមានភាពសកម្មក្នុងការជានាឲ្យមានការគោរពទំនាក់ទំនងរវាងស្ត្រី និងបុរស ព្រមទាំងសកម្មក្នុងការលើកកម្ពស់ សមភាពយេនឌ័រ ប៉ុន្តែពេលខ្លះត្រូវបណ្តុះបណ្តាលបន្ថែមដល់ ស្ត្រីដែលបានស្នើតែងតាំង<br>• បុគ្គលិកភាគច្រើនខិតខំប្រឹងប្រែងគាំទ្រស្ត្រីឲ្យមានសមភាព យេនឌ័រ ព្រមទាំងការពារ និងដោះស្រាយការព្រួយបារម្ភរបស់ ស្ត្រី និងកុមារ។ ការចូលរួមរបស់ស្ត្រីនាពេលបច្ចុប្បន្នមានគុណ ភាពខ្ពស់<br>• សម្រាប់ការជ្រើសរើសបុគ្គលិកថ្មី យើងតែងពិចារណាការជ្រើសរើសស្ត្រីជាអាទិភាព ហើយនៅពេលអនាគតឲ្យមានតំណាងស្ត្រីនៅគ្រប់ស្ថាប័ន អង្គភាព ព្រមទាំងឆ្លើយតបចំពោះការបញ្ហា យេនឌ័រនៅក្នុងក្របខ័ណ្ឌច្បាប់ និងការផ្តល់អំណាចដល់ស្ត្រី នៅក្នុងការតាក់តែង និងអនុវត្តយុទ្ធសាស្រ្ត<br>• ៧៨%គិតថារបៀបអនុវត្តរបស់ស្ថាប័នអនុវត្តអនុកម្មវិធី ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ព្រមទាំងការធ្វើសេចក្តីសម្រេច ត្រូវគោរពមតិយោបល់ផ្សេងៗគ្នា ឥរិយាបថ ក្រមសីលធម៌ ហើយព័ត៌មានត្រូវមានគ្រប់គ្រាន់ ឬពេញលេញ។<br>• ៤៤%គិតថាអង្គភាពនានាមិនបានប្រឹងប្រែងឲ្យបានគ្រប់គ្រាន់ក្នុងការលុបបំបាត់នូវការបង្ហាញពីវិសមភាពយេនឌ័រ ដូចជា រូបភាព | • ត្រូវមានការខិតខំប្រឹងប្រែងលុបបំបាត់ពីវិសមភាពយេនឌ័រនៅកន្លែងធ្វើការ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | ដែលមិនបង្ហាញនូវការគោរព មតិយោបល់ និងការនិយាយកម្លែងពីយេនឌ័រ ជាដើម។<br>• ៨៩%រាយការណ៍ថាមានការយកចិត្តទុកដាក់ខ្ពស់ដើម្បីឲ្យមានការគោរពរវាងបុរស និងស្ត្រីនៅកន្លែងធ្វើការ<br>• ៧៨%ឯកភាពថា កិច្ចប្រជុំនៅកន្លែងធ្វើការគឺត្រូវបានគ្របដណ្ដប់បុរស<br>• ១០០%មិនឯកភាពដែលថាការអនុវត្តយុទ្ធសាស្ត្រយេនឌ័រក្នុងគម្រោងផអ៣ គឺជាការទទួលខុសត្រូវរបស់ទីប្រឹក្សាយេនឌ័រ និងក្រសួងកិច្ចការនារី<br>• ១០០%រាយការណ៍ថាបានចូលរួមលើកកម្ពស់សមភាពយេនឌ័រនៅក្នុងការតាក់តែង និងអនុវត្តគម្រោងផអ៣ ឬឆ្លើយតបចំពោះបញ្ហាពាក់ព័ន្ធយេនឌ័រ នៅកន្លែងធ្វើការ។ | |
| ៤.៤. ឆ្លុះបញ្ចាំងសមភាពយេនឌ័រ និងផ្តល់អំណាច ដល់ស្ត្រីឲ្យបានឃើញជាសាធារណៈ | -- | | |
| ៤.៥. ការយល់ដឹងពីការរីកចម្រើនលើការអនុវត្តយុទ្ធសាស្ត្រយេនឌ័រគម្រោងផអ៣ | ១.៧ | • ៦៧%គិតថាមានការរីកចម្រើនក្នុងការអនុវត្តយុទ្ធសាស្ត្រយេនឌ័រក្នុងគម្រោងផអ៣<br>• ភាគច្រើនគិតថាពួកគាត់យល់ដឹងពីការបញ្ជ្រាបយេនឌ័រ ប៉ុន្តែចំណេះដឹងពីរបៀបបញ្ជ្រាបយេនឌ័រនៅទាបនៅឡើយ<br>• ថ្នាក់ដឹកនាំជាបុរសបានឯកភាពក្នុងការបញ្ជ្រាបយេនឌ័រ ប៉ុន្តែអត្តចរិក និងទស្សនៈពីមុននៅតែជាឧបសគ្គនៅឡើយ | សូមមើលចំនុចខាងលើ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
| --- | --- | --- | --- |
| | | • ស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិទទួលស្គាល់ថាសមត្ថភាពពួក គាត់នៅទាប<br>• ពេលស្ត្រីបានជាប់ឆ្នោតនៅថ្នាក់ឃុំ ពួកគាត់គិតថានៅតែមានបញ្ហាប្រឈម ខ្លះប្រឈមនឹងបញ្ហាគ្រួសារ ដូចជាបញ្ហាសេដ្ឋកិច្ច ការចាត់ចែង និងការទទួលខុសត្រូវក្នុងគ្រួសារ ព្រមទាំងបញ្ហាប្រពៃណី និងវប្បធម៌។ ប៉ុន្តែយើងនៅតែជំរុញ លើកកម្ពស់ពួកគាត់។ | |
| **៥. ការឆ្លើយតបបញ្ហាយេនឌ័ររបស់អង្គការដៃគូ** | ២.៨ | | |
| ៥.១. តួនាទីរបស់ដៃគូអភិវឌ្ឍន៍ក្នុងការលើកកម្ពស់ និងការគាំទ្រសមភាពយេនឌ័រ | ២.៨ | • ទាំងអស់គ្នាទទួលស្គាល់ថាការលើកកម្ពស់សមភាពយេនឌ័រ មានសារៈសំខាន់ណាស់សម្រាប់ដៃគូអភិវឌ្ឍន៍ភាគច្រើន<br>• ក្នុងពេលកន្លងមក ដៃគូអភិវឌ្ឍន៍បានគាំទ្រក្រុមប្រឹក្សាឃុំ ដែលស្ត្រីហាក់ដូចជាភាពវាងវៃជាងស្ត្រីនៅថ្នាក់ស្រុក (ដែលស្ថិតក្នុងអាណត្តទី១)។ | • ត្រូវការការគាំទ្រពីដៃគូអភិវឌ្ឍន៍បន្ថែមទៀតដើម្បីពង្រឹងថ្នាក់ ស្រុកទាំងក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការងារអភិវឌ្ឍ និងការបញ្ជ្រាបយេនឌ័រ។ |
| ៥.២. តួនាទីអង្គការមិនមែនរដ្ឋាភិបាលជាដៃគូក្នុងការ លើកកម្ពស់ និងគាំទ្រសមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី។ | ២.៨ | • ទាំងអស់គ្នាទទួលស្គាល់ថាមិនមែនរដ្ឋាភិបាលមានសារសំខាន់ក្នុងការតាក់តែង និងអនុវត្តសកម្មភាពពង្រឹងសមត្ថភាព និង បង្កើនសមភាពយេនឌ័រ និងភាពជាតំណាង ព្រមទាំងសម្លេងរបស់ស្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ | • ក្រសួងមហាផ្ទៃ និងអនុកម្មវិធីទី២នៅតែត្រូវការអង្គការមិនមែនរដ្ឋាភិបាលជាដៃគូក្នុងការគាំទ្រលើការអភិវឌ្ឍសមត្ថភាព និងកំណែទម្រង់នានា។<br>• ការផ្តល់រង្វាន់ដល់ស្ត្រី គ្រាន់តែជារូបភាពប៉ុណ្ណោះ អនុកម្មវិធីទី២ត្រូវការពង្រឹងគុណភាពនៃការបញ្ជ្រាបយេនឌ័រ។ អនុកម្មវិធីទី២នឹងសាកល្បង |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | | គម្រោងនៅសហគមន៍មួយចំនួន បន្ទាប់មក ពង្រីកសកម្មភាពទៅសហគមន៍ផ្សេងទៀត។ |
| **ពិន្ទុសមាសភាគ** | ២.០ | | |

## ឧបសម្ព័ន្ធទី ៦.៣ ÷ បណ្ណដាក់ពិន្ទុ

អនុកម្មវិធីទី៣ ៖ ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| **១. យេនឌ័រនៅក្នុងការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការត្រួតពិនិត្យ វាយតម្លៃ និងឥទ្ធិពល ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** | ២.១ | | |
| ១.១. ការរៀបចំតាក់តែងគោលនយោបាយ | ២.០ | • កម្មវិធីជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្លើយតបភាគច្រើនចំពោះអនុសាសន៍របស់សវនកម្ម យេនឌ័រ ឧទាហរណ៍ ប្រព័ន្ធកូតា ដែលបានបង្កើតគោលនយោបាយជាតិស្តីពីការជ្រើសរើសស្ត្រី(២០-៥០%នៃអ្នកជ្រើសរើសថ្មី) បានបង្កើនអាយុចូលនិវត្តន៍សម្រាប់ដល់៦០ឆ្នាំដូចបុរស<br>• សេចក្តីព្រាងគោលនយោបាយស្តីការអភិវឌ្ឍ និងការគ្រប់គ្រងធនធានមនុស្សសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក៏បានដាក់ថាស្ត្រីជាអាទិភាព ក្នុងការជ្រើសរើសមន្ត្រីរាជការ ការតំឡើងឋានៈ និងការតែងតាំង ព្រមទាំងការលើកចិត្តផ្សេងៗ។ ចំណុចទី៣នៃគោលនយោបាយនេះចែងថា "ពង្រឹង និងពង្រីកការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅក្នុងមុខងារសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយមានការយល់ដឹងឲ្យបានស៊ីជម្រៅ និងទូលំទូលាយលើការអភិវឌ្ឍសមត្ថភាព និងការចូលរួមយ៉ាងសកម្មរបស់បុរស និងស្ត្រីនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅ | |

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | មូលដ្ឋាន ក៏ដូចជាការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ជាតិឆ្ពោះទៅភាពរុងរឿង ភាពរីកចម្រើន និងសុខដុមនីយកម្ម<br>•ឆ្លើយតបដោយប្រសិទ្ធភាពចំពោះបញ្ហាយេនឌ័រតាមរយៈលិខិតបទដ្ឋានគតិយុត្តនានា ដែលគាំទ្រដោយលេខាធិការដ្ឋានគ.ជ.អ.ប និងក្រសួងកិច្ចការនារីក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ។ | |
| ១.២. ការកសាងផែនការ | ២.៧ | •អាទិភាពលើការគ្រប់គ្រងធនធានមនុស្សពាក់ព័ន្ធយេនឌ័រ បានបញ្ចូលត្រឹមត្រូវទៅក្នុងគម្រោងផអ៣ និងផ.ស.ថប្រចាំឆ្នាំ<br>•៨០% នៃអ្នកដែលបានឆ្លើយសំណួរគិតថាប្រព័ន្ធនៃការរៀបចំ កម្មវិធីក្នុងស្ថាប័នអនុវត្តអនុកម្មវិធីបានល្អប្រសើរដើម្បីធានា នូវគុណភាពនៃការអនុវត្តយុទ្ធសាស្ត្រយេនឌ័រផអ៣<br>•អ្នកដែលបានឆ្លើយសំណួរស្ទើរទាំងអស់ឯកភាពថាមានការលំបាកក្នុងការបញ្ជ្រាបយេនឌ័រក្នុងយុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣ពីព្រោះជាការលំបាកសម្រាប់អនុកម្មវិធីទាំងអស់ដើម្បី កំណត់ការទទួលខុសត្រូវ និងសកម្មភាពនានា។ | •យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រត្រូវកំណត់សកម្មភាពឲ្យបានច្បាស់លាស់នូវការទទួលខុសត្រូវរបស់អនុកម្មវិធីនីមួយៗ (រួមទាំងអនុកម្មវិធីទី៣)<br>•លេខាធិការដ្ឋានគ.ជ.អ.ប ត្រូវបង្កើតអង្គភាពមួយដែលទទួល ខុសត្រូវការងារយេនឌ័រ។ ប្រសិនបើអនុកម្មវិធីណាមួយត្រូវការ ស្នើសុំយោបល់ស្តីពីការបញ្ជ្រាបយេនឌ័រ គឺអង្គភាពយេនឌ័រអាច គាំទ្រដល់អនុកម្មវិធីទាំងនោះ។ |
| ១.៣. ការរៀបចំថវិកា | ១.៥ | •ពុំទាន់មានការវិភាជថវិកាជាក់លាក់សម្រាប់សកម្មភាពឆ្លើយតបយេនឌ័រ (មានតែមន្ត្រីរាជការ១០០នាក់ប៉ុណ្ណោះ បានទទួលការបណ្តុះបណ្តាល)។ | •វិភាជថវិកាគួរផ្តោតលើការពង្រឹងការបញ្ជ្រាបយេនឌ័រ និងពង្រឹងភាពជាអ្នកដឹកនាំរបស់ស្ត្រី។ |
| ១.៤. ការអនុវត្ត | ២.៣ | •ការអនុវត្តគោលនយោបាយជាតិស្តីពីសមត្ថភាពយេនឌ័រ ក្នុងការជ្រើសរើស (២០-៥០%នៃអ្នកជ្រើសរើសថ្មី) | |

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | •សេចក្ដីព្រាងគោលនយោបាយអភិវឌ្ឍន៍ និងគ្រប់គ្រងធនធាន មនុស្សថ្នាក់ក្រោមជាតិ នៅរង់ចាំការអនុមត<br>•ក្រសួងមុខងារសាធារណៈបានអនុវត្តការបញ្ជ្រាបយេនឌ័រក្នុងការរៀបចំគោលនយោបាយ (ដូចជា មុនពេលបញ្ជ្រាបយេនឌ័រ ក្នុងគោលនយោបាយអភិវឌ្ឍ និងគ្រប់គ្រងធនធានមនុស្ស យើងបានបណ្ដុះបណ្ដាលមន្ត្រីស្រុកដើម្បីប្រមូលទិន្នន័យនៅថ្នាក់ក្រោមជាតិរួមមានអភិបាលរងជាស្ត្រីនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ត្រីមន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីស្រុក និងមន្ទីរជំនាញនានា។<br>•អនុកម្មវិធីទី៣បានសហការជាមួយក្រសួងកិច្ចការនារីក្នុងការបញ្ចូលបញ្ហាយេនឌ័រតាមនាយកដ្ឋាននូវក្រុមការងារបញ្ជ្រាបយេនឌ័រ។ អនុកម្មវិធីទី៣បានស្វែងយល់តាមរយៈវគ្គបណ្ដុះបណ្ដាលពីការយល់ដឹងយេនឌ័រពីទីប្រឹក្សាយេនឌ័រដែលបានចូលរួមរៀបចំគោលនយោបាយ។ អនុកម្មវិធីទី៣ក៏បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា (រួមទាំងក្រុមការងារបញ្ជ្រាបយេនឌ័រ)។ | |
| ១.៥. ការត្រួតពិនិត្យ | ១.៨ | •សូចនាករពាក់ព័ន្ធនឹងចំនួនស្ត្រីនៅក្នុងសេវាសាធារណៈបានឆ្លុះ បញ្ចាំងបានល្អនៅក្នុងសូចនាករនៃរបាយការណ៍ត្រួតពិនិត្យ | |
| **២. ជំនាញបច្ចេកទេសដើម្បីគាំទ្រការតាក់តែង និងការអនុវត្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលមានលក្ខណៈឆ្លើយតបយេនឌ័រ** | ១.៧ | | |

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| ២.១. សមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ | ២.១ | •៦០%បានគិតថាពួកគាត់មានសមត្ថភាពការបញ្ចូលបញ្ហា យេនឌ័រទៅក្នុងដំណាក់កាលនានា<br>•៦០%តែងតែបានពិចារណាការបញ្ហាយេនឌ័រនៅក្នុងការងាររបស់ពួកគាត់ ហើយ២០%គឺបានធ្វើជាញឹកញាប់<br>•ទាំងអស់គ្នាយល់ថាស្ថាប័នអនុវត្តអនុកម្មវិធីរបស់ខ្លួនមានសមត្ថភាព ឬសមត្ថភាពច្រើនក្នុងការវិភាគយេនឌ័រ និងបញ្ចូលនូវការសន្និដ្ឋានបានពីការវិភាគទៅក្នុងដំណើរការកសាងផែនការ | |
| ២.២. ការពង្រឹងសមត្ថភាពផ្ទៃក្នុងស្តីពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រទៅក្នុងការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី | ១.៨ | •ភាគច្រើនយល់ថាពួកគាត់ទទួលបានការពង្រឹងសមត្ថភាពគ្រប់គ្រាន់ស្តីពីយេនឌ័រ អនុកម្មវិធីទី៣មានក្រុមការងារបញ្ជ្រាបយេនឌ័រដើម្បីគាំទ្រការបញ្ជ្រាបយេនឌ័រផ្ទៃក្នុងព្រមទាំងមានទំនាក់ទំនងការងារល្អជាមួយក្រសួងកិច្ចការនារី<br>•ការបណ្តុះបណ្តាលស្តីពីយេនឌ័រភាគច្រើនតាមត្រឹមតែទ្រឹស្តី និងការយល់ដឹងផ្សេងៗ ប៉ុន្តែមានការសំណូមពរឲ្យការបណ្តុះបណ្តាលពីភាពជាក់ស្តែង (ដូចជា មិនបានដឹងពីរបៀបបញ្ចូលយេនឌ័រទៅក្នុងសកម្មភាពមួយចំនួន)<br>•ការបណ្តុះបណ្តាលបានផ្តោតទាំងបុរស និងស្ត្រីស្មើគ្នា<br>•៨០%គិតថាអង្គភាពពួកគាត់បានផ្តល់ឱកាសគ្រប់គ្រាន់ដើម្បីពង្រឹងចំណេះដឹងស្តីពីបញ្ហាយេនឌ័រ។ | •ត្រូវការថវិកាបន្ថែមទៀតសម្រាប់វគ្គបណ្តុះបណ្តាលយេនឌ័រ កាលពីឆ្នាំមុខអនុកម្មវិធីទី៣ និងក្រសួងកិច្ចការនារីបានបណ្តុះបណ្តាលមន្ត្រីរាជការថ្មីតែ១០០នាក់ប៉ុណ្ណោះដែលផ្តល់ថវិកាដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ។ |
| ២.៣. ការបណ្តុះបណ្តាលគ្រប់គ្រាន់ និងឯកសារយោងផ្សេងៗស្តីពីបញ្ហាយេនឌ័រ និងការ | ១.៣ | •ភាគច្រើនយល់ថាពួកគេត្រូវការវគ្គបណ្តុះបណ្តាលយេនឌ័របន្ថែមទៀតអនុកម្មវិធីទី៣មិនមានសៀវភៅណែនាំ ហើយសហការជាមួយក្រសួង | •រៀបចំចងក្រងនូវឧបករណ៍ថ្មីសមស្រប |

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| បញ្ជ្រាបយេនឌ័រ។ | | កិច្ចការនារីដោយប្រើប្រាស់សៀវភៅណែនាំយេនឌ័ររបស់ក្រសួងកិច្ចការនារី។<br>• ៦០%គិតថានៅពុំទាន់មានឧបករណ៍គ្រប់គ្រាន់ ក្នុងការបញ្ជ្រាប(ឧ. សេចក្តីណែនាំ សៀវភៅណែនាំ បញ្ជីផ្ទៀងផ្ទាត់ជាដើម) ព្រមទាំងខ្វះបច្ចេកទេសបញ្ជ្រាបយេនឌ័រនៅក្នុងការងារ។<br>• ៤០%គិតថាពួកគាត់មិនមានព័ត៌មាន និងអនុវត្តមិនគ្រប់គ្រាន់ លើការប្រើប្រាស់ឧបករណ៍វិភាគយេនឌ័រ និងបញ្ចូលការសន្និដ្ឋានពីការវិភាគទៅក្នុងគ្រប់ដំណាក់កាលនៃដំណើរការរៀបចំកម្មវិធី និងសកម្មភាពផ្សេងៗ។ | |
| ២.៤. មានជំនាញដើម្បីគាំទ្រដល់ការបញ្ជ្រាបអំពីគុណភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | ២.៧ | • ភាគច្រើនបានប្រើប្រាស់ចំណេះដឹង និងពេញចិត្តចំពោះការ គាំទ្រពីអ្នកជំនាញយេនឌ័ររបស់លេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងកិច្ចការនារី និងក្រុមការងារបញ្ជ្រាបយេនឌ័រ ដើម្បីរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានមនុស្សសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយកំពុងរង់ចាំការអនុមតពីនាយករដ្ឋមន្ត្រី<br>• ៨០%បានពិគ្រោះយោបល់ផ្ទាល់ជាមួយក្រសួងកិច្ចការនារី ទីប្រឹក្សា ឬអ្នកជំនាញយេនឌ័រផ្សេងទៀតច្រើនជាង៣ដងលើការបញ្ជ្រាបយេនឌ័រនៅក្នុងការងារ<br>• ៨០%ពេញចិត្តចំពោះការគាំទ្រពីទីប្រឹក្សាយេនឌ័ររបស់លេខាធិការដ្ឋានគ.ជ.អ.បស្តីពីការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | |

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | •៨០%ពេញចិត្តចំពោះការរួមចំណែករបស់ក្រសួងកិច្ចការនារីក្នុងការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅពុំទាន់បានគ្រប់គ្រាន់នៅឡើយ<br>•៦០%បានផ្តល់ពិន្ទុចំពោះការរួមចំណែករបស់ក្រុមការងារបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានល្អបំផុត និង៤០%គិតថាបានគ្រប់គ្រាន់។ | |
| ២.៥. បញ្ចូលគុណភាពយេនឌ័រទៅក្នុងការអភិវឌ្ឍ សមត្ថភាពនៃកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ១.៥ | •មានការប្រឹងប្រែងបញ្ចូលយេនឌ័រទៅក្នុងការអភិវឌ្ឍសមត្ថភាពដោយសហការជាមួយក្រសួងកិច្ចការនារី និងអ្នកជំនាញនៅលេខាធិការដ្ឋាន គ.ជ.អ.ប, មានធនធានតិចតួចដើម្បីអនុវត្តអភិវឌ្ឍសមត្ថភាព។ | |
| **៣. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងការចាត់ចែងបុគ្គលិក** | ១.៧ | | |
| ៣.២. សមាមាត្រស្ត្រីនៅតំណែងធ្វើសេចក្តីសម្រេច ក្នុងអនុកម្មវិធីនានា | ១.០ | • ១១%នៃតំណែងធ្វើសេចក្តីសម្រេចថ្នាក់ខ្ពស់នៅក្នុងចំណោម មន្ត្រីរាជការនៅថ្នាក់ជាតិ មានស្ត្រី ១៧៧នាក់/១៥៦៨នាក់ ដែលមានឋានៈចាប់ពីលំដាប់អគ្គនាយកដល់លំដាប់នាយកដ្ឋាន និងអង្គភាព (ព្រឹត្តប័ត្រនារីតនះផ្សាយលេខ៧ខែមិនាឆ្នាំ២០១៣)។ | •ខិតខំស្វែងរកជម្រើសនានាសម្រាប់ពង្រឹងជំនាញនិងទំនុកចិត្តដល់បុគ្គលិកជាស្ត្រីដើម្បីពួកគាត់មានគុណសម្បត្តិទទួលបាន តំណែងខ្ពស់ៗ។ |
| ៣.៣. សមាមាត្រស្ត្រី ក្នុងតំណែងគ្រប់គ្រងថ្នាក់កណ្តាល និងបុគ្គលិកជំនាញនៅតាមអនុកម្មវិធីនានា | ២.០ | •២៦%នៃតំណែងគ្រប់គ្រងថ្នាក់កណ្តាល និងបុគ្គលិកជំនាញនៅថ្នាក់ជាតិមានស្ត្រី៨៣០៤នាក់/៣១៩៨២នាក់ដែលមានឋានៈចាប់ពីអនុប្រធាននាយកដ្ឋានដល់មន្ត្រីជំនាញ (ព្រឹត្តប័ត្រនារីតនះផ្សាយលេខ៧ ខែមិនាឆ្នាំ២០១៣)។ | ដូចចំនុចខាងលើ<br>•ពង្រឹងគោលនយោបាយថ្នាក់ជាតិស្តីពីសមភាពយេនឌ័រ ក្នុងការជ្រើសរើសមន្ត្រី (២០-៥០%)។ |
| ៣.៤. ការយល់ដឹងស្តីពីយេនឌ័រ និង បញ្ហា | ២.១ | •កម្រិតយល់ដឹងពីយេនឌ័រ និងការលើកកម្ពស់សមភាពយេនឌ័រ ត្រូវ | •ត្រូវកែសម្រួលការរៀបចំលក្ខណៈ |

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| រសើបផ្នែកយេនឌ័រនៅក្នុងការគ្រប់គ្រងធនធានមនុស្ស | | បានបញ្ចូលក្នុងលក្ខខ័ណ្ឌការងារ ដែលផ្តល់អាទិភាពពេល ជ្រើសរើសតាមរយៈការផ្តល់ពិន្ទុ ការសម្ភាសន៍ និងការសម្រេច ចុងក្រោយ (យុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រក្នុងមុខងារសាធារណៈ ឆ្នាំ២០១១-១៣)<br>• មានការប្រឹងប្រែងក្នុងការជ្រើសរើស និងលើកកម្ពស់ស្រ្តី ប៉ុន្តែ នៅពុំទាន់បានផ្តួចផ្តើមជាមុនឲ្យបានសកម្មខ្លាំងខ្លានៅឡើយ<br>•ស្រ្តីច្រើនត្រូវជ្រើសរើស និងតែងតាំងក្នុងតួនាទីជាប្រពៃណីរបស់ស្រ្តី (ដូចជាៈផ្នែកហិរញ្ញវត្ថុ ធនធានមនុស្ស និងលទ្ធកម្មជាដើម) ប៉ុន្តែមិនមែនសម្រាប់ការងារបច្ចេកទេស ដូចជាក្រសួងមុខងារសាធារណៈ ជ្រើសរើសបានមន្ត្រី ៥នាក់សុទ្ធតែបុរសដោយសារពុំមានបេក្ខនារីដាក់ពាក្យប្រលង បើទោះបីក្រសួងព្យាយាមលើកទឹកចិត្តបេក្ខនារីតាមរយៈសេចក្តីប្រកាសរបស់ខ្លួនក៏ដោយ<br>• ៤០%គិតថាពួកគាត់បានយល់ដឹងដែលថាការលើកកម្ពស់សមភាពយេនឌ័រមានសារសំខាន់នៅក្នុងកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅក្នុងដំណើរការជ្រើសរើស(ដូចជា ការតែងតាំង ការជ្រើសរើស និងការសម្ភាសន៍ជាដើម)<br>• ៦០%យល់ថាមានការផ្តួចផ្តើមជាមុនតិចតួចក្នុងការជ្រើសរើសបុគ្គលិកជាស្រ្តីឲ្យបានច្រើន<br>•៤០%យល់ថាទាំងបុរស និងស្រ្តីត្រូវបានអនុវត្តដូចគ្នាក្នុងការ សម្រេចលើការតែងតាំងផ្សេងៗ។ | សម្បត្តិនៅក្នុងល័ក្ខខ័ណ្ឌការងារសម្រាប់ស្រ្តី។ |
| ៣.៦. ការបណ្តុះបណ្តាលពីភាពជាអ្នកដឹកនាំ | -- | •៦០%នៃអ្នកចូលរួមបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការថ្មីគឺជា ស្ត្រីនៅ | •ត្រូវការឲ្យមានវគ្គបណ្តុះបណ្តាល |

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| ដល់ស្ត្រី | | ថ្នាក់ជាតិដោយសារអនុវកម្មវិធីទី៣តម្រូវឲ្យមានបុរស ៥០% និងស្ត្រី ៥០%។ វគ្គបណ្តុះបណ្តាលនេះរួមមានភាពជា អ្នកដឹកនាំ និងការបញ្ជ្រាបយេនឌ័រ(ក្រសួងមុខងារសាធារណៈ និងក្រសួងកិច្ចការនារី)។ | កាន់តែស៊ីជម្រៅស្តីការបញ្ជ្រាបយេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី។<br>• ត្រូវការថវិកាបន្ថែមសម្រាប់វគ្គបណ្តុះបណ្តាល។ |
| **៤. ចំនុចរសើបផ្នែកយេនឌ័រ នៅក្នុងការអនុវត្តរបស់ស្ថាប័ន និងការយល់ដឹងពីលទ្ធផលនានាពាក់ព័ន្ធសមភាពយេនឌ័រ** | ២.៣ | | |
| ៤.១. ការយល់ដឹងពីសារសំខាន់នៃសមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | ២.៥ | • មានការយល់ដឹងច្រើនពីសារសំខាន់នៃសមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅក្នុងគោលនយោបាយរបស់ រាជរដ្ឋាភិបាលកម្ពុជា<br>• ទាំងអស់គ្នាទទួលស្គាល់ថាយេនឌ័រមានសារសំខាន់ចំពោះរាជរដ្ឋាភិបាលដោយបានដឹងពីគោលបំណងរួមរបស់កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>• ទាំងអស់គ្នាទទួលស្គាល់ថាយុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣មានសារសំខាន់ណាស់ចំពោះស្ថាប័នអនុវត្តអនុកម្មវិធីក្នុងការសម្រេចបានបាននូវគោលបំណងរួមរបស់គម្រោង។ | -- |
| ៤.២. ការយល់ដឹងពីយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ របស់កម្មវិធីជាតិ និងគម្រោងផអ៣ | ២.២ | • ភាគច្រើនបានយល់ដឹងពីយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់កម្មវិធីជាតិ និងគម្រោងផអ៣ និងយល់ថាយុទ្ធសាស្ត្រផអ៣មានភាពច្បាស់លាស់គ្រប់គ្រាន់។<br>• ៦០%បានរាយការណ៍ថាបានអាននូវឧបសម្ព័ន្ធស្តីពីការបញ្ជ្រាប | -- |

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | យេនឌ័រនៅថ្នាក់ក្រោមជាតិនៃឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនិងយុទ្ធសាស្ត្រយេនឌ័ររបស់ ផអ៣<br>•៦០%គិតថាយុទ្ធសាស្ត្រយេនឌ័រនៃផអ៣បានផ្តល់នូវការណែនាំបានច្បាស់លាស់ពីរបៀបបញ្ចូលសមភាពយេនឌ័រ និងការ ផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅក្នុងអនុកម្មវិធីរបស់ខ្លួន<br>•ការយល់ដឹងលម្អិតអំពីយុទ្ធសាស្ត្រផអ៣មានកម្រិតទាប<br>•៤០%បានផ្តល់ពិន្ទុលើស២ក្នុងពិន្ទុសរុប៣ក្នុងការកំណត់នូវអនុសាសន៍ដែលបានបញ្ចូលក្នុងយុទ្ធសាស្ត្រយេនឌ័ររបស់ផអ៣ | |
| ៤.៣. លើកកម្ពស់សមភាពយេនឌ័រនៅកន្លែងធ្វើ | ២.២ | •បុគ្គលិកមានភាពសកម្មក្នុងការធានាឲ្យមានការគោរពទំនាក់ទំនងរវាងស្ត្រី និងបុរស ព្រមទាំងសកម្មក្នុងការលើកកម្ពស់ សមភាពយេនឌ័រ ប៉ុន្តែពេលខ្លះត្រូវបណ្តុះបណ្តាលបន្ថែមដល់ ស្ត្រីដែលបានស្នើតែងតាំង<br>•សម្រាប់ការជ្រើសរើសបុគ្គលិកថ្មី យើងតែងពិចារណាការជ្រើសរើសស្ត្រីជាអាទិភាពតាមរយៈការផ្តល់ពិន្ទុ<br>•ទាំងអស់គ្នាគិតថារបៀបអនុវត្តរបស់ស្ថាប័នអនុវត្តអនុកម្មវិធី ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ព្រមទាំងការធ្វើសេចក្តីសម្រេច ត្រូវគោរពមតិយោបល់ផ្សេងៗគ្នា ឥរិយាបថ ក្រមសីលធម៌ ហើយព័ត៌មានត្រូវមានគ្រប់គ្រាន់ ឬពេញលេញ។<br>•ទាំងអស់គ្នាគិតថាអង្គភាពរបស់ខ្លួនបានប្រឹងប្រែងក្នុងការលុបបំបាត់នូវការបង្ហាញពីវិសមភាពយេនឌ័រ ដូចជា រូបភាពដែលមិនបង្ហាញនូវការ | |

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | គោរព មតិយោបល់ និងការនិយាយកម្លែងពីយេនឌ័រ ជាដើម<br>• ទាំងអស់គ្នាគិតថាពួកគាត់បានយកចិត្តទុកដាក់ដើម្បីឲ្យមានការគោរពទំនាក់ទំនងរវាងបុរស និងស្ត្រីនៅកន្លែងធ្វើការ (៨០%ឆ្លើយថាយកចិត្តទុកដាក់ខ្ពស់ ២០%ឆ្លើយថាយកចិត្តទុកដាក់ ល្មម)<br>• ៨០%ឯកភាពថា កិច្ចប្រជុំនៅកន្លែងធ្វើការគឺត្រូវបានគ្របដណ្តប់បុរស<br>• ៨០%មិនឯកភាពដែលថាការអនុវត្តយុទ្ធសាស្ត្រយេនឌ័រក្នុងគម្រោងផអ៣ គឺជាការទទួលខុសត្រូវរបស់ទីប្រឹក្សាយេនឌ័រ និងក្រសួងកិច្ចការនារី<br>• ៦០%រាយការណ៍ថាបានចូលរួមលើកកម្ពស់សមភាពយេនឌ័រនៅក្នុងការតាក់តែង និងអនុវត្តគម្រោងផអ៣ ឬឆ្លើយតបចំពោះបញ្ហាពាក់ព័ន្ធយេនឌ័រ នៅកន្លែងធ្វើការ<br>• ដោយសារវប្បធម៌ខ្មែរ សម្រាប់ស្ត្រីមួយចំនួនមិនសូវចង់និយាយច្រើន។ អនុកម្មវិធីទី៣គាំទ្រការផ្តល់អំណាចដល់ស្ត្រីដើម្បីចូលរួមក្នុងការបញ្ចេញគំនិតយោបល់ក្នុងកិច្ចប្រជុំថ្នាក់ជាតិ ឬអន្តរជាតិ។ | |
| ៤.៤. ឆ្លុះបញ្ចាំងសមភាពយេនឌ័រ និងផ្តល់អំណាច ដល់ស្ត្រីឲ្យបានឃើញជាសាធារណៈ | -- | • ការផ្តល់អំណាចដល់ស្ត្រីបង្ហាញពីការតាំងអចិត្តខ្ពស់តាមព្រឹត្តិការណ៍សាធារណៈដូចជា របាយការណ៍ គេហទំព័រ ប្រតិទិន កូនសៀវភៅតូចៗ និងសកម្មភាពផ្សេងៗទៀត។ | • ត្រូវមានការលើកទិកចិត្តបន្ថែមទៀតដល់ស្ត្រី |
| ៤.៥. ការយល់ដឹងពីការរីកចម្រើនលើការអនុវត្ត យុទ្ធសាស្ត្រយេនឌ័រក្នុងគម្រោងផអ៣ | ១.៧ | • ទាំងអស់គ្នារាយការណ៍ថាមានការរីកចម្រនើក្នុងការអនុវត្តយុទ្ធសាស្ត្រយេនឌ័រក្នុងគម្រោងផអ៣ក្នុងនោះ យល់ថាបានល្អ (៨០%) និងបានល្អ ប្រសើរ (២០%)។ | សូមមើលចំនុចខាងលើ |

| សូចនាករ | ពិន្ទុ | មតិយោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| **៥. ការឆ្លើយតបបញ្ហាយេនឌ័រ របស់អង្គការដៃគូ** | ២.០ | | |
| ៥.១. តួនាទីរបស់ដៃគូអភិវឌ្ឍន៍ក្នុងការលើកកម្ពស់ និងការគាំទ្រសមភាពយេនឌ័រ | ២.០ | • ការលើកកម្ពស់សមភាពយេនឌ័រត្រូវបានទទួលស្គាល់ថា មានសារៈសំខាន់ណាស់សម្រាប់ដៃគូអភិវឌ្ឍន៍ភាគច្រើន ប៉ុន្តែអនុកម្មវិធីទី៣មានបញ្ហាប្រឈមផ្នែកថវិកា។ | • ត្រូវការការគាំទ្រពីដៃគូអភិវឌ្ឍន៍បន្ថែមទៀតដើម្បីពង្រឹងសមត្ថភាពសម្រាប់មន្ត្រីរាជការស៊ីវិល។ |
| ៥.២. តួនាទីអង្គការមិនមែនរដ្ឋាភិបាលជាដៃគូក្នុងការ លើកកម្ពស់ និងគាំទ្រសមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី។ | ២.០ | • ទាំងអស់គ្នាទទួលស្គាល់ថាមិនមែនរដ្ឋាភិបាលមានសារសំខាន់ក្នុងការតាក់តែង និងអនុវត្តយុទ្ធសាស្ត្រយេនឌ័រគម្រោងផអ៣។ | • ក្រសួងមុខងារសាធារណៈ និងអនុកម្មវិធីទី៣ នៅតែត្រូវការអង្គការមិនមែនរដ្ឋាភិបាលជាដៃគូក្នុងការគាំទ្រលើការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលពាក់ព័ន្ធនឹងកំណែទម្រង់រដ្ឋបាល។ |
| **ពិន្ទុសមាសភាគ** | ២.០ | | |

# ឧបសម្ព័ន្ធទី ៦.៤
# របាយការណ៍សវនកម្មយេនឌ័រសម្រាប់អនុកម្មវិធីទី៤

## ១. សេចក្តីផ្តើម

អនុកម្មវិធីទី៤ លើកឡើងពីក្របខ័ណ្ឌគោលនយោបាយសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងរៀបចំតាក់តែង និងអនុវត្តយន្តការផ្តល់មូលនិធិចំនួន៣ប្រភេទដើម្បីធានាឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបានការផ្តល់មូលនិធិផ្អែកតាមរូបមន្តច្បាស់លាស់ មានតម្លាភាព និងគ្មានល័ក្ខខ័ណ្ឌ។ យន្តការទាំងនោះរួមមាន៖ មូលនិធិឃុំ សង្កាត់ មូលនិធិក្រុង ស្រុក និងឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF)។ ទន្ទឹមនឹងនេះ យន្តការផ្ទេរថវិកាបច្ចុប្បន្នពីថ្នាក់ជាតិទៅរាជធានី ខេត្ត គួរត្រូវបានពិនិត្យមើលឡើងវិញដើម្បីធ្វើឲ្យប្រសើរឡើង និងធានានូវគោលការណ៍សម្រាប់សមធម៌ តម្លាភាព គណនេយ្យភាព និងភាពសក្តិសិទ្ធិ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលស្ថិតក្រោមអនុកម្មវិធីនេះ ក៏ទទួលខុសត្រូវសម្រាប់រៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ (រួមមានប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិ នីតិវិធីលទ្ធកម្ម ជាដើម) កែសម្រួលប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់បច្ចុប្បន្ន ដើម្បីអាចឲ្យឃុំ សង្កាត់ មានលទ្ធភាពចូលរួមអនុវត្តនូវការផ្តល់មូលនិធិរួមគ្នា និងគ្រប់គ្រងចាត់ចែងគម្រោងអន្តររដ្ឋបាល ព្រមទាំងរៀបចំដំណើរការ សម្រាប់ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឲ្យមានប្រសិទ្ធភាព។

ជាងនេះទៀត អនុកម្មវិធីទី៤មិនគ្រាន់តែពាក់ព័ន្ធបញ្ហាគោលនយោបាយ និងរៀបចំកម្មវិធីអភិវឌ្ឍន៍សមត្ថភាព ដែលតាមរយៈនោះ ក្រសួងសេដ្ឋកិច្ចនឹងអភិវឌ្ឍសមត្ថភាពដើម្បីប្រតិបត្តិការ និងត្រួតពិនិត្យមើលគំរូនៃការផ្តល់មូលនិធិ ព្រមទាំងបង្កើតនូវប្រព័ន្ធ និងសមត្ថភាពសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ក្រោមជាតិ នៅថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ព្រមទាំងអភិវឌ្ឍន៍សមត្ថភាពបន្ថែមទៀតដល់ឃុំ សង្កាត់ លើការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន។

## ២. គោលបំណង

ក). ដើម្បីវាយតម្លៃតើអនុកម្មវិធីទី៤ បានបញ្ជ្រាបយេនឌ័រកម្រិតណាទៅក្នុងការអនុវត្តកម្មវិធីពាក់ព័ន្ធការរៀបចំគោលនយោបាយ ជំនាញបច្ចេកទេស ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការគ្រប់គ្រងបុគ្គលិក ព្រមទាំងពីភាពរសើបនៅក្នុងដំណើរការរបស់ស្ថាប័ន និងការទទួលស្គាល់ពីលទ្ធផលនានាពាក់ព័ន្ធសមធម៌យេនឌ័រ។

ខ). ដើម្បីកំណត់បញ្ហាដែលរារាំងដល់ដំណើរការបញ្ជ្រាបយេនឌ័រទៅក្នុងការកសាងផែនការ និងការអនុវត្តអនុកម្មវិធីទី៤។

គ). ដើម្បីផ្តល់អនុសាសន៍ជាក់លាក់នានាក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីនៅក្នុងអនុកម្មវិធីទី៤

## ៣. វិធីសាស្ត្រ និងការកំណត់ទំហំការងារ

វិធីសាស្ត្រដែលបានគ្រោងបានអនុវត្តនូវដំណើរការ៣ប្រភេទ គឺទី១.ការពិនិត្យមើលឯកសារ ទី២.ការបំពេញបញ្ជីសំណួរអនឡាញ និងចុងក្រោយគឺការសម្ភាសន៍។ ការសម្ភាសន៍ត្រូវធ្វើជាមួយប្រធានអនុកម្មវិធីទី៤ អនុប្រធាន២រូប និងទីប្រឹក្សាអនុកម្មវិធីទី៤។ ទោះបីយ៉ាងណាក៏ដោយ អវត្តមានប្រធាន និងអនុប្រធាន១រូប ដូច្នេះមានតែអនុប្រធាន១រូប និងទីប្រឹក្សា១រូបត្រូវបានសម្ភាសន៍។ ការសម្ភាសន៍ជាមួយមន្ត្រីទាំង២រូបនេះ បានធ្វើការពិភាក្សាជាក្រុម។ ក្រៅពីនេះ មានតែមន្ត្រីតែម្នាក់បានបំពេញបញ្ជីសំណួរក្នុងចំណោមមន្ត្រីអនុកម្មវិធីទី៤ទាំងអស់ដែលបានស្នើសុំឲ្យបំពេញបញ្ជីសំណួរ។ ដូច្នេះ ការសវនកម្មនេះ ភាគច្រើនតាមរយៈការពិនិត្យមើលឯកសារ និងការសម្ភាសន៍។

## ៤. លទ្ធផលរកឃើញ

លទ្ធផលរកឃើញពីការធ្វើសវនកម្ម ត្រូវបានរៀបរាប់ និងពិភាក្សានៅក្នុងតារាងខាងក្រោម ដោយមានអនុសាសន៍លើបញ្ហាជាក់លាក់មួយចំនួន។

## បណ្ណដាក់ពិន្ទុសវនកម្មយេនឌ័រ

អនុកម្មវិធីទី៤ ៖ ធនធានរដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| **១. យេនឌ័រនៅក្នុងការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការត្រួតពិនិត្យ វាយតម្លៃ និងឥទ្ធិពល ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** | ១.២ | | |
| ១.១. ការរៀបចំតាក់តែងគោលនយោបាយ | ១.០. | • ពុំមានអនុសាសន៍ពាក់ព័ន្ធយេនឌ័រក្នុងការវាយតម្លៃជម្រើស ក្នុងការតាក់តែងឧបករណ៍វិនិយោគថ្នាក់ក្រោមជាតិនៅក្នុង ប្រទេសកម្ពុជា (ឧសភាឆ្នាំ២០១៣)<br>• បញ្ហាពាក់ព័ន្ធយេនឌ័រមិនបានឆ្លុះបញ្ចាំងនៅក្នុងអនុក្រឹត្យស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក ឬអនុក្រឹត្យស្ដីពីការបង្កើត និងដំណើរការមូលនិធិក្រុងស្រុក។ | • ធ្វើការវិភាគយេនឌ័រនៅដំណាក់កាលចាប់ផ្ដើមនៃដំណើរការរៀបចំតាក់តែងគោលនយោបាយ<br>• គួរពិចារណាបញ្ចូលនូវបញ្ហាយេនឌ័រទៅក្នុងល័ក្ខខ័ណ្ឌការងារសម្រាប់ការពិគ្រោះយោបល់ពាក់ព័ន្ធការរៀបចំគោលនយោបាយ។ |
| ១.២. ការកសាងផែនការ | ២.០ | • ក្នុងផ.ស.ថឆ្នាំ២០១៣ យេនឌ័រត្រូវបានបញ្ចូលក្នុងលទ្ធផលរំពឹងទុកមួយចំនួនរួមទាំង SNIF ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឆ្លើយតបយេនឌ័ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលនយោបាយរៀបចំថវិកាឆ្លើយតបយេនឌ័រ ដោយបានសហការជាមួយអនុកម្មវិធីទី១ និងក្រសួងកិច្ចការនារី<br>• ក្រុមការងារបញ្ជ្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ច និង | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខាធិការដ្ឋានគ.ជ.អ.បក្រសួងកិច្ចការនារី គួរធ្វើការជាមួយគ្នាដើម្បីពង្រឹងការងាររបស់ក្រុមការងារបញ្ជ្រាបយេនឌ័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងពង្រឹងទំនាក់ទំនងរវាងក្រុមការងារបញ្ជ្រាបយេនឌ័រ ជាមួយមន្ត្រីទទួលបន្ទុកអនុវត្តអនុកម្មវិធីទី៤។ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | ហិរញ្ញវត្ថុ មិនមានដំណើរការដើម្បីជួយអនុកម្មវិធីទី៤ ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការសកម្មភាពរបស់ខ្លួន។ | |
| ១.៣. ការរៀបចំថវិកា | ១.០ | • ថវិកាចំនួន$31,700 សម្រាប់រៀបចំគោលនយោបាយឆ្លើយតបយេនឌ័រ (តិចជាង០,០២%នៃថវិកាសរុបសម្រាប់អនុកម្ម វិធីទី៤ឆ្នាំ២០១៣ ហើយថវិកាវិភាជឲ្យអនុកម្មវិធីទី៤មាន៨,៦%នៃកញ្ចប់ថវិការួម<br>• មូលនិធិសម្រាប់ឃុំគោលដៅពីអង្គការយូនីសេហ្វមាន ០,៩%នៃមូលនិធិសរុបវិភាជឲ្យឃុំ សង្កាត់។ មូលនិធិឃុំសង្កាត់បន្ថែមពីរាជរដ្ឋាភិបាលអាចប្រើប្រាស់សម្រាប់សេវាសង្គមប៉ុន្តែមានការលំបាកត្រួតពិនិត្យតាមដាន។ | |
| ១.៤. ការអនុវត្ត | ១.០ | • រហូតមកដល់បច្ចុប្បន្នលទ្ធផលរំពឹងទុកខាងលើ (ចំនុច១.២) មិនទាន់បានសម្រេចនៅឡើយ<br>• ការវាយតម្លៃពីផលប៉ះពាល់នៃគោលនយោបាយ និងការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមទស្សនៈយេនឌ័រពុំទាន់បានអនុវត្តនៅឡើយ។ ផ្អែកតាមយុទ្ធសាស្ត្រយេនឌ័រក្នុងគម្រោងផអ៣ ការវាយតម្លៃត្រូវធ្វើជាប្រចាំឆ្នាំ។<br>• មានការរំពឹងទុកថា គោលនយោបាយរៀបចំថវិកាឆ្លើយតបយេនឌ័រ នឹងត្រូវរៀបចំត្រឹមខែមិថុនាឆ្នាំ២០១៤ | • គួរពិចារណាកែសម្រួលលើការពិគ្រោះយោបល់ក្នុងការរៀបចំ គោលនយោបាយរៀបចំថវិកាឆ្លើយតបយេនឌ័រដោយផ្ដោតលើជំនួយបច្ចេកទេសនិងការបណ្ដុះបណ្ដាលដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផែនការក្នុងការបញ្ចូលបញ្ហាយេនឌ័រ និងដំណើរការឆ្លើយតបយេនឌ័រទៅក្នុងប្រព័ន្ធ កសាងផែនការ និងថវិកាដែលកំពុងកែសម្រួល សម្រាប់ប្រភេទផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។<br>• គួរសិក្សារៀនសូត្រពីដំណើរការជ្រើសរើសពីមុនៗ ក្នុង |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | បន្ទាប់ពី ទីប្រឹក្សាត្រូវជ្រើសរើសក្នុងពេលឆាប់ៗ។ មូលហេតុដែល គោលនយោបាយរៀបចំថវិកាឆ្លើយតបយេនឌ័រ ត្រូវពន្យា ពេលដោយសារពុំមានទីប្រឹក្សាដែលមានជំនាញផ្នែកនេះ។អនុកម្មវិធីបានព្យាយាមរយៈពេល១ឆ្នាំហើយក្នុងការជ្រើសរើសទីប្រឹក្សា។ | ការ ជ្រើសរើសទីប្រឹក្សាលើកក្រោយៗទៀត។ |
| ១.៥. ការត្រួតពិនិត្យ | ១.០ | • ពុំមានគោលការណ៍ណែនាំច្បាស់លាស់ពីរបៀបបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការរៀបចំថវិកា ដូច្នេះប្រព័ន្ធត្រួតពិនិត្យដើម្បីវាស់វែងកម្រិតនៃការបញ្ជ្រាបយេនឌ័រគឺមិនមាន ដំណើរការពេញលេញទេ។ ការកត់ត្រាសកម្មភាពពាក់ព័ន្ធ យេនឌ័រគឺមានតែចំនួនអ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា គិតតាមចំនួនភេទ។ | • គួរធ្វើឲ្យប្រសើរប្រព័ន្ធត្រួតពិនិត្យតាមដានបន្ទាប់ពីគោលនយោបាយរៀបចំថវិកាឆ្លើយតបយេនឌ័រត្រូវបានរៀបចំ ដើម្បីតាមដានតើយេនឌ័រត្រូវបានបញ្ជ្រាបកម្រិតណាទៅក្នុងផែនការ ការរៀបចំថវិកា និងការអនុវត្ត។<br>• ទិន្នន័យមូលដ្ឋានស្តីពីការអនុវត្តសារពើពន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវរៀបចំ និងដាក់ឲ្យប្រើប្រាស់ក្នុងការៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដោយមានការគាំទ្រពីADB គួរបញ្ចូលទិន្នន័យមូលនិធិសម្រាប់សេវាសង្គម និងការកសាងសមត្ថភាពពាក់ព័ន្ធយេនឌ័រ។ |
| **២. ជំនាញបច្ចេកទេសដើម្បីគាំទ្រការតាក់តែង និងការអនុវត្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលមានលក្ខណៈឆ្លើយតបយេនឌ័រ** | ១.៥ | | |
| ២.១. សមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ | ១.០ | • ភ្នាក់ងារអនុវត្តទទួលស្គាល់ថាមិនមានភាពច្បាស់លាស់ក្នុងការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយថវិកា | សូមពិនិត្យមើលចំណុច ១.៤.ខាងលើ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| ២.២. ការពង្រឹងសមត្ថភាពផ្ទៃក្នុងស្តីពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រទៅក្នុងការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី | ១.៣ | • ដូចក្នុងចំនុច១.៥ ការរៀបចំថវិកាឆ្លើយតបយេនឌ័រមិនទាន់មាននៅឡើយ ដូច្នេះការពង្រឹងសមត្ថភាពពីការវិភាគ យេនឌ័រ និងការបញ្ជ្រាបយេនឌ័រក្នុងការកសាងផែនការនិងការងារត្រួតពិនិត្យ វាយតម្លៃ មានកម្រិតតិចតួចនៅ<br>• អ្នកផ្តល់បទសម្ភាសន៍បានបញ្ជាក់ថា ទោះបីយេនឌ័រមិនបានឆ្លុះបញ្ចាំងក្នុងផែនការសកម្មភាព ប៉ុន្តែបញ្ហាយេនឌ័រត្រូវបានយកចិត្តទុកដាក់ក្នុងការអនុវត្តការងារ។ | សូមពិនិត្យមើលចំណុច ១.៤.ខាងលើ |
| ២.៣. ការបណ្តុះបណ្តាលគ្រប់គ្រាន់ និងឯកសារយោងផ្សេងៗស្តីពីបញ្ហាយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ។ | ១.៥ | • យេនឌ័រត្រូវបានគិតថាគ្រាន់តែជាចំនួនអ្នកចូលរួមគិតតាមភេទ | • រៀបចំឯកសារពាក់ព័ន្ធចំណុច ១.៤.ខាងលើ |
| ២.៤. មានជំនាញដើម្បីគាំទ្រដល់ការបញ្ជ្រាបអំពីគុណភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | ២.៥ | • មុនពេលបញ្ចប់ផ.ស.ថប្រចាំឆ្នាំ អនុកម្មវិធីទី៤ បានដាក់ជូនសេចក្តីព្រាងទៅឲ្យអ្នកជំនាញយេនឌ័រនៅលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងកិច្ចការនារីដើម្បីពិនិត្យមើលឡើងវិញ ហើយការគាំទ្រមានពេញចិត្តដោយភ្នាក់ងារអនុវត្ត។ | • មានការលើកឡើងថា គួរប្តូរឈ្មោះក្រសួងកិច្ចការនារីទៅជាក្រសួងយេនឌ័រវិញ |
| ២.៥. បញ្ចូលគុណភាពយេនឌ័រទៅក្នុងការអភិវឌ្ឍ សមត្ថភាពនៃកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ១.០ | • សូមមើលចំនុច១.៥ (ការកត់ត្រាចំនួនអ្នកចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាតាមភេទ) | • នៅពេលដែលសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីត្រូវបានបញ្ជ្រាបទៅក្នុងដំណើរការកសាងផែនការ និងថវិកា ការបណ្តុះបណ្តាលដើម្បីណែនាំពីដំណើរការដែលបាន កែសម្រួលនៅថ្នាក់ក្រោមជាតិ គួរ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | | បញ្ចូលនូវទិដ្ឋភាពពាក់ព័ន្ធយេនឌ័រ។ |
| **៣. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងការចាត់ចែងបុគ្គលិក** | ១.៣ | | |
| ៣.១. សមាមាត្រស្ត្រីនៅលេខាធិការដ្ឋានគ.ជ.អ.ប (សម្រាប់តែអនុកម្មវិធីទី១) | | | |
| ៣.២. សមាមាត្រស្ត្រីនៅតំណែងធ្វើសេចក្តីសម្រេច ក្នុងអនុកម្មវិធីនានា | ១.០ | • សមាមាត្រស្ត្រីនៅថ្នាក់ជាតិចាប់ពីតំណែងលំដាប់អគ្គនាយក អគ្គាធិការទៅប្រធាននាយកដ្ឋានគឺមាន៣រូប/៧២រូប(៤%) | • អត្រានេះតម្រូវឲ្យអនុកម្មវិធីត្រូវធ្វើសកម្មភាពឲ្យបានម៉ឺងម៉ាត់ដើម្បីបង្កើនចំនួនស្ត្រីក្នុងការធ្វើសេចក្តីសម្រេចតាមរយៈការគ្រប់គ្រងធនធានមនុស្សឲ្យបានស៊ីជម្រៅដោយគិតគូរពីបញ្ហាយេនឌ័រ។<br>• ខិតខំស្វែងរកជម្រើសនានាសម្រាប់ពង្រឹងជំនាញ និងទំនុកចិត្ត ដល់បុគ្គលិកជាស្ត្រីដើម្បីពួកគាត់មានគុណសម្បត្តិទទួលបាន តំណែងខ្ពស់ៗ។ |
| ៣.៣. សមាមាត្រស្ត្រី ក្នុងតំណែងគ្រប់គ្រងថ្នាក់កណ្តាល និងបុគ្គលិកជំនាញនៅតាមអនុកម្មវិធីនានា | ២.០ | • សមាមាត្រស្ត្រីនៅថ្នាក់ជាតិមានតំណែងចាប់ពីអនុប្រធាននាយកដ្ឋានទៅអនុប្រធានការិយាល័យមាន ១៤៤នាក់/១០៧១នាក់(១៣%)(ព្រឹត្តិប័ត្រនារីរតនៈឆ្នាំ២០១៣)<br>• ផ្អែកលើទិន្នន័យពីក្រសួងមុខងារសាធារណៈផ្សាយថ្ងៃ៣១ខែមករាឆ្នាំ២០១៣ក្នុងព្រឹត្តិប័ត្រនារីរតនៈចំនួនសរុបមន្ត្រីរាជការនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺ ៤,៨៦៨នាក់ ក្នុងនោះស្ត្រី២,២០៦នាក់(២៣%)។ | • ពង្រឹងគោលនយោបាយថ្នាក់ជាតិស្តីពីសមភាពយេនឌ័រក្នុងការជ្រើសរើសមន្ត្រីថ្មី (២០-៥០%) ពិសេសនៅថ្នាក់ជាតិ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | ប្រសិនយើងពិនិត្យមើលលម្អិតរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បុគ្គលិកសរុបនៅថ្នាក់ជាតិគឺ៣,៣២៥នាក់ ស្ត្រី៩០៨នាក់(២៧%) ថ្នាក់ ក្រោមជាតិមាន៤៣៧នាក់ស្ត្រី១៩៨នាក់(៤៥%)។ | |
| ៣.៤. ការយល់ដឹងស្តីពីយេនឌ័រ និង បញ្ហារសើបផ្នែកយេនឌ័រនៅក្នុងការគ្រប់គ្រងធនធានមនុស្ស | ១.០ | • ភ្នាក់ងារអនុវត្តបានទទួលស្គាល់ថាយេនឌ័រត្រូវបានគិតគូរ ក្នុងការជ្រើសរើសមន្ត្រីប៉ុន្តែពុំមានវិធានការឬយុទ្ធសាស្ត្រ គ្រប់គ្រាន់ដើម្បីបង្កើនចំនួនស្ត្រីក្នុងអនុកម្មវិធីនេះឲ្យមាន សមភាពយេនឌ័រ។ មានជំហ៊ានផ្តួចផ្តើមខ្លះៗដើម្បីជ្រើសរើសបុគ្គលិកជាស្ត្រី។ ពេលខ្លះយេនឌ័រត្រូវបានត្រូវបាន គិតគូរតែនៅពេលថ្នាក់ដឹកនាំបញ្ជាឲ្យបញ្ចូលស្ត្រីក្នុងការតែងតាំងឬតម្លើងឋានៈ។ | សូមពិនិត្យមើលចំណុច ៣.២. និង៣.៣ ខាងលើ |
| ៣.៥. យេនឌ័រក្នុងប្រព័ន្ធគ្រប់គ្រងការបំពេញការងារ | -- | | |
| ៣.៦. ការបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំដល់ស្ត្រី | -- | • ផ្អែកលើផ.ស.ថ ឆ្នាំ២០១៣ពុំមានសកម្មភាពគ្រោងសម្រាប់បណ្តុះបណ្តាលពី ភាពជាអ្នកដឹកនាំ | |
| **៤. ចំនុចរសើបផ្នែកយេនឌ័រ នៅក្នុងការអនុវត្តរបស់ស្ថាប័ន និងការយល់ដឹងពីលទ្ធផលនានាពាក់ព័ន្ធសមភាពយេនឌ័រ** | ១.៣ | | |
| ៤.១. ការយល់ដឹងពីសារសំខាន់នៃសមភាព | ២.០ | • ផ្អែកតាមការសម្ភាសន៍ជាមួយភ្នាក់ងារអនុវត្ត ពួកគេ | |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| យេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | | យល់ថារដ្ឋាភិបាលបានយកចិត្តទុកដាក់លើកកម្ពស់សមភាពយេនឌ័រក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ ប៉ុន្តែនៅមានការយកចិត្តទុកដាក់តិចតួចក្នុងការអនុវត្តជាក់ស្តែង។ | |
| ៤.២. ការយល់ដឹងពីយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ របស់កម្មវិធីជាតិ និងគម្រោងផអ៣ | ១.០ | • យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងកម្មវិធីជាតិ/ផអ៣មិនត្រូវបានផ្សព្វផ្សាយ និងស្វែងយល់បានទូលំទូលាយនៅក្នុងភ្នាក់ងារអនុវត្តទេ។ | |
| ៤.៣. លើកកម្ពស់សមភាពយេនឌ័រនៅកន្លែងធ្វើ | ១.០ | • ដូចនៅក្នុងផ្នែកមុខៗដែរ បុគ្គលិកម្នាក់ៗបានដឹងពីតម្រូវការដើម្បីបញ្ជ្រាបយេនឌ័រក្នុងការអនុវត្តតួនាទី និងភារកិច្ច ប៉ុន្តែជាក់ស្តែងគ្នាមិនមានការយកចិត្តទុកដាក់ទេ។ បញ្ហានេះគឺ ដោយសារវិធានការឆ្លើយតបយេនឌ័រមិនត្រូវបានបញ្ចូលក្នុងផែនការសកម្មភាព។ | |
| ៤.៤. ឆ្លុះបញ្ចាំងសមភាពយេនឌ័រ និងផ្តល់អំណាច ដល់ស្ត្រីឲ្យបានឃើញជាសាធារណៈ | -- | | |
| ៤.៥. ការយល់ដឹងពីការរីកចម្រើនលើការអនុវត្ត យុទ្ធសាស្ត្រយេនឌ័រគម្រោងផអ៣ | ១.០ | • មានការរីកចម្រើនតិចតួច ទោះបីយ៉ាងណាក៏ដោយមានការរំពឹងទុកថាការបញ្ជ្រាប និងការលើកកម្ពស់យេនឌ័រ មានដំណើរការទៅមុខបណ្តើរៗសម្រាប់ឆ្នាំ២០១៤បន្ទាប់ពីការធ្វើសវនកម្ម និងបន្ទាប់ពីគោលនយោបាយរៀបចំថវិកាឆ្លើយតបយេនឌ័រត្រូវបានរៀបចំក្នុងឆ្នាំ២០១៤។ | • ក្រុមការងារបញ្ជ្រាបយេនឌ័ររបស់ក្រសួងគួរត្រូវបានពង្រឹង អភិវឌ្ឍន៍សមត្ថភាព និងមានការប្រជុំទៀងទាត់។ គួរមានថវិកាដោយឡែកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ដំណើរការរបស់ក្រុមការងារបញ្ជ្រាបយេនឌ័រ។ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
| --- | --- | --- | --- |
| **៥. ការឆ្លើយតបបញ្ហាយេនឌ័រ របស់អង្គការដៃគូ** | ២.៨ | | |
| ៥.១. តួនាទីរបស់ដៃគូអភិវឌ្ឍន៍ក្នុងការលើកកម្ពស់ និងគាំទ្រសមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី។ | ២.៨ | • ដៃគូអភិវឌ្ឍន៍ផ្តល់តម្លៃខ្ពស់ដល់ការលើកកម្ពស់យេនឌ័រនៅក្នុងការរៀបចំគោលនយោបាយបាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរួមទាំងសហគមន៍អឺរ៉ុប និងធនាគារពិភពលោក។ | |
| ៥.២. តួនាទីអង្គការមិនមែនរដ្ឋាភិបាលជាដៃគូក្នុងការ លើកកម្ពស់ និងគាំទ្រសមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី។ | -- | | |
| **COMPOSITE SCORE** | ១.៦ | | |

## ៥. សន្និដ្ឋាន

ការខិតខំប្រឹងប្រែងក្នុងការបញ្ជ្រាប និងលើកកម្ពស់យេនឌ័រ ក្នុងអនុកម្មវិធីទី៤ បានធ្វើតិចតួចដើម្បីសម្រេចបាននូវយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃគម្រោងផអ៣ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ការវាយតម្លៃធ្វើដោយអនុកម្មវិធី មិនបានលើកអនុសាសន៍កែលម្អ វិមជ្ឈការសារពើពន្ធដើម្បីឆ្លើយតបបញ្ហាយេនឌ័រទេ។ ជាងនេះទៀត សកម្មភាពឆ្លើយតបយេនឌ័រដែលបាន គ្រោងក្នុងឆ្នាំ២០១៣ មិនបានសម្រេចហើយត្រូវពន្យាពេលក្នុងការអនុវត្តសកម្មភាពផ្សេងៗទៀត។

ទោះបីយ៉ាងណាក៏ដោយ មានការយល់ឃើញថាយេនឌ័រត្រូវបញ្ចូលក្នុងការជ្រើសរើសបុគ្គលិក ប៉ុន្តែការអនុវត្តមិនបានដូចការយល់ឃើញនោះទេ។ សមាមាត្រស្ត្រីនៅក្នុងតំណែងធ្វើសេចក្តីសម្រេចនៅក្នុង អនុកម្មវិធីនៅមានកម្រិតទាបនៅឡើយត្រឹមតែ៤%ប៉ុណ្ណោះ។

ដោយមានការតាំងចិត្តពីថ្នាក់ដឹកនាំនៅក្នុងអនុកម្មវិធី ការបញ្ជ្រាប និងការលើកកម្ពស់យេនឌ័រ សង្ឃឹមថានឹងមានការរីកចម្រើនទៅមុខបន្ទាប់ពីក្រុមការងារបញ្ជ្រាបយេនឌ័របានដំណើរការ ហើយគោលនយោបាយរៀបចំថវិកាឆ្លើយតបយេនឌ័រ ត្រូវបានរៀបចំពិសេសបន្ទាប់ពីការបង្ហាញលទ្ធផលរកឃើញរបស់ក្រុមសវនកម្ម។

## ឧបសម្ព័ន្ធទី ៦.៥ ÷ បណ្ណដាក់ពិន្ទុ

### ខេត្តបាត់ដំបង

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| **១. យេនឌ័រនៅក្នុងការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការត្រួតពិនិត្យ វាយតម្លៃ និងផលប៉ះពាល់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** | ១.៦ | | |
| ១.១. ការកសាងផែនការ | ១.៥ | • បញ្ហាភាគច្រើនត្រូវបានលើកឡើងដោយ គ.ក.ស.ក ត្រូវបានដោះស្រាយតាមករណីជាក់ស្តែងនីមួយៗនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ដោយមិនបានបញ្ចូលក្នុងផែនការរបស់ខេត្តជាមុន។<br>• យ៉ាងណាក៏ដោយថវិកាសម្រាប់ការបញ្ជ្រាបយេនឌ័រអាចស្នើសុំ ពីថវិការួមរបស់ខេត្តបាន។ | • គ.ក.ស.ក ត្រូវបានផ្តល់យោបល់ឲ្យបន្ថែមសមាជិកមកពីអង្គការមិនមែនរដ្ឋាភិបាល<br>• ចំនួនសមាជិកគ.ក.ស.ក ត្រូវសកម្មបន្ថែមទៀតដោយមិនត្រូវ លើកឡើងថាពួកគាត់ទទួលខុសត្រូវនៅមន្ទីរជំនាញរបស់ខ្លួន។ |
| ១.២. ការរៀបចំថវិកា | ១.០ | • ពុំមានការប្រែប្រួលក្នុងមូលនិធិផអ៣ដល់ក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារីរវាងពីឆ្នាំ២០១២ដល់ឆ្នាំ២០១៣ សម្រាប់ការបណ្តុះបណ្តាល ការកសាងបណ្តាញ និងការគាំទ្រ។ | • ថវិកាបន្ថែមសម្រាប់ដល់ខេត្តគួរត្រូវបានប្រើប្រាស់សម្រាប់អភិវឌ្ឍន៍សមត្ថភាពដល់បុគ្គលិកជាស្ត្រីតនៅរដ្ឋបាលខេត្ត និងការបណ្តុះបណ្តាលយេនឌ័រសម្រាប់បុរសបន្ថែមទៀត។ |
| ១.៣. ការអនុវត្ត | ១.៥ | • ផ.ស.ថប្រចាំឆ្នាំ និងផអ៣ ភាគច្រើនត្រូវបានអនុវត្តនៅថ្នាក់ខេត្ត<br>• មានការពិបាកក្នុងការចំណាយលើសកម្មភាពសេវា | • បញ្ចូលនីតិវិធីសម្រាប់ចំណាយមូលនិធិលើសកម្មភាពតូចៗ (ដូចជាសេវាសង្គម ការត្រួតពិនិត្យដល់គ.ក.ន.ក)។ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | សង្គម សម្រាប់មូលនិធិឃុំ សង្កាត់ និងចំណាយសម្រាប់ត្រួតពិនិត្យ គ.ក.ន.ក ដោយស្រុកព្រមទាំងថវិកាគាំទ្រផ្សេងៗ។ | |
| ១.៤. ការត្រួតពិនិត្យ | ១.៥ | • ទិន្នន័យបែងចែកតាមភេទមានកត់ត្រាអ្នកចូលរួមបណ្តុះបណ្តាលសិក្ខាសាលា<br>• ការកត់ត្រាច្រើនផ្តោតលើចំនួនអ្នកចូលរួមជាបុរស ស្ត្រីជាជាង ផ្តោតលើការប្រែប្រួលចំណេះដឹង អត្តចរិក និងឥរិយាបថ។ | • ពង្រឹងនីតិវិធីប្រើប្រាស់ព័ត៌មានពីការត្រួតពិនិត្យ ដើម្បីកែលម្អ ការតាក់តែង និងការអនុវត្តសកម្មភាព។ |
| ១.៥. ផលប៉ះពាល់ (ការអភិវឌ្ឍ/ស្ថាប័ន) | ២.០ | • គោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជាទី៣ សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រីទទួលបានពិន្ទុមធ្យម (៦៧)<br>• គោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជាទី៥សុខភាពមាតាទទួលបានពិន្ទុមធ្យម (៧៩)<br>• ពិន្ទុសម្រាប់យេនឌ័រនៅក្នុងប័ណ្ណដាក់ពិន្ទុតាមវិស័យនៅក្នុងទិន្នន័យឃុំទទួលទាប(៥០,៨) | • ប័ណ្ណដាក់ពិន្ទុតាមវិស័យ និងគោលដៅអភិវឌ្ឍន៍សហវត្សរ៍ៈ ជាឧបករណ៍សម្រាប់កំណត់អាទិភាពនៃបញ្ហានៅថ្នាក់ស្រុក ឃុំ។<br>• ទោះបីពិន្ទុសម្រាប់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច និងការគ្រប់គ្រងមានកម្រិតទាប ប៉ុន្តែបានពិន្ទុខ្ពស់សម្រាប់គោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជាទី៥ដោយសារទីតាំងភូមិសាស្ត្រល្អរបស់ខេត្តបាត់ដំបងហើយមិនមានន័យថាត្រូវភ្លេចបញ្ហាពិន្ទុទាប នៃស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចនិងការគ្រប់គ្រងបុគ្គលិក។ |
| **២. ជំនាញបច្ចេកទេសដើម្បីគាំទ្រការតាក់តែង និងការអនុវត្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលមានលក្ខ** | ១.៦ | | |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| **ណៈឆ្លើយតបយេនឌ័រ** | | | |
| ២.១. សមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ | ១.៩ | • បុគ្គលិកភាគច្រើនគិតថាពួកគេមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបញ្ជ្រាបយេនឌ័រ<br>• ភាគច្រើនយល់ថារដ្ឋបាលថ្នាក់ក្រោមជាតិជាស្ថាប័នដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការបញ្ជ្រាបយេនឌ័រ។ | សូមមើលចំនុចខាងក្រោម |
| ២.២. ការពង្រឹងសមត្ថភាពផ្នែកក្នុងស្តីពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រទៅក្នុងការកសាងផែនការ និងការត្រួតពិនិត្យ វាយតម្លៃ | ១.៧ | • បុគ្គលិកភាគច្រើនយល់ថាពួកគាត់បានទទួលការអភិវឌ្ឍសមត្ថភាពគ្រប់គ្រាន់ស្តីពីយេនឌ័រ<br>• ការបណ្តុះបណ្តាលពីយេនឌ័រផ្តោតតែលើទ្រឹស្តី ហើយមានការចាប់អារម្មណ៍ច្រើនលើការបណ្តុះបណ្តាលលើការអនុវត្តជាក់ស្តែង។<br>• ការបណ្តុះបណ្តាលផ្តោតតែលើស្ត្រី។ | • ពង្រឹងលើការយល់ដឹង ជំនាញការវិភាគ និងការបញ្ជ្រាបយេនឌ័រដែលជាតម្រូវការរបស់មន្ត្រីម្នាក់ៗក្នុងការអនុវត្តតួនាទី និងការ ទទួលខុសត្រូវរបស់ខ្លួន។<br>• បណ្តុះបណ្តាលយេនឌ័រដល់បុរសឲ្យបានច្រើនដើម្បីពង្រឹងការយល់ដឹងយេនឌ័រ និងពង្រឹងការគាំទ្រដល់ការបញ្ជ្រាបយេនឌ័រ និងបង្កើនចំនួនតំណាង និងសម្លេងរបស់ស្ត្រីនៅក្នុងរដ្ឋបាលមូលដ្ឋាន។ |
| ២.៣. ការបណ្តុះបណ្តាលគ្រប់គ្រាន់ និងឯកសារយោងផ្សេងៗស្តីពីបញ្ហាយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ។ | ១.១ | • បុគ្គលិកភាគច្រើនយល់ថាពួកគាត់ត្រូវការការណែនាំបន្ថែមទៀតហើយឧបករណ៍ស្តីពីការបញ្ជ្រាប និងការវិភាគយេនឌ័រ។ | • បង្កើតឧបករណ៍សមស្របពាក់ព័ន្ធចំនុច២.២.ខាងលើ |
| ២.៤. មានជំនាញ និងសមត្ថភាពផ្នែកយេនឌ័រដើម្បីគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | ១.៦ | • ភាគច្រើនប្រើប្រាស់ និងពេញចិត្តចំពោះការគាំទ្រដែលទទួលបានពីអ្នកជំនាញយេនឌ័រ។ | -- |
| ២.៥. បញ្ចូលគុណភាពយេនឌ័រទៅក្នុងការអភិវឌ្ឍ សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ | ១.៥ | • មានការខិតខំប្រឹងប្រែងដើម្បីបញ្ចូលយេនឌ័រទៅក្នុងសេចក្តីណែនាំនានាដល់រដ្ឋបាល និងក្រុមប្រឹក្សា និង | -- |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | ការអភិវឌ្ឍសមត្ថភាព។ | |
| **៣. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងការចាត់ចែងបុគ្គលិក** | ១.២ | | |
| ៣.១. ស្ត្រីនៅក្នុងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ | ១.០ | • មានស្ត្រីតែ៥%ប៉ុណ្ណោះជាសមាជិកនៅក្នុងក្រុមប្រឹក្សាខេត្ត | • លើកទឹកចិត្តគណបក្សនយោបាយក្នុងការដាក់ស្ត្រីនៅលំដាប់លើនៃបញ្ជីបេក្ខជន។ |
| ៣.២. ស្ត្រីនៅក្នុងតំណែងថ្នាក់ខ្ពស់ក្នុងការធ្វើសេចក្តីសម្រេច នៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ១.០ | • បុគ្គលិកភាគច្រើនយល់ថាពួកគេត្រូវការគោលការណ៍ណែនាំបន្ថែមទៀត ព្រមទាំងឧបករណ៍វិភាគ និងការបញ្ជ្រាបយេនឌ័រ។ មានស្ត្រីតិចជាង២០% ធ្វើការក្នុងតំណែងធ្វើសេចក្តីសម្រេចនៅ ថ្នាក់ខេត្ត។ | • ខិតខំស្វែងរកជម្រើសនានាសម្រាប់ពង្រឹងជំនាញ និងទំនុកចិត្ត ដល់បុគ្គលិកជាស្ត្រីដើម្បីពួកគាត់មានគុណសម្បត្តិទទួលបាន តំណែងខ្ពស់ៗ |
| ៣.៣. ស្ត្រីក្នុងតំណែងគ្រប់គ្រងថ្នាក់កណ្តាល និងបុគ្គលិកជំនាញនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ១.០ | • មានស្ត្រី១៦%នៃតំណែងគ្រប់គ្រងថ្នាក់កណ្តាល និងបុគ្គលិកជំនាញ នៅរដ្ឋបាលខេត្ត។ | ខ្លឹមសារដូចចំនុចខាងលើ |
| ៣.៤. ការយល់ដឹងស្តីពីយេនឌ័រ និង បញ្ហារសើបផ្នែកយេនឌ័រនៅក្នុងការគ្រប់គ្រងធនធានមនុស្ស | ១.៩ | • កម្រិតយល់ដឹងពីយេនឌ័រ និងការលើកកម្ពស់សមភាពយេនឌ័រ គឺជាអាទិភាពពេលដំណើរការជ្រើសរើសបុគ្គលិក<br>• ស្ត្រីច្រើនត្រូវជ្រើសរើស និងតែងតាំងក្នុងតួនាទីជាប្រពៃណីរបស់ស្ត្រី (ដូចជា៖ ផ្នែកហិរញ្ញវត្ថុ ធនធានមនុស្ស និងលទ្ធកម្មជាដើម)។ | • ខិតខំរិះរកជម្រើសរើសលើការផ្តួចផ្តើមជាមុនឲ្យបានច្រើន ក្នុងការកំណត់ និងទាក់ទាញស្ត្រីបន្ថែមទៀតដើម្បីប្រកួតប្រជែង តំណែងក្នុងរដ្ឋបាលខេត្ត រួមទាំងតួនាទីមិនមែនជាប្រពៃណីរបស់ស្ត្រី។<br>• ប្រើប្រាស់ប្រព័ន្ធកូតាសម្រាប់ជាយុទ្ធសាស្ត្ររយៈពេលវែង។ |
| **៤. ចំនុចរសើបផ្នែកយេនឌ័រ នៅក្នុងការអនុវត្តរបស់ស្ថាប័ន និងការយល់ដឹងពីលទ្ធផល** | ២.០ | | |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| **នានាពាក់ព័ន្ធសមភាពយេនឌ័រ** | | | |
| ៤.១. ការយល់ដឹងពីសារសំខាន់នៃសមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | ២.៤ | • មានការយល់ដឹងច្រើនពីសារសំខាន់នៃសមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា<br>• ការយល់ដឹងពីសារសំខាន់នៃគោលនយោបាយយេនឌ័រក្នុងផអ៣នៅមានកម្រិតទាបសម្រាប់រដ្ឋបាលថ្នាក់ខេត្ត។ | -- |
| ៤.២. ការយល់ដឹងពីយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ របស់កម្មវិធីជាតិ និងគម្រោងផអ៣ | ២.៥ | • ភាគច្រើនបានយល់ដឹងពីយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់កម្មវិធីជាតិ និងគម្រោងផអ៣ និងយល់ថាយុទ្ធសាស្ត្រផអ៣ មានភាពច្បាស់លាស់។<br>• ការយល់ដឹងលម្អិតពីយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់គម្រោងផអ៣មានកម្រិតទាប។ | -- |
| ៤.៣. លើកកម្ពស់សមភាពយេនឌ័រនៅកន្លែងធ្វើ | ១.៨ | • បុគ្គលិកមានភាពសកម្មក្នុងការធានាឲ្យមានការគោរពទំនាក់ទំនងរវាងស្ត្រី និងបុរស ព្រមទាំងសកម្មក្នុងការលើកកម្ពស់ សមភាពយេនឌ័រ<br>• របៀបបង្កើនសមភាពយេនឌ័ររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ភាគ ច្រើនគិតថាមានលក្ខណៈគ្រប់គ្រាន់។<br>• ជាង៣០%គិតថារដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រឹងប្រែងបន្ថែម ទៀត ក្នុងការលុបបំបាត់នូវការបង្ហាញពីវិសមភាពយេនឌ័រ | • ត្រូវមានការខិតខំប្រឹងប្រែងលុបបំបាត់ការ និយាយបង្ហាញ នូវវិសមភាពយេនឌ័រ។<br>• ត្រូវជំនះឲ្យបាននូវការយល់ឃើញថាយេនឌ័រគឺគ្រាន់តែនិយាយអំពីស្ត្រី ហើយស្ត្រីត្រូវទទួលខុសត្រូវ យកចិត្តទុកដាក់បញ្ហាស្ត្រី។ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| | | • បុគ្គលិកមួយចំនួនយល់ថាគ.ក.ន.ក, គ.ក.ស.ក និងមន្ទីរកិច្ចការ នារីខេត្តនិងការិយាល័យកិច្ចការនារីស្រុកទទួលខុសត្រូវក្នុងការអនុវត្តយុទ្ធសាស្ត្រយេនឌ័ររបស់គម្រោងផងឧ៣។ | |
| ៤.៤. ឆ្លុះបញ្ចាំងសមភាពយេនឌ័រ និងផ្តល់អំណាច ដល់ស្ត្រីក្នុងព្រឹត្តិការណ៍ជាសាធារណៈ | ២.០ | • ភាគច្រើនបានឆ្លើយថាមានរបាយការណ៍ជាច្រើន មានបញ្ចូលនូវ ព័ត៌មានស្តីពីយេនឌ័រ ជាដើម។ | |
| ៤.៥. ការយល់ដឹងពីការរីកចម្រើនពីសមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី។ | ១.៥ | • ភាគច្រើនដឹងថាពួកគាត់តម្រូវឲ្យអនុវត្តការបញ្ជ្រាបយេនឌ័រ ប៉ុន្តែ ចំណេះដឹងពីរបៀបអនុវត្តការបញ្ជ្រាបយេនឌ័រនៅទាប។<br>• ថ្នាក់ដឹកនាំជាបុរសឯកភាពបញ្ជ្រាបយេនឌ័រប៉ុន្តែអត្តចរិក និងផ្នត់គំនិតនៅតែជាឧបសគ្គ<br>• តំណាងស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងបុគ្គលិកជំនាញនៅទាប។ មានការឯកភាពថា ស្ត្រីគួរត្រូវបានតម្លើងឋានៈប៉ុន្តែជាក់ស្តែងមានតែក្នុងការងារហិរញ្ញវត្ថុ និងរដ្ឋបាល។<br>• ស្ត្រីនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលស្គាល់ថាសមត្ថភាពនៅទាប<br>• ត្រូវមានធនធានមនុស្ស និងហិរញ្ញវត្ថុបន្ថែមទៀតដើម្បីជំរុញ និងគាំទ្រឲ្យមានការកើនឡើងសមភាពយេនឌ័រ | សូមមើលចំនុចខាងលើ |

| សូចនាករ | ពិន្ទុ | យោបល់ផ្សេងៗ | អនុសាសន៍បឋម |
|---|---|---|---|
| **៥. ការឆ្លើយតបបញ្ហាយេនឌ័រ របស់អង្គការដៃគូ** | ២.៦ | | |
| ៥.១. តួនាទីរបស់ដៃគូអភិវឌ្ឍន៍ក្នុងការលើកកម្ពស់ និងការគាំទ្រសមភាពយេនឌ័រ | ២.៧ | • ការលើកកម្ពស់សមភាពយេនឌ័រ មានសារៈសំខាន់ណាស់សម្រាប់ដៃគូអភិវឌ្ឍន៍ភាគច្រើន។ | -- |
| ៥.២. តួនាទីអង្គការមិនមែនរដ្ឋាភិបាលជាដៃគូក្នុងការ លើកកម្ពស់ និងគាំទ្រសមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី។ | ២.៥ | • ទាំងអស់គ្នាទទួលស្គាល់ថាអង្គការមិនមែនរដ្ឋាភិបាលមានសារសំខាន់ក្នុងការតាក់តែង និងអនុវត្តសកម្មភាពពង្រឹងសមត្ថភាព និងបង្កើនសមភាពយេនឌ័រ និងភាពជាតំណាង ព្រមទាំងសម្លេងរបស់ស្ត្រី។<br>• ទោះបីយ៉ាងណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗមួយចំនួនត្រូវអស់ថវិកាក្នុងពេលឆាប់ៗ។ | • គួរបញ្ចូលតំណាងអង្គការមិនមែនរដ្ឋាភិបាលទៅក្នុង គ.ក.ស.ក |
| **ពិន្ទុសមាសភាគ** | ១.៨ | | |

ពិន្ទុសមាសភាគ មានកម្រិតទាបជាងខេត្តក្រចេះ (១,៩) និងទាបជាងនៅស្រុករតនមណ្ឌល ខេត្តបាត់ដំបង (២,0) ប៉ុន្តែពាក់ព័ន្ធតួលេខនេះ សារសំខាន់នៃភាពខុសគ្នានេះ ប្រហែលមិនសូវចាំបាច់ទេ ដោយសារទិន្នន័យ និងភាពមិន ច្បាស់លាស់នៃវិធីសាស្ត្រដែលប្រើ។

# ឧបសម្ព័ន្ធទី ៦.៦ ៖ តារាងពិន្ទុ

## ខេត្តកោះកុង

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| **១. យេនឌ័រនៅក្នុងការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការតាមដានត្រួតពិនិត្យ វាយតម្លៃ និងផលប៉ះពាល់នៃលើការអនុវត្តការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** | **១.៥** | | |
| ១.១. ការកសាងផែនការ | ១.៥ | • បញ្ហាភាគច្រើនបំផុតដែលបានលើកឡើងដោយ គ.ក.ន.ក ត្រូវបានដោះស្រាយតាមករណីនីមួយៗ ម្តងមួយៗ ដោយមិនបានបញ្ចូលក្នុងផែនការរបស់ខេត្តឡើយ<br>• យន្តការ និងដំណើរការត្រូវបានរៀបចំ និងដាក់ឲ្យប្រើប្រាស់នៅថ្នាក់ឃុំ សង្កាត់ ប៉ុន្តែមិនទាន់បានរៀបចំសម្រាប់ថ្នាក់ខេត្ត និងក្រុង ស្រុកឡើយ។<br>• កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត មិនទាន់បានកំណត់ច្បាស់លាស់អំពីការឆ្លើយតបយេនឌ័រទាំងសកម្មភាពអន្តរាគមន៍ និងការអភិវឌ្ឍសមត្ថភាព | • បញ្ចប់សេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការរបស់រដ្ឋ បាលថ្នាក់ក្រោមជាតិ ដោយបញ្ចូលនូវនីតិវិធីនានា ដើម្បីធានាឲ្យមាន ការវិភាគយេនឌ័របានសមស្រប នៅក្នុងដំណើរការកសាងផែនការ ព្រមទាំងការកំណត់អំពីអាទិភាព ឆ្លើយតបយេនឌ័រដែលត្រូវដាក់បញ្ចូលក្នុងផែនការ។ |
| ១.២. ការរៀបចំថវិកា | ១.៥ | • នៅក្នុងចន្លោះឆ្នាំ២០១២ និង២០១៣ មិនមានការប្រែប្រួលចំនួនមូលនិធិ ផអ៣ ដែលវិភាជន៍ឲ្យក្រសួងកិច្ចការនារី ឬមន្ទីរកិច្ចការនារី សម្រាប់គាំទ្រ | • គួរបង្កើនចំនួនមូលនិធិដែលត្រូវ ផ្ទេរឲ្យខេត្ត។ ឧទាហរណ៍ ថវិកា ទាំងនោះអាចនឹងប្រើសម្រាប់ការអភិវឌ្ឍសមត្ថភាពបុគ្គលិកជាស្ត្រី នៅរដ្ឋបា |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បថម |
|---|---|---|---|
| | | សកម្មភាពបណ្តុះបណ្តាល ការចងក្រងបណ្តាញនានា និងការគាំទ្រ<br>• តែងតែមានភាពយឺតយ៉ាវក្នុងការផ្ទេរថវិកាផអ៣ | លខេត្ត និងសម្រាប់ការ បណ្តុះបណ្តាលអំពីយេនឌ័រសម្រាប់បុរសឲ្យបានកាន់តែច្រើន<br>• ការផ្ទេរថវិកាគួរតែធ្វើឲ្យបានទាន់ ពេលវេលា |
| ១.៣. ការអនុវត្ត | ១.៥ | • ផែនការសកម្មភាព និងថវិការបស់ផអ៣ : អនុវត្តភាគច្រើននៅថ្នាក់ខេត្ត<br>• ពិបាកក្នុងការទទួលបានមូលនិធិសម្រាប់សេវាសង្គមថ្នាក់ឃុំ សង្កាត់ ការតាមដាន និងគាំទ្រ គ.ក.ស.ក នៅថ្នាក់ ក្រុង ស្រុក<br>• គ.ក.ន.ក បានរៀបចំកិច្ចប្រជុំទៀងទាត់ស្របតាមផែនការ និងងថវិកា ប៉ុន្តែសកម្មភាពប្រជុំនេះ មិនទាន់បានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខេត្តឡើយ។ | • រៀបចំបែបបទ និងនីតិវិធីសម្រាប់ បើកប្រាក់មូលនិធិដើម្បីអនុវត្ត សកម្មភាពតូចៗ (ដូចជាសកម្មភាពសេវាសង្គម ការតាមដាន និងគាំទ្រ គ.ក.ស.ក ជាដើម) |
| ១.៤. ការតាមដានត្រួតពិនិត្យ | ១.៥ | • មានទិន្នន័យបែងចែកតាមភេទសម្រាប់ការចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលានានា<br>• ការកំណត់អ្នកត្រូវចូលរួមផ្អែកតាមភេទ (ស្ត្រី ឬបុរស) ច្រើនជាងផ្អែកលើការផ្លាស់ប្តូរចំណេះដឹង ឥរិយាបថ និងអាកប្បកិរិយា<br>• ថ្នាក់ដឹកនាំជាបុរសបានទទួលការបញ្ជ្រាបយេនឌ័រ ប៉ុន្តែមិនទាន់អនុវត្តបានពេញលេញក្នុងការឆ្លើយតបចំពោះបញ្ហាយេនឌ័រ | • ពង្រឹងការប្រើប្រាស់ព័ត៌មាន ដែលទទួលបានពីការតាមដានត្រួតពិនិត្យ ដើម្បីកែលម្អការរៀបចំ និងអនុវត្តសកម្មភាពនានា<br>• ការកំណត់អ្នកត្រូវចូលរួម គួរផ្អែក លើអត្ថន័យនៃការចូលរួម រួមទាំងការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយា<br>• បង្កើនការយល់ដឹងនៅកន្លែងធ្វើការ ដើម្បីឲ្យថ្នាក់ដឹកនាំជាបុរសយកចិត្តទុកដាក់កាន់តែខ្លាំង |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| | | | លើបញ្ហាយេនឌ័រ។ |
| ១.៥. ផលប៉ះពាល់ (ការអភិវឌ្ឍ/ស្ថាប័ន) | ១.៣ | • ពិន្ទុនៃគោលដៅអភិវឌ្ឍសហវត្សទី៣ ដែលកំណត់អំពីសមភាពយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រីទទួលបានពិន្ទុទាប (៥១)<br>• ពិន្ទុនៃគោលដៅអភិវឌ្ឍសហវត្សទី៥ ដែលកំណត់អំពីសុខភាពមាតា និងទារកទទួលបានពិន្ទុទាបណាស់ (២៨)<br>• យេនឌ័រនៅក្នុងប្រព័ន្ធទិន្នន័យឃុំ សង្កាត់មានពិន្ទុទាប (៤៩.៨)<br>• ទោះបីជា គ.ក.ន.ក បានកំពុងដំណើរការក៏ដោយ ក៏គណៈកម្មាធិការនេះ ត្រូវការអភិវឌ្ឍន៍សមត្ថភាពបន្ថែមជាចាំបាច់ និងត្រូវការការគាំទ្រពីថ្នាក់លើ និងពីវិស័យជំនាញនានាផងដែរ។ | • បង្កើតឧបករណ៍នានាសម្រាប់កំណត់វិស័យអាទិភាពនៅថ្នាក់ឃុំ សង្កាត់ និងថ្នាក់ក្រុង ស្រុក<br>• គួរមានការអភិវឌ្ឍសមត្ថភាពដល់ គ.ក.ន.ក បន្ថែមទៀត (បន្ថែមលើការអភិវឌ្ឍសមត្ថភាពដែលរៀបចំដោយមន្ទីរកិច្ចការនារី)<br>• ពិនិត្យឡើងវិញ ធ្វើសុខដុមនីយកម្ម និងពង្រឹងយន្តការស្ថាប័នក្នុងការគាំទ្រការបញ្ជ្រាបយេនឌ័រនៅថ្នាក់ក្រោមជាតិ |
| **២.ជំនាញបច្ចេកទេសក្នុងការគាំទ្រដល់ការ រៀបចំ និងអនុវត្តការឆ្លើយតបយេនឌ័រសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ** | **១.៦** | | |
| ២.១. សមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ | ២.១ | • អ្នកផ្តល់ព័ត៌មានភាគច្រើនមានអារម្មណ៍ថា ខ្លួនគេមានសត្ថភាពគ្រប់គ្រាន់ក្នុងការបញ្ជ្រាបយេនឌ័រ<br>• អ្នកផ្តល់ព័ត៌មានភាគច្រើនយល់ឃើញថា រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាស្ថាប័នដែលមានសមត្ថភាព | • មើលខាងក្រោម |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បថម |
|---|---|---|---|
| | | ក្នុងការបញ្ជ្រាបយេនឌ័រ | |
| ២.២. ការអភិវឌ្ឍសមត្ថភាពអំពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធី និងក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ (P&ME) | ១.២ | • អ្នកផ្តល់ព័ត៌មានភាគច្រើនយល់ថា ពួកគេទទួលបានការអភិវឌ្ឍសមត្ថភាពអំពីយេនឌ័រគ្រប់គ្រាន់ ប៉ុន្តែពួកគេនៅតែមានតម្រូវការអភិវឌ្ឍន៍សមត្ថភាពបន្ថែមទៀត<br>• ការបណ្តុះបណ្តាលយេនឌ័របានផ្តោតលើទ្រឹស្តីច្រើនពេក ដូច្នេះ ការបណ្តុះបណ្តាលគួរផ្តោតលើការអនុវត្ត<br>• ការបណ្តុះបណ្តាលផ្តោតតែលើស្ត្រី | • ការពង្រឹងងសមត្ថភាព គួរផ្តោត លើការយល់ដឹងអំពីយេនឌ័រ ជំនាញក្នុងការវិភាគ និងបញ្ជ្រាប យេនឌ័រ ដែលសិក្ខាកាមម្នាក់ៗត្រូវការ ដើម្បីឲ្យពួកគេអាចយកចំណេះដឹង និងជំនាញនោះទៅអនុវត្ត<br>• រៀបចំវគ្គបណ្តុះបណ្តាលអំពីយេនឌ័រសម្រាប់សិក្ខាកាមជាបុរសឲ្យ បានច្រើនថែមទៀត ដើម្បីបង្កើន ការយល់ដឹងរបស់ពួកគេ ក្នុងការ ពង្រឹងការគាំទ្រដល់ការបញ្ជ្រាប យេនឌ័រ ព្រមទាំងគាំទ្រនូវ ភាពជាតំណាងរបស់ស្ត្រី និងសម្លេងរបស់ស្ត្រីនៅរដ្ឋបាលមូលដ្ឋាន។ |
| ២.៣. ភាពគ្រប់គ្រាន់នៃសម្ភារបណ្តុះបណ្តាល និងឯកសារយោងស្តីពីបញ្ហាយេនឌ័រ និងការ បញ្ជ្រាបយេនឌ័រ | ១.៤ | • អ្នកផ្តល់ព័ត៌មានភាគច្រើនត្រូវការការណែនាំ និងឧបករណ៍បន្ថែមទៀតអំពីការវិភាគ និងការបញ្ជ្រាបយេនឌ័រ | • បង្កើតឧបករណ៍សមស្រប ដែល ពាក់ព័ន្ធនឹងចំណុច ២.២ ខាងលើ |
| ២.៤. ជំនាញ និងសមត្ថភាពផ្នែកយេនឌ័រដែលមាននៅថ្នាក់ក្រោមជាតិ | ១.៩ | • អ្នកផ្តល់ព័ត៌មានភាពច្រើនបានប្រើប្រាស់ និងបានពេញចិត្តនឹងការគាំទ្ររបស់អ្នកជំនាញយេនឌ័រ | |
| ២.៥. ការបញ្ចូលសមភាពយេនឌ័រទៅក្នុងការអភិវឌ្ឍសមត្ថភាព | ១.៥ | • យេនឌ័រត្រូវបានដាក់បញ្ចូលយ៉ាងល្អទៅក្នុង សេចក្តីណែនាំ និងការបណ្តុះបណ្តាលសម្រាប់ ក្រុមប្រឹក្សា និងរដ្ឋបាល | |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បថម |
|---|---|---|---|
| **៣. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការចាត់ចែងបុគ្គលិក** | **១.៥** | | |
| ៣.១. ស្ត្រីនៅក្នុងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ | ១.០ | • ស្ត្រីមានចំនួនលើសពី២០% នៅក្នុងសមាជិក ក្រុមប្រឹក្សាខេត្ត | • លើកទឹកចិត្តឲ្យគណៈបក្សនយោបាយនីមួយៗ រៀបចំបេក្ខភាពជាស្ត្រីឲ្យបានច្រើន និងស្ថិតនៅក្នុងលំដាប់ខាងលើនៅក្នុងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះ។ |
| ៣.២. ស្ត្រីនៅក្នុងកម្រិតនៃអ្នកធ្វើសេចក្តីសម្រេចជាន់ខ្ពស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ១.០ | • មានតែស្ត្រីដែលជាអភិបាលរងខេត្តមួយរូបគត់ នៅថ្នាក់ខេត្ត | • បង្កើតជម្រើសនានាសម្រាប់បង្កើន ជំនាញ និងទំនុកចិត្តដល់មន្ត្រីជា ស្ត្រី ដូច្នេះពួកគេអាចមានសមត្ថភាពក្នុងការទទួលបាននូវការតម្លើងតួនាទី |
| ៣.៣. ស្ត្រីនៅក្នុងកម្រិតអ្នកគ្រប់គ្រងថ្នាក់មធ្យម និងកម្រិតជំនាញបច្ចេកទេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ២.០ | • មានស្ត្រីមួយចំនួនតូចបានបំពេញតួនាទីជាប្រធានការិយាល័យ ប៉ុន្តែភាគច្រើនពាក់ព័ន្ធនឹងការងារ រដ្ឋបាល និងហិរញ្ញវត្ថុប៉ុណ្ណោះ | • ដូចខាងលើ |
| ៣.៤. ការយល់ដឹងអំពីយេនឌ័រ និងបញ្ហាយេនឌ័រនៅក្នុងការអនុវត្តការគ្រប់គ្រងធនធានមនុស្ស | ២.០ | • មានការយល់ដឹងបានល្អអំពីយេនឌ័រ និងការលើកកម្ពស់យេនឌ័រ ព្រមទាំងបានចាត់ទុកការងារនេះ ជាអាទិភាពក្នុងការជ្រើសរើសបុគ្គលិក<br>• មានការខិតខំប្រឹងប្រែងក្នុងការជ្រើសរើសនិងបង្កើនចំនួនស្ត្រីឲ្យបានច្រើនប៉ុន្តែមិនបានត្រៀមសកម្មភាពទុកជាមុនឡើយ<br>• ស្ត្រីទំនងជាត្រូវបានជ្រើសរើស និងតម្លើងតួនាទីពាក់ព័ន្ធតែនឹងតួនាទីជាប្រពៃណីរបស់ស្ត្រី ( ដូចជា | • បង្កើតជម្រើសនានាសម្រាប់ សកម្មភាពត្រៀមទុកជាមុនក្នុងការកំណត់ និងទាក់ទាញស្ត្រីឲ្យដាក់ពាក្យស្នើសុំបំពេញការងារបានច្រើនសម្រាប់មុខតំណែងនានានៅសាលាខេត្ត ដោយរួមបញ្ចូលទាំងមុខតំណែងដែលមិនមានជាតួនាទីជាប្រពៃណីរបស់ស្ត្រី ផងដែរ។ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| | | ការងារពាក់ព័ន្ធនឹងហិរញ្ញវត្ថុ គ្រប់គ្រងធន ធានមនុស្ស លទ្ធកម្មជាដើម) | |
| **៤. បញ្ហាយេនឌ័រនៅក្នុងស្ថាប័ន និង ការសម្រេចបាននូវសមភាពយេនឌ័រ** | **២.០** | | |
| ៤.១. ការយល់ឃើញអំពីសារសំខាន់នៃសមភាពយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រី | ២.៦ | • មានការយល់ដឹងខ្ពស់អំពីសារសំខាន់នៃសមភាពយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រីក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល<br>• មានការយល់ដឹងទាបជាងតិចតួចអំពីសារសំខាន់នៃគោលនយោបាយយេនឌ័ររបស់ផអ៣ សម្រាប់រដ្ឋបាលខេត្ត | • ជួយឲ្យពួកគេយល់ថា ការបញ្ជ្រាប យេនឌ័រ គឺជាពិន្ទុរបស់ ផអ៣ |
| ៤.២. ភាពស៊ាំទៅនឹងឯកសារកម្មវិធីជាតិ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ | ២.១ | • អ្នកផ្តល់ព័ត៌មានភាគច្រើនស៊ាំទៅនឹងកម្មវិធីជាតិ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងផអ៣ ព្រមទាំងបានយល់ឃើញថា យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងផអ៣មានលក្ខណៈច្បាស់លាស់។<br>• មានការយល់ដឹងតិចតួចអំពីខ្លឹមសារលម្អិតនៃ យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ | |
| ៤.៣. ការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងកន្លែងធ្វើការងារ | ២.០ | • ម្នាក់ៗមានភាពសកម្មក្នុងការធានាឲ្យមានការគោរពដល់ទំនាក់ទំនងរវាងបុរស និងស្ត្រី និងបានចូល រួមយ៉ាងសកម្មក្នុងការលើកកម្ពស់សមភាពយេនឌ័រ (មន្ត្រី និងថ្នាក់ដឹកនាំជាបុរសបានទទួលយកការ | • ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីកាត់បន្ថយការបង្ហាញ នូវវិសមភាពយេនឌ័រ<br>• ត្រូវជំនះនូវទស្សនៈដែលយល់ថា យេនឌ័រ គឺនិយាយតែស្ត្រី ប៉ុណ្ណោះ និងទស្សនៈដែលយល់ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| | | បញ្ជ្រាបយេនឌ័រ)<br>• រដ្ឋបាលថ្នាក់ក្រោមជាតិមានវិធីសាស្ត្រគ្រប់គ្រាន់ក្នុងការធ្វើឲ្យមានសមភាពយេនឌ័រ<br>• អ្នកផ្តល់ព័ត៌មានច្រើនជាងពាក់កណ្តាលយល់ឃើញថា គ.ក.ស.ក គ.ក.ន.ក មន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីក្រុង ស្រុក គឺជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣<br>• បញ្ចូលប្រធានបទស្តីពីការបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់សាលាភូមិន្ទរដ្ឋបាល | ថា ស្ត្រី គឺជាអ្នកទទួលបន្ទុកក្នុងការដោះស្រាយបញ្ហារបស់ស្ត្រី |
| ៤.៤. ការយល់ឃើញអំពីវឌ្ឍនភាពនៃសមភាព យេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រី | ១.២ | • អ្នកផ្តល់ព័ត៌មានភាគច្រើនដឹងថា ពួកកគេបានទទួលការបញ្ជ្រាបយេនឌ័រ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ចំណេះដឹងរបស់ពួកគេក្នុងការអនុវត្តការបញ្ជ្រាបយេនឌ័រនៅមានកម្រិតនៅឡើយ<br>• អ្នកដឹកនាំជាបុរសឯកភាពអំពីការបញ្ជ្រាបយេនឌ័រ ប៉ុន្តែឥរិយាបថ និងផ្នត់គំនិតនៅតែជាឧបសគ្គ។<br>• តំណាងរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងនៅក្នុងកម្រិតមន្ត្រីជំនាញនៅមានចំនួនតិចតួច។ អ្នកផ្តល់ព័ត៌មានយល់ឃើញថា ចំនួនស្ត្រីគួរត្រូវបានបង្កើន ប៉ុន្តែភាគច្រើនពាក់ព័ន្ធនឹងការងាររដ្ឋបាល និងហិរញ្ញវត្ថុ។ | • ដូចខាងលើ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បថម |
|---|---|---|---|
| | | • ស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិយល់ឃើញថា សមត្ថភាពរបស់ពួកគេនៅមានកម្រិតទាប នៅឡើយ<br>• ត្រូវការធនធានមនុស្ស និងធនធានហិរញ្ញវត្ថុបន្ថែមទៀតដើម្បីគាំទ្រ និងលើកកម្ពស់សមភាពយេនឌ័រ | |
| **៥. ការឆ្លើយតបយេនឌ័ររបស់អង្គការដៃគូ** | **២.៧** | | |
| ៥.១. តួនាទីរបស់ដៃគូអភិវឌ្ឍន៍ក្នុងការគាំទ្រ និងលើកកម្ពស់សមភាពយេនឌ័រ | ២.៨ | • ដៃគូអភិវឌ្ឍន៍ភាគច្រើនបំផុតបានទទួលស្គាល់ អំពីសារសំខាន់នៃការលើកកម្ពស់សមភាពយេនឌ័រ | |
| ៥.២. តួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការ គាំទ្រ និងការលើកកម្ពស់សមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រី | ២.៦ | • អ្នកផ្តល់ព័ត៌មានទាំងអស់បានទទួលស្គាល់ថា អង្គការសង្គមស៊ីវិលមានសារសំខាន់ណាស់ក្នុង ការចូលរួមរៀបចំ និងអនុវត្តដើម្បីបង្កើននូវសមភាពយេនឌ័រ ព្រមទាំងបង្កើននូវភាពជាតំណាង និងសម្លេងរបស់ស្ត្រី | • គួរបញ្ចូលតំណាងអង្គការសង្គមស៊ីវិលនៅក្នុង គ.ក.ស.ក<br>• គួររៀនសូត្រពីបទពិសោធនានា ដែលអង្គការសង្គមស៊ីវិលបានអនុវត្តគម្រោងនៅថ្នាក់ឃុំសង្កាត់ |
| **ពិន្ទុសរុបជាមធ្យម** | **១.៩** | | |

# ឧបសម្ព័ន្ធទី ៦.៧ ÷ តារាងពិន្ទុ

**ខេត្តក្រចេះ**

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| **១. យេនឌ័រនៅក្នុងការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងផលប៉ះពាល់នៃលើការអនុវត្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** | **១.៦** | | |
| ១.១.ការកសាងផែនការ | ១.៧ | • បញ្ហាភាគច្រើនបំផុតដែលបានលើក ឡើងដោយ គ.ក.ស.ក ត្រូវបានដោះស្រាយតាមករណីនីមួយៗ ម្តងមួយៗ ដោយមិនបានបញ្ចូលក្នុងផែនការរបស់ខេត្តឡើយ<br>• យន្តការ និងដំណើរការត្រូវបានរៀបចំ និងដាក់ឲ្យប្រើប្រាស់នៅថ្នាក់ឃុំ សង្កាត់ ប៉ុន្តែមិនទាន់បានរៀបចំសម្រាប់ថ្នាក់ខេត្ត និងក្រុង ស្រុកឡើយ។ | • បញ្ចប់សេចក្តីណែនាំបច្ចេកទេស ស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបញ្ចូល នូវនីតិវិធីនានា ដើម្បីធានាឲ្យមានការវិភាគយេនឌ័របានសមស្រប នៅក្នុងដំណើរការកសាងផែនការ ព្រមទាំងការកំណត់អំពីអាទិភាព ឆ្លើយតបយេនឌ័រដែលត្រូវដាក់ បញ្ចូលក្នុងផែនការ។ |
| ១.២. ការរៀបចំថវិកា | ២.០ | • នៅក្នុងចន្លោះឆ្នាំ២០១២ និង២០១៣ មិនមានការប្រែប្រួលចំនួនមូលនិធិផអ៣ដែលវិភាជន៍ឲ្យ ក្រសួងកិច្ចការនារី ឬមន្ទីរកិច្ចការនារី សម្រាប់គាំទ្រសកម្មភាពបណ្តុះបណ្តាល ការចងក្រងបណ្តាញនានា និងការគាំទ្រ | • គួរបង្កើនចំនួនមូលនិធិដែលត្រូវ ផ្ទេរឲ្យខេត្ត ។ ឧទាហរណ៍ ថវិកា ទាំងនោះអាចនឹងប្រើសម្រាប់ការអភិវឌ្ឍសមត្ថភាពបុគ្គលិកជាស្ត្រី នៅរដ្ឋបាលខេត្ត និងសម្រាប់ការ បណ្តុះបណ្តាលអំពីយេនឌ័រសម្រាប់បុរសឲ្យបានកាន់តែច្រើន |
| ១.៣. ការអនុវត្ត | ១.៥ | • ផែនការសកម្មភាព និងថវិការបស់ផអ៣ : អនុវត្ត | • រៀបចំបែបបទ និងនីតិវិធីសម្រាប់ បើកប្រាក់ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| | | ភាគច្រើននៅថ្នាក់ខេត្ត<br>• ពិបាកក្នុងការទទួលបានមូលនិធិសម្រាប់សេវាសង្គមថ្នាក់ឃុំ សង្កាត់ ការតាមដាន និងគាំទ្រ គ.ក.ស.ក នៅថ្នាក់ ក្រុង ស្រុក | មូលនិធិដើម្បីអនុវត្ត សកម្មភាពតូចៗ (ដូចជា សកម្មភាពសេវាសង្គម ការតាមដាន និងគាំទ្រ គ.ក.ស.ក ជាដើម) |
| ១.៤. ការតាមដានត្រួតពិនិត្យ | ២.០ | • មានទិន្នន័យបែងចែកតាមភេទសម្រាប់ការចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលានានា<br>• ការកំណត់អ្នកត្រូវចូលរួមផ្អែកតាមភេទ (ស្ត្រី ឬ បុរស) ច្រើនជាងផ្អែកលើការផ្លាស់ប្តូរចំណេះដឹង ឥរិយាបថ និងអាកប្បកិរិយា | • ពង្រឹងការប្រើប្រាស់ព័ត៌មាន ដែលទទួលបានពីការតាមដានត្រួតពិនិត្យ ដើម្បីកែលម្អការរៀបចំ និងអនុវត្តសកម្មភាពនានា |
| ១.៥. ផលប៉ះពាល់ (ការអភិវឌ្ឍ/ស្ថាប័ន) | ១.០ | • ពិន្ទុនៃគោលដៅអភិវឌ្ឍសហវត្សទី៣ ដែលកំណត់អំពីសមភាពយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រីទទួលបានពិន្ទុទាប (៥៧)<br>• ពិន្ទុនៃគោលដៅអភិវឌ្ឍសហវត្សទី៥ ដែលកំណត់អំពីសុខភាពមាតា និងទារកទទួលបានពិន្ទុទាបណាស់ (៣៧)<br>• យេនឌ័រនៅក្នុងប្រព័ន្ធទិន្នន័យឃុំ សង្កាត់មានពិន្ទុទាប (៥៤)<br>• ទោះបីជា គ.ក.ស.ក បានកំពុងដំណើរការក៏ដោយ ក៏គណៈកម្មាធិការនេះ ត្រូវការអភិវឌ្ឍន៍សមត្ថភាពបន្ថែមជាចាំបាច់ និងត្រូវការការគាំទ្រពីថ្នាក់លើ ។ | • គោលដៅអភិវឌ្ឍសហវត្ស និង តារាងពិន្ទុតាមវិស័យ : បង្កើតឧបករណ៍នានាសម្រាប់កំណត់បញ្ហាតាមវិស័យអាទិភាពនៅថ្នាក់ឃុំ សង្កាត់ និងថ្នាក់ក្រុង ស្រុក<br>• ពិនិត្យឡើងវិញ ធ្វើសុខដុមនីយកម្ម និងការពង្រឹងយន្តការស្ថាប័ន ក្នុងការគាំទ្រការបញ្ជ្រាបយេនឌ័រ នៅថ្នាក់ក្រោមជាតិ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| **២. ជំនាញបច្ចេកទេសក្នុងការគាំទ្រដល់ការរៀបចំ និងអនុវត្តការឆ្លើយតបយេនឌ័រសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ** | **១.៧** | | |
| ២.១. សមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ | ២.១ | • អ្នកផ្តល់ព័ត៌មានភាគច្រើនមានអារម្មណ៍ថា ខ្លួនគេមានសត្ថភាពគ្រប់គ្រាន់ក្នុងការបញ្ជ្រាបយេនឌ័រ<br>• ខណៈដែលអ្នកផ្តល់ព័ត៌មានភាគច្រើនយល់ឃើញថា រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាស្ថាប័នដែលមានសមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ អ្នកផ្តល់ព័ត៌មានចំនួន ៣៧% យល់ឃើញថា មិនទាន់មាន សមត្ថភាពគ្រប់គ្រាន់នៅឡើយ។ | • មើលខាងក្រោម |
| ២.២. ការអភិវឌ្ឍសមត្ថភាពអំពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធី និងក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ (P&ME) | ១.៦ | • ខណៈដែលអ្នកផ្តល់ព័ត៌មានភាគច្រើនយល់ថា ពួកគេទទួលបានការអភិវឌ្ឍន៍សមត្ថភាពអំពីយេនឌ័រគ្រប់គ្រាន់ អ្នកផ្តល់ព័ត៌មានចំនួន ៣៧% យល់ឃើញថា ពួកគេនៅតែមានតម្រូវការអភិវឌ្ឍន៍សមត្ថភាពបន្ថែមទៀត<br>• ការបណ្តុះបណ្តាលយេនឌ័របានផ្តោតលើទ្រឹស្តីច្រើនពេក ដូច្នេះការបណ្តុះបណ្តាលគួរផ្តោតលើការអនុវត្ត<br>• ការបណ្តុះបណ្តាលផ្តោតតែលើស្ត្រី | • ការពង្រឹងសមត្ថភាព គួរផ្តោត លើការយល់ដឹងអំពីយេនឌ័រ ជំនាញក្នុងការវិភាគ និងបញ្ជ្រាប យេនឌ័រ ដែលសិក្ខាកាមម្នាក់ៗត្រូវការ ដើម្បីឲ្យពួកគេអាចយកចំណេះដឹង និងជំនាញនោះទៅអនុវត្ត<br>• រៀបចំវគ្គបណ្តុះបណ្តាលអំពីយេនឌ័រសម្រាប់សិក្ខាកាមជាបុរសឲ្យ បានច្រើនថែមទៀត ដើម្បីបង្កើន ការយល់ដឹងរបស់ពួកគេ ក្នុងការ ពង្រឹងការគាំទ្រដល់ការបញ្ជ្រាប យេនឌ័រ ព្រមទាំងគាំទ្រនូវភាពជាតំណាងរបស់ស្ត្រី និងសម្លេងរបស់ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បថម |
|---|---|---|---|
| | | | ស្ត្រីនៅរដ្ឋបាលមូលដ្ឋាន |
| ២.៣. ភាពគ្រប់គ្រាន់នៃសម្ភារបណ្តុះបណ្តាល និងឯកសារយោងស្តីពីបញ្ហាយេនឌ័រ និងការ បញ្ជ្រាបយេនឌ័រ | ១.៤ | • អ្នកផ្តល់ព័ត៌មានភាគច្រើនត្រូវការការណែនាំ និងឧបករណ៍បន្ថែមទៀតអំពីការវិភាគ និងការបញ្ជ្រាបយេនឌ័រ | • បង្កើតឧបករណ៍សមស្រប ដែល ពាក់ព័ន្ធនឹងចំណុច ២.២ ខាងលើ |
| ២.៤. ជំនាញ និងសមត្ថភាពផ្នែកយេនឌ័រដែលមាននៅថ្នាក់ក្រោមជាតិ | ១.៩ | • អ្នកផ្តល់ព័ត៌មានភាពច្រើនបានប្រើប្រាស់ និងបានពេញចិត្តនឹងការគាំទ្ររបស់អ្នកជំនាញយេនឌ័រ | |
| ២.៥. ការបញ្ចូលសមភាពយេនឌ័រទៅក្នុងការអភិវឌ្ឍសមត្ថភាព | ១.៥ | • យេនឌ័រត្រូវបានដាក់បញ្ចូលយ៉ាងល្អទៅក្នុង សេចក្តីណែនាំ និងការបណ្តុះបណ្តាលសម្រាប់ ក្រុមប្រឹក្សា និងរដ្ឋបាល | |
| **៣. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និង ការចាត់ចែងបុគ្គលិក** | **១.៥** | | |
| ៣.១. ស្ត្រីនៅក្នុងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ | ១.០ | • ស្ត្រីមានចំនួន១៣% នៅក្នុងសមាជិកក្រុមប្រឹក្សាខេត្ត | • លើកទឹកចិត្តឲ្យគណៈបក្សនយោបាយនីមួយៗរៀបចំបេក្ខភាព ជាស្ត្រីឲ្យបានច្រើន និងស្ថិតនៅក្នុងលំដាប់ខាងលើនៅក្នុងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះ។ |
| ៣.២. ស្ត្រីនៅក្នុងកម្រិតនៃអ្នកធ្វើសេចក្តីសម្រេចជាន់ខ្ពស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ១.០ | • មានតែស្ត្រីចំនួន ១៩% ស្ថិតនៅក្នុងមុខតំណែងជាអ្នកធ្វើសេចក្តីសម្រេចជាន់ខ្ពស់នៅថ្នាក់ខេត្ត | • បង្កើតជម្រើសនានាសម្រាប់បង្កើន ជំនាញ និងទំនុកចិត្តដល់មន្ត្រីជាស្ត្រី ដូច្នេះ ពួកគេអាចមានសមត្ថភាពក្នុងការទទួលបាននូវការតម្លើងតួនាទី |
| ៣.៣. ស្ត្រីនៅក្នុងកម្រិតអ្នកគ្រប់គ្រងថ្នាក់មធ្យម | ២.០ | • មានស្ត្រីមួយចំនួនលើសពី២០% ស្ថិតនៅក្នុងមុខ | • ដូចខាងលើ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| និងកម្រិតជំនាញបច្ចេកទេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | | តំណែងជាអ្នកគ្រប់គ្រងថ្នាក់មធ្យម និងជាបុគ្គលិកជំនាញនៅថ្នាក់ខេត្ត | |
| ៣.៤. ការយល់ដឹងអំពីយេនឌ័រ និងបញ្ហាយេនឌ័រនៅក្នុងការអនុវត្តការគ្រប់គ្រងធនធានមនុស្ស | ២.០ | • មានការយល់ដឹងបានល្អអំពីយេនឌ័រ និងការលើកកម្ពស់យេនឌ័រ ព្រមទាំងបានចាត់ទុកការងារនេះ ជាអាទិភាពក្នុងការជ្រើសរើសបុគ្គលិក<br>• មានការខិតខំប្រឹងប្រែងក្នុងការជ្រើសរើស និងបង្កើនចំនួនស្ត្រីឲ្យបានច្រើន ប៉ុន្តែមិនបានត្រៀមសកម្មភាពទុកជាមុនឡើយ<br>• ស្ត្រីទំនងជាត្រូវបានជ្រើសរើស និងតម្លើងតួនាទីពាក់ព័ន្ធតែនឹងតួនាទីជាប្រពៃណីរបស់ស្ត្រី ( ដូចជាការងារពាក់ព័ន្ធនឹងហិរញ្ញវត្ថុ គ្រប់គ្រងធនធានមនុស្ស លទ្ធកម្មជាដើម) | • បង្កើតជម្រើសនានាសម្រាប់ សកម្មភាពត្រៀមទុកជាមុន ក្នុងការកំណត់ និងទាក់ទាញស្ត្រីឲ្យដាក់ពាក្យស្នើសុំបំពេញការងារបានច្រើនសម្រាប់មុខតំណែងនានានៅសាលាខេត្ត ដោយរួមបញ្ចូលទាំងមុខតំណែងដែលមិនមានជាតួនាទីជាប្រពៃណីរបស់ស្ត្រី ផងដែរ។ |
| ៣.៥. ការបណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំរបស់ស្ត្រី | | | |
| **៤. បញ្ហាយេនឌ័រនៅក្នុងស្ថាប័ន និង ការសម្រេចបាននូវសមភាពយេនឌ័រ** | **២.១** | | |
| ៤.១. ការយល់ឃើញអំពីសារសំខាន់នៃសមភាពយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រី | ២.៥ | • មានការយល់ដឹងខ្ពស់អំពីសារសំខាន់នៃសមភាពយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រីក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល<br>• មានការយល់ដឹងទាបជាងតិចតួចអំពីសារសំខាន់នៃ | |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បថម |
|---|---|---|---|
| | | គោលនយោបាយយេនឌ័ររបស់ផអ៣សម្រាប់រដ្ឋបាលខេត្ត | |
| ៤.២. ភាពស៊ាំទៅនឹងឯកសារកម្មវិធីជាតិ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ | ២.១ | • អ្នកផ្តល់ព័ត៌មានភាគច្រើនស៊ាំទៅនឹងកម្មវិធីជាតិ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងផអ៣ ព្រមទាំងបានបានយល់ឃើញថា យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងផអ៣មានលក្ខណៈច្បាស់លាស់។<br>• មានការយល់ដឹងតិចតួចអំពីខ្លឹមសារលម្អិតនៃយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ | • |
| ៤.៣. ការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងកន្លែងធ្វើការងារ | ២.០ | • ម្នាក់ៗមានភាពសកម្មក្នុងការជានាឲ្យមានការគោរពដល់ទំនាក់ទំនងរវាងបុរស និងស្ត្រី និងបានចូល រួមយ៉ាងសកម្មក្នុងការលើកកម្ពស់សមភាពយេនឌ័រ<br>• រដ្ឋបាលថ្នាក់ក្រោមជាតិមានវិធីសាស្ត្រគ្រប់គ្រាន់ក្នុងការធ្វើឲ្យមានសមភាពយេនឌ័រ<br>• អ្នកផ្តល់ព័ត៌មានចំនួន ៣៤% យល់ឃើញថា រដ្ឋបាលថ្នាក់ក្រោមជាតិគួរចាត់វិធានការបន្ថែម ទៀត ដើម្បីទប់ស្កាត់នូវសកម្មភាពដែលនាំឲ្យមាន វិសមភាពយេនឌ័រ<br>• អ្នកផ្តល់ព័ត៌មានច្រើនជាងពាក់កណ្តាលយល់ឃើញថា គ.ក.ស.ក គ.ក.ន.ក មន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីក្រុង ស្រុក គឺជាអ្នក | • ត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីទប់ស្កាត់សកម្មភាព ដែលនាំឲ្យមានវិសមភាពយេនឌ័រ<br>• ត្រូវជំនះនូវទស្សនៈដែលយល់ថា យេនឌ័រ គឺនិយាយតែស្ត្រីប៉ុណ្ណោះ និងទស្សនៈដែលយល់ថា ស្ត្រី គឺជាអ្នកទទួលបន្ទុកក្នុងការដោះស្រាយបញ្ហារបស់ស្ត្រី |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| | | ទទួលខុសត្រូវក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាប យេនឌ័រនៃផអ៣ | |
| ៤.៤. ការឆ្លុះបញ្ចាំងអំពីការយល់ឃើញជាសាធារណៈពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រី | | | |
| ៤.៥. ការយល់ឃើញអំពីវឌ្ឍនភាពនៃសមភាព យេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រី | ១.៦ | • អ្នកផ្តល់ព័ត៌មានភាគច្រើនដឹងថា ពួកគេបានទទួលការបញ្ជ្រាបយេនឌ័រ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏ចំណេះដឹងរបស់ពួកគេក្នុងការអនុវត្តការបញ្ជ្រាបយេនឌ័រនៅមានកម្រិតនៅឡើយ<br>• អ្នកដឹកនាំជាបុរសឯកភាពអំពីការបញ្ជ្រាបយេនឌ័រ ប៉ុន្តែឥរិយាបថ និងផ្នត់គំនិតនៅតែជាឧបសគ្គ។<br>• តំណាងរបស់ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេច និងនៅក្នុងកម្រិតមន្ត្រីជំនាញនៅមានចំនួនតិចតួច។ អ្នកផ្តល់ព័ត៌មានយល់ឃើញថា ចំនួនស្ត្រីគួរត្រូវបានបង្កើន ប៉ុន្តែភាគច្រើនពាក់ព័ន្ធនឹងការងារ រដ្ឋបាល និងហិរញ្ញវត្ថុ។<br>• ស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិយល់ឃើញថា សមត្ថភាពរបស់ពួកគេនៅមានកម្រិតទាបនៅឡើយ<br>• ត្រូវការធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ បន្ថែមទៀតដើម្បីគាំទ្រ និងលើកកម្ពស់សមភាព យេនឌ័រ | • ដូចខាងលើ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បថម |
|---|---|---|---|
| **៥. ការឆ្លើយតបយេនឌ័ររបស់អង្គការដៃគូ** | **២.៧** | | |
| ៥.១. តួនាទីរបស់ដៃគូអភិវឌ្ឍន៍ក្នុងការគាំទ្រ និងលើកកម្ពស់សមភាពយេនឌ័រ | ២.៨ | • ដៃគូអភិវឌ្ឍន៍ភាគច្រើនបំផុតបានទទួលស្គាល់ អំពីសារសំខាន់នៃការលើកកម្ពស់សមភាពយេនឌ័រ | |
| ៥.២. តួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការ គាំទ្រ និងការលើកកម្ពស់សមភាពយេនឌ័រ ការបញ្ជ្រាបយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រី | ២.៥ | • អ្នកផ្តល់ព័ត៌មានទាំងអស់បានទទួលស្គាល់ថា អង្គការសង្គមស៊ីវិលមានសារសំខាន់ណាស់ក្នុង ការចូលរួមរៀបចំ និងអនុវត្តដើម្បីបង្កើននូវសមភាពយេនឌ័រ ព្រមទាំងបង្កើននូវភាពជាតំណាង និងសម្លេងរបស់ស្ត្រី | • គួរបញ្ចូលតំណាងអង្គការសង្គមស៊ីវិលនៅក្នុង គ.ក.ស.ក |
| **ពិន្ទុសរុបជាមធ្យម** | **១.៩** | | |

# ឧបសម្ព័ន្ធទី ៦.៨ ÷ តារាងពិន្ទុ

## ខេត្តស្វាយរៀង

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បថម |
|---|---|---|---|
| **១. យេនឌ័រនៅក្នុងការកសាងផែនការ ការរៀបចំថវិកា ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងផលប៉ះពាល់នៃលើការអនុវត្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** | ២.១ | | |
| ១.១. ការកសាងផែនការ | ២.៥ | • បញ្ហារបស់ស្ត្រី និងកុមារត្រូវបានយកចិត្តទុកដាក់ដោយក្រុមប្រឹក្សា។ ការងាររបស់ គ.ក.ស.ក តែងតែងត្រូវបានដាក់បញ្ចូលជារបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សា។ កិច្ចការនេះ ក៏ត្រូវបានពិនិត្យឡើង វិញតាមរយៈការផ្ទៀងផ្ទាត់ព័ត៌មានជាមួយគណៈ អភិបាល។<br>• ការកសាងផែនការពាក់ព័ន្ធនឹងការបញ្ជ្រាបយេនឌ័រត្រូវបានរៀបចំឡើងដោយមន្ទីរពាក់ព័ន្ធនៅក្នុងខេត្ត ហើយផែនការទាំងនោះត្រូវបានដាកើបញ្ចូលក្នុងផែនការសកម្មភាពប្រចាំឆ្នាំរបស់ គ.ក.ស.ក<br>• ផែនការប្រចាំឆ្នាំសម្រាប់អនុវត្តផអ៣នៅថ្នាក់ខេត្តបានឆ្លុះបញ្ចាំងទៅនឹងសកម្មភាពបញ្ជ្រាប និងការលើកកម្ពស់យេនឌ័រ | |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បថម |
|---|---|---|---|
| ១.២. ការរៀបចំថវិកា | ២.០ | • ប្រភពថវិកាប្រើប្រាស់សម្រាប់អនុវត្តសកម្មភាព របស់មន្ទីរកិច្ចការនារីខេត្ត និងការិយាល័យកិច្ចការនារីក្រុង ស្រុកភាគច្រើនបំផុតបានមកពីអង្គការសង្គមស៊ីវិល<br>• មិនមានការវិភាជន៍ថវិកាផអពាបន្ថែមដល់មន្ទីរ កិច្ចការនារីខេត្ត នៅពេលមន្ទីរខ្វះថវិកាអនុវត្តសកម្មភាព<br>• មិនមានថវិកាគ្រប់គ្រាន់សម្រាប់គាំទ្រកិច្ចប្រជុំ គ.ក.ស.ក | • គួរបង្កើនចំនួនថវិកា ដើម្បីឲ្យ គ.ក.ស.ក អាចបង្កើនចំនួនវគ្គបណ្តុះបណ្តាល ពិសេសវគ្គបណ្តុះបណ្តាលស្តីពីទស្សនទាននៃការបញ្ជ្រាបយេនឌ័រ ដល់បុគ្គលិកជាបុរស<br>• គួរបន្តកិច្ចសហប្រតិបត្តិការល្អ ជាមួយដៃគូរអភិវឌ្ឍន៍ និងអង្គការ សង្គមស៊ីវិល |
| ១.៣. ការអនុវត្ត | ១.៩ | • សកម្មភាពបញ្ជ្រាបយេនឌ័រ និងការលើកកម្ពស់សមភាពយេនឌ័រនៅថ្នាក់ខេត្តត្រូវបានអនុវត្ត ស្របតាមផែនការដែលបានគ្រោង<br>• នៅតាមឃុំមួយចំនួន ជួបឧបសគ្គខ្លះៗពាក់ព័ន្ធនឹងការបើកប្រាក់សម្រាប់សកម្មភាពសេវាសង្គម។ ពេលខ្លះ កិច្ចប្រជុំ គ.ក.ន.ក ត្រូវបានរៀបចំបញ្ចូលជាមួយកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ ដែលនាំឲ្យមានភាពមិនយកចិត្តទុកដាក់ ចំពោះបញ្ហាពាក់ព័ន្ធនឹងស្ត្រី និងកុមារ។ ជនបង្គោលនារី និងកុមារឃុំ មិនទាន់មានភាពច្បាស់លាស់ពាក់ព័ន្ធនឹងនីតិវិធី បើកប្រាក់ | • ពង្រឹងសមត្ថភាពជនបង្គោលនារី និងកុមារឃុំ សង្កាត់ពាក់ព័ន្ធនឹងនីតិវិធីនៃការទូទាត់ចំណាយសម្រាប់ថវិកាសេវាសង្គម។ ជាមួយគ្នានេះ ចាំបាច់ត្រូវមានការគាំទ្រពីមេឃុំ ចៅសង្កាត់ និងស្មៀនឃុំ សង្កាត់ ដើម្បីលើកទឹកចិត្តឲ្យជនបង្គោលអាចអនុវត្តសកម្មភាពបានយ៉ាងមានប្រសិទ្ធភាព។ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បថម |
|---|---|---|---|
| | | • ទោះបីជាយ៉ាងណាក៏ដោយ គ.ក.ស.ក និង គ.ក.ន.ក ត្រូវបានទទួលស្គាល់ថា ជាគណៈកម្មាធិការដែលសកម្មជាងគណៈកម្មាធិការផ្សេងៗទៀត | |
| ១.៤. ការតាមដានត្រួតពិនិត្យ | ២.០ | • មានទិន្នន័យបែងចែកតាមភេទរវាងបុរស និងស្ត្រី ដែលទិន្នន័យនេះបង្ហាញត្រឹមតែចំនួនស្ត្រី និងចំនួនបុរសដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលានានាប៉ុណ្ណោះ ប៉ុន្តែមិនបានបង្ហាញ អំពីការផ្លាស់ប្តូរឥរិយាបថ កម្រិតនៃការចូលរួម ឬការផ្សព្វផ្សាយចំណេះដឹងឡើយ។ | • បង្កើនចំណេះដឹងបច្ចេកទេស តាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីប្រមូលបានព័ត៌មានកាន់តែច្រើន ជាជាងផ្តោតតែលើចំនួន ស្ត្រី និង បុរស។ |
| ១.៥. ផលប៉ះពាល់ (ការអភិវឌ្ឍ/ស្ថាប័ន) | ២.០ | • ពិន្ទុនៃគោលដៅអភិវឌ្ឍសហវត្សទី៣ នៅស្វាយរៀងទទួលបានពិន្ទុត្រឹមតែ៦៥ នៅក្នុងឆ្នាំ ២០១៣។ ចំណែកឯពិន្ទុនៃគោលដៅអភិវឌ្ឍសហវត្សទី៥ ដែលកំណត់ អំពីសុខភាពមាតា និង ទារកទទួលបានពិន្ទុត្រឹមតែ ៥២ ប៉ុណ្ណោះ។ ដូច្នេះ ត្រូវចាត់វិធានការបន្តទៀត ដើម្បីសម្រេចគោល ដៅអភិវឌ្ឍន៍សហសវត្សឆ្នាំ ២០១៥។<br>•ម្យ៉ាងវិញទៀត គ.ក.ន.ក គឺជាគណៈកម្មាធិការ តែមួយគត់ដែលអនុវត្តមុខងារបានល្អ ជាគណៈកម្មា ធិការផ្សេងៗទៀតរបស់ក្រុមប្រឹក្សា។ ចំណុចឆ្លុះបញ្ចាំងឲ្យឃើញថា មានការយកចិត្តទុកដាក់កាន់ | • តារាងពិន្ទុនៃគោលដៅអភិវឌ្ឍ សហសវត្សដែលបានរៀបចំដោយ ក្រសួងផែនការ ត្រូវបានប្រើប្រាស់ ជាឧបករណ៍សម្រាប់វាស់វែងអំពី ស្ថានភាពស្ត្រីនៅកម្ពុជា ដើម្បីកំណត់អំពីបញ្ហាអាទិភាព និងចាត់វិធានការដោះស្រាយយ៉ាងមានប្រសិទ្ធភាពក្នុងការលើកកម្ពស់តុល្យភាពយេនឌ័រ។<br>• យេនឌ័រ គឺជាបញ្ហាអន្តរវិស័យ ដូច្នេះ ចាំបាច់ត្រូវមានការចូលរួមពីវិស័យជំនាញនានា។ កម្មវិធីចាំបាច់ត្រូវការការគាំទ្រ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| | | តែច្រើនឡើងពីគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការបញ្ជ្រាបយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រី។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការចូលរួមរបស់ជនបង្គោលយេនឌ័រពីមន្ទីរជំនាញនានានៅមានកម្រិតនៅឡើយ ដោយសារតែមិនមានការឧបត្ថម្ភគ្រប់គ្រាន់ដើម្បីឲ្យពួកគេអាចអនុវត្តកាន់ តែសកម្មជាងនេះ។ | |
| **២. ជំនាញបច្ចេកទេសក្នុងការគាំទ្រដល់ការរៀបចំ និងអនុវត្តការឆ្លើយតបយេនឌ័រសម្រាប់ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ** | ២.១ | | |
| ២.១. សមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រ | ២.៣ | • អ្នកផ្តល់ព័ត៌មានចំនួន ៥៦% ក្នុងចំណោម២៩ នាក់ យល់ឃើញថា សមត្ថភាពស្ថាប័នក្នុងការ វិភាគយេនឌ័រ និងការបញ្ចូលការវិភាគនោះទៅ ក្នុងដំណើរការកសាងផែនការនៅមានកម្រិតនៅ ឡើយ ដែលពួកគេគិតអំពីបញ្ហាយេនឌ័រពាក់ព័ន្ធ ត្រឹមតែការអនុវត្តភារកិច្ចរបស់ពួកគេប៉ុណ្ណោះ។ | |
| ២.២. ការអភិវឌ្ឍសមត្ថភាពអំពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធី និង ក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ (P&ME) | ១.៨ | • អ្នកផ្តល់ព័ត៌មានចំនួន៧៦% បានឆ្លើយថា ពួកគេបានទទួលការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពពាក់ព័ន្ធនឹងយេនឌ័រនៅក្នុងជំនាញវិជ្ជាជីវៈរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយ កម្រិតចំណេះ | • បន្តពង្រឹងចំណេះដឹង និងជំនាញ អំពីការវិភាគយេនឌ័រ និងការបញ្ជ្រាបយេនឌ័រក្នុងអនុវត្តការងារ ដល់គ្រប់បុគ្គលិកទាំងអស់ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| | | ដឹងដែលទទួលបានមិនទាន់គ្រប់គ្រាន់នៅឡើយ។ លើសពីនេះទៀត ការបណ្តុះបណ្តាលដែលបានទទួលកន្លងមក ផ្តោត ត្រឹមតែទ្រឹស្តីច្រើនជាការអនុវត្តជាក់ស្តែង។ | |
| ២.៣. ភាពគ្រប់គ្រាន់នៃសម្ភារបណ្តុះបណ្តាល និងឯកសារយោងស្តីពីបញ្ហាយេនឌ័រ និងការ បញ្ជ្រាបយេនឌ័រ | ១.៥ | • អ្នកផ្តល់ព័ត៌មានភាគច្រើនត្រូវការការណែនាំ និងឧបករណ៍បន្ថែមទៀតអំពីការវិភាគ និងការ បញ្ជ្រាបយេនឌ័រ | • បង្កើតឧបករណ៍នានាពាក់ព័ន្ធនឹងរបៀបវិភាគ និងរបៀបបញ្ជ្រាប យេនឌ័រនៅក្នុងការកសាងផែនការ និងវិធានការនានាដើម្បីលើក កម្ពស់យេនឌ័រ |
| ២.៤. ជំនាញ និងសមត្ថភាពផ្នែកយេនឌ័រដែលមាននៅថ្នាក់ក្រោមជាតិ សម្រាប់គាំទ្រដល់ការ បញ្ជ្រាបយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រី | ២.៤ | • អ្នកផ្តល់ព័ត៌មានភាពច្រើនបានប្រើប្រាស់ និងបានពេញចិត្តនឹងការគាំទ្ររបស់អ្នកជំនាញយេនឌ័រដែលរួមបញ្ចូលទាំងលេខាធិការដ្ឋាន គ.ជ.អ.ប និងមន្ទីរ និងការិយាល័យកិច្ចការនារីខេត្ត ស្រុក | |
| ២.៥. ការបញ្ចូលសមភាពយេនឌ័រទៅក្នុងការអភិវឌ្ឍសមត្ថភាព | ២.៥ | • មានការខិតខំប្រឹងប្រែងបានល្អក្នុងការបញ្ជ្រាបយេនឌ័រតាមរយៈការរៀបចំសម្ភារៈបណ្តុះបណ្តាលរបស់ក្រុមអភិវឌ្ឍសមត្ថភាពខេត្ត | |
| **៣. ស្ត្រីនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការចាត់ចែងបុគ្គលិក** | **១.៥** | | |
| ៣.១. អត្រាស្ត្រីនៅក្នុងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ | ១.០ | • មានស្ត្រីចំនួន២រូប ក្នុងចំណោម១៥ ឬស្មើនឹង ១៣% នៅក្នុងសមាជិកក្រុមប្រឹក្សាខេត្ត | • លើកទឹកចិត្តឲ្យគណៈបក្សនយោបាយនីមួយៗ រៀបចំបេក្ខភាព ជាស្ត្រីឲ្យបានច្រើន នៅក្នុងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះ។ ប្រសិនអាចធ្វើបាន |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| | | | គួររៀបចំបញ្ជីបេក្ខភាពដោយរៀប ឆ្លាស់គ្នារវាងបុរស និងស្ត្រី។ |
| ៣.២. អត្រាស្ត្រីនៅក្នុងកម្រិតនៃអ្នកធ្វើសេចក្តីសម្រេចជាន់ខ្ពស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ១.០ | • មានស្ត្រីចំនួន ១៥%នៅក្នុងជួរអ្នកដឹកនាំជាន់ខ្ពស់ | • បង្កើតជម្រើសនានាសម្រាប់បង្កើន ជំនាញ និងទំនុកចិត្តដល់មន្ត្រីជា ស្ត្រី ដូច្នេះ ពួកគេអាចមានសមត្ថភាពក្នុងការទទួលបាននូវការតម្លើងតួនាទី។ |
| ៣.៣. អត្រាស្ត្រីនៅក្នុងកម្រិតអ្នកគ្រប់គ្រងថ្នាក់មធ្យម និង កម្រិតជំនាញបច្ចេកទេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | ២.០ | • រដ្ឋបាលខេត្តមានស្ត្រីមួយ ២០% នៅក្នុងកម្រិតអ្នកគ្រប់គ្រងថ្នាក់មធ្យម និង កម្រិតជំនាញបច្ចេកទេស | |
| ៣.៤. ការយល់ដឹងអំពីយេនឌ័រ និងបញ្ហាយេនឌ័រនៅក្នុងការអនុវត្តការគ្រប់គ្រងធនធានមនុស្ស | ២.០ | • មានការយល់ដឹងបានល្អអំពីយេនឌ័រ និងការលើកកម្ពស់យេនឌ័រ ព្រមទាំងបានចាត់ទុកការងារនេះ ជាអាទិភាពក្នុងការជ្រើសរើសបុគ្គលិក<br>• មិនទាន់មានកិច្ចខិតខំប្រឹងប្រែង ឬរៀបចំផែនការគ្រប់គ្រាន់របស់ទីចាត់ការធនធានមនុស្សក្នុងការត្រៀមរៀបចំជាមុនដើម្បីបង្កើនចំនួនបុគ្គលិកជាស្ត្រី<br>• បុគ្គលិកជាស្ត្រីមួយចំនួនស្ថិតនៅក្នុងកម្រិតទាបដែលធ្វើឲ្យពួកគេមិនអាចសមស្របនឹងមុខតំណែងខ្ពស់ៗបាន<br>• ស្ត្រីនៅតែទទួលបានតួនាទីជាប្រពៃណីរបស់ស្ត្រីដែលពាក់ព័ន្ធនឹងការងាររដ្ឋបាល និងហិរញ្ញវត្ថុ | • ទីចាត់ការធនធានមនុស្សគួររៀបចំផែនការយុទ្ធសាស្ត្រ ដើម្បី បង្កើនចំនួនបុគ្គលិកជាស្ត្រីនៅក្នុងជួរមន្ត្រីរាជការជាន់ខ្ពស់ ដើម្បីឲ្យពួកគេមានឱកាសកាន់មុខ តំណែងក្នុងការធ្វើសេចក្តីសម្រេចនានា<br>• ផ្តល់សិទ្ធអំណាចឲ្យនាយកទីចាត់ ការធនធានមនុស្ស ក្នុងការស្នើសុំ ការតម្លើងតួនាទីដល់មន្ត្រី ពីព្រោះ ពួកគេអាចស្គាល់មន្ត្រីច្បាស់ ពិសេសមន្ត្រីជាស្ត្រី |
| **៤. បញ្ហាយេនឌ័រនៅក្នុងស្ថាប័ន និង ការសម្រេចបាននូវសមភាពយេនឌ័រ** | **១.៧** | | |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
| --- | --- | --- | --- |
| ៤.១. ការយល់ឃើញអំពីសារសំខាន់នៃសមភាពយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រីនៅថ្នាក់ក្រោមជាតិ | ២.៥ | • មានការយល់ដឹងខ្ពស់អំពីសារសំខាន់នៃសមភាពយេនឌ័រ និងការពង្រឹងអំណាចដល់ស្ត្រីក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងផអ៣ | |
| ៤.២. ភាពស៊ាំទៅនឹងឯកសារកម្មវិធីជាតិ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃផអ៣ | ២.១ | • អ្នកផ្តល់ព័ត៌មានភាគច្រើនមិនទាន់ស៊ាំទៅនឹងកម្មវិធីជាតិ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងផអ៣។ ពួកគេគ្រាន់តែអានចំណងជើងតូចៗ នៅក្នុងបញ្ជីសំណួរប៉ុណ្ណោះ។<br>• សមាជិកក្រុមប្រឹក្សាជាបុរសភាគច្រើនមិនបានទទួលការបណ្តុះបណ្តាលពាក់ព័ន្ធនឹងយេនឌ័រ | • ដើម្បីជានាឲ្យមានការលើកកម្ពស់សមាសភាពយេនឌ័រយ៉ាងមានប្រសិទ្ធភាពគួរផ្តល់ការបណ្តុះបណ្តាលស្តីពីទស្សនទានយេនឌ័រដល់សមាជិកថ្នាក់ដឹកនាំជាបុរស |
| ៤.៣. ការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងកន្លែងធ្វើការងារ | ២.២ | • អ្នកផ្តល់ព័ត៌មានចំនួន៣៩% យល់ឃើញថា កិច្ចប្រជុំនៅក្នុងរដ្ឋបាលរបស់ខ្លួនទំនងជាគ្រប់គ្រងដោយបុរស។ ជាងនេះទៀត អ្នកផ្តល់ព័ត៌មានលើសពី៥០% គិតថា មានតែ គ.ក.ស.ក គ.ក.ន.ក មន្ទីរ និងការិយាល័យកិច្ចការនារី គឺជាទីភ្នាក់ងារអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៃ ផអ៣។<br>• អ្នកផ្តល់ព័ត៌មានជាស្ត្រីបានបង្ហាញនូវការពេញចិត្តនឹងការគាំទ្ររបស់សហការីជាបុរស។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកផ្តល់ព័ត៌មានជា ស្ត្រីទាំងនោះមានអារម្មណ៍ថា ថ្នាក់ដឹកនាំជាបុរសតែងតែប្រគល់ការងារឲ្យបុគ្គលិកជាស្ត្រីធ្វើការងារ ណាដែលពាក់ | • ត្រូវជំនះនូវទស្សនៈដែលយល់ថា ស្ត្រី គឺជាអ្នកទទួលបន្ទុកក្នុងការដោះស្រាយបញ្ហារបស់ស្ត្រីដោយខ្លួនឯង។ |

| សូចនាករ | ពិន្ទុ | យោបល់ | អនុសាសន៍បឋម |
|---|---|---|---|
| | | ព័ន្ធនឹងបញ្ហារបស់ស្ត្រី | |
